# សម្មោហវិនោទនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ទុតិយភាគ

## ៧

ព. ស. ២៥៥៧

# សម្មោហវិនោទនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ទុតិយភាគ

## ៧

រចនាដោយព្រះពុទ្ធឃោសាចារ្យ

ផ្ដើមប្រែរៀបរៀងដោយខ្ញុំព្រះករុណាខ្ញុំបាទ សុន្ទរ៍-សារះមៀន

ព. ស. ២៥៥៧ គ. ស. ២០១៣

# សម្មោហ

# វិនោទនី

# អដ្ឋកថា

# ព្រះអភិធម្ម

# បិដក

# ទុតិយភាគ

# ៧

ព.ស.

២៥៥៧

# សេចក្តីបញ្ជាក់

*គម្ពីរ* **អដ្ឋកថាព្រះអភិធម្ម** *ជាពាក្យអធិប្បាយសេចក្តីក្នុងព្រះអភិ-ធម្មបិដក ចាត់ជាភាគធំៗ មាន ៣ ភាគ គឺ*

**១.បឋមភាគ** *ឈ្មោះ* **អដ្ឋសាលិនី** *អធិប្បាយគម្ពីរ* ***ធម្មសង្គណី***

**២.ទុតិយភាគ** *ឈ្មោះ* **សម្មោហវិនោទនី** *អធិប្បាយគម្ពីរ* ***វិភង្គ***

**៣.តតិយភាគ** *ឈ្មោះ* **បរមត្ថទីបនី** *អធិប្បាយគម្ពីរ* ***បញ្ចបករណ៍*** *តាំងពី* ***ធាតុកថា*** *រហូតដល់ចប់គម្ពីរ* ***បដ្ឋាន*** *ទាំងអស់ ។*

*បើចាត់ជាភាគតូចៗ មាន ១២ ភាគ ដោយបែងចែកចេញពីភាគធំៗ ទាំង ៣ ខាងលើនេះ ក្នុងមួយភាគៗ មាន ៤ លេខ ខុសគ្នាទៅនឹងការបោះពុម្ពមុនៗ ។ ឯសៀវភៅដែលលោកអ្នកកំពុងអាននេះ ជាគម្ពីរអដ្ឋ-កថា* ***អភិធម្មបិដក ទុតិយភាគ ៧*** *កើតឡើងដោយស្នាព្រះហស្តនៃ* ***ព្រះពុទ្ធឃោសាចារ្យ*** *ជាជនជាតិឥណ្ឌា បានរចនានៅឯប្រទេសសិរីលង្កា ក្រោយការបរិនិព្វានរបស់ព្រះពុទ្ធជាង ៩០០ឆ្នាំ ។ ឯរូបខ្ញុំផ្ទាល់វិញ គ្រាន់តែជាអ្នកផ្តើមប្រែសម្រួលរៀបរៀង ជាបណ្តោះអាសន្ន សម្រាប់អ្នកដែលត្រូវការសិក្សារៀនសូត្រតែប៉ុណ្ណោះ ព្រោះហេតុដូច្នេះ ខ្ញុំ****សូមបញ្ជាក់*** *និងសូមទោសជាមុន ចំពោះអ្នកអាន និងអ្នកសិក្សាជាទីគោរពថា ខ្ញុំពុំមានសមត្ថភាពនៃការចេះដឹងគ្រប់គ្រាន់ ដូចសេចក្តីនៃធម៌ដែលមាននៅ*

ក្នុងសៀវភៅនេះទេ ថែមទាំងសមត្ថភាពនៃការប្រែសម្រួល និងរៀបរៀង នេះទៀត មិនអាចគេចផុតពីការខុសឆ្គាំឆ្គងបានឡើយ ។ ការខុសឆ្គាំឆ្គង ទាំងនុ៎ះ មានដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ តែខ្ញុំយល់ ឃើញថា **មានប្រសើរជាងគ្មាន** ព្រោះសៀវភៅដែលរងនូវព្រះអភិធម្ម បិដកបែបនេះ មិនទាន់ដែលមានគ្រប់គ្រាន់ក្នុងប្រទេសយើងទេ ដូច្នេះ យើងក៏អាចឧទាហរណ៍បានថា ៖

* សម័យណា ដែលមានភាពអន្ធការ សូម្បីតែពន្លឺអំពិលអំពែក ក៏ អាចភ្លឺបានដែរ ។

* សម័យណា គ្មានដើមឈើ គេក៏អាចយកដើមល្ហុង ធ្វើជាដើម ឈើបានដែរ ។ ល ។ (ស្រីហិតោបទេស) ។

ព្រោះហេតុដូច្នេះ ខ្ញុំសូមផ្ញើនូវគម្ពីរនេះ ដល់លោកអ្នកសិក្សា និង វិញ្ញូជនទាំងឡាយ ជួយកែសម្រួល សម្រាប់សិក្សាតរៀងទៅ ។ ដើម្បី សម្រួលដល់ការបូកសរុបមតិកែតម្រូវ ក្នុងអត្ថបទនេះ សូមមេត្តា ជ្រាបដូចតទៅ ៖

១-សូមសរសេរឈ្មោះ ទីកន្លែង និងថ្ងៃ ខែ ឆ្នាំ ដែលកែ សម្រេចនៅលើក្រដាសដែលផ្ញើមក ។

២-ចុះលេខទំព័រ បន្ទាត់ ក្នុងតារាងលេខ ១ និងលេខ ២ ។ ចំពោះសេចក្ដី ពាក្យ ឃ្លា ឬអក្ខរាវិរុទ្ធត្រង់ណា ដែលយល់ថា មិនទាន់ត្រឹមត្រូវ សូមសរសេរចុះក្នុងតារាងលេខ ៣ ។ ចំណែកពាក្យដែលយល់ថា គួរកែមកជាយ៉ាងណាវិញនោះ សូមសរសេរចុះក្នុងតារាងលេខ ៤ ។

៣-ប្រសិនបើ ការកែតម្រូវនោះ មានឯកសារបញ្ជាក់ សូមចុះឈ្មោះឯកសារនោះ ក្នុងតារាងលេខ ៥ ។

៤-នៅក្នុងតារាងលេខ ៦ សម្រាប់បញ្ជាក់បន្ថែម ចំពោះករណីពិសេសណា ដែលប្រាថ្នាចង់បញ្ជាក់បន្ថែម ។

៥-សូមផ្ញើកំណែមកខ្ញុំ ដោយការទាក់ទង តាមទូរសព្ទដែលមាននៅក្នុងសៀវភៅនេះស្រាប់ ។

* ប្រសិនបើ នៅក្នុងសៀវភៅនេះ មានការខុសទំព័រលេខរៀង អក្សរដាច់ ឬមើលមិនសូវច្បាស់ជាដើម នុ៎ះពុំមែនជាកំហុសនៃសំណៅដើមរបស់ខ្ញុំឡើយ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣

ខ្ញុំព្រះករុណា ខ្ញុំបាទ **សុន្ទរ៍ សាមៀន**

សូមអរព្រះគុណ និងអរគុណ

# តារាងកែតម្រូវ “ឮ”

## នាមឈ្មោះអ្នកជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួល
## អដ្ឋកថាឧត្តិយភាគ ៧ នេះ មាន ៖

-ភិក្ខុសាមណេរជាពហូសូតក្នុងវត្តធុតង្គ (ចំការដូង) មាន ៦ រូប

-ភិក្ខុសាមណេរជាពហូសូតក្នុងវត្តនិគ្រោធវ័ន (គល់ទទឹង) មាន ៦ រូប

-ភិក្ខុខន្តិជាតិកោ **ថៃ តិរម្យ**

-ភិក្ខុវិនយប្បញ្ញោ **សឹម រតនៈ**

-ភិក្ខុធម្មរក្ខិតោ **គង់ វន**

-ភិក្ខុអគ្គធីរោ គង់ សុមិត្ត

-ឧបាសក **ស៊ីវ វណ្ណា**

-ឧបាសក **រឿង ស៊ីសុគន្ធ**

-អ្នកគ្រូ **នី សុធី**

-ឧបាសក **ខ៉ូវ សុខុម** ៕

## អ្នកមានឧបការៈក្នុងការចារធម្មទាននេះ

*-លោកបញ្ញាបទីបោ* ***វ្រឿង ប៊ុនធឿន***

*-លោកខន្តិជាតិកោ* ***ថៃ តិរក្ស***

*-ឧបាសិកា* ***លី ស៊ីវង្ស*** *ជាដើម*

*-ឧបាសិកា* ***ខុន ស៊ូគី*** *ជាដើម*

*-ភិក្ខុសាមណេរ* ***វត្តគិរីរម្យចាស់*** *ជាដើម*

-ឧបាសិកា **អ៊ឹ សរុន** ជាដើម

-លោក **ហេង សុវណ្ណារ៉ា** និងក្រុមគ្រួសារ

-ឧបាសក **ស្រេង ចាន់ណា** និងក្រុមគ្រួសារ

-ឧបាសក **ម៉ៅ ផុន** ហៅ **ពុយ** និងសហការី ។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុមោទនា ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសទ្ធានចិត្តដ៏ល្អរបស់គុណម្ចាស់ ញាតិញោមជាពុទ្ធបរិស័ទទាំងក្នុង និងក្រៅប្រទេស ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជួយពិនិត្យកែសម្រួល ព្រមទាំងចំណាយរូបិយវត្ថុជាដើម ដើម្បីជំរុញឲ្យអត្ថបទនៃគម្ពីរនេះ ចេញជារូបរាងឡើង ។

បន្ទាប់ពីទុតិយភាគ ៧ នេះទៅ ខ្ញុំនឹងដំណើរការបោះពុម្ពនូវទុតិយភាគ ៨ ជាបន្តទៀត ។

អាស្រ័យហេតុនេះ បើព្រះគុណម្ចាស់ ញាតិញោមត្រូវការចូលប្រាក់ដើម្បីថតចម្លងជាធម្មទាន ឬយកផ្ទាល់ខ្លួន ឬក៏យកទៅតម្កល់តាមវត្តនានា សូមមេត្តាទាក់ទងតាមរយៈទូរសព្ទដូចខាងក្រោមនេះ ៖

០៩២ ៩០ ៨២ ៦៥

០៩៧ ២៣ ៣០ ២១៥

០១៦ ៤៦ ៥២ ៣៤

## ឧទ្ទិសកថា

ខ្ញុំសូមផ្សាយនូវមហាកុសលធម្មទាននេះ ប្រគេន ថ្វាយ ជូន ចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ព្រះថេរានុត្ថេរៈគ្រប់រូប ទាំងក្នុង ទាំងក្រៅប្រទេស, **អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រក្នុងបច្ចុប្បន្ន** រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោ **ហ៊ុន សែន** ជាប្រមុខ និងមន្ត្រីរាជការគ្រប់ៗ ស្ថាប័ន, ព្រមទាំងពុទ្ធបរិស័ទទាំងក្នុងប្រទេស ទាំងក្រៅប្រទេស មានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាដើម មួយអន្លើដោយសព្វសត្វទាំងអស់ សូមទ្រង់ត្រេកអរ និងត្រេកអរ អនុមោទនា យកចំណែកបុណ្យធម្មទាននេះ គ្រប់ៗ រូប គ្រប់ៗ អង្គ គ្រប់ៗ គ្នា កុំបីខានឡើយ ។

**ដោយអំណាចនៃមហាកុសលធម្មទាននេះ សូមឱ្យ ៖**

-សត្វទាំងឡាយ កុំមានពៀរនឹងគ្នា មានតែសេចក្តីសុខ កុំមានទុក្ខ

-សត្វទាំងឡាយ កុំព្យាបាទគ្នា កុំមានការចង្អៀតចង្អល់នឹងគ្នា

-សត្វទាំងឡាយ មានអាយុវែង សម្រេចដោយសម្បត្តិទាំងឡាយ

-សត្វទាំងឡាយ រក្សានូវខ្លួន ឱ្យបានជាសុខតរៀងទៅ ៕

**តារាងកែតម្រូវ**

**អដ្ឋកថានុតិយភាគ ៧**

សម្រាប់បោះពុម្ពលើកទី ៣

ថ្ងៃទី ....... ខែ ..... ឆ្នាំ ...

ឈ្មោះ ..........................

អាសយដ្ឋាន .................

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ | ឯកសារយោង | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |

# សម្មោហវិនោទនី

# អដ្ឋកថាព្រះអភិធម្មបិដក

# ទុតិយភាគ ៧

**មាតិកាធម៌** **ទំព័រ**

## ៨. អដ្ឋកថាសម្មប្បធានវិភង្គ


១-ពណ៌នាអំពីសុត្តន្តភាជនិយ ..... ..... ..... ..... ..... ..... ..... ..... ..... ... ១

ពណ៌នាតាមបាលីនិទ្ទេសវារៈ ..... ..... ..... ..... ..... ..... ..... ..... ...... ៣

ឆន្ទនិទ្ទេស ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ...... ៣

វីរិយនិទ្ទេស ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៥

ចិត្តបគ្គហនិទ្ទេស ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៦

វិនិច្ឆ័យកថាព្រះបាលី ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៦

រឿងមួយទៀត ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... .... ១៥

វិនិច្ឆ័យក្នុងលោកិយសម្មប្បធានកថា ..... ..... ..... ..... ..... ..... ...... ១៧

## អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាចប់** **ទំព័រ**


២.ពណ៌នាអំពីអភិធម្មភាជនិយ ..... ..... ..... ..... ..... ..... ..... ..... ... ២៩

៣.ពណ៌នាអំពីបញ្ហាបុច្ឆកៈ ..... ..... ..... ..... ..... ..... ..... ..... ..... ... ៣០


## ៩. អដ្ឋកថាឥទ្ធិបាទវិភង្គ


១.ពណ៌នាអំពីសុត្តន្តភាជនិយ ..... ..... ..... ..... ..... ..... ..... ..... ..... ៣៣

កម្មដ្ឋានដែលដល់ទីបំផុតរបស់ភិក្ខុ ៤ ពួក ..... ..... ..... ..... ..... ...... ៣៧

២.ពណ៌នាអំពីអភិធម្មភាជនិយ ..... ..... ..... ..... ..... ..... ..... ..... .... ៤៣

៣.ពណ៌នាអំពីបញ្ហាបុច្ឆកៈ ..... ..... ..... ..... ..... ..... ..... ..... ..... .... ៤៤


## ១០. អដ្ឋកថាពោជ្ឈង្គវិភង្គ


១.ពណ៌នាអំពីសុត្តន្តភាជនិយ ពោជ្ឈង្គ ៧ ន័យទី ១ ..... ..... ..... ..... .... .... .... ..... ៤៧

សតិសម្ពោជ្ឈង្គ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... .... ៥១

ធម្មវិចយសម្ពោជ្ឈង្គ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ... ៥៣

វីរិយសម្ពោជ្ឈង្គ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ... ៥៤

បីតិសម្ពោជ្ឈង្គ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៥៤

# សម្មោហវិនោទនី

**មាតិកាធម៌** **ទំព័រ**


បសស្សទ្ធិសម្ពោជ្ឈង្គ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ...... ៥៤

សមាធិសម្ពោជ្ឈង្គ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ...... ៥៥

ឧបេក្ខាសម្ពោជ្ឈង្គ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ...... ៥៥

ពោជ្ឈង្គ ៧ ន័យទី ២ ..... ..... ..... ..... ..... ..... ..... ..... ..... ..... .. ៥៦

ពោជ្ឈង្គ ៧ ន័យទី ៣ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ... ៦០

**២_ពណ៌នាអំពីអភិធម្មភាជនិយ**
ន័យរបស់ឯកតោបុច្ឆាវិសជ្ជនា ..... ..... ..... ..... ..... .... .... .... ..... ៦២

**៣_ពណ៌នាអំពីបញ្ហាបុច្ឆកៈ** ..... ..... ..... ..... ..... ..... ..... ..... ..... .... ៦៤


## ១១. អដ្ឋកថាមគ្គវិភង្គ


**១_ពណ៌នាអំពីសុត្តន្តភាជនិយ**
អធិប្បាយអរិយមគ្គមានអង្គ ៨ ន័យទី ១ ..... ..... ..... ..... ..... .... ៦៧

**២_ពណ៌នាអំពីអភិធម្មភាជនិយ** ..... ..... ..... ..... ..... ..... ..... ..... ... ៦៧

មគ្គ ៨ ក្នុងកថាវត្ថុបករណ៍ ..... ..... ..... ..... ..... ..... ..... ..... ...... ៧២

**៣_ពណ៌នាអំពីបញ្ហាបុច្ឆកៈ** ..... ..... ..... ..... ..... ..... ..... ..... ..... ... ៧៤

# អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**

## ១២. អដ្ឋកថាឈានវិភង្គ


ពណ៌នាអំពីមាតិកា ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៧៥

**១.ពណ៌នាអំពីសុត្តន្តភាជនិយ** ..... ..... ..... ..... ..... ..... ..... ..... ..... ៨០

អធិប្បាយបទមាតិកានិទ្ទេស ..... ..... ..... ..... ..... ..... ..... ..... ៨០

ភិក្ខុនិទ្ទេស ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៨៥

បាតិមោក្ខសំវរនិទ្ទេស ..... ..... ..... ..... ..... ..... ..... ..... ..... ..... .. ៩២

អនាចារនិទ្ទេស ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៩៩

អធិប្បាយឥរិយាបថ ..... ..... ..... ..... ..... ..... ..... ..... ..... ....... ១៣០

អធិប្បាយ { **អាលោកិតេ** = ក្រឡេកមើលទៅខាងមុខ<br>**វិលោកិតេ** = ក្រឡេកមើលទៅខាងៗ } ..... .... ១៥២

អធិប្បាយ **សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ** ..... ..... .... ១៦០

សម្ដែងអំពីគោចរសម្បជញ្ញៈ ..... ..... ..... ..... ..... ..... ..... ..... .... ១៦៣

**២.ពណ៌នាអំពីអភិធម្មភាជនិយ** ..... ..... ..... ..... ..... ..... ..... .. ១៩៧

**៣.ពណ៌នាអំពីបញ្ហាបុច្ឆកៈ** ..... ..... ..... ..... ..... ..... ..... ..... ....... ១៩៧

## សម្ពោហវិនោទនី

**មាតិកាធម៌** **ទំព័រ**

### ១៣. អដ្ឋកថាអប្បមញ្ញាវិភង្គ

**១.ពណ៌នាអំពីសុត្តន្តភាជនិយ** .... .... .... .... .... ..... .... ..... .... .... ១០៩

មេត្តាអប្បមញ្ញា .... .... .... .... .... ..... .... ..... .... .... .... .... .... ២១២

ករុណាអប្បមញ្ញា .... .... .... .... .... ..... .... ..... .... .... .... .... ... ២១៥

មុទិតាអប្បមញ្ញា .... .... .... .... .... ..... .... ..... .... .... .... .... ... ២១៦

ឧបេក្ខាអប្បមញ្ញា .... .... .... .... .... ..... .... ..... .... .... .... .... .. ២១៧

**២.ពណ៌នាអំពីអភិធម្មភាជនិយ** .... .... .... .... .... ..... .... ..... .... .. ២១៧

**៣.ពណ៌នាអំពីបញ្ហាបុច្ឆកៈ** .... .... .... .... .... ..... .... ..... .... .... ... ២១៨

### ១៤. អដ្ឋកថាសិក្ខាបទវិភង្គ

**១.ពណ៌នាអំពីសុត្តន្តភាជនិយ** .... .... ....... ..... .... .... ..... ..... ..... ២១៩

បទភាជនិយ (ការចែកបទ) .... .... .... .... .... ..... .... ..... ........ ២២១

បាណាតិបាត មានទោសតិច និងច្រើន .... .... .... .... .... ..... .... ..... ២២៣

អទិន្នាទាន មានទោសតិច និងច្រើន .... .... .... .... .... ..... .... ..... ២២៤

កាមេសុមិច្ឆាចារ មានទោសតិច និងច្រើន .... .... .... .... ..... ..... ២២៥

មុសាវាទ មានទោសតិច និងច្រើន .... .... .... .... .... ..... .... .... ២២៦

ការផឹកសុរា មានទោសតិច និងច្រើន .... .... .... .... .... ..... .... ..... ២២៧

## អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**

ធម៌ជាសិក្ខា .... .... .... .... .... ..... .... ..... .... .... .... .... ........ ២៣០

**២.ពណ៌នាអំពីបញ្ហាបុច្ឆកៈ** .... .... .... .... .... ..... .... ..... .... ..... ២៣១

## ១៥. អដ្ឋកថាបដិសម្ភិទាវិភង្គ

**១.ពណ៌នាអំពីសុត្តន្តភាជនិយ** .... .... .... .... .... ..... .... ..... .... .... ២៣៣

អធិប្បាយពាក្យថា អត្ថៈ .... .... .... .... .... ..... .... ..... .... .... .. ២៣៤

អធិប្បាយពាក្យថា ធម្មៈ .... .... .... .... .... ..... .... ..... ..... ...... ២៣៥

អធិប្បាយពាក្យថា ធម្មនិរុត្តិ = ភាសារបស់សភាវៈ ..... ..... ..... .... ២៣៥

ភាសាមគធៈជាភាសាទូទៅរបស់សត្វលោក .... .... ..... ...... ....... ២៣៧

ពណ៌នាអំពីសង្គហវារៈ .... .... .... .... .... .... .... .... .... .... .... .... ២៤៣

**២.ពណ៌នាអំពីអភិធម្មភាជនិយ** .... .... .... .... .... ..... .... ..... ..... ២៤៦

បដិសម្ភិទា ៣ (វៀរធម្មៈ) .... .... .... .... .... ..... .... ..... .... ..... ២៤៦

**៣.ពណ៌នាអំពីបញ្ហាបុច្ឆកៈ** .... .... .... .... .... ..... .... ..... .... ...... ២៥២

# អក្សរសង្ខេប

## ដែលប្រើក្នុងអដ្ឋកថាទុតិយភាគ ៧ នេះ

| | | |
|---|---|---|
| អំ. អដ្ឋក. | = | អង្គុត្តរនិកាយ អដ្ឋកនិបាត |
| អំ. ចតុក្ក. | = | អង្គុត្តរនិកាយ ចតុក្កនិបាត |
| ខុ. បដិ. | = | ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ |
| ទី. បា. | = | ទីឃនិកាយ បាដិកវគ្គ |
| ទី. ម. | = | ទីឃនិកាយ មហាវគ្គ |
| ម. ឧ. | = | មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ |
| ម. ម. | = | មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ |
| វិនយ. | = | វិនយបិដក |
| វិសុទ្ធិ. | = | វិសុទ្ធិមគ្គ |
| សម្មោ. អត្ថ. | = | សម្មោហវិនោទនី អត្ថយោជនា |
| សំ. ខ. | = | សំយុត្តនិកាយ ខន្ធវារវគ្គ |
| សំ. និ. | = | សំយុត្តនិកាយ និទានវគ្គ |
| សំ. ម. | = | សំយុត្តនិកាយ មហាវារវគ្គ ៕ |

# សម្មោហវិនោទនី

## អដ្ឋកថាព្រះអភិធម្មបិដក

### ឈ្មោះ វិភង្គបករណ៍

### ទុតិយភាគ ៧

ព. ស. ២៥៥៧

# សម្មោហវិនោទនី

# អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ វិភង្គបករណ៍

## ទុតិយភាគ ៧

## ៨. អដ្ឋកថាសម្មប្បធានវិភង្គ

### ១-ពណ៌នាអំពីសុត្តន្តភាជនិយ

ឥឡូវនេះ គប្បីជ្រាបការវិនិច្ឆ័យក្នុង **សម្មប្បធានវិភង្គ** ដែលជាលំដាប់នៃ **សតិបដ្ឋានវិភង្គ** នោះតទៅ ៖

ពាក្យថា ៤ ជាពាក្យកំណត់ចំនួន ។ ដោយពាក្យនោះ ព្រះមានព្រះភាគទ្រង់តែងតែបញ្ជាក់ការកំណត់សម្មប្បធានថា “មិនតិចជាងនោះ មិនច្រើនជាងនោះ” ។ ពាក្យថា **សម្មប្បធានា** បានដល់ សេចក្តីព្យាយាមដែលជាហេតុ, សេចក្តីព្យាយាមដែលជាឧបាយ, សេចក្តីព្យាយាមដោយត្រូវទំនង ។

ពាក្យថា “**ឥធ ភិក្ខុ**” បានដល់ ភិក្ខុអ្នកបដិបត្តិក្នុងសាសនានេះ ។

ពាក្យថា “**អនុប្បន្នានំ**” បានដល់ ដែលនៅមិនទាន់កើតឡើង ។

ពាក្យថា “**បាបកានំ**” បានដល់ ដ៏លាមក ។

ពាក្យថា “**អកុសលានំ ធម្មានំ**” បានដល់ ធម៌ទាំងឡាយដែលជាអកុសល ក្នុងអត្ថថា **មិនឈ្លាស** ។

ពាក្យថា **"អនុប្បាទាយ"** បានដល់ ដើម្បីត្រូវការមិនឱ្យកើតឡើង ។

ពាក្យថា **"ឆន្ទំ ជនេតិ"** បានដល់ រមែងញុំាងឆន្ទៈក្នុងកុសល ពោលគឺភាពជាអ្នកមានប្រាថ្នាដើម្បីធ្វើឱ្យកើត គឺឱ្យកើតឡើង ។

ពាក្យថា **"វាយមតិ"** បានដល់ រមែងធ្វើការឧស្សាហ៍ប្រកបដោយសេចក្តីព្យាយាម ។

ពាក្យថា **"វីរិយំ អារភតិ"** បានដល់ ធ្វើសេចក្តីព្យាយាមដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងផ្លូវចិត្ត ។

ពាក្យថា **"ចិត្តំ បគ្គណ្ហាតិ"** បានដល់ រមែងលើកចិត្តឡើងដោយសេចក្តីព្យាយាមដែលជាសហជាតនោះនុ៎ះឯង ។

ពាក្យថា **"បទហតិ"** បានដល់ រមែងធ្វើសេចក្តីព្យាយាមដែលជាប្រធាន ។ម្យ៉ាងទៀត បទទាំង ៤ នេះ គប្បីប្រកបដោយការសេព ការចម្រើន ការធ្វើឱ្យច្រើន និងការធ្វើឱ្យជាប់តគ្នាទៅដោយលំដាប់ ។

ពាក្យថា **"ឧប្បន្នានំ បាបកានំ"** បានដល់ បាបធម៌ដែលដល់នូវពាក្យដែលបុគ្គលមិនគួរពោលថា នៅមិនកើតឡើង ។

ពាក្យថា **"បហានាយ"** បានដល់ ដើម្បីត្រូវការលះ ។

ពាក្យថា **"អនុប្បន្នានំ កុសលានំ ធម្មានំ"** បានដល់ កុសលធម៌ទាំងឡាយដែលនៅមិនទាន់កើតឡើង ។

ពាក្យថា **"ឧប្បាទាយ"** បានដល់ ត្រូវការឱ្យកើតឡើង ។

ពាក្យថា **"ឧប្បន្នានំ"** បានដល់ បង្កើតឡើងហើយ ។

ពាក្យថា **“ឋិតិយា”** បានដល់ ដើម្បីការតាំងនៅ ។

ពាក្យថា **“អសម្មោសាយ”** បានដល់ ដើម្បីការមិនសាបសូន្យទៅ ។

ពាក្យថា **“ភិយ្យោភាវាយ”** បានដល់ ដើម្បីការចម្រើនរឿយៗ ។

ពាក្យថា **“វេបុល្លាយ”** បានដល់ ដើម្បីការសម្បូរ ។

ពាក្យថា **“ភាវនាយ”** បានដល់ ដើម្បីការចម្រើន ។

ពាក្យថា **“បរិបូរិយា”** បានដល់ ដើម្បីសេចក្តីបរិបូណ៌ ។

នេះជាការលើកអត្ថ ដែលប្រកបដោយបទលើកឡើងទុក ដោយអំណាចនៃឧទ្ទេសវារៈ របស់សម្មប្បធាន ៤ ជាមុនសិន ៕

## ពណ៌នាតាមបាលីនិទ្ទេសវារៈ

ឥឡូវនេះ ដើម្បីទ្រង់សំដែងចែកបទទាំងនោះ ដោយលំដាប់ ទើបព្រះមានព្រះភាគទ្រង់ផ្តើមនិទ្ទេសវារៈ ដោយន័យថា **“ឥធ ភិក្ខុ អនុប្បន្នានំ”** ជាអាទិ៍ ។ ក្នុងនិទ្ទេសវារៈនេះ បទណា ដូចបទដែលមានមកហើយ ក្នុងធម្មសង្គហៈខាងក្រោយ,បទនោះ គប្បីជ្រាបដោយន័យដែលលោកពោលហើយ ក្នុងការពណ៌នាធម្មសង្គហៈនោះចុះ; ប៉ុន្តែថា បទណាមិនមានមកក្នុងធម្មសង្គហៈនោះ, គប្បីជ្រាបក្នុងឆន្ទនិទ្ទេសនៃព្រះបាលីនោះ ដូចតទៅនេះ ៖

## ឆន្ទនិទ្ទេស

ពាក្យថា **“យោ ឆន្ទោ”** បានដល់ ឆន្ទៈ ដោយអំណាចនៃការតាំងទុកនូវសេចក្តីពេញចិត្តឯណា ។

ពាក្យថា **“ឆន្ទិកតា”** បានដល់ ភាពជាអ្នកប្រកបដោយឆន្ទៈ, ឬអាការនៃ

ការធ្វើឆន្ទៈ ។

ពាក្យថា **"កត្តុកម្យតា"** បានដល់ ភាពជាអ្នកប៉ងដើម្បីធ្វើ ។

ពាក្យថា **"កុសលោ"** បានដល់ អ្នកឆ្លាត ។

ពាក្យថា **"ធម្មច្ឆន្ទោ"** បានដល់ ឆន្ទៈដែលជាសភាវៈ ។

ពិតណាស់ ឈ្មោះថា **ឆន្ទៈនេះ មានប្រការផ្សេងៗ ច្រើនយ៉ាង** គឺ តណ្ហាឆន្ទៈ ទិដ្ឋិឆន្ទៈ វីរិយច្ឆន្ទៈ និងធម្មច្ឆន្ទៈ ។

ក្នុងឆន្ទៈទាំងនោះ ពាក្យថា **"ធម្មច្ឆន្ទោ"** លោកបំណងយកឆន្ទៈ ក្នុងធម៌ដែលជាកុសលរបស់អ្នកប្រាថ្នាដើម្បីនឹងធ្វើក្នុងទីនេះ ។

ពាក្យថា **"ឥមំ ឆន្ទំ ជនេតិ"** បានដល់ អ្នកធ្វើនូវឆន្ទៈនោះ ៗ ឯង ឈ្មោះថា រមែងញុំាងឆន្ទៈឱ្យកើត ។

ពាក្យថា **"សញ្ជនេតិ"** បានដល់ បទ (ជនេតិ) នោះ លោកបន្ថែមបទឧបសគ្គមក ។

ពាក្យថា **"ឧដ្ឋាបេតិ"** បានដល់ អ្នកធ្វើឆន្ទៈនោះឯង ឈ្មោះថា រមែងឱ្យឆន្ទៈតាំងឡើង ។

ពាក្យថា **"សមុដ្ឋាបេតិ"** បានដល់ បទ (ឧដ្ឋាបេតិ) នោះ លោកបន្ថែមបទឧបសគ្គ ។

ពាក្យថា **"និព្វត្តេតិ"** បានដល់ អ្នកធ្វើឆន្ទៈយ៉ាងនោះ ឈ្មោះថា រមែងឱ្យឆន្ទៈនោះកើត ។

ពាក្យថា **"អភិនិព្វត្តេតិ"** បានដល់ បទ (និព្វត្តេតិ) នោះ លោកពោល

បន្ថែមបទឧបសគ្គ ។

**ម្យ៉ាងទៀត ភិក្ខុអ្នកធ្វើឆន្ទៈនោះឯង ឈ្មោះថា តែងតែឱ្យឆន្ទៈកើត** អ្នកធ្វើឆន្ទៈនោះឯង ឱ្យជាប់ត១ គ្នាទៅ ឈ្មោះថា តែងតែឱ្យឆន្ទៈកើតឡើងល្អ; អ្នកលើកឡើងទៀត នូវឆន្ទៈដែលធ្លាក់ទៅហើយ ដោយអន្តរាយយ៉ាងណានីមួយ ឈ្មោះថា **រមែងឱ្យឆន្ទៈកើតឡើង**; អ្នកញ៉ាំងឆន្ទៈដែលតាំងឡើងនោះ ឱ្យទៅដល់ជាប់តគ្នា ឈ្មោះថា **រមែងឱ្យឆន្ទៈតាំងឡើងដោយល្អ**; អ្នកធ្វើឆន្ទៈនោះឱ្យប្រាកដ ឈ្មោះថា **រមែងឱ្យកើត**; អ្នកឱ្យឆន្ទៈកើតឡើង ដោយភាពជាធំលែង ព្រោះការមិនរាថយ **ព្រោះការមិនធុញទ្រាន់** (នឹង) **ប្រព្រឹត្ត ទើបឈ្មោះថា រមែងកើតយ៉ាងក្រៃលែង** ៕

## វីរិយនិទ្ទេស

ក្នុងនិទ្ទេសនៃវីរិយៈ ព្រះយោគាវចរ ដែលកំពុងធ្វើការព្យាយាមនោះឯង **ឈ្មោះថា ប្រារព្ធសេចក្តីព្យាយាម** ។ បទទី ២ លោកធ្វើឱ្យច្រើនដោយឧបសគ្គ ។

ពេលធ្វើសេចក្តីព្យាយាមនោះឯង **ឈ្មោះថា រមែងសេព រមែងចម្រើន**។ ពេលធ្វើសេចក្តីព្យាយាមរឿយ១ ឈ្មោះថា **ធ្វើឱ្យច្រើន** ។ ពេលធ្វើតាំងពីដើមដូចគ្នា ឈ្មោះថា **រមែងប្រារព្ធ** ។ ពេលធ្វើរឿយ១ ឈ្មោះថា **ប្រារព្ធដោយល្អ** ។ ពេលចង់សេពដោយអំណាចនៃភាវនា ឈ្មោះថា **រមែងសេព** ។ ពេលសេពឱ្យច្រើន ឈ្មោះថា **រមែងចម្រើន** ។ ពេលធ្វើវត្ថុនោះ១ ក្នុងកិច្ចទាំងពួងឱ្យច្រើន គប្បីជ្រាបថា **“រមែងធ្វើឱ្យច្រើន”** ៕

## ចិត្តបគ្គហនិទ្ទេស

ក្នុងនិទ្ទេសនៃការផ្គងចិត្តទុក ព្រះយោគាវចរប្រកបដោយការផ្គងនូវសេចក្ដីព្យាយាម ឈ្មោះថា **រមែងផ្គងចិត្តទុក**, អធិប្បាយថា លើកចិត្តឡើង ។ ពេលផ្ចិតផ្ចង់ចិត្តរឿយៗ ឈ្មោះថា **រមែងផ្គងចិត្តទុកដោយល្អ** ។ ចិត្តដែលបុគ្គលផ្ចិតផ្ចង់ទុកដោយល្អ រមែងមិនធ្លាក់ទៅដោយប្រការណា,ពេលឧបត្ថម្ភឋានៈ ដោយប្រការនោះ ដោយការឧបត្ថម្ភតាមសេចក្ដីព្យាយាម ឈ្មោះថា **ឧបត្ថម្ភ**; ពេលឧបត្ថម្ភចិត្តសូម្បីដែលលោកឧបត្ថម្ភហើយរឿយៗ ដើម្បីសេចក្ដីតាំងមាំ ឈ្មោះថា **រមែងទ្រទ្រង់នូវចិត្តនោះ** ។

ក្នុងនិទ្ទេសនៃបទថា **"ឋិតិយា"** ព្រះមានព្រះភាគជាម្ចាស់ ដើម្បីទ្រង់សំដែងនូវពាក្យវេវចនៈរបស់ពាក្យថា **ឋិតិ** (ការតាំងនៅ) សូម្បីនៃធម៌ទាំងអស់ មានសេចក្ដីមិនសាបសូន្យជាដើម ទើបទ្រង់ត្រាស់ពាក្យថា **"យា ឋិតិ សោ អសម្មោសោ** = ការតាំងនៅឯណា, នោះ គឺសេចក្ដីមិនសាបសូន្យ" ជាដើម ។ តាមពិត ក្នុងសេចក្ដីនេះ ទោះបីនឹងពោលថា "បទក្រោយៗ ជាពាក្យអធិប្បាយខ្លឹមសាររបស់បទមុន, និងបទមុនៗ ជាពាក្យអធិប្បាយខ្លឹមសាររបស់បទក្រោយៗ" ដូច្នេះក៏គួរ ។ ពាក្យដែលនៅសល់ក្នុងទីទាំងពួង មានអត្ថងាយស្រួលទាំងអស់ ។ នេះជាការពណ៌នាតាមព្រះបាលីជាមុនសិន ៕

## វិនិច្ឆ័យកថាព្រះបាលី

ក៏គប្បីជ្រាបការវិនិច្ឆ័យកថាក្នុងព្រះបាលីដូចតទៅ ៖

ពិតណាស់ **សម្មប្បធានកថានេះ** មាន ២ យ៉ាង គឺជាលោកិយម្យ៉ាង ជាលោកុត្តរម្យ៉ាង ។ ក្នុង ២ យ៉ាងនោះ សម្មប្បធានដែលជាលោកិយ រមែងមានក្នុងបុព្វភាគទាំងអស់, សម្មប្បធាននោះ គប្បីជ្រាបក្នុងខណៈដែលជាលោកិយមគ្គ ដោយបរិយាយនៃ **កស្សបសំយុត្ត** ។ សមពិតដូចលោកពោលទុកថា ៖ “ម្នាលអាវុសោ បណ្តាធម៌ទាំងនោះ សម្មប្បធាននេះ មាន ៤ ។ សម្មប្បធានមាន ៤ តើដូចម្តេច ? ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ តែងតែធ្វើសេចក្តីព្យាយាមដុតកម្តៅកិលេស ដោយការគិតថា ‘ អកុសលធម៌ដ៏លាមករបស់យើង ដែលនៅមិនកើតឡើង ពេលកើតឡើង គប្បីប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស’ ដូច្នេះ, គេរមែងធ្វើសេចក្តីព្យាយាមដុតកម្តៅកិលេស ដោយគិតថា ‘ អកុសលធម៌ដ៏លាមករបស់យើង ដែលកើតឡើងហើយ ដែលយើងមិនលះចេញ ក៏នឹងគប្បីប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស’ ។ គេរមែងធ្វើសេចក្តីព្យាយាម ដោយគិតថា ‘ កុសលធម៌ទាំងឡាយរបស់យើង ដែលនៅមិនកើត ពេលកើតឡើង គប្បីប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស’ ។ គេរមែងធ្វើសេចក្តីព្យាយាមដុតកម្តៅកិលេស ដោយគិតថា ‘ កុសលធម៌ទាំងឡាយរបស់យើង ដែលកើតឡើងហើយ ពេលរលត់ទៅ (សំដៅដល់ការសាបសូន្យទៅ) ក៏នឹងគប្បីប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស” ។

ក៏ក្នុងពាក្យថា “កុសលធម៌របស់យើងដែលនៅមិនកើតឡើង” នេះ បានដល់ សមថៈ វិបស្សនា និងមគ្គ ។

សមថៈ និងវិបស្សនានោះឯង ឈ្មោះថា **កុសលធម៌ដែលកើតឡើងហើយ**; ចំណែកមគ្គកើតម្តងហើយ ក៏រលត់ទៅ ឈ្មោះថា មិនប្រព្រឹត្តទៅ

ដើម្បីសេចក្តីវិនាស; ព្រោះថា មគ្គនោះឱ្យភាពជាបច្ច័យដល់ផលប៉ុណ្ណោះ ហើយក៏រលត់ទៅ ។

ម្យ៉ាងទៀត លោកពោលទុកថា "សមថៈ និងវិបស្សនាក្នុងកុសលដែលមានមកពីមុននោះឯង ក៏គប្បីកាន់យក; ប៉ុន្តែសេចក្តីនោះ មិនគួរទេ, ព្រោះបណ្តាកុសលធម៌ទាំងឡាយ មានសមថៈ វិបស្សនា និងមគ្គនោះ សមថៈ និងវិបស្សនាដែលកើតឡើងហើយ ពេលរលត់ទៅ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ។

ដើម្បីសេចក្តីជាក់ច្បាស់នៃខ្លឹមសារនេះ គប្បីជ្រាបរឿងតទៅនេះ ៖

បានឮថា ព្រះថេរៈជាព្រះខីណាស្រពមួយអង្គ ជាមួយសាមណេរអ្នកបានសមាបត្តិ ជាអ្នកកាន់ភណ្ឌៈ មកកាន់មហាវិហារអំពីជនបទ លោកគិតថា "យើងនឹងថ្វាយបង្គំព្រះមហាចេតិយ និងមហាពោធិ៍" ហើយបានចូលទៅដល់បង្គោលបរិវេណ ។ ពេលភិក្ខុសង្ឃជាច្រើនថ្វាយបង្គំព្រះចេតិយ ក្នុងវេលាល្ងាច លោកមិនបានចេញទៅដើម្បីនឹងថ្វាយបង្គំព្រះចេតិយ ។ **សួរថា** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះព្រះខីណាស្រពទាំងឡាយ ជាអ្នកគោរពក្នុងព្រះរតនត្រ័យណាស់, ព្រោះហេតុនោះ ពេលភិក្ខុសង្ឃថ្វាយបង្គំហើយគេចចេញទៅ ព្រះថេរៈទើបគិតថា "ក្នុងវេលាដែលមនុស្សទាំងឡាយបរិភោគសណ្តែក (របស់ស៊ីក្រោយអាហារ) ពេលល្ងាច យើងមិនឱ្យនរណា ៗ ដឹង សូម្បីតែសាមណេរ ហើយនឹងទៅថ្វាយបង្គំព្រះចេតិយ" ដូច្នេះ តែម្នាក់ឯងប៉ុណ្ណោះ ចេញទៅហើយ ។

សាមណេរគិតថា "ហេតុអ្វីហ្ន៎ ព្រះថេរៈទើបជាអ្នកតែម្នាក់ឯង ទៅក្នុងវេលាដែលមិនសមគួរ, យើងនឹងដឹងហេតុនោះ" ទើបចេញទៅតាមឧបជ្ឈាយ៍របស់

ខ្លួន ។ ព្រះថេរៈមិនពិចារណា ទើបមិនជ្រាបការមករបស់សាមណេរនោះ លោកបានឡើងទៅដល់លានព្រះមហាចេតិយ តាមផ្លូវទិសទក្សិណ ។ សូម្បីសាមណេរក៏ឡើងតាមផ្លូវនោះដែរ ។ ព្រះមហាថេរក្រឡេកមើលព្រះមហាចេតិយ ហើយកាន់យកបីតិ ដែលមានពុទ្ធគុណជាអារម្មណ៍ ហើយក៏ប្រមូលមកនូវពុទ្ធគុណទាំងពួងដោយចិត្ត ជាអ្នករីករាយហើយ រីករាយខ្លាំងហើយ ថ្វាយបង្គំនូវព្រះមហាចេតិយ ។ សូម្បីសាមណេរឃើញអាការ គឺកិរិយាដែលថ្វាយបង្គំរបស់ព្រះថេរៈ ទើបគិតថា “ឧបជ្ឈាយ៍របស់យើង មានចិត្តជ្រះថ្លាយ៉ាងខ្លាំងកំពុងថ្វាយបង្គំ, លោកបានផ្កាឈើហើយឬ ទើបធ្វើការបូជា” ។ ពេលព្រះថេរៈថ្វាយបង្គំហើយក្រោកឡើង ក៏តាំងផ្គងអញ្ជលីដោយគោរព កំពុងឈរសម្លឹងព្រះមហាចេតិយ ទើបសាមណេរគ្រហែមឱ្យព្រះថេរៈជ្រាបដំណើរដែលខ្លួនមកហើយ ។

ព្រះថេរៈងាកមកមើលហើយសួរថា “ឯងមកពេលណា” ទើបសាមណេរប្រាប់ថា “ព្រះគុណម្ចាស់ ក្នុងកាលដែលព្រះគុណម្ចាស់ថ្វាយបង្គំព្រះចេតិយ ព្រះគុណម្ចាស់មានចិត្តជ្រះថ្លាយ៉ាងខ្លាំងថ្វាយបង្គំព្រះចេតិយ, ព្រះគុណម្ចាស់បានផ្កាឈើទាំងឡាយបូជាឬ ?” ព្រះថេរៈពោលថា “អើសាមណេរ ឈ្មោះថា ការបញ្ចុះព្រះធាតុមានប្រមាណប៉ុណ្ណោះ ក្នុងទីណាមួយ ដូចព្រះចេតិយ * នេះ មិនបានមានទេ, មហាសថូប (ស្តូប) បែបនេះ មិនដូចជាសថូបដទៃឡើយ, នរណាៗ បានផ្កាឈើ

* ប្រហែលជាសុវណ្ណមាលិកចេតិយ ព្រោះចេតិយនេះ មានបញ្ចុះនូវព្រះបរមសារីរិកធាតុ ២ នាឡិ ដែលនៅមានរហូតមកដល់សព្វថ្ងៃនេះ ។

ទាំងឡាយ ហើយនឹងមិនគប្បីបូជា” ។

សាមណេរទើបប្រាប់ថា “បពិត្រលោកម្ចាស់ដ៏ចម្រើន បើយ៉ាងនោះ ចូរចាំខ្ញុំព្រះករុណាផង ខ្ញុំព្រះករុណានឹងនាំផ្កាឈើមក” ហើយចូលឈានក្នុងខណៈនោះឯង ទៅដល់ហេមវ័ន្តដោយឫទ្ធិ កាន់យកផ្កាឈើទាំងឡាយ ដែលដល់ព្រមដោយពណ៌ និងក្លិន ឱ្យពេញចម្ក្រក (កំប៉ុងតម្រងទឹក) ហើយ ពេលព្រះថេរៈទៅអំពីមុខផ្នែកទិសខាងត្បូង នៅមិនទាន់ដល់មុខទ្វារទិសខាងលិច មកហើយប្រាប់លោកថា “ព្រះគុណម្ចាស់ ! សូមព្រះគុណម្ចាស់ទុកចម្ក្រកផ្កាក្នុងដៃ ហើយបូជាចុះ” ព្រះថេរៈពោលថា “សាមណេរផ្កាឈើរបស់យើងតិចណាស់” សាមណេរប្រាប់ថា “បពិត្រលោកម្ចាស់ដ៏ចម្រើន សូមព្រះគុណម្ចាស់នឹកដល់គុណទាំងឡាយ របស់ព្រះមានព្រះភាគ ហើយបូជាចុះ” ។

ព្រះថេរៈឈានឡើងទៅតាមភ្ញាក់ដៃ ដែលជាប់មុខផ្លូវទិសខាងលិច ហើយផ្ដើមធ្វើការបូជាដោយផ្កាឈើ លើគ្រែបូជា (កុច្ឆិវេទិកា) ដែលតាំងនៅផ្នែកខាងក្នុងនោះឯង; ផ្ទាំងដែលជាកន្លែងគ្រែបូជាក៏ពេញ, ផ្កាឈើទាំងឡាយ នឹងធ្លាក់ចុះទៅនៅផ្ទាំងជាន់ក្រោម ឱ្យពេញកំពុងឡើង មានប្រមាណដល់ក្បាលជង្គង់; បន្ទាប់ពីនោះព្រះថេរៈក៏ល្បងចុះទៅផ្នែកខាងក្រោម លើពានសម្រាប់បូជា ហើយបូជា, សូម្បីផ្កាឈើក៏ពេញជុំវិញហើយ; ព្រះថេរៈជ្រាបសេចក្ដីដែលផ្កាឈើទាំងនោះ ពេញជុំវិញហើយ ទើបរាសផ្កាឈើទៅក្នុងផ្ទៃជាន់ក្រោម ហើយទើបទៅ, លាននៃព្រះចេតិយទាំងពួង ក៏មានផ្កាឈើពេញជុំវិញ; ពេលលានព្រះចេតិយមានផ្កាឈើពេញជុំវិញហើយ ទើបពោលថា “សាមណេរ ផ្កាឈើនៅមិនអស់”; ទើបសាមណេរប្រាប់លោក

ថា "បពិត្រព្រះគុណម្ចាស់ សូមព្រះគុណម្ចាស់ផ្កាប់ធម្មក្រកចុះ; ទើបព្រះថេរៈផ្កាប់មាត់ធម្មក្រកហើយរលាស់, ទើបផ្កាឈើទាំងឡាយ អស់ទៅក្នុងវេលានោះ ។

ព្រះថេរៈឱ្យធម្មក្រកដល់សាមណេរ ហើយធ្វើប្រទក្សិណព្រះចេតិយ ដើរទៅតាមកំពែងប្រមាណ ៦០ ហត្ថ អស់វារៈ ៣ ដង ហើយថ្វាយបង្គំក្នុងទិសទាំង ៤, ខណៈដែលកំពុងដើរជុំវិញបរិវេណ ក៏គិតថា "សាមណេរមានឫទ្ធិច្រើនណាស់ នឹងអាចដើម្បីរក្សាឥទ្ធានុភាពនេះបានរហូតទៅឬទេហ្ន៎ ?" លំដាប់នោះ ក៏ជ្រាបថា សាមណេរនេះ នឹងមិនអាចរក្សាឥទ្ធានុភាពទុកបានឡើយ ទើបបានពោលនឹងសាមណេរថា "សាមណេរ ឥឡូវនេះ អ្នកមានឫទ្ធិច្រើន, តែក្នុងកាលទីបំផុតឫទ្ធិដែលឃើញច្បាស់បែបនេះ នឹងវិនាសទៅ អ្នកនឹងផឹកទឹកបាយដែលជាងកីតម្បាញខ្វាក់ភ្នែកម្ខាង យកដៃខ្វាំហើយ" ។ ក៏ចំណុចត្រង់ដែលឫទ្ធិសាបសូន្យទៅនេះ ជាការខ្វះខាត (ជាទោស) នៃភាពជាមនុស្សកំលោះ, សាមណេរនោះ ស្លុតចិត្តដោយពាក្យរបស់ឧបជ្ឈាយ៍ ទាំងមិនបានពោលសូមកម្មដ្ឋានថា "បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន សូមព្រះគុណម្ចាស់ប្រាប់នូវកម្មដ្ឋានដល់ខ្ញុំ"; បែរជាគិតថា "ឧបជ្ឈាយ៍របស់យើងនិយាយអ្វី" បានដើរទៅ ដូចបុគ្គលដែលមិនបានឮពាក្យសម្ដីនោះ ។

ព្រះថេរៈកាលថ្វាយបង្គំមហាចេតិយ និងមហាពោធិ៍ហើយ ឱ្យសាមណេរកាន់បាត្រ និងចីវរ ទៅកាន់មហាវិហារ ឈ្មោះថា **កុដេឡិតស្សៈ** ដោយលំដាប់ ។ សាមណេរដែលជាប់តាមឧបជ្ឈាយ៍ មិនប្រាថ្នានឹងដើរទៅដើម្បីភិក្ខាហារ ទើបសួរលោកថា "ព្រះគុណម្ចាស់ នឹងចូលទៅភូមិណា" ដូច្នេះ ពេលដឹងថា "ឥឡូវនេះឧបជ្ឈាយ៍របស់ខ្លួននឹងដល់ទ្វារភូមិហើយ" ទើបកាន់យកបាត្រ និងចីវររបស់ខ្លួន

ព្រមទាំងរបស់ឧបជ្ឈាយ៍មកតាមផ្លូវអាកាស ថ្វាយបាត្រ និងចីវរដល់ព្រះថេរៈ ហើយ នឹងចូលទៅដើម្បីបិណ្ឌបាត ។ ព្រះថេរៈបានពោលដាស់តឿនសាមណេរ រហូតអស់កាលទាំងពួងថា **"សាមណេរ អ្នកកុំធ្វើយ៉ាងនេះ, ឈ្មោះថា ឫទ្ធិរបស់បុថុជ្ជន ជាសភាពអង្គី (កម្រើក) មិនមាំទាំ, បានអារម្មណ៍មានរូបារម្មណ៍ជាដើម ដែលជាអសប្បាយហើយ រមែងដាច់ទៅដោយហេតុ ត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះ, ពេលសមាបត្តិ ដែលកំពុងមានការសាបសូន្យទៅ បុថុជ្ជនទាំងឡាយ តែងតែមិនតាំងមាំក្នុងការប្រព្រឹត្តព្រហ្មចារ្យ"** ។ សាមណេរគិតថា "ឧបជ្ឈាយ៍របស់យើងនិយាយអ្វី" ដូច្នេះ មិនបានចង់នឹងស្ដាប់ នៅតែធ្វើយ៉ាងនោះឯង ។ ព្រះថេរៈពេលធ្វើការថ្វាយបង្គំព្រះចេតិយដោយលំដាប់ ហើយទៅកាន់វិហារឈ្មោះថា **កម្ពុបេណ្ឌវិហារ** ។ ទោះបីព្រះថេរៈនៅក្នុងវិហារនោះ សាមណេរក៏នៅតែធ្វើយ៉ាងនោះដែរ ។

ថ្ងៃក្រោយមក ធីតារបស់នាយជាងកីតម្បាញម្នាក់ មានរូបស្អាត ស្ថិតនៅក្នុងបឋមវ័យ ចេញចាកផ្ទះទីនៅអាស្រ័យហើយចុះទៅកាន់ស្រះឈូក ច្រៀងកាច់ផ្កាឈូក, **ក៏ក្នុងសម័យនោះ សាមណេរទៅដល់ស្រះឈូក, ស្ដាប់ចម្រៀងរបស់ស្ត្រីហើយ ហាក់ដូចជាសត្វល្អិតខ្វាក់ភ្នែកជាប់នៅក្នុងរសទឹកស្ករ;** ក្នុងខណៈមួយភ្លែតនោះ ឫទ្ធិអន្តរធានទៅអស់, ដូចក្អែកបាក់ស្លាប យ៉ាងនោះដែរ; តែដោយកម្លាំងសមាបត្តិកំពុងនៅមាន ទើបសាមណេរមិនបានធ្លាក់ទៅក្នុងផ្ទៃទឹកនោះ បានឈរនៅហើយត្រង់កន្លែងមាត់ស្រះឈូក បីដូចប៉ុយមិនអណ្ដែតឡើង ក៏អណ្ដែតលិចចុះទៅ ។ សាមណេរនោះ ត្រឡប់មកដោយរហ័ស ថ្វាយបាត្រ និងចីវរ ដល់ព្រះ

ឧបជ្ឈាយ៏ហើយក៏ទៅ ។ ព្រះមហាថេរមិនពោលពាក្យអ្វីដោយគិតថា **“រឿងនោះយើងឃើញហើយ, ទោះបីយើងហាម ក៏គេមិនត្រឡប់មក”** ទើបទៅបិណ្ឌបាត ។ ចំណែកសាមណេរទៅឈរនៅកន្លែងមាត់ស្រះឈូក រង់ចាំមើលធីតាជាងកីតម្បាញ នោះដែលឡើងមក ។ ឯធីតានោះ ក៏ឃើញសាមណេរ អ្នកទៅតាមផ្លូវអាកាស និងត្រឡប់មកវិញ ក៏យល់បានថា **“សាមណេរអាស្រ័យយើង ទើបមានសេចក្តីស្រើបស្រាល** (អផ្សុក) **”** ទើបពោលថា **“សាមណេរ ចូរចៀសចេញ”** សាមណេរនោះ ក៏គេចចេញទៅ; ធីតាជាងតម្បាញ ក៏ឡើងពីស្រះឈូកស្លៀកពាក់ ហើយចូលទៅរកសាមណេរសួរថា “មានការអ្វីឬ ?”; សាមណេរនោះបានប្រាប់រឿងរ៉ាវនោះហើយ; ធីតានោះសូម្បីសំដែងទោសក្នុងការនៅគ្រប់គ្រងផ្ទះដោយហេតុច្រើនយ៉ាង និងសំដែងអានិសង្សនៅប្រព្រឹត្តព្រហ្មចារ្យ ដើម្បីដាស់តឿនក៏មិនអាចដើម្បីឱ្យសាមណេរនោះបន្ទោបង់នូវសេចក្តីអផ្សុកបាន ទើបគិតថា “សាម-ណេរនេះ ច្បាស់ជាអស់ឫទ្ធិ ព្រោះយើង, ឥឡូវនេះ យើងមិនគួរបោះបង់គេ” ទើបពោលថា “ចូរឈប់នៅទីនេះសិន” ហើយត្រឡប់ទៅផ្ទះ បានប្រាប់រឿងនោះដល់មាតាបិតារបស់ខ្លួន ។

មាតាបិតាទៅឱ្យឱវាទ ដល់សាមណេរមានប្រការផ្សេងៗ បានពោលពាក្យពេចន៍ដែលខ្លួនមិនទទួលព្រមថា “លោកកុំសម្គាល់ថា ពួកយើងមានត្រកូលខ្ពស់, យើងគ្រប់គ្នាជាជាងកី, លោកនឹងអាចធ្វើការងាររបស់ជាងកីបានឬ ?” សាមណេរពោលថា “ម្នាលឧបាសក ឈ្មោះថា ជាគ្រហស្ថ ក៏ត្រូវតែធ្វើអ្វីៗ ទោះបីជាការងាររបស់ជាងកី ឬជាការងាររបស់មនុស្សចងកណ្តាប់ក៏ដោយ, សូមអ្នកកុំកំណាញ់សំពត់

ស្បៀក ដោយហេតុនេះឡើយ"; នាយជាងកីបានឱ្យសំពត់ដែលរុំទុកត្រង់ចង្កេះនោះ ឯង ហើយនាំទៅកាន់ផ្ទះ រួចលើកធីតាឱ្យ ។

មាណព (បុរសដែលសឹកហើយ) នោះ រៀនការងាររបស់ជាងកីហើយ ក៏ធ្វើការងារត្រង់កន្លែងសាលាជាមួយជាងកីទាំងឡាយ ។ ស្ត្រីទាំងឡាយនៃគ្រួសារដទៃចាត់ចែងអាហារហើយនាំមកពីព្រឹក; ចំណែកភរិយារបស់មាណពនោះ នៅមិនទាន់មក, ពេលជនទាំងឡាយសម្រាកការងារបរិភោគអាហារ មាណពនោះ អង្គុយចាំមើលផ្លូវប្រពន្ធដែលចូលមកក្រោយគេ ។ លំដាប់នោះ មាណពគំរាមភរិយាដោយពាក្យថា "ឯងមកយូរម្លេះ" ។

**តាមធម្មតា មាតុគ្រាមតែងយល់ចិត្តដែលនរណា១ មានសេចក្តីស្រឡាញ់ចំពោះខ្លួនហើយ រមែងសម្គាល់បុគ្គលទាំងឡាយ សូម្បីជាស្តេចចក្រពត្រាធិរាជថា ហាក់ដូចជាទាសៈ ។**

ព្រោះហេតុនោះ ទើបស្ត្រីនោះពោលយ៉ាងនេះថា "ក្នុងផ្ទះរបស់អ្នកដទៃគេមានអ្នកនាំវត្ថុ គ្រឿងប្រើប្រាស់ អុស បន្លែ អំបិលជាដើម អំពីក្រៅមកទុកត្រៀម, ឯខ្ញុំម្នាក់ឯង, ហើយបងឯងឥតដឹងថា ' ក្នុងផ្ទះយើង របស់នេះមាន របស់នោះមិនមានទេឬ' ។ បើបងត្រូវការ ក៏ចូរបរិភោគទៅ, បើមិនត្រូវការទេ កុំបរិភោគ" ។ មាណពនោះក្រោធហើយ ដោយគិតថា "ស្រីនេះ មិនគ្រាន់តែនាំអាហារមកយឺតទេ, ថែមទាំងបញ្ឈឺយើងដោយពាក្យសម្តីទៀត" លុះមិនឃើញគ្រឿងប្រហារផ្សេង ទើបដោះឈើត្រល់ត្បាញសំពត់នោះឯងចេញ ហើយពួយទៅ ។ ស្រីនោះ ឃើញនូវឈើត្រល់នោះហើយ គេចចេញបន្តិច; ក៏ធម្មតាចុងនៃឈើត្រល់ជាធម្មជាតិរហ័ស,

ពេលស្រីនោះកំពុងភៀសខ្លួន ចុងកំណាត់ឈើត្រល់ ក៏ទៅបុកចុងគ្រាប់ភ្នែក; ស្រីនោះបានយកដៃទាំងពីរក្តោបគ្រាប់ភ្នែកដោយរហ័ស, ឈាមហូរចេញពីកន្លែងដែលបែកហើយ; មាណពនោះ រឭកដល់ពាក្យរបស់ឧបជ្ឈាយ៍បានក្នុងវេលានោះ ទើបចាប់ផ្តើមស្រែកយំរៀបរាប់ថា “ឧបជ្ឈាយ៍ពោលនឹងយើង សំដៅយក រឿងនេះថា ‘ក្នុងអនាគត អ្នកនឹងផឹកទឹកបាយ ដែលជាងកឹម្នាក់ខ្វាក់ភ្នែកម្ខាងយកដៃខ្វាំ’, ហេតុយ៉ាងនេះដែលព្រះថេរៈឃើញហើយ, ឱ ! ព្រះគុណម្ចាស់ ឃើញការណ៍ឆ្ងាយហ្ន៎” ។ ជាងកឹទាំងឡាយពោលឆ្លើយថា “កុំឡើយ អ្នកកុំយំឡើយ, ធម្មតាគ្រាប់ភ្នែកបែកហើយ ទោះបីអ្នកស្រែកយំ ក៏មិនអាចធ្វើភ្នែកឱ្យជាប្រក្រតីបានឡើយ” ។

មាណពនោះពោលថា “ខ្ញុំមិនបានស្រែកយំដោយហេតុនេះទេ, ប៉ុន្តែថា ខ្ញុំស្រែកយំសំដៅយករឿងនេះ” ហើយទើបបានប្រាប់រឿងរ៉ាវ ដែលប្រព្រឹត្តទៅទាំងអស់ ដោយលំដាប់ ។

សមថៈ និងវិបស្សនាដែលកើតឡើងហើយ ពេលរលត់ទៅ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ដូចពណ៌នាមកដូច្នេះ ៕

## រឿងមួយទៀត

ភិក្ខុសាមណេរ ៣០ រូប ថ្វាយបង្គំព្រះមហាចេតិយដ៏រុងរឿង ហើយក៏ឈានទៅដល់ផ្លូវធំ ដោយតាមផ្លូវដែលជាព្រៃក្រាស់ ក្នុងចន្លោះផ្លូវបានជួបមនុស្សម្នាក់កំពុងដើរមកធ្វើការងារក្នុងចំការដែលភ្លើងឆេះ; រាងកាយរបស់គេ កខ្វក់ដោយធ្យូង, ពេលនរណា១ ក្រឡេកឃើញគេ អ្នកមានសំពត់ស្លៀកប្រឡាក់ម្រែងភ្លើង

នោះផង សំពត់ស្លៀកដែលគេត្បៀតទុកមួយផ្ទាំងផង ក៏នឹងប្រាកដហាក់បីដូចដើមឈើដែលភ្លើងឆេះហើយ ។ គេធ្វើការងារក្នុងវេលាកណ្ដាលថ្ងៃស្រេចហើយ ទើបលើកបាច់អុសដែលភ្លើងឆេះហើយមួយបាច់ដាក់លើខ្នង មានសក់ស្ញូញស្មាញដើរមកខុសផ្លូវ បានមកឈប់ត្រង់មុខភិក្ខុទាំងឡាយ ។

ពួកសាមណេរឃើញហើយ ក៏សម្លឹងមើលគ្នាឯង ហើយនិយាយថា "ពុករបស់អ្នក តារបស់អ្នក អ៊ំរបស់អ្នក" ដូច្នេះ នាំគ្នាសើច ហើយសួរឈ្មោះថា "ម្នាលឧបាសក អ្នកឈ្មោះអ្វី ?" ដូច្នេះ ។

មនុស្សនោះ ពេលឮសួរដល់ឈ្មោះ ក៏មានសេចក្ដីក្ដៅចិត្ត (វិប្បដិសារី) បោះបាច់អុសចុះ បានរៀបចំសម្លៀកបំពាក់ស្រួលបួល ថ្វាយបង្គំព្រះមហាថេរ ហើយប្រាប់ថា "បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន សូមព្រះគុណម្ចាស់ឈប់សិន" ។

ព្រះមហាថេរបានឈប់ហើយ; ពួកសាមណេរកំលោះៗ ទោះបីមកហើយដល់មុខព្រះថេរៈទាំងឡាយ ក៏នៅតែនិយាយពាក្យចំអន់គ្នា ។

ឧបាសកពោលថា "បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ពួកព្រះគុណម្ចាស់ឃើញខ្ញុំហើយរីករាយណាស់ (សើចចំអក) ចូលចិត្តថា 'ពួកយើងដល់ទីបំផុតហើយដោយហេតុមានប្រមាណប៉ុណ្ណេះតែម្ដង" ; ពេលមុនសូម្បីខ្ញុំនេះ ក៏ជាសមណៈដូចជាពួកលោកអ៊ីចឹងដែរ, ក៏ហេតុតែថា ភាពជាឯកគ្គតានៃចិត្តរបស់ពួកព្រះគុណម្ចាស់មិនមាន; ឯខ្ញុំវិញបានជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ក្នុងព្រះពុទ្ធសាសនានេះ, ធ្វើអាកាសឱ្យដូចជាផែនដី, ធ្វើផែនដីឱ្យដូចជាអាកាស; កាន់យករយៈផ្លូវដែលឆ្ងាយ ឱ្យជិត, ធ្វើទីជិត ឱ្យឆ្ងាយ; ទៅបានដល់ពាន់ចក្រវាឡ ដោយមួយខណៈ,

ព្រះគុណម្ចាស់ទាំងឡាយ ចូរមើលដៃរបស់ខ្ញុំព្រះករុណា, ក៏ឥឡូវនេះ វាដូចជាដៃស្វាអ៊ីចឹង; ខ្ញុំព្រះករុណាអង្គុយនៅក្នុងលោកនេះឯង អាចយកដៃទាំងពីរស្ទាបអង្អែលព្រះចន្ទ និងព្រះអាទិត្យបាន ។ ខ្ញុំព្រះករុណាអង្គុយ ហើយធ្វើព្រះចន្ទ និងព្រះអាទិត្យ ឱ្យដូចជាផ្ទាំងរងទឹសម្រាប់លាងជើងក៏បាន; **ឫទ្ធិរបស់ខ្ញុំព្រះករុណាមានសភាពដូច្នេះនេះ អន្តរធានទៅហើយ ដោយសេចក្ដីប្រមាទ, សូមព្រះគុណម្ចាស់ទាំងឡាយ កុំប្រមាទឡើយ**; ព្រោះថា សត្វទាំងឡាយដល់សេចក្ដីវិនាសទៅដូច្នេះ ដោយសេចក្ដីប្រមាទ; ព្រះគុណម្ចាស់ទាំងឡាយ ជាអ្នកមិនប្រមាទ កំពុងនឹងធ្វើទីបំផុតនៃជាតិ ជរា និងមរណៈបាន; ព្រោះហេតុដូច្នោះ សូមព្រះគុណម្ចាស់ទាំងឡាយ ធ្វើខ្ញុំឱ្យជាអារម្មណ៍ហើយ ចូរជាអ្នកមិនប្រមាទចុះ” លុះគម្រាមហើយបានឱ្យនូវឱវាទ ។

ពេលមនុស្សនោះ កំពុងពោលយ៉ាងនោះៗ ភិក្ខុសាមណេរទាំង ៣០ រូប ដល់សេចក្ដីសង្វេគហើយ ឃើញច្បាស់ហើយ ក៏ពន្លះព្រះអរហត្តក្នុងទីនោះឯង ។

សមថៈ និងវិបស្សនាដែលកើតឡើងហើយយ៉ាងនេះ ពេលរលត់ទៅ បណ្ឌិតគប្បីជ្រាបថា រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស ដូចពណ៌នាមកដូច្នេះ ៕

## វិនិច្ឆ័យក្នុងលោកិយសម្មប្បធានកថា

គប្បីជ្រាបការវិនិច្ឆ័យក្នុងលោកិយសម្មប្បធានកថាជាមុន ដូចតទៅនេះ ៖

**ក៏សម្រាប់ក្នុងខណៈនៃលោកុត្តរមគ្គ សេចក្ដីព្យាយាមតែម្យ៉ាងប៉ុណ្ណោះ រមែងបានឈ្មោះ ៤ យ៉ាង ដោយអំណាចនៃការញ៉ាំងកិច្ច ៤ យ៉ាង ឱ្យសម្រេច ។**

បណ្ដាពាក្យទាំងនោះ ពាក្យថា **អនុប្បន្នានំ** បានដល់ (អកុសលធម៌ដ៏លាមកទាំងឡាយ) ដែលមិនទាន់កើតឡើង ដោយអំណាចនៃការប្រាកដ ឬដោយអំណាចនៃអារម្មណ៍ដែលនៅមិនធ្លាប់សេព ។ ពិតណាស់ ក្នុងសំសារដែលរកខាងដើម និងខាងចុងមិនបាន ក៏ឈ្មោះថា អកុសលធម៌ដ៏លាមកទាំងឡាយ ដែលនៅមិនកើតឡើងហើយ ដោយប្រការផ្សេងៗ មិនបានមាន ។ ក៏អកុសលធម៌ដែលនៅមិនកើតឡើងទាំងនោះឯង ទោះបីពេលនឹងកើតឡើង ក៏រមែងកើតឡើងបាន, ទោះបីពេលលះ ក៏គប្បីលះបាន ។

ក្នុងបទថា **"អនុប្បន្នានំ"** នោះ កិលេសទាំងឡាយរមែងមិនប្រាកដដោយអំណាចនៃវត្តរបស់ភិក្ខុរូបខ្លះ, គឺរមែងមិនប្រាកដដល់ភិក្ខុរូបខ្លះ ដោយអំណាចនៃវត្តយ៉ាងណាមួយនៃគន្ថៈ ធុតង្គ សមាធិ វិបស្សនា នវកម្ម និងភព ។ កិលេសទាំងឡាយ រមែងមិនប្រាកដដោយអំណាចនៃវត្ត តើដូចម្ដេច ? ក៏ភិក្ខុរូបខ្លះ ជាអ្នកសម្បូរដោយវត្ត, ពេលអ្នកធ្វើនូវវត្តស្រាលៗ តូចៗ ៨២ មហាវត្ត ១៤ និងចេតិយ-វត្ត ពោធិយង្គវត្ត បានិយវត្ត មាឡកវត្ត ឧបោសថាគារវត្ត អាគន្តុកវត្ត និងគមិកវត្ត កំពុងធ្វើនោះឯង កិលេសទាំងឡាយរមែងមិនបានឱកាស ។ ក្នុងកាលផ្សេងទៀត ពេលដែលលោកលះបង់វត្តចោល និងមានវត្តបែកហើយ ព្រោះកិលេសទាំងឡាយ **អាស្រ័យអយោនិសោមនសិការ និងការភ្លេចសតិហើយ រមែងកើតឡើង** ។ កិលេសទាំងឡាយដែលនៅមិនទាន់កើត គប្បីកើតឡើងដោយអំណាចនៃការមិនប្រាកដយ៉ាងនេះ ឈ្មោះថា រមែងកើតឡើងបាន ។

ភិក្ខុរូបខ្លះ ប្រកបក្នុងការសិក្សារៀនសូត្រ, កាន់យក រៀនយកពុទ្ធវចនៈ ១ និកាយខ្លះ, ២- ៣- ៤- ៥ និកាយខ្លះ, ពេលភិក្ខុនោះឯងកាន់យក កំពុងស្វាធ្យាយ កំពុងគិត កំពុងប្រាប់ កំពុងប្រកាសនូវព្រះត្រៃបិដក គឺព្រះពុទ្ធវចនៈ ដោយអំណាចនៃអត្ថ ដោយអំណាចនៃបាលី ដោយអំណាចនៃអនុសន្ធិ ដោយអំណាចនៃបទដើម និងបទចុង កិលេសទាំងឡាយរមែងមិនបានឱកាស ។ ក៏ប៉ុន្តែក្នុងកាលផ្សេងទៀត អ្នកលះការសិក្សា ជាអ្នកត្រាច់ទៅទាំងដោយការខ្ជិលច្រអូស **កិលេសទាំងឡាយ អាស្រ័យអយោនិសោមនសិការ និងការភ្លេចសតិហើយ រមែងកើតឡើង** ។

កិលេសទាំងឡាយដែលនៅមិនកើតឡើង ដោយអំណាចនៃការមិនប្រាកដសូម្បីយ៉ាងនេះ ឈ្មោះថា រមែងកើតឡើងបាន ។

ឯភិក្ខុរូបខ្លះ ជាអ្នកទ្រទ្រង់ធុតង្គ, សមាទានប្រព្រឹត្តធុតង្គគុណ ១៣, ពេលលោកបរិហារធុតង្គគុណទាំងឡាយ កិលេសទាំងឡាយរមែងមិនបានឱកាស ។ ប៉ុន្តែក្នុងកាលផ្សេងទៀត ភិក្ខុនោះលះធុតង្គទាំងឡាយហើយ ងាកមកដើម្បីភាពជាអ្នកត្រាច់ទៅទាំងដោយការប្រាថ្នាច្រើន **កិលេសទាំងឡាយ អាស្រ័យអយោនិសោមនសិការ និងការលះសតិហើយ រមែងកើតឡើង** ។ កិលេសទាំងឡាយដែលមិនទាន់កើតឡើង ដោយអំណាចនៃការមិនប្រាកដ សូម្បីយ៉ាងនេះ ក៏រមែងកើតឡើងបាន ។

ក៏ភិក្ខុរូបខ្លះ ជាអ្នកជំនាញក្នុងសមាបត្តិ ៨; លោកអាស្រ័យនៅដោយអំណាចនៃអាវជ្ជនវសីជាដើម ក្នុងបឋមជ្ឈានជាដើម កិលេសទាំងឡាយរមែងមិនបានឱកាស ។ ប៉ុន្តែក្នុងកាលផ្សេងទៀត ភិក្ខុនោះសាបសូន្យចាកឈាន ឬលះឈាន

ចេញ ឬថាជាអ្នកប្រកបរឿយៗ ក្នុងការនិយាយរឿងដែលឥតប្រយោជន៍ជាដើម **កិលេសទាំងឡាយដែលអាស្រ័យអយោនិសោមនសិការ និងការលះសតិហើយ រមែងកើតឡើង** ។ កិលេសទាំងឡាយដែលមិនទាន់កើតឡើងដោយអំណាចនៃការមិនប្រាកដ សូម្បីយ៉ាងនេះ ក៏រមែងកើតឡើងបាន ។

ក៏ភិក្ខុរូបខ្លះជាអ្នកបដិបត្តិវិបស្សនា, កំពុងចម្រើននូវអនុបស្សនា ៧ ឬមហាវិបស្សនា ១៨ កំពុងប្រព្រឹត្តទៅ ពេលលោកកំពុងបដិបត្តិយ៉ាងនេះ កិលេសទាំងឡាយ រមែងមិនបានឱកាស ។ ប៉ុន្តែក្នុងកាលផ្សេងទៀត អ្នកលះការងារនៃវិបស្សនា ជាអ្នកច្រើនដោយការធ្វើរាងកាយឱ្យខ្លាំងក្លា **កិលេសទាំងឡាយអាស្រ័យអយោនិសោមនសិការ និងការលះសតិហើយ រមែងកើតឡើង** ។ កិលេសទាំងឡាយ ដែលនៅមិនទាន់កើតឡើង ដោយអំណាចនៃការមិនប្រាកដ សូម្បីយ៉ាងនេះ ក៏ឈ្មោះថា រមែងកើតឡើង ។

ភិក្ខុខ្លះ ជានវកម្មិកៈ (អ្នកកសាង), តែងតែធ្វើរោងឧបោសថ (ព្រះវិហារ) និងឧបដ្ឋានសាលាជាដើម ។ ពេលលោកគិតពីឧបករណ៍នៃរោងឧបោសថជាដើមនោះ កិលេសទាំងឡាយរមែងមិនបានឱកាស; ប៉ុន្តែក្នុងកាលផ្សេងទៀត ពេលនវកម្មរបស់លោកស្រេចហើយ ឬជាអ្នកលះនវកម្មហើយ **កិលេសទាំងឡាយអាស្រ័យអយោនិសោមនសិការ និងការលះសតិហើយ រមែងកើតឡើង** ។ កិលេសទាំងឡាយ ដែលនៅមិនទាន់កើតឡើង ដោយអំណាចនៃការមិនប្រាកដ សូម្បីយ៉ាងនេះ ក៏ឈ្មោះថា រមែងកើតឡើង ។

ភិក្ខុរូបខ្លះ មកអំពីព្រហ្មលោក ជាសត្វបរិសុទ្ធ, កិលេសទាំងឡាយ មិនបានឱកាស ព្រោះនៅមិនមានការសេពគប់ ។ ប៉ុន្តែថា ក្នុងកាលផ្សេងទៀត គេមានការសេពគប់ហើយ **កិលេសទាំងឡាយ អាស្រ័យអយោនិសោមនសិការ និងការលះសតិហើយ រមែងកើតឡើង** ។ កិលេសទាំងឡាយ ដែលនៅមិនទាន់កើតឡើង ដោយអំណាចនៃការមិនប្រាកដ សូម្បីយ៉ាងនេះ ក៏ឈ្មោះថា រមែងកើតឡើងបាន ។

គប្បីជ្រាបសេចក្ដីដែលកិលេសទាំងឡាយ នៅមិនទាន់កើតឡើង ដោយអំណាចនៃការមិនប្រាកដ ដូចពណ៌នាមកដូច្នេះសិន ។

អកុសលធម៌ដ៏លាមកដែលនៅមិនកើតឡើង ដោយអំណាចនៃអារម្មណ៍ដែលមិនធ្លាប់សេព តើដូចម្ដេច ?

ភិក្ខុរូបខ្លះក្នុងសាសនានេះ បានអារម្មណ៍ផ្សេងដោយអារម្មណ៍ មានអារម្មណ៍ដែលជាទីពេញចិត្តជាដើម ដែលនៅមិនទាន់ធ្លាប់សេព, កិលេសទាំងឡាយ មានរាគៈជាដើម អាស្រ័យអយោនិសោមនសិការ និងការលះសតិហើយ រមែងកើតឡើងដល់លោក ព្រោះអារម្មណ៍នោះបាន ។ កិលេសទាំងឡាយ ដែលនៅមិនទាន់កើតឡើង ដោយអំណាចនៃអារម្មណ៍ដែលនៅមិនទាន់សេពយ៉ាងនេះ ក៏ឈ្មោះថា រមែងកើតឡើងបាន ។ តែថា ក្នុងខណៈនៃលោកុត្តរមគ្គ វិរិយៈមួយនោះឯង រមែងញ៉ាំងកិច្ច គឺការមិនឱ្យកិលេសទាំងឡាយ ដែលនៅមិនទាន់កើតឡើង នឹងគប្បីកើតឡើងយ៉ាងនេះ រមែងមិនឱ្យកើតឡើង ញ៉ាំងកិច្ច គឺការលះកិលេសទាំងឡាយ ដែលកើតឡើងហើយផង ឱ្យសម្រេច ។

ព្រោះហេតុដូច្នោះ ក្នុងបទថា **“ឧប្បន្នានំ ធាតុភានំ”** នេះ ទើបបាន ឧប្បន្នៈ (កិលេសដែលកើតឡើងហើយ) ៤ យ៉ាង គឺ

**១. វត្តមានុប្បន្នៈ** កើតឡើងប្រព្រឹត្តទៅក្នុងខណៈទាំង ៣

**២. ភុត្វា វិគតុប្បន្នៈ** កើតឡើងសេពអារម្មណ៍ហើយរលត់ទៅ

**៣. ឱកាសកតុប្បន្នៈ** កើតឡើងធ្វើឱកាសឱ្យដល់ខ្លួន

**៤. ភូមិលទ្ធុប្បន្នៈ** កើតឡើងក្នុងភូមិដែលខ្លួនបានហើយ ។

បណ្តាឧប្បន្នធម៌ទាំង ៤ នោះ កិលេសណាដែលនៅមាន កិលេសនោះ ជាសភាពព្រមព្រៀងដោយឧប្បាទៈជាដើម (ឧប្បាទៈ ឋិតិ ភង្គៈ), នេះ ឈ្មោះថា **វត្តមានុប្បន្នៈ** ។ ក៏ពេលកិលេសនោះសេពព្រោះកម្មហើយ សោយរសនៃអារម្មណ៍ហើយ វិបាករលត់ទៅហើយ ឈ្មោះថា **ភុត្វា វិគតៈ** (សេពហើយប្រាសទៅ) ។ កម្មដែលកើតឡើងហើយ រលត់ទៅ ក៏ឈ្មោះថា **ភុត្វា វិគតៈ** ។ សូម្បីទាំងពីរនេះ រមែងដល់នូវការរាប់ថា **ភុត្វា វិគតុប្បន្នៈ** ។ កម្មដែលជាកុសល និងអកុសល ហាមវិបាកនៃកម្មផ្សេង ហើយឱ្យឱកាសដល់វិបាកនៃខ្លួន; ពេលកម្មធ្វើឱកាសហើយយ៉ាងនេះ វិបាកដែលកើតឡើងតាំងពីការធ្វើឱកាស លោកហៅថា **ឧប្បន្នៈ** (កិលេសកើតឡើងហើយ), នេះ ឈ្មោះថា **ឱកាសកតុប្បន្នៈ** ។

ឯបញ្ចក្ខន្ធ ឈ្មោះថា **ភូមិនៃវិបស្សនា**, បញ្ចក្ខន្ធដែលផ្សេងដោយអតីតៈជាដើមនោះនៅមាន; ក៏កិលេសដែលដេកត្រាំហើយក្នុងខន្ធនោះ នរណា១ មិនគប្បីពោលថា “ជាអតីតៈ ឬអនាគត ឬក៏បច្ចុប្បន្ន” ; ព្រោះថា កិលេសទាំងឡាយទោះបីដេកត្រាំហើយក្នុងអតីតខន្ធទាំងឡាយ រមែងជាសភាវៈនៅតែលះមិនបាន;

សូម្បីក្នុងអនាគតខន្ធទាំងឡាយ ក្នុងបច្ចុប្បន្នខន្ធទាំងឡាយ ក៏ដូចគ្នា; នេះ ឈ្មោះថា **ភូមិលទ្ធុប្បន្នៈ** ។

ដោយហេតុនោះ ទើបអាចារ្យទាំងឡាយក្នុងជំនាន់មុន ពោលថា "កិលេសទាំងឡាយដែលនៅមិនបានដកឡើងក្នុងភូមិនោះៗ រមែងដល់នូវការរាប់ថា **ជាភូមិលទ្ធុប្បន្នៈ**" ។

ឧប្បន្នធម៌ ៤ យ៉ាង ផ្សេងទៀត គឺ

**១. សមុទាចារុប្បន្នៈ ២. អារម្មណាធិគហិតុប្បន្នៈ**
**៣. អវិក្ខម្ភិតុប្បន្នៈ ៤. អសមុគ្ឃាដិតុប្បន្នៈ ។**

ក្នុង ៤ យ៉ាងនោះ កិលេសទាំងឡាយកំពុងប្រព្រឹត្តទៅក្នុងពេលនេះឯង ឈ្មោះថា **សមុទាចារុប្បន្នៈ** ។

ពេលបុគ្គលបើកភ្នែកម្តងហើយចំណាំនូវអារម្មណ៍ នរណាៗ មិនគប្បីពោលថា "កិលេសទាំងឡាយនឹងមិនកើតឡើង ក្នុងខណៈដែលខ្លួនតាមរឭកបានហើយ និងរឭកដល់ហើយ" ។ **សួរថា** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះភាពជាអ្នកទាញយកនូវអារម្មណ៍ ។ លោកពោលទុកដូចម្តេច ? លោកពោលប្រៀបដូចថា នរណាៗ មិនគប្បីពោលថា ប្រេងនឹងមិនចេញទៅអំពីដើមឈើដែលមានប្រេង ក្នុងឋានៈដែលបុគ្គលយកពូថៅស្ទោះ និងស្ទោះហើយ យ៉ាងណា, សេចក្តីនេះ ក៏ឈ្មោះថា **អារម្មណាធិគហិតុប្បន្នៈ** យ៉ាងនោះដែរ ។

ឯកិលេសដែលនៅមិនបានសង្កត់ទុកដោយសមាបត្តិ នរណាៗ មិនគប្បីពោលថា "កិលេសទាំងនោះនឹងមិនកើតឡើងក្នុងទីឈ្មោះឯណោះ" ។ **សួរថា** ព្រោះ

ហេតុអ្វី ? ឆ្លើយថា ព្រោះមិនបានសង្កត់ទុក ។ លោកពោលទុកដូចម្តេច ? លោកពោលទុកថា បើបុគ្គលយកពូថៅស្ទោះដើមឈើមិនមានជ័រ, នរណា១ មិនគប្បីពោលថា ជ័រចេញទៅក្នុងទីឈ្មោះនោះ, សេចក្តីនេះ ក៏ដូច្នោះដែរ ទើបឈ្មោះថា **អវិក្ខម្ភិតុប្បន្នៈ** ។

ម្យ៉ាងទៀត បណ្ឌិតគប្បីញុំាងពាក្យថា "កិលេសដែលនៅមិនបានដកឡើងដោយមគ្គហើយ នឹងមិនកើតឡើង ទោះបីដល់អ្នកកើតក្នុងភវគ្គភូមិ (ភូមិជាន់ខ្ពស់)" ឱ្យពិស្តារដោយន័យមុននោះចុះ នេះ ឈ្មោះថា **អសមុគ្ឃាដិតុប្បន្នៈ** ។

បណ្តាឧប្បន្នៈ (គឺកិលេសដែលកើតឡើងហើយ) ឧប្បន្នៈ ៤ យ៉ាង ដែលមគ្គមិនគប្បីសម្លាប់ គឺ

**១. វត្តមានុប្បន្នៈ ២. ភុត្វា វិគតុប្បន្នៈ**

**៣. ឱកាសកតុប្បន្នៈ ៤. សមុទាចារុប្បន្នៈ ។**

ឧប្បន្នៈដែលមគ្គគប្បីសម្លាប់ ៤ យ៉ាង គឺ

**១. ភូមិលទ្ធុប្បន្នៈ ៣. អវិក្ខម្ភិតុប្បន្នៈ**

**២. អារម្មណាធិគហិតុប្បន្នៈ ៤. អសមុគ្ឃាដិតុប្បន្នៈ ។**

ពិតណាស់ មគ្គពេលកើតឡើង រមែងលះកិលេសទាំងឡាយនេះ; ក៏ប៉ុន្តែថា មគ្គនោះលះកិលេសឯណា, កិលេសទាំងនោះ នរណា១ មិនគប្បីពោលថាជាអតីតៈ ឬអនាគត ឬក៏បច្ចុប្បន្ន ។

**សេចក្តីនេះ សមពិតដូចដែលលោកពោលថា** ៖

បើថា មគ្គរមែងលះកិលេសទាំងឡាយដែលជាអតីតៈបានសោត, បើយ៉ាងនោះ មគ្គនោះ ក៏ញុំាំងកិលេសដែលអស់ទៅហើយ ឱ្យអស់ទៅបាន,

រមែងញ៉ាំងកិលេសដែលរលត់ទៅហើយ ឱ្យរលត់ទៅបាន, រមែងញ៉ាំងកិលេសដែលប្រាសទៅហើយ ឱ្យប្រាសទៅបាន, រមែងញ៉ាំងកិលេស ដែលដល់នូវសេចក្តីសាបសូន្យទៅហើយ ឱ្យដល់នូវសេចក្តីសាបសូន្យទៅបាន, វត្ថុណាដែលជាអតីតៈនៅមិនទាន់មាន, រមែងលះវត្ថុនោះបាន ។

បើថា មគ្គរមែងលះកិលេសទាំងឡាយ ដែលជាអនាគតបានសោត, បើយ៉ាងនោះ មគ្គនោះក៏រមែងលះកិលេសដែលមិនទាន់បានកើតឡើងហើយ, រមែងលះកិលេសដែលនៅមិនទាន់កើតហើយ, ដែលមិនកើតឡើងហើយ, ដែលមិនបានប្រាកដហើយ; វត្ថុណានៅមិនទាន់មកដល់ ដែលមិនបានមាន, រមែងលះវត្ថុនោះបាន ។

បើថា មគ្គរមែងលះកិលេសទាំងឡាយ ដែលកើតឡើងចំពោះមុខ (បច្ចុប្បន្ន) បាន, បើយ៉ាងនោះ មគ្គនោះ ក៏មានរាគៈស្រើបស្រាលហើយទើបលះរាគៈ, មានទោសប្រទូសរ៉ាយហើយ ទើបលះទោសៈ, មានមោហៈវង្វេងហើយ ទើបលះមោហៈ, មានមានះចងពន្ធហើយ ទើបលះមានះ, មានទិដ្ឋិប្រកាន់ទុកហើយ ទើបលះទិដ្ឋិ, មានសេចក្តីរាយមាយហើយ ទើបលះឧទ្ធច្ចៈ, មានការឆ្ងេឆ្ងាមិនតាំងមាំហើយ ទើបលះវិចិកិច្ឆា និងមានកិលេសដែលមានកម្លាំងហើយ ទើបលះអនុស្ស័យបាន ។ ធម៌ដែលខ្មៅ និងស កំពុងប្រព្រឹត្តទៅជាប់គ្នាជាគូៗ (បែបនេះ); មគ្គភាវនាក៏រមែងប្រកបទៅដោយសង្កិលេស ។ ល ។ បើយ៉ាងនោះ មគ្គភាវនាក៏រមែងមិនមាន, ការធ្វើឱ្យជាក់ច្បាស់នូវផលក៏មិនមាន, ការលះកិលេសក៏មិនមាន, ធម្មាភិសម័យ (ការត្រាស់ដឹងធម៌) ក៏មិនមាន ។ ឯដែលពិត មគ្គភាវនាមាន ។ ល ។ ធម្មាភិ-សម័យ ក៏មាន ។

សួរថា ដូចអ្វី ?

ឆ្លើយថា ដូចដើមឈើដែលនៅមិនទាន់មានផល (ផ្លែ) នឹងមានមកក្នុងព្រះបាលី (សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ) ថា៖

**សេយ្យថាបិ តរុណោ រុក្ខោ ។ បេ ។ អបាតុភូតានេវ ន បាតុភវន្តិ** = ដូចដើមឈើនៅសាវ៉ មិនទាន់មានផ្លែ បុរសគប្បីកាត់ដើមឈើនោះត្រង់ ឫស ផ្លែដែលនៅមិនទាន់កើតត្រង់ដើមឈើនោះ ក៏នឹងមិនកើតឡើយ, ដែលនៅមិនបង្កើតហើយ ក៏មិនបង្កើតឡើយ, ដែលមិនកើតឡើងហើយ ក៏មិនកើតឡើងឡើយ, ដែលនៅមិនបានប្រាកដហើយ ក៏មិនប្រាកដឡើយ យ៉ាងណា ។ល។ ដូចយ៉ាងថា ដើមស្វាយសាវ៉ដែលមានផ្លែ មនុស្សទាំងឡាយគប្បីបរិភោគ ផ្លែទាំងឡាយរបស់ដើមស្វាយនោះ, ផ្លែទាំងឡាយដែលនៅសល់ធ្លាក់ចុះទៅហើយ ក៏គប្បីញ៉ាំងដើមស្វាយដែលកើតកាលក្រោយឱ្យសម្បូរ, លំដាប់នោះ មនុស្សដទៃ គប្បីយកពូថៅកាត់ដើមស្វាយនោះ; ដោយហេតុនោះ ផ្លែទាំងឡាយរបស់ដើម ស្វាយដែលជាអតីតៈនោះ ទើបមិនបានវិនាស, ផ្លែទាំងឡាយរបស់ដើមស្វាយដែលជាអនាគត និងបច្ចុប្បន្ន ក៏មិនវិនាសទៅ; ព្រោះថា ផ្លែស្វាយដែលជាអនាគតទៀត ក៏នៅមិនកើតឡើង; ទើបមិនអាចដើម្បីវិនាសទៅ; តែក្នុងសម័យណា ដើមស្វាយនោះ ត្រូវកាត់ដាច់ហើយ, ក្នុងកាលនោះ ផ្លែស្វាយទាំងអស់នោះ រមែងមិនមាន ព្រោះហេតុដូច្នោះ សូម្បីផ្លែស្វាយដែលជាបច្ចុប្បន្ន ក៏មិនវិនាសទៅ; ហើយបើថា ដើមស្វាយមិនត្រូវបានកាត់ទៅហើយសោត, ផ្លែស្វាយពួកណាអាស្រ័យរសបឋវី និងរសនៃអាបោហើយ ក៏គប្បីកើតទៀត, ផ្លែស្វាយ (ដើមដែលត្រូវកាត់ហើយ) ទាំងនោះ ជា

របស់វិនាសទៅហើយ ។ ពិតណាស់ ផ្លែស្វាយដែលនៅមិនកើតទាំងនោះៗ រមែងមិនកើតឡើង, ដែលនៅមិនប្រាកដ យ៉ាងណា; មគ្គក៏យ៉ាងនោះដែរ រមែងលះកិលេសទាំងឡាយ ដែលផ្សេងដោយអតីតៈជាដើម ក៏ទេ រមែងមិនលះកិលេសទាំងឡាយក៏មិនមែន ។ ព្រោះថា ពេលខន្ធទាំងឡាយដែលមគ្គមិនបានកំណត់ដឹងហើយ ការកើតឡើងនៃកិលេសពួកណា គប្បីមាន, ព្រោះសភាពនៃខន្ធទាំងឡាយ ដែលមគ្គកំណត់ដឹងហើយនូវកិលេស ដែលមិនទាន់កើតឡើងនោះៗ រមែងមិនកើតឡើង, ដែលនៅមិនទាន់បង្កើតនោះឯង រមែងមិនបង្កើតឡើង, ដែលនៅមិនប្រាកដនោះឯង រមែងមិនប្រាកដ ។

បណ្ឌិតគប្បីជាក់ច្បាស់សេចក្ដីនេះ ដោយថ្នាំដែលបុគ្គលផឹកហើយ ដើម្បីការមិនកើតឡើងនៃកូនខ្ចីរបស់ស្ត្រី ឬដើម្បីសេចក្ដីចូលទៅស្ងប់ នៃរោគរបស់អ្នកមានព្យាធិក៏បាន ។

បណ្ឌិតមិនគប្បីពោលថា មគ្គរមែងលះកិលេសពួកណា កិលេសពួកនោះ ជាអតីតៈ ឬអនាគត ឬក៏បច្ចុប្បន្ន ដូចពណ៌នាមកដូច្នេះទេ ។ មួយទៀត មគ្គរមែងមិនលះកិលេសទាំងឡាយ ក៏មិនមែន; តែថាមគ្គលះកិលេសពួកណា, ព្រះមានព្រះភាគសំដៅយកកិលេសពួកនោះ ទើបត្រាស់ថា **“ឧប្បន្នានំ ធាបកានំ”** ជាដើម ។

មគ្គរមែងលះកិលេសតែម្យ៉ាងក៏មិនមែន, ឧបាទានក្ខន្ធណា គប្បីកើតឡើង ព្រោះសេចក្ដីដែលកិលេសទាំងឡាយ នៅមិនបានលះ, មគ្គរមែងលះសូម្បីឧបាទានក្ខន្ធនោះផង ។

សេចក្ដីនេះ លោកពោលញែកសេចក្ដីដោយសោតាបត្តិមគ្គញ្ញាណ ដែលរលត់នូវអភិសង្ខារ និងវិញ្ញាណ គឺវៀរភពទាំង ៧ ហើយ ឧបាទានក្ខន្ធណា គឺនាម និងរូបគប្បីកើតឡើងក្នុងសង្សារ ដែលរកខាងដើម និងទីបំផុតមិនបាន ឧបាទានក្ខន្ធនោះរមែងរលត់ក្នុងអធិការនេះ ព្រោះហេតុដូច្នោះ មគ្គនោះ ទើបមានអត្ថទូលំទូលាយ ។

**ដោយប្រការដូច្នេះ មគ្គទើបឈ្មោះថា រមែងចេញទៅចាកឧបាទិន្នក្ខន្ធ និងអនុបាទិន្នក្ខន្ធ ។**

**តែកាលបើពោលដោយអំណាចនៃភពហើយ សោតាបត្តិមគ្គរមែងចេញទៅចាកអបាយភព, សកទាគាមិមគ្គ រមែងចេញទៅចាកសុគតិភពចំណែកខ្លះ, អនាគាមិមគ្គរមែងចេញទៅចាកសុគតិកាមភព, អរហត្តមគ្គរមែងចេញទៅចាករូបភព និងអរូបភព ។**

អាចារ្យទាំងឡាយពោលថា “អរហត្តមគ្គ រមែងចេញទៅចាកភពទាំងអស់ដោយសព្វគ្រប់” ដូច្នេះក៏មាន ។ *សួរថា* កាលបើយ៉ាងនោះ ក្នុងខណៈនៃមគ្គ-ភាវនា រមែងមានដើម្បីការកើតឡើងនៃធម៌ទាំងឡាយ ដែលនៅមិនកើតឡើង, ឬដើម្បីសេចក្ដីតាំងមាំនៃធម៌ទាំងឡាយ ដែលកើតឡើងហើយ យ៉ាងណា ?, ឆ្លើយថា ភាវនារមែងមាន ព្រោះការប្រព្រឹត្តទៅនៃមគ្គនោះឯង ។ ពិតមែនហើយ មគ្គកាលបើកំពុងប្រព្រឹត្តទៅ លោកពោលថា មិនធ្លាប់កើតឡើង ព្រោះសេចក្ដីដែលមគ្គនោះ មិនធ្លាប់កើតឡើង, ព្រោះសេចក្ដីដែលមគ្គនោះ មិនធ្លាប់កើតឡើងក្នុងកាលមុន ។ ដូចជនទាំងឡាយអ្នកទៅកាន់ទីដែលមិនធ្លាប់ទៅ ឬសោយអារម្មណ៍ដែលខ្លួន មិនធ្លាប់សោយ គេរមែងពោលថា “ពួកយើងមកហើយ កាន់ទីដែលមិនធ្លាប់មក, ឬថា រមែងសោយអារម្មណ៍ដែលមិនធ្លាប់សោយ” ។ មួយទៀត សេចក្ដី

នៃមគ្គឯណា នេះឯង ឈ្មោះថា ការតាំងមាំ ព្រោះហេតុដូច្នោះ ការពោលថា "រមែងចម្រើនមគ្គ ដើម្បីការតាំងមាំ" ដូច្នេះក៏គួរ ។

ក្នុងខណៈនៃលោកុត្តរមគ្គ សេចក្តីព្យាយាមរបស់ភិក្ខុនេះ រមែងបានឈ្មោះ ៤ យ៉ាង ដែលមានពាក្យជាអាទិ៍ថា **"អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ"** ដូចពណ៌នាមកដូច្នេះ ។ នេះជាសម្មប្បធានកថា ក្នុងខណៈនៃលោកុត្តរមគ្គ ។ លោកពន្យល់សម្មប្បធាន ដែលលាយឡំដោយលោកិយ និងលោកុត្តរ ទុកក្នុងសម្មប្បធានវិភង្គនេះ ដោយប្រការដូច្នេះ ៕

**ពណ៌នាអំពីសុត្តន្តភាជនិយចប់**

## ២-ពណ៌នាអំពីអភិធម្មភាជនិយ

ក្នុងអភិធម្មភាជនិយ សូម្បីសម្មប្បធានទាំងអស់ ព្រះមានព្រះភាគជាម្ចាស់ទ្រង់សំដែងទុកត្រឹមតែមាតិកា របស់ន័យទេសនា ដែលទ្រង់ចែកហើយក្នុងធម្មសង្គណីនោះឯង ដែលជាពាក្យពន្យល់ច្បាស់លាស់ហើយ ។

ក្នុងអធិការនេះ គប្បីជ្រាបន័យដែលផ្សេងគ្នា ៖

**គប្បីជ្រាបយ៉ាងណា ? គឺគប្បីជ្រាបនូវសោតាបត្តិមគ្គ ក្នុងសម្មប្បធានទីមួយជាមុនសិន ។**

**ក្នុងឈានាភិនិវេស** (ការអាស្រ័យឈាន) មាន ១០ ន័យ ដោយអំណាចនៃចតុក្កៈ និងបញ្ចកៈពីរ ៗ យ៉ាង ក្នុងឋានៈទាំង ៥ នេះ គឺសុទ្ធិកបដិបទា សុទ្ធិកសុញ្ញតា សុញ្ញតបដិបទា សុទ្ធិកអប្បណិហិតា អប្បណិហិតបដិបទា ។ សូម្បីក្នុងន័យទាំងឡាយដ៏សេស ក៏ដូចគ្នាដែរ, ព្រោះហេតុដូច្នោះ ក្នុងអភិនិវេស ២០

ន័យ ទើបបាន ២០០ ន័យ ។ ន័យទាំង ២០០ នោះ គុណដោយអធិបតី ៤ ជា ៨០០ ន័យ ។ សូម្បីន័យទាំងអស់ គឺ សុទ្ធិកៈ ២០០ ជាមួយអធិបតី ៨០០ ទើបជា ១.០០០ ន័យ ដោយប្រការដូច្នេះ ។

ក៏សុទ្ធិកសម្មប្បធាន ត្រង់ទុតិយសម្មប្បធានជាដើមក៏ដូចគ្នា គឺបាន ៥.០០០ ន័យ ក្នុងសោតាបត្តិមគ្គ ។ ក្នុងសោតាបត្តិមគ្គ យ៉ាងណា, សូម្បីក្នុងមគ្គដ៏សេស ក៏ដូច្នោះដែរ ព្រោះហេតុដូច្នោះ ទើបជា ២០.០០០ ន័យ ដោយអំណាចនៃកុសល ។

**តែក្នុងវិបាកកិច្ច ដែលគប្បីធ្វើដោយសម្មប្បធានទាំងឡាយ មិនមាន ព្រោះហេតុដូច្នោះ វារៈពោលអំពីវិបាក ព្រះមានព្រះភាគជាម្ចាស់ មិនបានទ្រង់កាន់យកដូច្នេះទេ ៕**

**ពណ៌នាអំពីអភិធម្មភាជនិយចប់**

## ៣-ពណ៌នាអំពីបញ្ហាបុច្ឆកៈ

ក៏ក្នុងទីនេះ **សម្មប្បធានវិភង្គ** នេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់សម្មប្បធានដែលកើតឡើង ជាលោកុត្តរប៉ុណ្ណោះ ។ ក្នុងបញ្ហាបុច្ឆកៈ គប្បីជ្រាបសេចក្ដីដែលសម្មប្បធានទាំងឡាយជាកុសលជាដើម តាមលំនាំព្រះបាលីនោះឯង ។ តែក្នុងអារម្មណត្តិកៈទាំងឡាយ សូម្បីសម្មប្បធានទាំងអស់នេះ ជាអប្បមាណារម្មណ៍ប៉ុណ្ណោះ ព្រោះប្រារព្ធព្រះនិព្វានដែលជាអប្បមាណធម៌ ហើយប្រព្រឹត្តទៅ, មិនជាមគ្គារម្មណ៍; តែជាមគ្គហេតុកៈដោយអំណាចនៃសហជាតហេតុ, ជាមគ្គាធិបតីក្នុងកាលចម្រើនមគ្គ ព្រោះធ្វើវីមំសាឱ្យជាប្រធាន, តែក្នុងមគ្គភាវនាដែលមានឆន្ទៈ និង

ចិត្តជាប្រធាន មិនគប្បីពោលថាជាមគ្គាធិបតី, ឬមិនគប្បីពោលថា ជាមគ្គាធិបតី ព្រោះមិនមានសេចក្តីព្យាយាមដទៃ ក្រៅពីសេចក្តីព្យាយាមដែលជាប្រធាន, ឬក៏មិនគប្បីពោល សូម្បីដោយសេចក្តីជាអារម្មណ៍មួយ៉ាង ក្នុងអតីតារម្មណ៍ជាដើម ។ សម្មប្បធាននោះ ឈ្មោះថា ជាពហិទ្ធារម្មណ៍ ព្រោះសេចក្តីដែលព្រះនិព្វានជាអារម្មណ៍ខាងក្រៅ ដោយប្រការដូច្នេះ ។ ក្នុងបញ្ហាបុច្ឆកៈនេះ ព្រះមានព្រះភាគត្រាស់សម្មប្បធានទាំងឡាយ ជាលោកុត្តរដែលកើតឡើងហើយប៉ុណ្ណោះ ។ ពិតណាស់ នៅក្នុងសុត្តន្តភាជនិយ ព្រះសម្មាសម្ពុទ្ធត្រាស់សម្មប្បធានទាំងឡាយទុក ទាំងដែលជាលោកិយ និងលោកុត្តរលាយគ្នា; តែក្នុងអភិធម្មភាជនិយ និងក្នុងបញ្ហាបុច្ឆកៈ ត្រាស់ថាជាលោកុត្តរប៉ុណ្ណោះ ។ សូម្បីក្នុងសម្មប្បធានវិភង្គនេះ ព្រះមានព្រះភាគ ក៏ទ្រង់នាំចេញមកចែកសំដែងហើយនូវបរិវដ្ត ៣ យ៉ាងនេះ ដោយប្រការដូច្នេះ ។៚

**ពណ៌នាអំពីបញ្ហាបុច្ឆកៈចប់**

**ចប់អដ្ឋកថាសម្មប្បធានវិភង្គ**

# ៩. អដ្ឋកថាឥទ្ធិបាទវិភង្គ

## ១. ពណ៌នាអំពីសុត្តន្តភាជនិយ

ឥឡូវនេះ គប្បីជ្រាបការវិនិច្ឆ័យក្នុង **ឥទ្ធិបាទវិភង្គ** ដែលជាលំដាប់តពី **សម្មប្បធានវិភង្គ** នោះតទៅ ៖

ពាក្យថា **“៤”** ជាពាក្យកំណត់ចំនួន ។ ក្នុងពាក្យថា **“ឥទ្ធិបាទា”** នេះ ឈ្មោះថា **ឥទ្ធិ** (ឫទ្ធិ) ព្រោះអត្ថថា រមែងរុងរឿង (ឥជ្ឈតីតិ > **ឥទ្ធិ**), អធិប្បាយថា រមែងរុងរឿងដោយល្អ គឺរមែងសម្រេច ។ ម្យ៉ាងទៀត សត្វទាំងឡាយ ដែលសម្រេច ដែលចម្រើន រមែងសម្រេច រមែងដល់ភាពជាអ្នកប្រសើរដោយសភាវៈនេះ ព្រោះហេតុនោះឯង សភាវៈនោះ ទើបឈ្មោះថា **ឥទ្ធិ** ។ **ពោលអំពីអត្ថទី ១ បាទោ** = បាទ (ជើង) គឺឥទ្ធិនោះឯង ឈ្មោះថា **ឥទ្ធិបាទ**, អធិប្បាយថា ជាចំណែកមួយរបស់ឫទ្ធិ ។ **ពោលអំពីអត្ថទី ២** ឈ្មោះថា **ឥទ្ធិបាទ** ព្រោះជាបាទនៃឫទ្ធិ ។ ពាក្យថា **“បាទោ”** បានដល់ ជាទីអាស្រ័យ គឺឧបាយជាគ្រឿងសម្រេច។ ពិតមែន ព្រោះសត្វទាំងឡាយ រមែងដល់ រមែងសម្រេចនូវឫទ្ធិ ពោលគឺគុណវិសេសដ៏ខ្ពស់ៗ ឡើងទៅ ដោយឧបាយជាគ្រឿងសម្រេចនោះ; ព្រោះហេតុដូច្នោះ ទើបលោកហៅថា បាទ (គឺជាជើង); បណ្ឌិតគប្បីជ្រាបសេចក្ដីក្នុងពាក្យថា **“ចត្តារោ ឥទ្ធិបាទា** = គឺឥទ្ធិបាទ ៤” នេះ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ដើម្បីនឹងទ្រង់សម្ដែងឥទ្ធិបាទទាំងនោះ ទើបផ្ដើមពាក្យថា **“ឥធ ភិក្ខុ”** ជាដើម ។ បណ្ដាពាក្យទាំងនោះ ពាក្យថា **“ឥធ ភិក្ខុ”** បានដល់ ភិក្ខុក្នុងសាសនានេះ ។ ក្នុងពាក្យថា **“ឆន្ទសមាធិបធានសង្ខារ-**

**សមន្នាគតំ**" នេះ បានដល់ សមាធិ មានឆន្ទៈជាហេតុ មានឆន្ទៈដ៏ក្រៃលែង ឈ្មោះថា **ឆន្ទសមាធិ** ។ ពាក្យថា "**ឆន្ទសមាធិ**" នេះ ជាឈ្មោះរបស់សមាធិដែលបានចំពោះហើយ ព្រោះធ្វើកត្តុកម្យតាឆន្ទៈ ឱ្យជាអធិបតី ។ សង្ខារទាំងឡាយដែលជាប្រធាន ឈ្មោះថា **បធានសង្ខារ** ។ ពាក្យថា "**បធានសង្ខារ**" នេះ ជាឈ្មោះរបស់សេចក្ដីព្យាយាមដែលជាសម្មប្បធាន ដែលញុំាងកិច្ច ៤ យ៉ាង ឱ្យសម្រេច ។ ពាក្យថា "**សមន្នាគតំ**" បានដល់ ចូលទៅដល់ហើយដោយឆន្ទសមាធិ និងបធានសង្ខារទាំងឡាយ ។ ពាក្យថា "**ឥទ្ធិបាទំ**" អធិប្បាយថា កងនៃចិត្ត និងចេតសិកដែលនៅសល់ ឈ្មោះថា **បាទ** ព្រោះអត្ថថា ជាទីតាំងមាំនៃឆន្ទសមាធិ និងបធានសង្ខារទាំងឡាយសម្បយុត្តដោយកុសលចិត្ត មានឧបចារ និងឈានជាដើម ដែលដល់នូវការរាប់ថា **ឥទ្ធិ** ដោយបរិយាយនៃការសម្រេច គឺដោយអត្ថនៃសេចក្ដីសម្រេច (អត្ថទីមួយ) ឬថា ដោយបរិយាយ (គឺអត្ថទី ២) នេះថា "សត្វទាំងឡាយដែលសម្រេច ដែលចម្រើន រមែងសម្រេច រមែងដល់នូវភាពជាអ្នកប្រសើរដោយសភាវៈនេះ" ។ ពិតមែន ពាក្យថា "**ឥទ្ធិបាទោ**" ខាងមុខ ដែលលោកពោលថា វេទនាខន្ធ ។ ល ។ វិញ្ញាណក្ខន្ធ របស់បុគ្គលអ្នកសម្រេចដោយអាការនោះ យ៉ាងណា, ពាក្យនោះ រមែងត្រឹមត្រូវដោយអត្ថនេះ; សូម្បីក្នុងពាក្យដែលនៅសល់ទាំងឡាយ ក៏គប្បីជ្រាបសេចក្ដីដោយន័យនេះ ។ បណ្ឌិតគប្បីជ្រាបសេចក្ដីដែលលោកពោលថា "ដូចយ៉ាងថា សមាធិដែលបានចំពោះហើយ ព្រោះធ្វើឆន្ទៈឱ្យជាអធិបតី ឈ្មោះថា **ឆន្ទសមាធិ** យ៉ាងណានោះឯង, សមាធិដែលបានពោលហើយ ព្រោះធ្វើវីរិយៈ ចិត្ត និងវីមង្សា ឱ្យជាអធិបតី ក៏លោកហៅថា វីរិយសមាធិ ចិត្ត

សមាធិ និងវីមង្សាសមាធិដូច្នោះដែរ ។

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ ដើម្បីនឹងទ្រង់សម្តែងបទទាំងឡាយមានឆន្ទសមាធិជាដើម ទើបផ្តើមពាក្យថា **“ភជពា្ញ ភិក្ខុ”** ជាដើម ។ បណ្តាពាក្យទាំងនោះ ពាក្យថា **“ឆន្ទញ្ចេ ភិក្ខុ អធិបតឹ ករិត្វា”** សេចក្តីថា បើភិក្ខុធ្វើឆន្ទៈឱ្យជាអធិបតី ធ្វើឆន្ទៈឱ្យចម្រើន ធ្វើឆន្ទៈឱ្យជាធុរៈ ធ្វើឆន្ទៈឱ្យជាប្រធាន ហើយបានចំពោះនូវសមាធិ គឺរមែងឱ្យសមាធិកើតឡើង, អធិប្បាយថា សមាធិនេះ ដែលកើតឡើងហើយយ៉ាងនេះ លោកហៅថា ឆន្ទសមាធិ ។ សូម្បីក្នុងពាក្យទាំងឡាយ មានពាក្យថា **“វីរិយញ្ចេ** = បើភិក្ខុធ្វើសេចក្តីព្យាយាម” ជាដើម ក៏ន័យនេះដែរ ។

វីរិយៈដែលញ៉ាំងកិច្ច ៤ ឱ្យសម្រេច ពោលគឺបធានសង្ខារ របស់ភិក្ខុដែលចម្រើននូវឥទ្ធិបាទ លោកពោលហើយដោយពាក្យមានប្រមាណប៉ុណ្ណេះថា **“ឥមេ វុច្ចន្តិ បធានសង្ខារា** = សភាវធម៌ទាំងនេះ ហៅថា បធានសង្ខារ” ។ ពាក្យថា **“តទេកជ្ឈំ អភិសញ្ញូហិត្វា** = ប្រមូលសង្ខេប ២ យ៉ាង ចូលជាមួយគ្នា” អធិ-ប្បាយថា ធ្វើសភាវៈសូម្បីទាំងអស់នោះ ឱ្យជាគំនរជាមួយគ្នា ។ ពាក្យថា **“សង្ខ្យំ គច្ឆតិ”** អធិប្បាយថា ឆន្ទសមាធិបធានសង្ខារនេះ បណ្ឌិតគប្បីជ្រាបថា រមែងដល់វោហារតែមួយជាមួយគ្នា ដោយប្រការដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់ចែកសម្តែងធម៌ មានឆន្ទៈជាដើម ដែលប្រជុំចុះក្នុងបទថា **ឆន្ទសមាធិបធានសង្ខារ** នេះ ទើបផ្តើមពាក្យថា **“តត្ថ កតមោ ឆន្ទោ”** ជាដើម ។ ពាក្យនោះ មានអត្ថងាយស្រួលទាំងអស់ទេ ។

ពាក្យថា **“ឧបេតោ ហោតិ”** គឺគំនរនៃធម៌ ពោលគឺឥទ្ធិបាទជាសភាវៈ

ដែលចូលទៅដល់ហើយ ។ ពាក្យថា **"តេសំ ធម្មានំ"** គឺធម៌ដែលមានឆន្ទៈជាដើម ដែលសម្បយុត្តដោយបធានសង្ខារទាំងនោះ ។

ពាក្យទាំងពួង មានពាក្យថា **"ឥទ្ធិ សមិទ្ធិ"** ជាដើម ជាពាក្យវេវចនៈរបស់និប្ផត្តិ (ការសម្រេចអត្ថដំបូង) ទាំងនោះ ។ កាលបើមានហេតុយ៉ាងនេះ ទើបលោកហៅថា **"ឥទ្ធិ"** ព្រោះអត្ថថា ការសម្រេច ។ ឥទ្ធិដែលសម្បូណ៌ហើយ លោកហៅថា **"សមិទ្ធិ"** ; ម្យ៉ាងទៀត បទថា **"សមិទ្ធិ"** នេះ ជាបទដែលចម្រើនហើយដោយឧបសគ្គ ។ អាការនៃការសម្រេច លោកហៅថា **"ឥជ្ឈនា** = សេចក្ដីសម្រេច" ។ បទថា **"សមិជ្ឈនា"** ជាបទដែលសម្រេចដោយឧបសគ្គ ។ ការបានដោយអំណាចនៃការប្រាកដក្នុងសន្ដានរបស់ខ្លួន លោកហៅថា **"លាភ"** ។ សូម្បីការបាននូវធម៌ដែលសាបសូន្យទៅ ដោយអំណាចនៃការផ្ដើមសេចក្ដីព្យាយាមទៀត លោកហៅថា **"បដិលាភោ** = ការបាន" ទៀត ។ ម្យ៉ាងទៀត បទថា "បដិលាភ" នេះ ជាបទដែលចម្រើនឡើងដោយឧបសគ្គ ។ បទថា **"បត្តិ** = ការដល់" គឺការសម្រេច ។ ការសម្រេចដោយល្អ ដោយអំណាចនៃការមិនសាបសូន្យទៅ, ព្រោះហេតុដូច្នោះ ទើបលោកហៅថា **"សម្បត្តិ** = ការដល់ដោយល្អ" ។ ពាក្យថា **"ផុស្សនា** = ការពាល់ត្រូវ" គឺការពាល់ត្រូវដោយអំណាចនៃការបានទៀត (បដិលាភផុស្សនា) ។ ពាក្យថា **"សច្ឆិកិរិយា"** គឺការធ្វើឱ្យជាក់ច្បាស់ ដោយបដិលាភនោះឯង ។ ពាក្យថា **"ឧបសម្បទា** = ការចូលដល់" បណ្ឌិតគប្បីជ្រាបថា ការចូលដល់ដោយបដិលាភដូចគ្នា ។ ពាក្យថា **"តថាភូតស្ស"** បានដល់ របស់បុគ្គលអ្នកប្រាកដហើយ ដោយអាការៈនោះ, អធិប្បាយថា បុគ្គលអ្នកបានចំពោះហើយនូវធម៌

មានឆន្ទៈជាដើមនោះ ហើយតាំងនៅ ។ សូម្បីខន្ធទាំង ៤ ព្រះភគវាត្រាស់ដោយពាក្យថា **“វេទនាខន្ធោ”** ជាដើម ដោយការធ្វើឆន្ទៈជាដើម ទុកខាងក្នុង ។ ពាក្យថា **“តេ ធម្មេ”** បានដល់ អរូបក្ខន្ធទាំង ៤ នោះ, ម្យ៉ាងទៀត ពាក្យនេះលោកពោលថា ធម៌ទាំង ៣ (គឺឆន្ទៈ សមាធិ និងបធានសង្ខារ) មានឆន្ទៈជាដើម ។ ពាក្យថា **“អាសេវតិ”** ជាដើម មានអត្ថតាមដែលខ្ញុំពោលហើយនោះឯង ។ សូម្បីក្នុងនិទ្ទេសនៃឥទ្ធិបាទដែលនៅសល់ បណ្ឌិតគប្បីជ្រាបសេចក្ដីដោយន័យនេះដូចគ្នា ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ លោកពោលទុកយ៉ាងណា ? គប្បីជ្រាបដូចតទៅនេះ ៖

## កម្មដ្ឋានដែលដល់ទីបំផុតរបស់ភិក្ខុ ៤ ពួក

លោកពោលកម្មដ្ឋានរបស់ភិក្ខុ ៤ ពួក ដែលដល់ទីបំផុត គឺភិក្ខុពួក ១ អាស្រ័យឆន្ទៈ,កាលមានសេចក្ដីត្រូវការដោយឆន្ទៈក្នុងកុសលធម៌របស់អ្នកប្រាថ្នាដើម្បីនឹងធ្វើ, លោកក៏ធ្វើឆន្ទៈឱ្យជាធំ ធ្វើឆន្ទៈឱ្យជាធុរៈ ធ្វើឆន្ទៈឱ្យជាប្រធាន ដោយការគិតថា “យើងនឹងញ៉ាំងលោកុត្តរធម៌ឱ្យកើត, ភាពធ្ងន់ចិត្តរបស់យើងដោយការកើតឡើងនៃឆន្ទៈនេះមិនមាន” ដូច្នេះ ហើយទើបញ៉ាំងលោកុត្តរធម៌ឱ្យកើតឡើង ។ ភិក្ខុមួយពួកទៀត អាស្រ័យវីរិយៈ, ភិក្ខុមួយពួកផ្សេងទៀត អាស្រ័យចិត្ត, ភិក្ខុមួយពួកដទៃទៀត អាស្រ័យបញ្ញា នៅពេលដែលមានសេចក្ដីត្រូវការដោយបញ្ញា លោកក៏នឹងធ្វើបញ្ញាឱ្យជាធំ ធ្វើបញ្ញាឱ្យជាធុរៈ ធ្វើបញ្ញាឱ្យជាប្រធាន ដោយការគិតថា “យើងនឹងញ៉ាំងលោកុត្តរធម៌ឱ្យកើតឡើង, ភាពធ្ងន់ចិត្តរបស់យើងដោយការកើតឡើងនៃបញ្ញានេះមិនមាន” ដូច្នេះ ហើយទើបញ៉ាំងលោកុត្តរធម៌ឱ្យកើតឡើង ។

តើដូចម្ដេច ?

ដូចយ៉ាងថា បុត្ររបស់អាមាត្យ ៤ នាក់ ប្រាថ្នាឋានន្តរៈហើយត្រាច់ទៅ ម្នាក់អាស្រ័យការបម្រុង, ម្នាក់ទៀត អាស្រ័យសេចក្ដីក្លាហាន, ម្នាក់ផ្សេងទៀត អាស្រ័យជាតិ, ម្នាក់ដទៃទៀត អាស្រ័យការដឹង ( មន្ត ) ។ គឺយ៉ាងណា ? គឺថា ក្នុងបុត្រអាមាត្យទាំងនោះ មនុស្សទីមួយ ពេលមានសេចក្ដីត្រូវការដោយឋានន្តរៈ ទើបគិតថា "យើងនឹងបានឋានន្តរៈនោះ" ដូច្នេះ ហើយអាស្រ័យការបម្រុង ព្រោះភាវៈនៃខ្លួនជាអ្នកមានប្រក្រតីធ្វើសេចក្ដីមិនប្រមាទក្នុងការបម្រុង ។ មនុស្សទី ២ សូម្បីមានសេចក្ដីមិនប្រមាទក្នុងការបម្រុងហើយ នៅគិតថា "មនុស្សខ្លះ ពេលសង្គ្រាមកើតឡើង រមែងមិនអាចដើម្បីតាំងមាំ, ក៏ទីកន្លែងជាយដែនរបស់ព្រះរាជា នឹងកម្រើកពិត; ពេលជាយដែនកម្រើកហើយ យើងនឹងធ្វើការងារក្នុងនាទីនៃរថ ( អ្នកបើករថ ) និងឱ្យព្រះរាជាពេញព្រះទ័យហើយ ក៏នឹងនាំមកឱ្យនូវឋានន្តរៈនោះ" ឈ្មោះថា អាស្រ័យហើយនូវភាពជាអ្នកក្លាហាន ។ មនុស្សទី ៣ សូម្បីមានភាពជាអ្នកក្លាហាន ក៏គិតថា "មនុស្សខ្លះ ជាអ្នកមានជាតិទាប, ជនទាំងឡាយ ពេលឱ្យឋានន្តរៈ គេនឹងឱ្យដល់យើង ព្រោះជម្រះជាតិហើយ" ឈ្មោះថា អាស្រ័យហើយនូវជាតិ ។ មនុស្សទី ៤ សូម្បីមានជាតិ ក៏គិតថា "មនុស្សខ្លះ មិនមានមន្ត ( ការដឹង ), ពេលការងារដែលគប្បីធ្វើដោយមន្ត ( ការដឹង ) កើតឡើងហើយ យើងដែលមានមន្ត នឹងឱ្យព្រះរាជានាំមកនូវឋានន្តរៈនោះ" ទើបឈ្មោះថា អាស្រ័យហើយនូវមន្ត ។ បុត្រអាមាត្យទាំងអស់នោះដល់ហើយ នូវឋានន្តរៈដោយកម្លាំងនៃភាវៈ ដែលជាទីអាស្រ័យ ( ដោយសេចក្ដីអង់អាច ) របស់ខ្លួនៗ ។

ក្នុងភិក្ខុទាំងនោះ ភិក្ខុដែលអាស្រ័យឆន្ទៈ ពេលមានសេចក្ដីត្រូវការដោយកុសលធម៌ ឆន្ទៈរបស់អ្នកប្រាថ្នាដើម្បីនឹងធ្វើមាន លោកទើបធ្វើឆន្ទៈឱ្យជាធំ ធ្វើឆន្ទៈឱ្យជាធុរៈ ធ្វើឆន្ទៈឱ្យជាប្រធាន ដោយគិតថា "កាលបើការកើតឡើងនៃអត្ថមាន យើងនឹងញ៉ាំងលោកុត្តរធម៌ឱ្យកើតឡើង, ភាពធ្ងន់ចិត្តដោយការកើតឡើងនៃឆន្ទៈរបស់យើងមិនមាន" ហើយទើបញ៉ាំងលោកុត្តរធម៌ ឱ្យកើតឡើង បណ្ឌិតគប្បីជ្រាបដូចបុត្រអាមាត្យ ដែលមិនប្រមាទក្នុងការបម្រុងហើយទើបបានឋានន្តរៈ ដូចព្រះរដ្ឋបាលត្ថេរ; ពិតមែន ព្រះរដ្ឋបាលត្ថេរមានអាយុនោះ ធ្វើឆន្ទៈឱ្យជាធុរៈ ហើយញ៉ាំងលោកុត្តរធម៌ឱ្យកើតឡើង ។

ភិក្ខុដែលធ្វើវីរិយៈឱ្យជាធំ ធ្វើវីរិយៈឱ្យជាធុរៈ ធ្វើវីរិយៈឱ្យជាប្រធាន ហើយញ៉ាំងលោកុត្តរធម៌ឱ្យកើតឡើង, បណ្ឌិតគប្បីជ្រាបដូចជាបុត្រអាមាត្យ ដែលញ៉ាំងព្រះរាជាឱ្យពេញព្រះទ័យ ដោយភាពជាអ្នកក្លាហានហើយបានឋានន្តរៈ ដូចព្រះសោណត្ថេរ; ពិតមែន ព្រះសោណត្ថេរមានអាយុនោះ ធ្វើវីរិយៈឱ្យជាធុរៈហើយ ញ៉ាំងលោកុត្តរឱ្យកើតឡើង ។

ភិក្ខុដែលធ្វើចិត្តឱ្យជាធំ ធ្វើចិត្តឱ្យជាធុរៈ ធ្វើចិត្តឱ្យជាប្រធាន ហើយ ញ៉ាំងលោកុត្តរធម៌ឱ្យកើតឡើង, បណ្ឌិតគប្បីជ្រាបដូចបុត្រអាមាត្យដែលបានឋានន្តរៈ ព្រោះការដល់ដោយល្អនៃជាតិ ដូចព្រះសម្ភូតត្ថេរ; ពិតមែន ព្រះសម្ភូតត្ថេរមានអាយុនោះ ធ្វើចិត្តឱ្យជាធុរៈ ហើយញ៉ាំងលោកុត្តរធម៌ឱ្យកើតឡើង ។

ភិក្ខុដែលធ្វើវីមង្សា ឱ្យជាធំ ធ្វើវីមង្សាឱ្យជាធុរៈ ធ្វើវីមង្សាឱ្យជាប្រធាន ហើយញ៉ាំងលោកុត្តរធម៌ឱ្យកើតឡើង បណ្ឌិតគប្បីជ្រាបដូចបុត្រអាមាត្យដែលបានឋានន្តរៈ ព្រោះអាស្រ័យមន្ត ដូចព្រះមោឃរាជត្ថេរ; ពិតមែន

ព្រះមោឃរាជត្ថេរ មានអាយុនោះ ធ្វើវីមង្សាឱ្យជាធុរៈ ហើយញុំាងលោកុត្តរធម៌ឱ្យកើតឡើង ។

មួយទៀត ក្នុងអធិការនេះ ធម៌ទាំង ៣ ពោលគឺឆន្ទសមាធិ និងបធានសង្ខារ ជាឥទ្ធិផង ជាឥទ្ធិបាទផង, ចំណែកខន្ធ ៤ ដែលសម្បយុត្តគ្នាដ៏សេស ជាឥទ្ធិប៉ុណ្ណោះ ។ សូម្បីធម៌ទាំង ៣ (យ៉ាងនីមួយៗ) ពោលគឺវីរិយៈ ១ ចិត្ត ១ វីមង្សា ១ សមាធិ និងបធានសង្ខារ ជាឥទ្ធិផង ជាឥទ្ធិបាទផង, ចំណែកខន្ធ ៤ ដែលសម្បយុត្តគ្នាដ៏សេស ជាឥទ្ធិបាទប៉ុណ្ណោះ ។ នេះជាកថាពោលអំពីភាពមិនប្លែកគ្នា ជាមុនសិន ។

មួយវិញទៀត កាលពោលអំពីសេចក្តីប្លែកគ្នា ឆន្ទៈ ឈ្មោះថា **ឥទ្ធិ**, នាមក្ខន្ធ ៤ ដែលអប់រំហើយដោយឆន្ទធុរៈ ឈ្មោះថា **ឆន្ទិទ្ធិបាទ** ។ ធម៌ទាំង ២ គឺ សមាធិ និងបធានសង្ខារ រមែងសង្គ្រោះចូលក្នុងឆន្ទិទ្ធិបាទ ដោយអំណាចនៃសង្ខារក្ខន្ធ ។ សូម្បីនឹងពោលថា "ធម៌ទាំងនោះសង្គ្រោះចូលហើយក្នុងបាទ" ដូច្នេះ ក៏គួរដូចគ្នា; ក្នុងធម៌ទាំងនោះឯង សមាធិ ឈ្មោះថា **ឥទ្ធិ**, ខន្ធ ៤ ដែលអប់រំហើយដោយសមាធិធុរៈ ឈ្មោះថា **សមាធិទ្ធិបាទ** ។ ធម៌ទាំង ២ គឺ ឆន្ទៈ និងបធានសង្ខារ រមែងសង្គ្រោះចូលក្នុងសមាធិទ្ធិបាទ ដោយអំណាចនៃសង្ខារក្ខន្ធ ។ សូម្បីនឹងពោលថា "ធម៌ទាំង ២ នោះ សង្គ្រោះចូលហើយក្នុងបាទ" ដូច្នេះ ក៏គួរដូចគ្នា ។ ក្នុងធម៌នោះឯង បធានសង្ខារ ឈ្មោះថា **ឥទ្ធិ**, ខន្ធ ៤ ដែលអប់រំហើយ ដោយបធានសង្ខារ ឈ្មោះថា **បធានសង្ខារិទ្ធិបាទ** ។ ធម៌ទាំង ២ គឺ ឆន្ទៈ និងសមាធិ រមែងសង្គ្រោះចូលក្នុងបធានសង្ខារិទ្ធិបាទ ដោយអំណាចនៃសង្ខារក្ខន្ធ ។ សូម្បីនឹងពោលថា "ធម៌ទាំង ២ នោះ សង្គ្រោះចូលហើយក្នុងបាទ" ដូច្នេះ ក៏គួរដូចគ្នា ។ ក្នុងធម៌នោះនុ៎ះឯង

**វីរិយៈ** ឈ្មោះថា **ឥទ្ធិ**, **ចិត្ត** ឈ្មោះថា **ឥទ្ធិ**, **វីមង្សា** ឈ្មោះថា **ឥទ្ធិ** ។ល ។ សូម្បី នឹងពោលថា "ធម៌ទាំង ២ នោះ សង្គ្រោះចូលហើយក្នុងបាទ" ដូច្នេះ ក៏គួរដូចគ្នា; នេះជាឈ្មោះកថាដោយសេចក្ដីផ្សេងគ្នា ។

ក្នុងអធិការដែលលោកបានពោលហើយនេះ មិនមែនជាពាក្យថ្មីទេ, ជាពាក្យដែលលោកធ្វើអធិប្បាយទុកជាក់ច្បាស់ហើយ ក៏កាន់យកតែម្ដង ។ គឺយ៉ាងណា ? គឺថា ធម៌ ៣ យ៉ាងនេះ គឺ ឆន្ទៈ សមាធិ និងបធានសង្ខារ ជាឥទ្ធិក៏បាន, ជាឥទ្ធិបាទក៏បាន, ចំណែកខន្ធ ៤ ដែលសម្បយុត្តគ្នាដ៏សេស ត្រឹមតែឥទ្ធិបាទប៉ុណ្ណោះ ។ ពិតមែន ធម៌ទាំង ៣ នេះ ពេលសម្រេច រមែងសម្រេចព្រមគ្នាជាមួយខន្ធ ៤ ដែលសម្បយុត្តគ្នានោះឯង, វៀរចាកខន្ធ ៤ ដែលសម្បយុត្តគ្នាហើយមិនសម្រេចបានទេ ។ មួយទៀត ខន្ធ ៤ ដែលសម្បយុត្តគ្នា ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា សម្រេច, ឈ្មោះថា **ជាបាទ** ព្រោះអត្ថថា ជាទីអាស្រ័យ ។ ពាក្យថា **ឥទ្ធិ** ឬថា **ឥទ្ធិបាទ** មិនមែនជាឈ្មោះរបស់ធម៌អ្វីៗ យ៉ាងដទៃទេ, គឺជាឈ្មោះរបស់ខន្ធ ៤ ដែលសម្បយុត្តគ្នានោះឯង ។ ធម៌ទាំង ៣ គឺ វីរិយៈ ចិត្ត និងវីមង្សាសមាធិបធានសង្ខារ ។ ល ។ ក៏ជាឈ្មោះរបស់ខន្ធ ៤ ប៉ុណ្ណោះដូចគ្នា ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបថា បុព្វភាគ ឈ្មោះថា **ឥទ្ធិបាទ** ដែលជាបុព្វភាគបដិលាភ ឈ្មោះថា ឥទ្ធិដែលជាបដិលាភ ។ គប្បីសម្ដែងសេចក្ដីនេះ ដោយឧបចារៈ ឬវិបស្សនា ។ ពិតមែន បរិកម្មរបស់បឋមជ្ឈាន ឈ្មោះថា **ឥទ្ធិបាទ**, បឋមជ្ឈាន ឈ្មោះថា ឥទ្ធិ ។

បរិកម្មនៃទុតិយៈ តតិយៈ ចតុត្ថៈ អាកាសានញ្ចាយតនៈ វិញ្ញាណញ្ចា-យតនៈ អាកិញ្ចញ្ញាយតនៈ និងនេវសញ្ញានាសញ្ញាយតនៈ ឈ្មោះថា **ឥទ្ធិបាទ**, នេវសញ្ញានាសញ្ញាយតនៈ ឈ្មោះថា **ឥទ្ធិ** ។ វិបស្សនានៃសោតាបត្តិមគ្គ ឈ្មោះថា **ឥទ្ធិបាទ**, សោតាបត្តិមគ្គ ឈ្មោះថា **ឥទ្ធិ** ។

វិបស្សនានៃសកទាគាមិមគ្គ អនាគាមិមគ្គ និងអរហត្តមគ្គ ឈ្មោះថា **ឥទ្ធិ-បាទ**, អរហត្តមគ្គ ឈ្មោះថា **ឥទ្ធិ** ។ ការសម្តែងសូម្បីដោយបដិលាភ ក៏គួរដូចគ្នា ។ ពិតមែន បឋមជ្ឈាន ឈ្មោះថា **ឥទ្ធិបាទ**, ទុតិយជ្ឈាន ឈ្មោះថា **ឥទ្ធិបាទ** ។

ទុតិយជ្ឈាន ឈ្មោះថា **ឥទ្ធិបាទ**, តតិយជ្ឈាន ឈ្មោះថា **ឥទ្ធិ** ។ល ។ អនា-គាមិមគ្គ ឈ្មោះថា **ឥទ្ធិបាទ**, អរហត្តមគ្គ ឈ្មោះថា **ឥទ្ធិ** ។

**សួរថា** ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា ដូចម្តេច ? ឈ្មោះថា **បាទ** ព្រោះ អត្ថថា ដូចម្តេច ? ឆ្លើយថា ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា ជាទីសម្រេចនោះឯង, ឈ្មោះថា **បាទ** ព្រោះអត្ថថា ជាទីអាស្រ័យនោះឯង ។ ដោយប្រការដូច្នេះ ពាក្យ ថា **ឥទ្ធិ** ឬ **ឥទ្ធិបាទ** សូម្បីក្នុងទីនេះ ទើបមិនមែនជាឈ្មោះរបស់ធម៌អ្វីដទៃ, តែ ជាឈ្មោះរបស់ខន្ធ ៤ ដែលសម្បយុត្តគ្នានោះឯង ។ ក៏កាលខ្ញុំពោលហើយយ៉ាងនេះ ទើបអាចារ្យទាំងឡាយពោលពាក្យនេះថា ៖

បើថា ពាក្យនេះគប្បីជាឈ្មោះរបស់ខន្ធ ៤ នោះឯងសោត, ព្រះសាស្តាក៏ មិនទ្រង់នាំឈ្មោះឧត្តរចូឡភាជនិយមកទុកខាងមុខ; ក៏ក្នុងឧត្តរចូឡភាជនិយ ព្រះ

មានព្រះភាគត្រាស់ថា "ឆន្ទៈប៉ុណ្ណោះ ឈ្មោះថា **ឆន្ទិទ្ធិបាទ**, វិរិយៈប៉ុណ្ណោះ, ចិត្ត ប៉ុណ្ណោះ, វីមង្សាប៉ុណ្ណោះ ឈ្មោះថា **វីមង្សិទ្ធិបាទ**" ។ ចំណែកអាចារ្យពួកខ្លះ ពោលថា "សភាវៈដែលនៅមិនទាន់សម្រេចហើយ ឈ្មោះថា **ឥទ្ធិ**, សភាវៈដែល សម្រេចហើយ ឈ្មោះថា **ឥទ្ធិបាទ**" ។ ខ្ញុំបដិសេធពាក្យរបស់អាចារ្យនោះហើយ ទើបធ្វើពាក្យសន្និដ្ឋានថា "ឥទ្ធិក្តី ឥទ្ធិបាទក្តី ជាសភាវៈដែលពាល់ត្រូវហើយ ដោយ ត្រៃលក្ខណ៍" ; ក្នុងសុត្តន្តភាជនិយនេះ ព្រះមានព្រះភាគត្រាស់ឥទ្ធិបាទទាំងឡាយ លាយដោយលោកិយ និងលោកុត្តរ ដូចពណ៌នាមកដូច្នេះឯង ៕

**ពណ៌នាអំពីសុត្តន្តភាជនិយចប់**

## ២. ពណ៌នាអំពីអភិធម្មភាជនិយ

ក្នុងអភិធម្មភាជនិយ មានអត្ថងាយស្រួលទាំងអស់ ។ ក៏បណ្ឌិតគប្បីរាប់ ចំនួនក្នុងអភិធម្មភាជនិយនេះថា ពិតមែន ក្នុងឋានៈដែលព្រះមានព្រះភាគជាម្ចាស់ ត្រាស់ហើយថា "ភិក្ខុក្នុងធម្មវិន័យនេះ ចម្រើនឥទ្ធិបាទដែលប្រកបដោយឆន្ទ-សមាធិបធានសង្ខារ" , ចំណែកលោកុត្តរចែកទុក ៤.០០០ ន័យ; សូម្បីក្នុងវិរិយៈ និងសមាធិជាដើម ក៏ន័យនេះដែរ ។ ដោយទំនងនោះ ក្នុងឧត្តរចូឡភាជនិយ ទើប លោកចែកឥទ្ធិបាទ សូម្បីទាំងអស់ទុក ៣២.០០០ ន័យ ដោយអំណាចនៃធម៌ដែល ជាពួក ៤ ពួកនីមួយៗ ៨ ន័យ គឺ ក្នុងឆន្ទិទ្ធិបាទ ៤.០០០ ន័យ, ក្នុងវិរិយៈ ចិត្ត

និងវិមង្សា យ៉ាងនីមួយៗ ៤.០០០ ន័យ (៤ x ៨ = ៣២) ។ បណ្ឌិតគប្បីជ្រាបពាក្យនេះថា លោកពោលហើយក្នុងអភិធម្មភាជនិយ ដែលប្រដាប់ចំពោះហើយដោយន័យ ៣២. ០០០ ន័យ ដោយអំណាចនៃឥទ្ធិបាទទាំងឡាយ ដែលជាលោកុត្តរដែលបង្កើតហើយនេះឯង ដូចពណ៌នាមកដូច្នេះ ៕

**ពណ៌នាអំពីអភិធម្មភាជនិយចប់**

## ៣.ពណ៌នាអំពីបញ្ហាបុច្ឆកៈ

ក្នុងបញ្ហាបុច្ឆកៈ បណ្ឌិតគប្បីជ្រាបសេចក្ដីដែលឥទ្ធិបាទទាំងឡាយជាកុសលជាដើម ដោយទំនងនៃព្រះបាលីនោះឯង ។ តែក្នុងអារម្មណត្តិកៈទាំងឡាយ សូម្បីឥទ្ធិបាទទាំងអស់នេះ ជាអប្បមាណារម្មណ៍ប៉ុណ្ណោះ, ព្រោះប្រារព្ធព្រះនិព្វានដែលជាអប្បមាណធម៌ហើយប្រព្រឹត្តទៅ, មិនជាមគ្គារម្មណ៍ ។ តែជាមគ្គហេតុកៈ ដោយអំណាចនៃសហជាតហេតុ, មិនជាមគ្គាធិបតី ។ ព្រោះថា អធិបតី ៤ រមែងមិនធ្វើនូវគ្នានឹងគ្នាឱ្យជាធំ ។ *សួរថា* ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះសេចក្ដីដែលខ្លួនឯងធំជាទីបំផុត ។

ដូចយ៉ាងថា ព្រះរាជបុត្រ ៤ អង្គ អ្នកមានជាតិស្មើគ្នា មានវ័យស្មើគ្នា មានកម្លាំងស្មើគ្នា មានសិប្បៈស្មើគ្នា រមែងមិនឱ្យភាពជាធំដល់គ្នានឹងគ្នា ព្រោះភាវៈនៃព្រះរាជបុត្រទាំង ៤ អង្គ ជាអ្នកខ្ពស់បំផុតយ៉ាងណា, សូម្បីអធិបតីទាំង ៤ នេះ

ក៏ដូច្នោះដែរ រមែងមិនធ្វើនូវគ្នានឹងគ្នាឱ្យជាធំ ព្រោះសភាវៈនៃធម៌ទាំងនោះ តែមួយកង១ ក៏ជាធំក្នុងទីបំផុតដូចគ្នា ព្រោះហេតុដូច្នោះ អធិបតីទាំងនោះ ទើបមិនជាមគ្គាធិបតី ដោយចំណែកតែមួយប៉ុណ្ណោះ ។ ក្នុងអតីតៈជាដើម ក៏មិនគប្បីពោលសូម្បីក្នុងភាពជាឯការម្មណ៍, ក៏អធិបតីទាំងនោះ ឈ្មោះថា ពហិទ្ធារម្មណ៍ ព្រោះសភាវៈនៃព្រះនិព្វានជាធម៌ខាងក្រៅដូច្នេះឯង ។ ក្នុងបញ្ហាបុច្ឆកៈនេះ លោកពោលថា ឥទ្ធិបាទទាំងឡាយដែលជាលោកុត្តរកើតឡើងហើយតែម្យ៉ាង ។ ពិតមែន ព្រះមានព្រះភាគត្រាស់ឥទ្ធិបាទទាំងឡាយ ដែលជាលោកិយ និងលោកុត្តរលាយគ្នា ទុកក្នុងសុត្តន្តភាជនិយនោះឯង, តែក្នុងអភិធម្មភាជនិយ និងបញ្ហាបុច្ឆកៈ ត្រាស់ថាជាលោកុត្តរតែម្យ៉ាង ។ សូម្បីឥទ្ធិបាទវិភង្គនេះ ព្រះមានព្រះភាគ ក៏ទ្រង់នាំចេញមកចែកសម្តែងហើយ ៣ បរិវដ្តយ៉ាងនេះ ដោយប្រការដូច្នេះឯង ។

ពណ៌នាអំពីបញ្ហាបុច្ឆកៈចប់

**ចប់អដ្ឋកថាឥទ្ធិបាទវិភង្គ**

# ១០. អដ្ឋកថាពោជ្ឈង្គវិភង្គ

## ១. ពណ៌នាអំពីសុត្តន្តភាជនិយ

## ពោជ្ឈង្គ ៧ ន័យទី ១

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងពោជ្ឈង្គវិភង្គ ដែលជាលំដាប់តអំពីឥទ្ធិបាទ-វិភង្គនោះតទៅ ៖

ពាក្យថា **“៧”** ជាពាក្យកំណត់ចំនួន ។

ពាក្យថា **“ពោជ្ឈង្គ”** មានវិគ្រោះថា ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា ជាអង្គនៃបញ្ញា ជាគុណជាតិជាគ្រឿងត្រាស់ដឹង, ឬជាអង្គនៃព្រះសាវ័កអ្នកត្រាស់ដឹង ។ លោកអធិប្បាយពាក្យនេះទុកថា ៖

ធម៌សាមគ្គីឯណា ដែលព្រះមានព្រះភាគត្រាស់ហៅថា **ពោធិ** ព្រោះធ្វើពាក្យអធិប្បាយថា ព្រះអរិយសាវ័ករមែងត្រាស់ដឹង ដោយធម៌សាមគ្គី ពោលគឺសតិ ធម្ម-វិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិ និងឧបេក្ខា ដែលកើតឡើងក្នុងខណៈនៃលោកុត្តរ-មគ្គយ៉ាងណា ដែលបដិបក្សចំពោះឧបទ្ទវៈ (អន្តរាយ) មិនមែនតិច មានការរួញរារវើរវាយ ការតាំងនៅនៃទុក្ខ ការកពូន (ប្រមូលមកនូវទុក្ខ) ដែលមានការប្រកាន់មាំក្នុងកាមសុខ អត្តកិលមថានុយោគ ឧច្ឆេទទិដ្ឋិ និងសស្សតទិដ្ឋិជាដើម ។

ពាក្យថា **រមែងត្រាស់ដឹង** គឺធម៌សាមគ្គីនោះ រមែងតាំងឡើងដើម្បីទម្លាយការបន្តនៃកិលេស ។ម្យ៉ាងទៀត ពាក្យថា **“រមែងត្រាស់ដឹង”** បានដល់ រមែងចាក់ធ្លុះសច្ចៈទាំង ៤, ម្យ៉ាងវិញទៀត... បានដល់ រមែងធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាននោះឯង ។ ក៏ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា ជាអង្គនៃបញ្ញាជាគ្រឿងត្រាស់ដឹងពោលគឺធម៌សាមគ្គីនោះ ដូចអង្គឈាន និងអង្គនៃមគ្គជាដើម ក៏បាន ។

ព្រះអរិយសាវ័កនេះឯង លោកហៅថា **ពោធិ** ព្រោះធ្វើអធិប្បាយថា រមែងត្រាស់ដឹងដោយធម៌សាមគ្គី មានប្រការតាមដែលពោលមកនោះ ។ សូម្បីព្រោះអត្ថថា ជាអង្គនៃព្រះអរិយសាវ័កអ្នកត្រាស់ដឹង ក៏ឈ្មោះថា **ពោជ្ឈង្គ** ដូចអង្គនៃសេនា អង្គនៃរថជាដើម ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា “ឬឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា ជាអង្គរបស់បុគ្គលអ្នកត្រាស់ដឹងយ៉ាងនេះនោះឯង” ។

ម្យ៉ាងទៀត បទថា **“ពោជ្ឈង្គទាំងឡាយ”** បានដល់ ក៏ឈ្មោះថា **ពោជ្ឈង្គ ព្រោះអត្ថថា ដូចម្តេច ?** ពាក្យនេះបណ្ឌិតគប្បីជ្រាបអត្ថនៃពោជ្ឈង្គ ដោយន័យរបស់បដិសម្ភិទាមគ្គនេះថា “ក៏ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា រមែងប្រព្រឹត្តទៅព្រមដើម្បីការត្រាស់ដឹង, ក៏ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា រមែងត្រាស់ដឹង, ក៏ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា រមែងដឹងតាម, ក៏ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា រមែងដឹងចំពោះ, ក៏ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា រមែងដឹងព្រម”[១] ដូច្នេះក៏បាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សតិពោជ្ឈង្គ** ជាដើម ។ ពោជ្ឈង្គដែលបណ្ឌិតសរសើរហើយផង ដែលល្អផង ឈ្មោះថា **សម្ពោជ្ឈង្គ**, សម្ពោជ្ឈង្គ គឺសតិនេះឯង ឈ្មោះថា **សតិសម្ពោជ្ឈង្គ**, (ពោជ្ឈង្គដែលនៅសល់ក៏ដូចគ្នា) ។ បណ្តាសម្ពោជ្ឈង្គទាំងនោះ **សតិសម្ពោជ្ឈង្គ** មានការតាំងមាំ (ឧបដ្ឋាន) ជាលក្ខណៈ, **ធម្មវិចយសម្ពោជ្ឈង្គ** មានការស្រាវជ្រាវពិចារណា (បវិចយៈ) ជាលក្ខណៈ, **វីរិយសម្ពោជ្ឈង្គ** មានការផ្គងចិត្តឡើងជាលក្ខណៈ, **បីតិសម្ពោជ្ឈង្គ** មានការផ្សាយទៅជាលក្ខណៈ, **បស្សទ្ធិសម្ពោជ្ឈង្គ** មានការស្ងប់ជាលក្ខណៈ, **សមាធិសម្ពោជ្ឈង្គ** មានការមិន

---

[១] ខុ. បដិ. ។

រវើរវាយទៅ ជាលក្ខណៈ, **ឧបេក្ខាសម្ពោជ្ឈង្គ** មានការសម្លឹងព្រងើយ (បដិសង្ខាន[*]) ជាលក្ខណៈ; ក្នុងសម្ពោជ្ឈង្គនោះ ព្រះមានព្រះភាគត្រាស់សតិសម្ពោជ្ឈង្គទុកមុន ព្រោះសភាវៈនៃសតិសម្ពោជ្ឈង្គ ជាធម៌មានឧបការច្រើនដល់ពោជ្ឈង្គទាំងអស់ ដូចព្រះបាលីថា **"ម្នាលភិក្ខុទាំងឡាយ ក៏តថាគតរមែងពោលថា សតិនុ៎ះឯង ជាធម៌មានប្រយោជន៍ក្នុងទីទាំងពួង (សតិនោះឯងចាំបាច់ត្រូវប្រាថ្នាក្នុងទីទាំងពួង)"**[២]; ខាងមុខអំពីនេះទៅ ជាការប្រកបបទដែលមានមកក្នុងព្រះបាលីដោយលំដាប់យ៉ាងនេះនោះឯង ដោយន័យជាដើមថា **"ភិក្ខុមានសតិយ៉ាងនោះ រមែងជ្រើសរើស ស្រាវជ្រាវ ពិចារណានូវធម៌ នោះ ដោយបញ្ញា"**[៣] ជាដើម ។

**សួរថា** ព្រះមានព្រះភាគត្រាស់ពោជ្ឈង្គ ៧ នេះថា មិនក្រៃលែង (មិនលើស មិនខ្វះ) ជាងនេះ ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះសេចក្ដីជាបដិបក្សចំពោះថីនមិទ្ធៈ (ការរួញរា) និងឧទ្ធច្ចៈ (ការរវើរវាយ) ព្រោះជាធម៌មានប្រយោជន៍ក្នុងទីទាំងពួង ។

ពិតមែន ក្នុងពោជ្ឈង្គនេះ ពោជ្ឈង្គ ៣ (ធម្មវិចយ បីតិ និងវីរិយៈ) ជាបដិបក្សចំពោះសេចក្ដីរួញរា ។ ដូចយ៉ាងដែលព្រះមានព្រះភាគត្រាស់ថា **"ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណានោះឯង ចិត្តរួញរា ក្នុងសម័យនោះ ជាកាលសមគួរដើម្បី**

---

[*] ពាក្យថា **បដិសង្ខាន** គឺការព្រងើយ ក្នុងទីនេះ សំដៅដល់ការតាក់តែងពោជ្ឈង្គ ៦ ដ៏សេស ដោយអាការជាកណ្ដាល អាចារ្យពួកខ្លះបានពោលថា ឧបេក្ខាសម្ពោជ្ឈង្គ តាក់តែងសទ្ធា និងបញ្ញា វីរិយៈ និងសមាធិឱ្យស្មើគ្នា ។

[២-៣] សំ. ម. ។

ចម្រើនធម្មវិចយសម្ពោជ្ឈង្គ, ជាកាលសមគួរដើម្បីចម្រើនវីរិយសម្ពោជ្ឈង្គ, ជាកាលសមគួរដើម្បីចម្រើនបីតិសម្ពោជ្ឈង្គ"[៤] ។ សម្ពោជ្ឈង្គ ៣ (បស្សទ្ធិ សមាធិ និងឧបេក្ខា) ជាបដិបក្សចំពោះឧទ្ធច្ចៈ ។ ដូចយ៉ាងដែលព្រះមានព្រះភាគត្រាស់ថា **"ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណានោះឯង ចិត្តរវើរវាយ, ក្នុងសម័យនោះ ជាកាលសមគួរ ដើម្បីចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ, ជាកាលសមគួរដើម្បីចម្រើនសមាធិសម្ពោជ្ឈង្គ, ជាកាលសមគួរដើម្បីចម្រើនឧបេក្ខាសម្ពោជ្ឈង្គ"**[៥] ។ ម្យ៉ាងទៀត ក្នុងពោជ្ឈង្គទាំងអស់នោះ ពោជ្ឈង្គមួយ (គឺសតិសម្ពោជ្ឈង្គ) ឈ្មោះថាមានប្រយោជន៍ក្នុងទីទាំងពួង ព្រោះសេចក្ដីជាធម៌ដែលសត្វគប្បីប្រាថ្នា ប្រៀបដូចការផ្សំរសប្រៃ (អំបិល) ក្នុងម្ហូបគ្រប់យ៉ាង និងប្រៀបដូចអាមាត្យអ្នកធ្វើការទាំងអស់ក្នុងព្រះរាជកិច្ចទាំងពួង ។ ដូចយ៉ាងដែលព្រះមានព្រះភាគត្រាស់ថា **"ម្នាលភិក្ខុទាំងឡាយ តថាគតរមែងពោលថា សតិនោះឯង ជាធម៌មានប្រយោជន៍ក្នុងទីទាំងពួង"** ។ ព្រះបាលីប្រើពាក្យថា **"សព្វត្ថិកំ"** នឹងប្រែថា ជាធម៌ចាំបាច់ត្រូវប្រាថ្នាក្នុងទីទាំងពួងក៏បាន, ព្រះបាលីថា **សព្វត្ថកំ** ដូច្នេះក៏មាន ។ សូម្បីទាំង ២ បទ លោកអធិប្បាយថា សត្វគប្បីប្រាថ្នាក្នុងទីទាំងពួង ។ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ថា ពោជ្ឈង្គ ៧ ប៉ុណ្ណោះ ជាបដិបក្ស ចំពោះថីនមិទ្ធៈ និងឧទ្ធច្ចៈ និងព្រោះជាធម៌មានប្រយោជន៍ក្នុងទីទាំងពួង ដូចពណ៌នាមកដូច្នេះឯង ៕

---

[៤-៥] សំ. ម. ។

## សតិសម្ពោជ្ឈង្គ

ឥឡូវនេះ ដើម្បីនឹងសម្ដែងហេតុនៃសេចក្ដីផ្សេងគ្នា ព្រោះអារម្មណ៍មួយនៃសម្ពោជ្ឈង្គនោះឯង ដោយអំណាចនៃកិច្ច (នាទី) របស់ខ្លួនៗ ទើបព្រះមានព្រះភាគ ផ្ដើមពាក្យថា **"តត្ថ កតមោ សតិសម្ពោជ្ឈង្គោ"** ជាដើម ។ បណ្ដាពាក្យទាំងនោះ ពាក្យថា **"ឥធ ភិក្ខុ"** បានដល់ ភិក្ខុណាក្នុងព្រះពុទ្ធសាសនានេះ ។ ពាក្យថា **"សតិមា ហោតិ"** បានដល់ ជាអ្នកមានសតិដូចបុគ្គលអ្នកមានបញ្ញា ព្រោះប្រកបដោយបញ្ញា, បុគ្គលអ្នកមានយស ព្រោះប្រកបដោយយស, បុគ្គលអ្នកមានទ្រព្យ ព្រោះប្រកបដោយ ទ្រព្យដូច្នោះ, អធិប្បាយថា ជាអ្នកដល់ព្រមហើយដោយសតិ ។ ពាក្យថា **"បរមេន** = ប្រកបដោយបញ្ញាដ៏ក្រៃលែង" បានដល់ ដោយបញ្ញាដ៏ខ្ពស់បំផុត ។ ពិតមែន ពាក្យនេះ ឈ្មោះថា ជាធម៌យ៉ាងក្រៃលែង ជាធម៌ខ្ពស់បំផុត ជាធម៌ប្រសើរបំផុត ព្រោះជាធម៌ចាក់បណ្ដោយ (អនុលោម) តាមព្រះនិព្វាន ដែលជាបរមត្ថសច្ច និងមគ្គសច្ច ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **"សតិនេបក្កេន"** បញ្ញាព្រះមានព្រះភាគត្រាស់ហៅថា **នេបក្កៈ**, អធិប្បាយថា ដល់ព្រមដោយសតិ និងបញ្ញា ។ **សួរថា** ក៏ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់សង្គ្រោះ (កាន់យក) បញ្ញា ក្នុងចំណែកនៃបទនេះ ? ឆ្លើយថា ដើម្បីសម្ដែងនូវសភាវៈនៃសតិ ជាធម៌មានកម្លាំង ។ **ពិតមែន សតិសូម្បីវៀរបញ្ញា ក៏កើតឡើងបាន, សតិនោះកាលកើតព្រមជាមួយនឹងបញ្ញា រមែងជាសភាវៈមានកម្លាំង, កាលវៀរអំពីបញ្ញារមែងទុព្វល (មានកម្លាំងខ្សោយ)** ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់កាន់យកបញ្ញាផងដើម្បីសម្ដែងនូវសភាពនៃពោជ្ឈង្គនោះ ជាសភាវៈមានកម្លាំង ។

ដូចយ៉ាងថា រាជមហាមាត្យទាំង ២ នាក់ គប្បីឈរនៅក្នុងទិសទាំងពីរ; បណ្ដាមហាមាត្យទាំងពីរនាក់នោះ មហាមាត្យមួយពព្រះរាជបុត្រនៅឈរ, មហាមាត្យម្នាក់ទៀតប៉ុណ្ណោះ ឈរនៅតាមធម្មតារបស់ខ្លួន ។ ក្នុងមហាមាត្យទាំងនោះ មហាមាត្យដែលពព្រះរាជបុត្រនៅឈរ រមែងជាអ្នកមានអំណាច ដោយអំណាចរបស់ព្រះរាជបុត្រនោះឯង, មហាមាត្យមួយនៅឈរតាមធម្មតារបស់ខ្លួន រមែងមិនមានអំណាចស្មើដោយអំណាចរបស់អាមាត្យដែលពព្រះរាជបុត្រនោះ យ៉ាងណា, សេចក្ដីនេះ ក៏ដូច្នោះដែរ, សតិកើតឡើងជាមួយនឹងបញ្ញា ប្រៀបដូចមហាមាត្យដែលពព្រះរាជបុត្រនៅឈរ, សតិដែលកើតឡើងវៀរអំពីបញ្ញា ប្រៀបដូចមហាមាត្យដែលនៅឈរតាមធម្មតារបស់ខ្លួន ។ ក្នុងមហាមាត្យទាំង ២ នោះ មហាមាត្យម្នាក់ដែលពព្រះរាជបុត្រនៅឈរ រមែងជាអ្នកមានអំណាច ដោយអំណាចរបស់ខ្លួនខ្លះ ដោយអំណាចរបស់ព្រះរាជបុត្រខ្លះ យ៉ាងណា, សតិដែលកើតឡើងព្រមដោយបញ្ញា ក៏ជាសភាវៈមានកម្លាំងដូច្នោះដែរ ។ មហាមាត្យម្នាក់ទៀតដែលនៅតាមធម្មតារបស់ខ្លួន រមែងជាអ្នកមិនមានអំណាច ស្មើដោយអំណាចរបស់មហាមាត្យដែលពព្រះរាជបុត្រនៅឈរ យ៉ាងណា, សតិដែលកើតឡើងវៀរអំពីបញ្ញា រមែងមានកម្លាំងខ្សោយ (ទុព្វល) ក៏ដូច្នោះដែរ, ដើម្បីសម្ដែងនូវសភាវៈនៃសតិជាធម៌មានកម្លាំង ទើបព្រះមានព្រះភាគទ្រង់កាន់យកបញ្ញាផង ដូចពណ៌នាមកដូច្នេះ ។

ពាក្យថា **“ចិរកតម្បិ”** បានដល់ វត្តដែលធ្វើទុកយូរៗ ដោយកាយរបស់ខ្លួន ឬរបស់អ្នកដទៃ ឬថាបានដល់ កសិណមណ្ឌល ឬកសិណបរិកម្ម ។ ពាក្យថា **“ចិរភាសិ-តម្បិ”** បានដល់ សូម្បីធម្មកថាដែលតាំងនៅក្នុងវត្តសីសៈច្រើន ដែលខ្លួន ឬអ្នកដទៃពោលដោយវាចាទុកយូរៗ ឬក៏បានដល់ ការវិនិច្ឆ័យក្នុងកម្មដ្ឋាន ឬថា ធម្មកថានោះឯង

ដែលតាំងនៅក្នុងវិមុត្តាយតនសីសៈ ។ ពាក្យថា **"សរិតា ហោតិ"** បានដល់ ចំណែកនៃអរូបធម៌ដែលញុំាងកាយវិញ្ញត្តិ និងវចីវិញ្ញត្តិនោះ ឱ្យតាំងឡើងព្រម ប្រព្រឹត្តទៅហើយ ក៏រឭកបានថា "វត្ថុនេះកើតឡើងហើយយ៉ាងនេះ, រលត់ទៅហើយយ៉ាងនេះ"។ ពាក្យថា **"អនុស្សរិតា"** បានដល់ រឭកបានញឹកញាប់ៗ; ពាក្យថា **"អយំ វុច្ចតិ សតិសម្ពោជ្ឈង្គោ"** បានដល់ សតិនេះ ដែលសម្បយុត្តដោយវិបស្សនា ដែលញុំាងពោ-ជ្ឈង្គដ៏សេសឱ្យតាំងឡើង ដែលកើតឡើងហើយយ៉ាងនេះ ព្រះមានព្រះភាគត្រាស់ថា "សតិសម្ពោជ្ឈង្គោ" ៕

## ធម្មវិចយសម្ពោជ្ឈង្គ

ពាក្យថា **"សោ តថា សតោ វិហរន្តោ"** ភិក្ខុនោះជាអ្នកមានសតិ ដោយសតិដែលកើតឡើងមានអាការៈយ៉ាងនោះ ។ ពាក្យថា **"តំ ធម្មំ"** បានដល់ កិច្ចដែលធ្វើទុកយូរៗ វាចាដែលពោលទុកយូរៗ ដែលជាធម៌មានប្រការតាមដែលពោលហើយពេលក្រោយនោះ ។ ពាក្យថា **"បញ្ញាយ វិចិនតិ"** បានដល់ រមែងវិច័យ (ដកស្រង់) ដោយបញ្ញាថា "នេះមិនទៀង, ជាទុក្ខ, ជាអនត្តា"។ ពាក្យថា **"បវិចិនតា"** បានដល់ ញុំាងបញ្ញាឱ្យគិតជញ្ជឹងទៅក្នុងធម៌នោះថា ជារបស់មិនទៀង, ជាទុក្ខ, ជាអនត្តា ។ ពាក្យថា **"បរិវិមំសំ អាបជ្ជតិ"** បានដល់ រមែងដល់ការជញ្ជឹងមើល ។ ពាក្យថា **"អយំ វុច្ចតិ"** មានប្រការតាមដែលពោលហើយ គឺជាសមុដ្ឋាននៃពោជ្ឈង្គ ជាវិបស្សនាញាណ ព្រះមានព្រះភាគត្រាស់ហៅថា **"ធម្មវិចយសម្ពោជ្ឈង្គោ"** ៕

## វីរិយសម្ពោជ្ឈង្គ

ពាក្យថា **“តស្ស តំ ធម្មំ”** បានដល់ ភិក្ខុនោះស្រាវជ្រាវនូវធម៌នោះ មានប្រការតាមដែលពោលហើយក្នុងពេលក្រោយ ។ ពាក្យថា **“អារទ្ធំ ហោតិ”** បានដល់ ជាសេចក្តីព្យាយាមដែលបរិបូណ៌ ជាសេចក្តីព្យាយាមមានធម៌ឧបត្ថម្ភហើយ ។ ពាក្យថា **“អសល្លីនំ”** បានដល់ ឈ្មោះថា ការមិនបន្ធូរបន្ថយ ព្រោះជាសេចក្តីព្យាយាមមែនពិត ។ ពាក្យថា **“អយំ ទុច្ចតិ”** នេះ ជាសេចកីព្យាយាមដែលញ៉ាំងពោជ្ឈង្គឱ្យតាំងឡើង សម្បយុត្តដោយវិបស្សនា ទើបព្រះមានព្រះភាគត្រាស់ហៅថា **“វីរិយ-សម្ពោជ្ឈង្គោ”** ៕

## បីតិសម្ពោជ្ឈង្គ

ពាក្យថា **“និរាមិសា”** បានដល់ បរិសុទ្ធ ឈ្មោះថា ប្រាសចាកអាមិស ព្រោះសេចក្តីមិនមានកាមាមិស លោកាមិស និងវដ្តាមិស ។ ពាក្យថា **“អយំ ទុច្ចតិ”** បានដល់ បីតិនេះ ជាធម៌ញ៉ាំងពោជ្ឈង្គឱ្យតាំងឡើង សម្បយុត្តដោយវិបស្សនា ព្រះមានព្រះភាគត្រាស់ហៅថា **“បីតិសម្ពោជ្ឈង្គោ”** ៕

## បស្សទ្ធិសម្ពោជ្ឈង្គ

ពាក្យថា **បីតិមនស្ស** = អ្នកមានចិត្តប្រកបដោយបីតិ ។

ពាក្យថា **“កាយោបិ បស្សម្ភតិ”** បានដល់ នាមកាយ ពោលគឺខន្ធ ៣ (វេទនា សញ្ញា និងសង្ខារ) រមែងស្ងប់រម្ងាប់ ព្រោះការស្ងប់រម្ងាប់ទៅនៃសេចក្តីក្តៅក្រហាយ

ដោយកិលេស ។ ពាក្យថា **"ចិត្តម្បិ"** បានដល់ សូម្បីវិញ្ញាណក្ខន្ធ ក៏រមែងស្ងប់រម្ងាប់ដូច្នោះដែរ ។ ពាក្យថា **"អយំ វុច្ចតិ"** បានដល់ បស្សទ្ធិនេះ ជាធម៌ញុំាងពោជ្ឈង្គឱ្យតាំងឡើង សម្បយុត្តជាមួយនឹងវិបស្សនា ព្រះមានព្រះភាគត្រាស់ហៅថា **"បស្សទ្ធិ-សម្ពោជ្ឈង្គោ"** ៕

## សមាធិសម្ពោជ្ឈង្គ

ពាក្យថា **"បស្សទ្ធកាយស្ស សុខិនោ"** បានដល់ អ្នកមានសេចក្ដីសុខដោយសុខដែលកើតឡើង ព្រោះកាយស្ងប់រម្ងាប់ហើយ ។ ពាក្យថា **"សមាធិយតិ"** បានដល់ រមែងតាំងមាំដោយប្រពៃ, គឺជាសភាវៈមិនញាប់ញ័រ ហើយតាំងនៅក្នុងអារម្មណ៍ដូចពន្លុះអប្បនា ។ ពាក្យថា **"អយំ វុច្ចតិ"** បានដល់ សភាវៈនៃចិត្តមានអារម្មណ៍តែមួយ (សមាធិ) នេះ ជាធម៌ញុំាងពោជ្ឈង្គឱ្យកើតឡើង សម្បយុត្តដោយវិបស្សនា ទើបព្រះមានព្រះភាគត្រាស់ហៅថា **"សមាធិសម្ពោជ្ឈង្គោ"** ៕

## ឧបេក្ខាសម្ពោជ្ឈង្គ

ពាក្យថា **"តថា សមាហិតំ"** បានដល់ តាំងមាំដោយសមាធិ ដូចការពន្លុះអប្បនានោះ ។ ពាក្យថា **"សាធុកំ អជ្ឈុបេក្ខិតា ហោតិ"** បានដល់ ចូលទៅតាំងមាំដោយល្អ; មិនជាសភាវៈផ្លាស់ប្ដូរទៅ ព្រោះការលះ និងការចម្រើនធម៌នោះ ទើបឈ្មោះថា រមែងតាំងមាំ ។ ពាក្យថា **"អយំ វុច្ចតិ"** បានដល់ ឧបេក្ខាសម្ពោជ្ឈង្គនេះ ជាសភាវធម៌ញុំាងពោជ្ឈង្គ ៦ មិនឱ្យនឿយណាយ ទាំងមិនឱ្យឈានកន្លង ឱ្យសម្រេច

ដែលជាអាការៈរបស់ភាពជាកណ្តាល ទើបព្រះមានព្រះភាគត្រាស់ហៅថា **"ឧបេក្ខា-សម្ពោជ្ឈង្គោ"** ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ពាក្យអ្វីទៅរមែងឈ្មោះថា ជាធម៌ដែលលោកពោលហើយ ទើបព្រះមានព្រះភាគត្រាស់ពោជ្ឈង្គទាំងឡាយ ដោយរស (មុខនាទី) ផ្សេងៗ ជាលក្ខណៈ (គ្រឿងសម្គាល់) ជាបុព្វភាគនៃវិបស្សនា ក្នុងជវនចិត្តមួយខណៈ មិនមុន មិនក្រោយគ្នា ដូចពណ៌នាមកដូច្នេះ ៕

**ចប់ន័យទី ១**

## ពោជ្ឈង្គ ៧ ន័យទី ២

ឥឡូវនេះ ពោជ្ឈង្គ ៧ រមែងជាពោជ្ឈង្គ ១៤ ដោយបរិយាយណា, ព្រះមាន-ព្រះភាគកាលទ្រង់សម្តែងន័យទី ២ ដើម្បីទ្រង់ប្រកាសដល់បរិយាយនៃពោជ្ឈង្គ ១៤ នោះ ទើបត្រាស់ពាក្យថា **សត្ត ពោជ្ឈង្គា** ជាដើមទៀត ។ ក្នុងន័យទីពីរនោះ គប្បីជ្រាបការពណ៌នាបទដោយលំដាប់ដូច្នេះ ៖

ពាក្យថា **"អជ្ឈត្តធម្មេសុ សតិ** = មានសតិនៅខាងក្នុងធម៌" បានដល់ សតិដែលកើតឡើងដល់អ្នកពិចារណាសង្ខារទាំងឡាយ ដែលជាខាងក្នុង ។ ពាក្យថា **"ពហិទ្ធា ធម្មេសុ សតិ** = មានសតិនៅខាងក្រៅធម៌" បានដល់ សតិដែលកើតឡើងដល់អ្នកពិចារណាសង្ខារខាងក្រៅ ។ បទថា **យទបិ** លោកកែជា **យាបិ** = សូម្បីអ្នកណា ។ បទថា **តទបិ** លោកកែជា **សាបិ** = សូម្បីទាំងនោះ ។ បទថា **អភិញ្ញាយ** បានដល់

សូម្បីការដឹង កាដើងដ៏ក្រៃលែង ក្នុងធម៌ដែលដឹងក្រៃលែង ។ **មគ្គ** ព្រះមានព្រះភាគត្រាស់ហៅថា **សម្ពោធិ** (ការត្រាស់ដឹង), ក្នុងបទថា **សម្ពោធាយ** អធិប្បាយថា ដើម្បីមគ្គ និងផល ។

**តណ្ហា** ព្រះមានព្រះភាគត្រាស់ហៅថា **វានៈ** ក្នុងបទថា **និព្វានាយ**, តណ្ហានោះ មិនមានក្នុងទីនោះ ព្រោះហេតុនោះ ទីនោះ ទើបហៅថា **និព្វាន**, អធិប្បាយថា រមែងប្រព្រឹត្តទៅព្រមដើម្បីព្រះនិព្វាននោះ ដើម្បីអសង្ខតៈ ដើម្បីអមតធាតុ និងដើម្បីការធ្វើឱ្យជាក់ច្បាស់” ។ សូម្បីក្នុងធម្មវិចយសម្ពោជ្ឈង្គ ក៏មានន័យដូចគ្នានេះដែរ ។

ពាក្យថា “**កាយិកំ វីរិយំ**” បានដល់ សេចក្តីព្យាយាមដែលកើតឡើងហើយដល់អ្នកអធិដ្ឋាននូវការចង្ក្រម ។ ពាក្យថា **ចេតសិកំ វីរិយំ** បានដល់ សេចក្តីព្យាយាមដែលកើតឡើងហើយ វៀរកាយបយោគយ៉ាងនេះថា “ដរាបណា ចិត្តរបស់ថាគតនឹងមិនរួចផុតអំពីអាសវៈទាំងឡាយ ដោយសេចក្តីមិនប្រកាន់មាំហើយ តថាគតមិនទម្លាយបល្ល័ង្ក (ភ្នែន) នេះឡើយ” ដូច្នេះ ។ ពាក្យថា **កាយបស្សទ្ធិ** បានដល់ ការស្ងប់រម្ងាប់នូវសេចក្តីក្រវល់ក្រវាយនៃខន្ធទាំង ៣ ។ ពាក្យថា **ចិត្តបស្សទ្ធិ** បានដល់ ការស្ងប់រម្ងាប់នូវសេចក្តីក្រវល់ក្រវាយរបស់វិញ្ញាណក្ខន្ធ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងឧបេក្ខាសម្ពោជ្ឈង្គដូចគ្នានឹងសតិសម្ពោជ្ឈង្គនោះឯង ។

ក្នុងន័យនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ពោជ្ឈង្គ ៧ លាយដោយលោកិយ និងលោកុត្តរ ។

ចំណែកព្រះថេរៈទាំងឡាយខ្លះ ក្នុងគ្រាមុនសម្តែងបែងចែកទុកថា “ន័យនេះប្រាកដបានដោយហេតុមានប្រមាណប៉ុណ្ណេះ” ដូច្នេះ ។ ព្រោះថា ក្នុងអជ្ឈត្តធម៌នេះ ធម៌

ទាំង ៣ គឺ សតិ បវិចយៈ (ធម្មវិចយៈ) និងឧបេក្ខា ជាលោកិយប៉ុណ្ណោះ ព្រោះសភាវៈនៃខ្លួន (ធម៌ទាំង ៣) មានខន្ធជាអារម្មណ៍, សេចក្តីព្យាយាមផ្លូវកាយ (វីរិយៈ) ដែលនៅមិនពន្លុះមគ្គក៏ដូចគ្នា (នៅជាលោកិយ); ចំណែកបីតិ សមាធិ ដែលជាអវិតក្កៈ និងអវិចារៈ ជាលោកុត្តរ, ធម៌ដ៏សេស លាយដោយលោកិយ និងលោកុត្តរ ។ ក្នុងពោជ្ឈង្គទាំងនោះ ធម៌ទាំងឡាយដែលជាអជ្ឈត្តជាមុនសិន សតិ បវិចយៈ និងឧបេក្ខា ជាអជ្ឈត្តារម្មណ៍, ចំណែកលោកុត្តរទាំងឡាយ ជាពហិទ្ធារម្មណ៍ ព្រោះហេតុដូច្នោះ ភាពជាលោកុត្តរ ទើបមិនបានប្រកបដោយសតិ បវិចយៈ និងឧបេក្ខាប៉ុណ្ណោះ ។ កាលនឹងពោលថា "សេចក្តីព្យាយាម សូម្បីដែលកើតឡើង ដោយបយោគក្នុងការឈានទៅជាលោកិយ" ដូច្នេះ ក៏មិនលំបាក (ក៏មិនធ្ងន់ចិត្ត) ។ **សួរថា** ក៏បីតិ និងសមាធិដែលជាអវិតក្កៈ និងអវិចារៈ ក្នុងកាលណានឹងជាលោកុត្តរទៅ ? ឆ្លើយថា ក្នុងខាងដើម បីតិសម្ពោជ្ឈង្គរមែងបានក្នុងកាមាវចរ បីតិដែលជាអវិតក្កៈ និងអវិចារៈ រមែងមិនបាន; បីតិដែលជាអវិតក្កៈ និងអវិចារៈ រមែងបានក្នុងរូបាវចរ, តែថា មិនបានបីតិសម្ពោជ្ឈង្គ ។ ពាក្យដែលពោលមកហើយ ដោយប្រការទាំងពួង រមែងមិនបានក្នុងអរូបាវចរ ។ ក៏ក្នុងអធិការនេះ លោកសំដៅយកសភាវៈដែលនៅមិនធ្លាប់បាន ទើបបដិសេធបីតិទាំងឡាយដែលបុគ្គលទាំងឡាយបាន ។ គឺថា បីតិសម្ពោជ្ឈង្គដែលជាអវិតក្កៈ និងអវិចារៈយ៉ាងនេះ ជាសភាវៈចេញទៅហើយ អំពីកាមាវចរខ្លះ រូបាវចរខ្លះ និងអរូបាវចរខ្លះ ដូច្នេះ ទើបលោកហៅថា ជាលោកុត្តរដែលកើតឡើងហើយប៉ុណ្ណោះ ។

សមាធិសម្ពោជ្ឈង្គ ក៏រមែងបានក្នុងកាមាវចរ ដោយពាក្យជាមួយគ្នា ។ ឥឡូវនេះ សមាធិដែលអវិតក្កៈ និងអវិចារៈរមែងមិនបាន ។ សមាធិដែលជាអវិតក្កៈ និង

អវិចារៈ រមែងបានក្នុងរូបាវចរ និងអរូបាវចរ, ចំណែកសមាធិសម្ពោជ្ឈង្គ រមែងមិនបាន។ ក៏ក្នុងអធិកានេះ លោកសំដៅយកសភាវៈដែលនៅមិនបាន ទើបបដិសេធសមាធិសូម្បីដែលបុគ្គលបានហើយ ។ សមាធិយ៉ាងនេះ ចេញទៅអំពីកាមាវចរខ្លះ រូបាវចរខ្លះ និងអរូបាវចរខ្លះ ព្រោះហេតុដូច្នោះ ទើបលោកហៅថា ជាលោកុត្តរដែលកើតឡើងហើយមែនពិត ។

ម្យ៉ាងទៀត បណ្ឌិតគប្បីកាន់យកលោកិយ ហើយធ្វើលោកុត្តរ, គប្បីកាន់យកលោកុត្តរ ហើយធ្វើលោកិយក៏បាន ។ ព្រោះថា សូម្បីវេលាចម្រើនលោកុត្តររបស់សតិបរិចយៈ និងឧបេក្ខា ក្នុងអជ្ឈត្តធម៌នៅមាន ។ ក្នុងអធិការនេះ មានព្រះសូត្រជាឧទាហរណ៍ថា ៖

“អ្នកមានអាយុ តថាគតរមែងពោលអជ្ឈត្តវិមោក្ខថា ជាធម៌អស់ទៅនៃសេចក្តីប្រកាន់ក្នុងទីទាំងពួង, អាសវៈទាំងឡាយនេះ រមែងមិនជាប់ជំពាក់ដល់ធម៌នោះ ដោយប្រការដូច្នេះ” [៦] ដូច្នេះ លោកុត្តរទាំងឡាយ ទើបឈ្មោះថា នៅមានដោយព្រះសូត្រនេះ ។ ក៏បើថា ក្នុងកាលណា សេចក្តីព្យាយាមប្រព្រឹត្តទៅផ្លូវកាយ ដែលកើតឡើងដោយចង្កមប្រយោគនៅមិនស្ងប់នោះឯង វិបស្សនារមែងបន្តទៅដោយមគ្គ, ក្នុងកាលនោះ សេចក្តីព្យាយាមនោះ ទើបជាលោកុត្តរ ។

ម្យ៉ាងវិញទៀត ព្រះថេរៈពួកណា រមែងពោលថា “ពោជ្ឈង្គដែលកើតឡើងមិនបានវៀរចាកកសិណជ្ឈានទាំងឡាយ អានាបានជ្ឈានទាំងឡាយ និងព្រហ្មវិហារជ្ឈានទាំងឡាយ”, ក្នុងវាទរបស់ព្រះថេរៈទាំងនោះ បីតិ សមាធិ និងសម្ពោជ្ឈង្គៈ ដែល

---

[៦] សំ. និ.។

ជាអវិតក្កៈ និងអវិចារៈ រមែងជាលោកិយ ៕

**ចប់ន័យទី ២**

## ពោជ្ឈង្គ ៧ ន័យទី ៣

ឥឡូវនេះ កាលនឹងទ្រង់សម្ដែងន័យទី ៣ ដែលប្រព្រឹត្តទៅដោយអំណាចនៃការចម្រើនពោជ្ឈង្គទាំងឡាយ ទើបព្រះមានជោគត្រាស់ពាក្យថា **សត្ត ពោជ្ឈង្គា** ជាដើមទៀត ។ សូម្បីក្នុងអាការៈនេះ បណ្ឌិតគប្បីជ្រាបការពណ៌នាបទ ដោយលំដាប់ដូច្នេះ ៖

បទថា **"ភាវេតិ"** បានដល់ រមែងចម្រើន, គឺរមែងឱ្យកើត ឱ្យកើតក្រៃលែងក្នុងសន្ដានរបស់ខ្លួនញឹកញាប់ៗ ។ បទថា **"វិវេកនិស្សិតំ"** បានដល់ ដែលអាស្រ័យវិវេក ។ បទថា **"វិវេកោ"** បានដល់ វិវេក គឺសេចក្ដីស្ងាត់ ។ ម្យ៉ាងទៀត វិវេកនេះមាន ៥ យ៉ាង គឺ **តទង្គវិវេក វិក្ខម្ភនវិវេក សមុច្ឆេទវិវេក បដិបស្សទ្ធិវិវេក និង និស្សរណវិវេក** ។ បណ្ដាវិវេកទាំងនោះ វិបស្សនា ឈ្មោះថា **តទង្គវិវេក** ។ សមាបត្តិ ៨ ឈ្មោះថា **វិក្ខម្ភនវិវេក** ។ មគ្គ ឈ្មោះថា **សមុច្ឆេទវិវេក** ។ ផល ឈ្មោះថា **បដិបស្សទ្ធិវិវេក** ។ ព្រះនិព្វានដែលរលាស់នូវនិមិត្តទាំងពួង ឈ្មោះថា **និស្សរណវិវេក** ។ បណ្ឌិតគប្បីជ្រាបសេចក្ដីនេះថា ព្រះយោគីរមែងចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវតទង្គវិវេក សមុច្ឆេទវិវេក និងនិស្សរណវិវេក ដោយសំដៅយកក្នុងពាក្យថា **វិវេក ៥** ទើបឈ្មោះថា អាស្រ័យនូវវិវេក ។ ពិតយ៉ាងនោះមែន ព្រះយោគីនេះប្រកបរឿយៗ ដោយការប្រកបក្នុងការចម្រើនសតិសម្ពោជ្ឈង្គ រមែងចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវតទង្គវិវេក ដោយកិច្ចក្នុងខណៈនៃវិបស្សនា, អាស្រ័យនូវ

និស្សរណវិវេក ដោយអជ្ឈាស្រ័យ (អជ្ឈាសយតោ), តែក្នុងកាលនៃមគ្គ អាស្រ័យនូវសមុច្ឆេទវិវេកដោយកិច្ច, អាស្រ័យនូវនិស្សរណវិវេក ដោយអារម្មណ៍ ។

អាចារ្យពួកខ្លះពោលថា **"អាស្រ័យវិវេកទាំង ៥ យ៉ាង ក៏បាន"** ។ ពិតមែន អាចារ្យទាំងនោះ មិនលើកយកពោជ្ឈង្គទាំងឡាយឡើង ក្នុងខណៈដែលវិបស្សនា មគ្គ និងផលនេះ មានកម្លាំងតែម្យ៉ាង, នៅលើកយកឡើងសូម្បីក្នុងកសិណជ្ឈាន អានាបានជ្ឈាន អសុភជ្ឈាន ព្រហ្មវិហារជ្ឈានដែលជាបាទនៃវិបស្សនា, ម្យ៉ាងទៀត សេចក្តីនេះ ព្រះអដ្ឋកថាចារ្យទាំងឡាយ មិនបដិសេធទេ; ព្រោះហេតុនោះ កាលពោល អំពីមតិរបស់អាចារ្យទាំងនោះ ព្រះយោគីរមែងចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិក្ខម្ភនវិវេកដោយកិច្ច ក្នុងខណៈដែលប្រព្រឹត្តទៅរបស់ឈាននោះៗ ឯង ។ ម្យ៉ាងវិញទៀត លោកពោលថា "ចម្រើនសតិសម្ពោជ្ឈង្គដែលអាស្រ័យនូវនិស្សរណវិវេកដោយអជ្ឈាស្រ័យ" ដូច្នេះ ក្នុងខណៈនៃវិបស្សនាយ៉ាងណា, សូម្បីនឹងពោលថា "ចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យបដិបស្សទ្ធិវិវេក" ដូច្នេះក៏គួរ ។ ក្នុងពាក្យថា អាស្រ័យនូវវិរាគៈជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ពិតមែន វិរាគៈជាដើម ក៏មានវិវេកជាអត្ថនោះឯង ។ ម្យ៉ាងផ្សេងទៀត **វោស្សគ្គៈ** (ការលះ ឬការដក) មានត្រឹមតែ ២ យ៉ាង គឺ បរិច្ចាគវោស្សគ្គៈ និងបក្ខន្ទនវោស្សគ្គៈ ។ ក្នុងវោស្សគ្គៈទាំង ២ នោះ **ការលះកិលេសដោយអំណាចនៃតទង្គវិវេក ក្នុងខណៈនៃវិបស្សនា និងដោយសមុច្ឆេទ-វិវេក ក្នុងខណៈនៃមគ្គ ឈ្មោះថា បរិច្ចាគវោស្សគ្គៈ ។ ការទៅកាន់ព្រះនិព្វាន ក្នុងខណៈនៃវិបស្សនា ដោយភាពជាអ្នកបង្អោនទៅកាន់តទង្គវិវេកនោះ, តែក្នុង**

ខណៈនៃមគ្គដោយការធ្វើឱ្យជាអារម្មណ៍ ឈ្មោះថា បក្ខន្ទនវោស្សគ្គៈ ។ សូម្បីវោស្សគ្គៈទាំង ២ នោះ រមែងគួរក្នុងន័យនៃការពណ៌នាដែលលាយដោយលោកិយ និងលោកុត្តរនេះ ។ ពិតយ៉ាងនោះ សតិសម្ពោជ្ឈង្គនេះ រមែងលះកិលេសទាំងឡាយតាមប្រការដែលពោលហើយផង, រមែងស្ទុះទៅកាន់ព្រះនិព្វានផង ។

បណ្ឌិតគប្បីជ្រាបថា ក៏ការដែលបង្អោនទៅ បង្អោនទៅហើយ ដល់ទីបំផុតហើយ ដោយពាក្យទាំងអស់នេះថា **“វោស្សគ្គបរិណាមី** = បង្អោនទៅដើម្បីលះ” ដូច្នេះ ដែលមានការលះជាអត្ថ; ព្រះមានព្រះភាគទ្រង់អធិប្បាយទុកថា ក៏ភិក្ខុនេះប្រកបរឿយៗ ក្នុងការចម្រើនពោជ្ឈង្គណា សតិសម្ពោជ្ឈង្គរមែងដល់ផលដែលលះកិលេស មានវោស្សគ្គៈជាអត្ថផង យ៉ាងណា, រមែងសម្រេចផលដែលមានការស្ទុះទៅកាន់ព្រះនិព្វានមានវោស្សគ្គៈជាអត្ថផង យ៉ាងណា, ក៏សតិសម្ពោជ្ឈង្គនោះ រមែងដល់បំផុតជុំវិញ យ៉ាងណា, ភិក្ខុរមែងញ៉ាំងសតិសម្ពោជ្ឈង្គនោះឱ្យចម្រើន ដូច្នោះដែរ ។ សូម្បីពោជ្ឈង្គដ៏សេសក៏មានន័យដូចគ្នានេះដែរ ។ សូម្បីក្នុងន័យនេះ លោកពោលថា **“ពោជ្ឈង្គទាំងឡាយលាយដោយលោកិយ និងលោកុត្តរ”** ដូច្នេះឯង ៕

ពណ៌នាអំពីសុត្តន្តភាជនិយចប់

## ២. ពណ៌នាអំពីអភិធម្មភាជនិយ

## ន័យរបស់ឯកតោបុច្ឆាវិសជ្ជនា

**ក្នុងអភិធម្មភាជនិយមាន ២ ន័យ** ដោយអំណាចនៃការសួរឆ្លើយ សូម្បីពោជ្ឈង្គទាំង ៧ ដោយរួមគ្នា និងដោយអំណាចនៃការសួរឆ្លើយពោជ្ឈង្គទាំង ៧ ដោយ

ញែកពីគ្នា ។ គប្បីជ្រាបអត្ថនៃការពណ៌នានូវពោជ្ឈង្គនោះ ដោយន័យដែលខ្ញុំពោលហើយក្នុងពេលក្រោយនោះឯង ។ ចំណែកក្នុងនិទ្ទេសនៃឧបេក្ខាសម្ពោជ្ឈង្គ ឈ្មោះថា **ឧបេក្ខា** ដោយអំណាចនៃការព្រងើយ ។ អាការ (កិរិយា) នៃការព្រងើយ ឈ្មោះថា **កិរិយាដែលព្រងើយ** ។ ឈ្មោះថា **ឧបេក្ខា** ព្រោះអត្ថថា រមែងសម្លឹង រមែងក្រើនរំឭកធម៌ទាំងឡាយ ដែលកំពុងប្រព្រឹត្តទៅដោយល្អ ដែលគួរដល់ការសម្លឹង ។ កិរិយាសម្លឹងដ៏ក្រៃលែង ដោយកិរិយាសម្លឹងជាលោកិយ ដែលពន្លុះសភាវៈជាពោជ្ឈង្គ ឈ្មោះថា **ការសម្លឹងដ៏ក្រៃលែង** ។ ភាវៈជាកណ្តាល ដោយការប្រព្រឹត្តទៅ និងមិនប្រព្រឹត្តទៅ ឈ្មោះថា **មជ្ឈត្តតា** (ភាពជាកណ្តាល); លោកពោលថា **មជ្ឈត្តតានៃចិត្ត** ក៏ដើម្បីសម្តែងថា "មជ្ឈត្តតានោះជារបស់ចិត្ត, មិនមែនជារបស់សត្វ" ដូច្នេះឯង ។ នេះជាការពណ៌នាបទតាមលំដាប់ក្នុងអភិធម្មភាជនិយនេះ ។

ក៏បណ្ឌិតគប្បីជ្រាបក្នុងអភិធម្មភាជនិយនោះ ព្រោះថា អភិធម្មភាជនិយនេះ លោកចែកន័យទុក ៤.០០០ ន័យ គឺក្នុងមគ្គមួយមាន ១.០០០ ន័យ (១.០០០ x ៤ = ៤.០០០) សម្រាប់ក្នុងការសួរ និងឆ្លើយ សូម្បីរួមពោជ្ឈង្គទាំង ៧ ។ សម្រាប់ក្នុងការវែកញែកវិសជ្ជនាម្តងមួយកងៗ ពោជ្ឈង្គទាំង ៧ មាន ៤ ប្រភេទ ចាត់ជា ២៨.០០០ ន័យ គឺពោជ្ឈង្គ ៧ ជា ៤ ដោយន័យរបស់ពោជ្ឈង្គតែគ្រប់កង ។ សូម្បីន័យទាំងអស់នោះជា ៣២.០០០ ន័យ ដោយការរាប់រួមជាមួយនឹង ៤ ន័យដំបូង ក្នុងអភិធម្មភាជនិយ លោកចែកកុសលទាំងឡាយទុក ៣២.០០០ ន័យដូចគ្នា ។ តែព្រោះពោជ្ឈង្គទាំង-ឡាយរមែងបានសូម្បីក្នុងខណៈនៃផល, គឺពោជ្ឈង្គទាំងឡាយ ជាកុសលហេតុ និងជា

សាមញ្ញផល, ព្រោះហេតុនោះ ដើម្បីសម្ដែងពោជ្ឈង្គសូម្បីក្នុងន័យនោះ ទើបលោកផ្ដើមវិបាកន័យ ដោយបែបផែនដែលជាខាងដើម គឺកុសលនិទ្ទេសនោះឯង ។ សូម្បីន័យរបស់វិបាកនោះ មាន ២ យ៉ាង ដោយអំណាចនៃការសួរ និងការឆ្លើយរួមគ្នា, និងដោយការសួរ និងការឆ្លើយញែកពីគ្នា ។ ន័យដ៏សេសក្នុងទីនេះ គប្បីជ្រាបដូចន័យដែលពោលហើយក្នុងពេលក្រោយនោះឯង ។ សម្រាប់វិបាកន័យ បណ្ឌិតគប្បីគុណជា ៣ អំពីកុសល ៕

**ពណ៌នាអំពីអភិធម្មភាជនិយចប់**

## ៣.ពណ៌នាអំពីបញ្ហាបុច្ឆកៈ

**ក្នុងបញ្ហាបុច្ឆកៈ** បណ្ឌិតគប្បីជ្រាបសភាវៈនៃពោជ្ឈង្គទាំងឡាយ ដែលជាកុសលជាដើម ដោយទំនងនៃព្រះបាលីនោះឯង ។ ចំណែកក្នុងអារម្មណត្តិកៈទាំងឡាយ សូម្បីពោជ្ឈង្គទាំងអស់នោះ ជាអប្បមាណារម្មណ៍ប៉ុណ្ណោះ ព្រោះប្រារព្ធព្រះនិព្វាន ដែលជាអប្បមាណហើយប្រព្រឹត្តទៅ, មិនជាមគ្គារម្មណ៍ ។ តែថា ក្នុងអធិការនេះ ពោជ្ឈង្គដែលជាកុសល ជាមគ្គហេតុកៈដោយអំណាចនៃសហជាតហេតុ, ពោជ្ឈង្គនោះ ជាមគ្គាធិបតី ក្នុងវេលាចម្រើនមគ្គ ដែលធ្វើវិរិយៈ ឬវីមង្សាឱ្យជាធំ ។

គប្បីពោលថា ជាមគ្គាធិបតីក្នុងការចម្រើនមគ្គដែលមានឆន្ទៈ ឬចិត្តជាធំ, ព្រោះហេតុនោះ ក្នុងខណៈនៃផល ក៏មិនគប្បីពោលដូចគ្នា ។ ក្នុងអតីតៈជាដើម ក៏មិនគប្បីពោលសូម្បីដោយភាពជាឯការម្មណ៍ ។ ក៏ប៉ុន្តែ ឈ្មោះថា ជាពហិទ្ធារម្មណ៍ ព្រោះសភាវៈ

នៃព្រះនិព្វានជាពហិទ្ធាធម៌ ។ សូម្បីក្នុងបញ្ហាបុច្ឆកៈនេះ ក៏លោកពោលថា ពោជ្ឈង្គទាំងអស់ ជាលោកុត្តរដែលកើតឡើងហើយដូចគ្នា ។ ពិតមែនពោជ្ឈង្គដែលជាលោកិយព្រះមានព្រះភាគត្រាស់ទុកក្នុងន័យទីមួយនៃសុត្តន្តភាជនិយមែនពិត, ក្នុងន័យទី ២ និងទី ៣ ត្រាស់ថា ពោជ្ឈង្គលាយដោយលោកិយ និងលោកុត្តរ ។ ក្នុងន័យទី ៤ នៃអភិធម្មភាជនិយក្តី និងក្នុងបញ្ហាបុច្ឆកៈនេះក្តី ត្រាស់ជាលោកុត្តរប៉ុណ្ណោះ ។ សូម្បីសម្មោជ្ឈង្គនេះ ព្រះអង្គក៏ទ្រង់នាំចេញមកចែកសម្តែងហើយ ៣ បរិវដ្តដូចពណ៌នាមកនេះ ។

ពណ៌នាអំពីបញ្ហាបុច្ឆកៈចប់

**ចប់អដ្ឋកថាពោជ្ឈង្គវិភង្គ**

# ១១. អដ្ឋកថាមគ្គវិភង្គ

## ១-ពណ៌នាអំពីសុត្តន្តភាជនិយ

### អធិប្បាយអរិយមគ្គមានអង្គ ៨ ន័យទី ១

ឥឡូវនេះ គប្បីជ្រាបការវិនិច្ឆ័យក្នុង **មគ្គវិភង្គ** ដែលជាលំដាប់តអំពី **ពោជ្ឈ-ង្គវិភង្គ** នោះតទៅ ៖

ពាក្យទាំងពួង មានពាក្យថា "**អរិយោ អដ្ឋង្គិកោ មគ្គោ** = អរិយមគ្គមានអង្គ ៨" ជាដើម បណ្ឌិតគប្បីជ្រាបដោយន័យដែលខ្ញុំពោលហើយ ក្នុងនិទ្ទេសនៃទុក្ខនិរោធគាមិនីបដិបទាក្នុងសច្ចវិភង្គនោះ ។ ពោលដោយអំណាចនៃភាវនា សូម្បីក្នុងន័យទី ២ ដែលព្រះមានព្រះភាគទ្រង់សម្ដែងទុកដោយឡែកហើយ រមែងឈ្មោះថា **ចម្រើនសម្មាទិដ្ឋិ** ។ ពាក្យទាំងពួងថា **វិវេកនិស្សិតំ** ជាដើម គប្បីជ្រាបដោយន័យដែល ពោលទុកហើយក្នុងពោជ្ឈង្គនោះឯង ។ សូម្បីសុត្តន្តភាជនិយ ពោលដោយន័យទាំងពីរ ព្រះមានព្រះភាគក៏ត្រាស់ជាមិស្សកៈ គឺលាយដោយលោកិយ និងលោកុត្តរនោះឯង ៕

## ២-ពណ៌នាអំពីអភិធម្មភាជនិយ

ក្នុងអភិធម្មភាជនិយ ព្រះមានព្រះភាគមិនត្រាស់ពាក្យថា "**អរិយោ**" , តែត្រាស់ពាក្យថា "មគ្គមានអង្គ ៨" ។ សូម្បីមិនត្រាស់ពាក្យថា **អរិយោ** ក៏ដោយ, មគ្គមានអង្គ ៨ នេះ ក៏ជាអរិយមគ្គដោយពិត ។ ដូចយ៉ាងថា បុត្ររបស់ព្រះរាជាមុទ្ធាភិសេកហើយ ដែលកើតក្នុងគភ៌របស់ព្រះទេពីដែលមុទ្ធាភិសេកហើយ សូម្បីនរណា១ មិនពោលថា "រាជបុត្រ" ដូច្នេះ គេក៏រមែងជារាជបុត្រនោះឯង យ៉ាងណា, សូម្បីអរិយមគ្គនេះ

សូម្បីព្រះមានព្រះភាគមិនត្រាស់ពាក្យថា **អរិយៈ** ក៏គប្បីជ្រាបថា មគ្គមានអង្គ ៨ នោះជាមគ្គដោយពិត ។ ពាក្យដែលនៅសល់សូម្បីក្នុងទីនេះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងសច្ចវិភង្គនោះឯង ។

សូម្បីក្នុងបញ្ហុិកវារៈ នឹងត្រាស់សូម្បី **មគ្គមានអង្គ ៨** ក៏គប្បីជ្រាបថា មគ្គនោះមានអង្គ ៨ ដូចគ្នា ។ ព្រោះថា ធម្មតាលោកុត្តរមគ្គ ប្រកបត្រឹមតែអង្គ ៥ មិនមាន ។

ក្នុងអធិការនេះ **គប្បីជ្រាបអដ្ឋកថានៃអាចារ្យទាំងឡាយ មានដូចតទៅ** ៖

ក៏អាចារ្យវិតណ្ឌវាទី (អ្នកមានប្រក្រតីពោលជំទាស់) ពោលថា សូម្បីលោកុត្តរមគ្គ ឈ្មោះថា ប្រកបដោយអង្គ ៨ មិនបានមាន, មានតែប្រកបដោយអង្គ ៥ ប៉ុណ្ណោះ" ដូច្នេះ; អាចារ្យវិតណ្ឌវាទីត្រូវគេជំទាស់ថា "ចូរនាំសូត្រមកអាង", អាចារ្យវិតណ្ឌវាទីនោះ កាលមិនឃើញសូត្រដទៃពិតៗ ក៏នឹងនាំចំណែកនៃសូត្រនេះមកអាងព្រោះជា **មហាសឡាយតនសូត្រ** ៖

"ទិដ្ឋិនៃភិក្ខុអ្នកមានសេចក្ដីយល់ឃើញយ៉ាងណា, ទិដ្ឋិរបស់ភិក្ខុនោះ ទើបឈ្មោះថា សម្មាទិដ្ឋិ ។ សង្កប្បៈ, វាយាមៈ, សតិ និងសមាធិនៃសេចក្ដីយល់ឃើញយ៉ាងនោះ រមែងមានដល់ភិក្ខុណា, សមាធិរបស់ភិក្ខុនេះ ក៏ឈ្មោះថា សម្មាសមាធិ ។ ព្រោះថា កាយកម្ម វចីកម្ម និងអាជីវៈរបស់ភិក្ខុនោះ រមែងជាធម៌បរិសុទ្ធល្អហើយ ក្នុងកាលមុននោះឯង" [៧] ។ លំដាប់នោះ គេគប្បីជំទាស់អាចារ្យវិតណ្ឌវាទីថា "សូមនាំបទនៃសូត្របន្ទាប់ពីសូត្រនោះមកអាង" ។ បើអាចារ្យវិតណ្ឌវាទីនាំមកនូវបទនៃសូត្រ សេចក្ដីនោះជាការល្អ; បើមិននាំមក លោកគប្បីនាំមកដោយខ្លួនឯង ហើយពោលថា "វាទៈ

---

[៧] ម. ឧ. ។

របស់អាចារ្យវិតណ្ឌវាទីនោះ បែកញែកចេញពីពាក្យទូន្មានរបស់ព្រះសាស្តា ដែលត្រាស់ថា "អរិយមគ្គដែលប្រកបដោយអង្គ ៨ នេះ រមែងដល់ការបរិបូណ៌ជុំវិញ ដោយភាវនារបស់ភិក្ខុនោះ"[៨]; ព្រោះហេតុនោះ ទើបលោកុត្តរមគ្គឈ្មោះថា ប្រកបដោយអង្គ ៥ មិនមាន, គឺមានតែប្រកបដោយអង្គ ៨ ប៉ុណ្ណោះ" ។ ក៏អង្គ ៣ នេះ (កាយកម្ម វចីកម្ម និងអាជីវៈ) រមែងជាធម៌បរិសុទ្ធហើយប្រព្រឹត្តទៅមុន, តែរមែងជាធម៌បរិសុទ្ធក្រៃលែងក្នុងខណៈលោកុត្តរមគ្គនោះឯង ។

**សួរថា** កាលបើដូច្នេះ ពាក្យថា **មគ្គប្រកបដោយអង្គ ៥** នេះ ព្រះមានព្រះភាគទ្រង់កាន់យកហើយដើម្បីប្រយោជន៍អ្វី ?

ឆ្លើយថា ដើម្បីសម្តែងកិច្ចដ៏ក្រៃលែង (ពិសេស); ពិតមែន ក្នុងសម័យណា រមែងលះមិច្ឆាវាចា រមែងញ៉ាំងសម្មាវាចាឱ្យបរិបូណ៌, ក្នុងសម័យនោះ សម្មាកម្មន្ត សម្មាអាជីព ឈ្មោះថា រមែងមិនមាន ។ អង្គទាំង ៥ នេះ ទើបជាអង្គដែលជាហេតុឱ្យលះមិច្ឆាវាចា, ក៏សម្មាវាចា រមែងបរិបូណ៌ (ពេញ) ខ្លួនឯង ដោយអំណាចនៃវិរតិ ។ ក្នុងសម័យណា រមែងលះមិច្ឆាកម្មន្ត, រមែងបំពេញសម្មាកម្មន្ត, ក្នុងសម័យនោះ សម្មាវាចា សម្មាអាជីព មិនបានមាន ។ អង្គ ៥ ដែលជាហេតុទាំងនេះនោះឯង រមែងលះមិច្ឆាកម្មន្ត; ក៏សម្មាកម្មន្តរមែងបរិបូណ៌ឯង ដោយអំណាចនៃវិរតិ ។ ក្នុងសម័យណា រមែងលះមិច្ឆាអាជីព, រមែងបំពេញសម្មាអាជីព, ក្នុងសម័យនោះ មិនមានសម្មាវាចា និងសម្មាកម្មន្ត; អង្គ ៥ ដែលជាហេតុទាំងនោះឯង រមែងលះមិច្ឆាអាជីព, រមែងបរិបូណ៌ឯង ដោយអំណាចនៃវិរតិ ។ ដើម្បីសម្តែងនូវសេចក្តីនៃធម៌ទាំង ៥ នេះ ជាអង្គដែលជា

---

[៨] ម. ឧ.។

ហេតុ និងធម៌ពិសេសដោយកិច្ចនេះ ទើបព្រះមានព្រះភាគទ្រង់កាន់យកដោយសព្ទថា **មគ្គប្រកបដោយអង្គ ៥ ដូច្នេះ** ។ ពិតមែន **លោកុត្តរមគ្គរមែងប្រកបដោយអង្គ ៨ ប៉ុណ្ណោះ**, មិនបានឈ្មោះថា ប្រកបដោយអង្គ ៥ ទេ ។ បើពោលថា "ប្រកបដោយអង្គ ៨ ដោយរួមសម្មាវាចាជាដើម" , ព្រោះសភាវៈនៃវិរតិនេះ មានចេតនាច្រើន គឺ សម្មាវាចា មានចេតនា ៤, សម្មាកម្មន្ត មានចេតនា ៣, សម្មាអាជីព មានចេតនា ៧; ព្រោះហេតុនោះ ទើបពោលថា "លោកុត្តរមគ្គប្រកបដោយអង្គ ៥ ប៉ុណ្ណោះ" នឹងគប្បីបកស្រាយយ៉ាងណា ? ខ្ញុំនឹងបកស្រាយ ព្រោះសូម្បីសភាវៈនៃវិរតិ ជាធម៌មានចេតនាច្រើនផង និងពោលថា លោកុត្តរមគ្គប្រកបដោយអង្គ ៨ ផង ។ ខាងដើមគប្បីសួរគេថា "**លោកអានគម្ពីរមហាចត្តារីសៈឬទេ** ? បើគេឆ្លើយថា "មិនបានអានទេ" , គប្បីពោលថា លោកមិនជ្រាប ព្រោះមិនបានសិក្សាទុក ។ បើគេពោលថា អាន (ទន្ទេញទុក) ក៏គប្បីនិយាយថា "ចូរនាំសូត្រមកអាង" ។ បើគេនាំសូត្រមកអាង, សេចក្ដីនោះជាការល្អ ។ បើមិននាំមក គប្បីនាំមកដោយខ្លួនឯង ពីឧបរិបណ្ណាសកៈដូចតទៅនេះថា ៖

**"ម្នាលភិក្ខុទាំងឡាយ ក៏សម្មាវាចាតើដូចម្ដេច ?** ម្នាលភិក្ខុទាំងឡាយ តថាគតរមែងពោលសម្មាវាចាថា មាន ២ យ៉ាង ៖

ម្នាលភិក្ខុទាំងឡាយ សម្មាវាចាដែលប្រព្រឹត្តទៅជាមួយអាសវៈ ចំណែកនៃបុណ្យជាផលនៃឧបធិ (ផលឱ្យកើតឧបធិ) ។ ម្នាលភិក្ខុទាំងឡាយ សម្មាវាចា ជាអរិយៈ **មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈ** ជាលោកុត្តរ ជាមគ្គង្គៈ ។

**ម្នាលភិក្ខុទាំងឡាយ ក៏សម្មាវាចាដែលមានអាសវៈ ជាចំណែកនៃបុណ្យ ជាផលនៃឧបធិ តើដូចម្ដេច ?** ចេតនាជាគ្រឿងវៀរចាកមុសាវាទ ចាកបិសុណាវាទ ចាកផរុសវាទ ចាកសម្ផប្បលាប; ម្នាលភិក្ខុទាំងឡាយ សម្មាវាចានេះ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ជាចំណែកនៃបុណ្យ ជាផលវិសេសនៃឧបធិ ។

**ម្នាលភិក្ខុទាំងឡាយ ក៏សម្មាវាចា ជាអរិយៈ មិនមានអាសវៈ ជាលោកុត្តរ ជាមគ្គង្គៈ តើដូចម្ដេច ?** ម្នាលភិក្ខុទាំងឡាយ ការវៀរចាក ការដាច់ចេតនាជាគ្រឿងវៀរចាកវចីទុច្ចរិត ៤ យ៉ាង របស់អរិយចិត្ត របស់ចិត្តដែលមិនមានអាសវៈ របស់អ្នកដល់ព្រមដោយអរិយមគ្គ របស់អ្នកចម្រើនអរិយមគ្គ ម្នាលភិក្ខុទាំងឡាយ សម្មាវាចានេះ ជាអរិយៈ មិនមានអាសវៈ ជាលោកុត្តរ ជាមគ្គង្គៈ ។ ល ។...

**ម្នាលភិក្ខុទាំងឡាយ ក៏សម្មាកម្មន្ត តើដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ តថាគតរមែងពោលសម្មាកម្មន្ត ២ យ៉ាង ។ ល ។ ជាផលនៃឧបធិ ។ ម្នាលភិក្ខុទាំងឡាយ ក៏សម្មាកម្មន្ត តើដូចម្ដេច ?** សម្មាកម្មន្តជាអរិយៈ មិនមានអាសវៈ ជាលោកុត្តរ ។ ល ។...

**ម្នាលភិក្ខុទាំងឡាយ សម្មាអាជីព តើដូចម្ដេច ?** ម្នាលភិក្ខុទាំងឡាយ តថាគតពោលសម្មាអាជីព ២ យ៉ាង ។ ល ។ ជាផលនៃឧបធិ ។

**ម្នាលភិក្ខុទាំងឡាយ សម្មាអាជីព តើដូចម្ដេច ?** ជាអរិយៈ មិនមានអាសវៈ ជាមគ្គង្គៈ ។ ម្នាលភិក្ខុទាំងឡាយ ការវៀរ ការវៀរចាក ការវៀរដាច់ ចេតនាជាគ្រឿង វៀរចាកមិច្ឆាអាជីព យ៉ាងណា របស់អរិយចិត្ត របស់ចិត្តដែលរកអាសវៈមិនបាន នៃការដល់ព្រមដោយអរិយមគ្គ របស់អ្នកចម្រើនអរិយមគ្គ ។ ម្នាលភិក្ខុទាំងឡាយ សម្មាអាជីពនេះ តថាគតពោលថា ជាអរិយៈ ជាអនាសវៈ ជាមគ្គង្គៈ

និងជាលោកុត្តរ” [៩] ។ ក្នុងអធិការនេះ ការវៀរតែម្យ៉ាង១ គឺវៀរចាកវចីទុច្ចរិត ៤ កាយទុច្ចរិត ៣ និងមិច្ឆាអាជីព តថាគតពោលថា ជាអរិយៈ ជាអនាសវៈ ជាលោកុត្តរ និងជាមគ្គង្គៈ ។ ក្នុងឋានដូច្នេះ ភាពជាអ្នកចម្រើនដោយចេតនា នឹងមានពីទីណាមក ? មគ្គប្រកបដោយអង្គ ៥ នឹងមានអំពីណា ?, ព្រះមានព្រះភាគទ្រង់សម្តែងសូត្រនេះ ដល់អ្នកមិនមានសេចក្តីព្រួយបារម្ភថា “លោកុត្តរមគ្គប្រកបដោយអង្គ ៨” ។

បើគេកំណត់បានដោយហេតុ មានប្រមាណប៉ុណ្ណេះសោត, សេចក្តីនោះជាការល្អ; **បើគេកំណត់មិនបាន** គប្បីនាំហេតុសូម្បីពួកដទៃមកឱ្យយល់ ។ ពិតមែន ព្រះមានព្រះភាគត្រាស់ពាក្យនេះទុកថា “ម្នាលសុភទ្ទ អរិយមគ្គប្រកបដោយអង្គ ៨ មិនមានក្នុងធម៌វិន័យណា; សូម្បីសមណៈ ក៏មិនមានក្នុងធម៌វិន័យនោះឯង ម្នាលសុភទ្ទ អរិយមគ្គប្រកបដោយអង្គ ៨ មានក្នុងធម៌វិន័យណា ម្នាលសុភទ្ទ សមណៈក៏មានក្នុង ធម៌វិន័យនោះ១ ឯង ។ល។ លទ្ធិរបស់អ្នកដទៃ (បរប្បវាទ) ទទេ ចាកសមណៈ” [១០] ។ មគ្គប្រកបដោយអង្គ ៨ មកហើយក្នុងសូត្រ សូម្បីពួកដទៃ ក៏មានជាអនេករាប់រយសូត្រ ៕

## មគ្គ ៨ ក្នុងកថាវត្ថុបករណ៍

សូម្បីកថាវត្ថុបករណ៍ លោកសកវាទាចារ្យ ក៏បានពោលអាងពុទ្ធវចនៈថា ៖ **“មគ្គានដ្ឋង្គិកោ សេដ្ឋោ សច្ចានំ ចតុរោ បទា វិរាគោ សេដ្ឋោ ធម្មានំ ទ្វិបទានញ្ច ចក្ខុមា** = បណ្តាមគ្គ (ផ្លូវ) ទាំងឡាយ មគ្គប្រកបដោយអង្គ ៨ ប្រសើរជា

---

[៩] ម. ឧ.។

[១០] ទី. ម. ១៦ ។

ទីបំផុត, បណ្ដាសច្ចៈទាំងឡាយ បទ ៤ ប្រសើរបំផុត, បណ្ដាធម៌ទាំងឡាយ វិរាគៈប្រ-សើរបំផុត, បណ្ដាសត្វជើងពីរ ព្រះតថាគតអ្នកមានចក្ខុ (គឺបញ្ញា) ប្រសើរបំផុត” ជាសូត្រមានពិត មិនមែនឬ ? លោកបរវាទាចារ្យទទួលឆ្លើយថា **អាមន្តា** = មែន ។

លោកសកវាទាចារ្យ ទើបពោលថា បើយ៉ាងនោះ មគ្គក៏ប្រកបដោយអង្គ ៨ ។ ក៏បើគេមិនយល់ សូម្បីដោយហេតុមានប្រមាណប៉ុណ្ណោះបានសោត, គប្បីបញ្ជូនលោកទៅដោយពាក្យថា “លោកចូរទៅកាន់វិហារ, ចូរហុតយាគូចុះ” (ការទទួលទានអាហារ ធ្វើឱ្យកើតបដិភាណបាន) ។ កាលដែលនឹងពោលហេតុផលឱ្យច្រើនជាងនេះ ជាអដ្ឋាននោះឯង ។ ពាក្យដែលនៅសល់ក្នុងទីនេះ មានអត្ថងាយទាំងអស់ ។

ក្នុងទីនេះ បណ្ឌិតគប្បីរាប់ន័យទាំងឡាយដូច្នេះ ៖

ក៏ក្នុងមគ្គទាំង ៤ លោកចែកទុក ៤.០០០ ន័យ ក្នុងការសួររួមគ្នា ឆ្លើយរួមគ្នាក្នុងមគ្គប្រកបដោយអង្គ ៨, ក្នុងមគ្គប្រកបដោយអង្គ ៥ ក្នុងការសួររួមគ្នា ឆ្លើយរួមគ្នា លោកចែកទុក ៤.០០០ ន័យ, តែក្នុងការសួរញែកគ្នា ឆ្លើយញែកគ្នា លោកចែកទុកម្យ៉ាងៗ ៤.០០០ ន័យ រួមក្នុងអង្គទាំង ៥ ទើបជា ២០.០០០ ន័យ ។

ម្យ៉ាងទៀត ន័យទាំងអស់ លោកចែកទុកក្នុងមគ្គវិភង្គ ២៨.០០០ ន័យ គឺ ៨.០០០ ន័យ ក្នុងគ្រាមុន រួមនឹង ២.០០០ ន័យ ក្រោយនេះ ដោយប្រការដូច្នេះ ។ ក៏កុសលទាំងឡាយនោះឯង ជាលោកុត្តរដែលកើតឡើងហើយ, តែការរាប់ន័យក្នុងវិបាកគប្បីធ្វើន័យរបស់កុសល ហើយគុណដោយ ៣ នោះឯង ៕

**ពណ៌នាអំពីអភិធម្មភាជនិយចប់**

## ៣. ពណ៌នាអំពីបញ្ហាបុច្ឆកៈ

ក្នុង**បញ្ហាបុច្ឆកៈ** បណ្ឌិតគប្បីជ្រាបសេចក្ដីនៃមគ្គង្គៈជាកុសលជាដើម ដោយទំនងនៃព្រះបាលីនោះឯង; តែក្នុងអារម្មណត្តិកៈ មគ្គទាំងអស់នោះ ជាអប្បមាណតែម្យ៉ាង មិនជាមគ្គារម្មណ៍ ព្រោះប្រារព្ធព្រះនិព្វានដែលជាអប្បមាណធម៌ ហើយទើបប្រព្រឹត្តទៅ, ព្រោះមគ្គរមែងមិនធ្វើផលឱ្យជាអារម្មណ៍; តែថាដោយសហជាតហេតុ ក្នុងទីនេះ កុសលទាំងឡាយ ជាមគ្គហេតុកៈ, ក្នុងការចម្រើនមគ្គ ឈ្មោះថា មគ្គាធិបតី ព្រោះធ្វើវិរិយៈ ឬវីមង្សាឱ្យជាប្រធាន, ក្នុងការចម្រើនមគ្គដែលមានឆន្ទៈ និងចិត្ត ជាប្រធានមិនគប្បីពោលថា ជាមគ្គាធិបតី, សូម្បីក្នុងកាលនៃផលចិត្ត ក៏មិនគប្បីពោលដែរ ។ សូម្បីដោយភាពជាឯការម្មណ៍ ក្នុងអតីតៈជាដើម ក៏មិនគប្បីពោល, តែរមែងឈ្មោះថា ជាពហិទ្ធារម្មណ៍បាន ព្រោះសេចក្ដីដែលព្រះនិព្វាន ជាពហិទ្ធាធម៌ដូច្នេះ ។

សូម្បីក្នុងបញ្ហាបុច្ឆកៈនេះ លោកក៏ពោលថា ជាមគ្គង្គៈ ជាលោកុត្តរ ដែលកើតឡើងហើយដូចគ្នា; សម្រាប់មគ្គង្គៈដែលជាលោកិយ និងលោកុត្តរ ព្រះសម្មាសម្ពុទ្ធត្រាស់ទុកក្នុងសុត្តន្តភាជនិយប៉ុណ្ណោះ, ចំណែកអភិធម្មភាជនិយ និងបញ្ហាបុច្ឆកៈ ត្រាស់ថា ជាលោកុត្តរតែម្យ៉ាង ។ សូម្បីក្នុងមគ្គវិភង្គនេះ ព្រះអង្គក៏ទ្រង់នាំចេញមកចែកសម្ដែងហើយ ៣ បរិវដ្ដដូច្នេះឯង ។

**ពណ៌នាអំពីបញ្ហាបុច្ឆកៈចប់**

**ចប់អដ្ឋកថាមគ្គវិភង្គ**

# ១២. អដ្ឋកថាឈានវិភង្គ

## ពណ៌នាអំពីមាតិកា

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងឈានវិភង្គ ដែលជាលំដាប់តអំពីមគ្គវិភង្គនោះដូចតទៅនេះ ៖

ខាងដើមនេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់តាំងសូម្បីមាតិកា (មេបទ) នៃសុត្តន្តភាជនិយទាំងអស់ជាមុនសិន ។ ក្នុងមាតិកាទាំងនោះ ពាក្យថា **ឥធ** ជាពាក្យសម្តែងពន្យល់ដល់ពាក្យទូន្មានដែលពិត ដោយអាងអាស្រ័យបុគ្គល អ្នកសម្បូណ៌ដោយសេចក្តីដល់ព្រមក្នុងករណីយកិច្ចដែលជាចំណែកខាងដើម ដែលញ៉ាំងឈាន មានប្រការទាំងពួងឱ្យកើតឡើងផង, ទាំងជាការបដិសេធសេចក្តីពិតរបស់សាសនាដទៃផង ។ សេចក្តីនេះ សមដូចដែលព្រះអង្គត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ សមណៈមាននៅក្នុងសាសនានេះប៉ុណ្ណោះ ។ល ។ លទ្ធិដទៃទទេចាកសមណៈ” ជាដើម ។

ពាក្យថា **ភិក្ខុ** ជាពាក្យសម្តែងដល់បុគ្គល អ្នកញ៉ាំងឈានទាំងនោះ ឱ្យកើតឡើង ។

ពាក្យថា **បាតិមោក្ខសំវរសំវុតោ** នេះ ជាពាក្យពន្យល់ដល់សេចក្តីដែលភិក្ខុនោះតាំងនៅមាំក្នុងបាតិមោក្ខសំវរៈ ។

ពាក្យថា **វិហរតិ** នេះ ជាពាក្យអធិប្បាយដល់សេចក្តីដែលភិក្ខុនោះ ជាអ្នកដល់ព្រមដោយការនៅ ដែលសមគួរដល់សេចក្តីជាយ៉ាងនោះ ។

ពាក្យថា “**អាចារគោចរសម្បន្នោ** = ដល់ព្រមហើយដោយអាចារ និងគោចរ” នេះ ជាការសម្តែងដល់ឧបការធម៌របស់ភិក្ខុនោះ ដែលមានបាតិមោក្ខសំវរៈខាងដើម

និងមានការប្រកបរឿយៗ ក្នុងឈានជាទីបំផុត ។

ពាក្យថា "**អនុមត្តេសុ វជ្ជេសុ ភយទស្សាវី** = ឃើញទោសមានប្រមាណតិច" នេះ ជាពាក្យពន្យល់ដល់សេចក្តីដែលភិក្ខុនោះ មានការមិនឃ្លាតចាកបាតិមោក្ខជាធម្មតា ។

ពាក្យថា "**សមាទាយ** = សមាទានហើយ" នេះ ជាពាក្យសម្តែងដល់ការកាន់យកសិក្ខាបទទាំងឡាយរបស់ភិក្ខុនោះ ដែលមិនសល់ ។

ពាក្យថា "**សិក្ខតិ** = ប្រព្រឹត្ត ឬសិក្សា" ជាពាក្យសម្តែងដល់ភិក្ខុនោះ ជាអ្នកដល់ព្រមដោយសិក្ខា ។

ពាក្យថា "**សិក្ខាបទេសុ** = ក្នុងសិក្ខាបទទាំងឡាយ" នេះ ជាពាក្យសម្តែងដល់ធម៌ដែលភិក្ខុនោះគប្បីសិក្សា ។

ពាក្យថា "**ឥន្ទ្រិយេសុ**" នេះ ជាពាក្យសម្តែងដល់ភូមិ (ភូមិបដិបត្តិ) ព្រោះភាវៈនៃភិក្ខុនោះ ជាអ្នកមានទ្វារគ្រប់គ្រងហើយ ។ អាចារ្យទាំងឡាយពោលថា ពាក្យនេះ ជាពាក្យសម្តែងដល់ឱកាសដែលបុគ្គលគួររក្សាដូច្នេះក៏បាន ។

ពាក្យថា "**គុត្តទ្វារោ**" នេះ ជាពាក្យសម្តែងដល់ភាវៈនៃភិក្ខុនោះ ជាអ្នកមានអារក្ខា (ការរក្សា) ដែលសង្រួមល្អហើយក្នុងទ្វារទាំង ៦ ។

ពាក្យថា "**ភោជនេ មត្តញ្ញូ** = ដឹងប្រមាណក្នុងភោជន" នេះ ជាពាក្យសម្តែងដល់ភាវៈនៃភិក្ខុនោះមានគុណធម៌ និងមានសេចក្តីសន្តោសជាដើម ។

ពាក្យថា "**បុព្វរត្តាបររត្តំ ជាគរិយានុយោគមនុយុត្តោ** = ប្រកបសេចក្តី

ព្យាយាម រហូតអស់បឋមយាម និងបច្ឆិមយាម” នេះ ជាពាក្យសម្តែងដល់ការរស់នៅរបស់ភិក្ខុនោះ ។

ពាក្យថា “**សាតច្ចំ នេបក្កំ** = ប្រកបសេចក្តីព្យាយាមដែលប្រព្រឹត្តទៅជាប់ជានិច្ច និងប្រកបដោយបញ្ញាដែលរក្សាខ្លួន” នេះ ជាពាក្យសម្តែងដល់ភាវៈនៃភិក្ខុនោះ ជាអ្នកធ្វើការព្យាយាមឱ្យជាប់តគ្នាទៅដោយសេចក្តីព្យាយាម ដែលសម្រេចហើយដោយបញ្ញា ។

ពាក្យថា “**ពោធិបក្ខិកានំ ធម្មានំ ភាវនានុយោគមនុយុត្តោ** = ប្រកបសេចក្តីព្យាយាមចម្រើននូវពោធិបក្ខិយធម៌” នេះ ជាពាក្យសម្តែងដល់សេចក្តីដែលជាចំណែកនៃការចាក់ធ្លុះ ដោយការបដិបត្តិរបស់ភិក្ខុនោះ ។

ពាក្យថា “**សោ អភិក្កន្តេ** ។ បេ ។ **តុណ្ហីភាវេ សម្បជានការី ហោតិ** = ភិក្ខុនោះដឹងច្បាស់ជាប្រក្រតី ក្នុងការឈានទៅមុខ ។ ល ។ ជាអ្នកដឹងច្បាស់ជាប្រក្រតីក្នុងការដើរ ឈរ អង្គុយ ដេក ភ្ញាក់ឡើង និយាយ និងនៅស្ងៀម” នេះ ជាពាក្យសម្តែងដល់ភាវៈនៃភិក្ខុនោះ ជាអ្នកប្រកបហើយដោយសតិសម្បជញ្ញៈ ក្នុងទីទាំងពួង ។

ពាក្យថា “**សោ វិវិត្តំ សេនាសនំ ភជតិ** = ភិក្ខុនោះអាស្រ័យសេនាសនៈដែលស្ងាត់” នេះ ជាពាក្យសម្តែងដល់ភាវៈនៃភិក្ខុនោះ កាន់យកសេនាសនៈដែលសមគួរ ។

ពាក្យថា “**អរញ្ញំ ។បេ។ បដិសល្លានសារូប្បំ** = ភិក្ខុនោះអាស្រ័យសេនា

សនៈដ៏ស្ងាត់ គឺព្រៃ ។ ល ។ សមគួរដល់ការគេចពួន” នេះ ជាពាក្យសម្ដែងដល់ប្រភេទសេនាសនៈដែលមិនមានទោស និងមានអានិសង្ស ។

ពាក្យថា “**សោ អរញ្ញគតោ វា** = ភិក្ខុនោះទៅព្រៃក៏ដោយ” នេះ ជាពាក្យសម្ដែងដល់ភាវៈនៃភិក្ខុនោះ ជាអ្នកប្រកបហើយដោយសេនាសនៈ មានប្រការតាមដែលពោលហើយនោះ ។

ពាក្យថា “**និសីទតិ** = អង្គុយ” នេះ ជាពាក្យសម្ដែងដល់ភាវៈនៃភិក្ខុនោះ ជាអ្នកមានឥរិយាបថដែលសមគួរដល់ការប្រកបសេចក្ដីព្យាយាម ។

ពាក្យថា “**បរិមុខំ សតឹ ឧបដ្ឋបេត្វា** = តាំងសតិមានមុខឆ្ពោះទៅរកកម្ម-ដ្ឋាន” នេះ ជាពាក្យសម្ដែងដល់ភាវៈនៃភិក្ខុនោះ ជាអ្នកផ្ដើមប្រកបដោយការព្យាយាម ។

ពាក្យថា “**សោ អភិជ្ឈំ លោកេ បហាយ** = ភិក្ខុនោះ នឹងលះអភិជ្ឈា ក្នុងលោក គឺខន្ធ ៥ បានហើយ” ជាដើម ជាពាក្យសម្ដែងដល់ភាវៈនៃភិក្ខុនោះ ជាអ្នកលះនីវរណៈ ដោយការប្រកបសេចក្ដីព្យាយាមរឿយៗ ក្នុងកម្មដ្ឋាន ។

ពាក្យថា “**តស្សេវ បហីននីវរណស្ស វិវិច្ចេវ កាមេហិ** = ភិក្ខុនោះ លះនីវរណៈទាំង ៥ នេះ ដែលធ្វើឱ្យចិត្តសៅហ្មង ធ្វើឱ្យបញ្ញាទន់ខ្សោយបានហើយ ស្ងាត់ចាកកាមទាំងឡាយ” ជាដើម ជាពាក្យសម្ដែងដល់ការសម្រេចឈានដោយលំដាប់ ។

មួយវិញទៀត ពាក្យថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុញុំាងឈានឱ្យកើតឡើងក្នុងសាសនានេះ ។ ក៏ព្រោះហេតុដែលភិក្ខុញុំាងឈានឱ្យកើតឡើង គប្បីជម្រះសីល ៤ ឱ្យបរិសុទ្ធ, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគសម្ដែងថា **បាតិមោក្ខសំវរសំវុតោ**

នេះ ជាសីលបរិសុទ្ធវិសេសហើយក្នុងបាតិមោក្ខសំវរៈក្នុងពេលឥឡូវនេះ ។

ព្រះមានព្រះភាគទ្រង់សម្តែងអាជីវបារិសុទ្ធិសីលដោយពាក្យថា អាចារគោចរសម្បន្នោជាដើម ។ ទ្រង់សម្តែងសីលទាំងពីររបស់ភិក្ខុនោះ ដោយមិនសល់ ដោយពាក្យថា **សមាទាយ សិក្ខតិ សិក្ខាបទេសុ** នេះ ។ ទ្រង់សម្តែងឥន្ទ្រិយសំវរៈ ដោយពាក្យថា **ឥន្ទ្រិយេសុ គុត្តទ្វារោ** នេះ ។ ទ្រង់សម្តែងបច្ចយសន្និស្សិតសីល ដោយពាក្យថា **ភោជនេ មត្តញ្ញូ** នេះ ។ ទ្រង់សម្តែងធមិទាំងឡាយ ដែលមានឧបការៈដល់ការចម្រើនឈានរបស់ភិក្ខុអ្នកតាំងនៅហើយ ក្នុងសីលដោយពាក្យថា **បុព្វរត្តាបររត្តំ** ជាដើម ។ ទ្រង់សម្តែងការប្រកបដោយល្អក្នុងសតិសម្បជញ្ញៈ ដោយការមិនសាបសូន្យទៅនៃធមិទាំងឡាយនោះ និងទាំងសេចក្តីមិនសាបសូន្យទៅនៃកម្មដ្ឋានដោយពាក្យថា សោ **អភិក្កន្តេ** ជាដើម ។ រមែងទ្រង់សម្តែងការកាន់យកសេនាសនៈ ដែលសមគួរដល់ភាវនា ដោយពាក្យថា **សោ វិវិត្តំ** ជាដើម ។ ទ្រង់សម្តែងឥរិយាបថដែលសមគួរដល់ឈាន និងការផ្តើមចម្រើន ឈានរបស់ភិក្ខុ អ្នកចូលដល់ហើយនូវសេនាសនៈនោះ ដោយពាក្យថា **សោ អរញ្ញគតោ វា** ជាដើម; ទ្រង់សម្តែងការលះធមិដែលជាសត្រូវដល់ឈាន ដោយការផ្តើមចម្រើនឈាន ដោយពាក្យថា **សោ អភិជ្ឈំ** ជាដើម ។ ទ្រង់សម្តែងលំដាប់នៃការសម្រេចឈានទាំងអស់របស់ភិក្ខុអ្នកមានធមិ ដែលជាសត្រូវដល់ឈានដែលលះហើយ យ៉ាងនេះដោយពាក្យថា “**សោ ឥមេ បញ្ច នីវរណេ បហាយ**” ជាដើម ៕

## ពណ៌នាអំពីមាតិកាចប់

## ១_ពណ៌នាអំពីសុត្តន្តភាជនិយ
## អធិប្បាយបទមាតិកានិទ្ទេស

ឥឡូវនេះ ព្រះមានព្រះភាគដើម្បីទ្រង់សម្តែង និងចែកមាតិកាតាមដែលទ្រង់ត្រាស់តាំងទុក ទើបផ្តើមពាក្យថា **ឥធាតិ ឥមិស្សា ទិដ្ឋិយា** = បទថា **ឥធ** មានអធិប្បាយថា ក្នុងទិដ្ឋិនេះជាដើម ។

ក្នុងមាតិកានិទ្ទេសទាំងនោះ ពាក្យទូន្មានរបស់ព្រះសព្វញ្ញុពុទ្ធ ពោលគឺត្រៃសិក្ខា ព្រះមានព្រះភាគត្រាស់ទុក ១០ [*] បទ មានពាក្យថា **ឥមិស្សា ទិដ្ឋិយា** ជាដើម ។ ពិតមែន ត្រៃសិក្ខានោះ ព្រះមានព្រះភាគហៅថា ទិដ្ឋិ ព្រោះសេចក្តីដែលត្រៃសិក្ខានោះ ព្រះមានព្រះភាគត្រាស់ដឹងហើយ ទ្រង់ឃើញហើយ (ទើបហៅឈ្មោះថា ទិដ្ឋិ); ត្រាស់ហៅឈ្មោះថា **ខន្តិ** ដោយអំណាចនៃសេចក្តីអត់ធន់របស់ព្រះមានព្រះភាគនោះឯង, ត្រាស់ហៅឈ្មោះថា រុចិ ដោយអំណាចសេចក្តីត្រេកអរ, ត្រាស់ហៅឈ្មោះថា លទ្ធិ (អាទាយ) ដោយអំណាចនៃការកាន់យក, ត្រាស់ហៅឈ្មោះថា **ធម្មៈ** ព្រោះអត្ថថាជាសភាវៈ, ត្រាស់ហៅឈ្មោះថា **វិន័យ** ព្រោះអត្ថថា គួរដល់ការសិក្សា, ត្រាស់ហៅឈ្មោះថា **ធម្មវិន័យ** សូម្បីដោយអត្ថទាំងពីរនោះ, អត្ថទាំងពីរនោះ ត្រាស់ហៅឈ្មោះថា **បាវចនៈ** ដោយអំណាចនៃពាក្យដែលព្រះអង្គត្រាស់ហើយ, ត្រាស់ហៅឈ្មោះថា **ព្រហ្មចរិយៈ** ព្រោះអត្ថថា ប្រព្រឹត្តធម៌ដ៏ប្រសើរបំផុត, ត្រាស់ហៅឈ្មោះថា

---

[*] ១០ បទ គឺ ទិដ្ឋិ, ខន្តិ, រុចិ, លទ្ធិ, ធម្ម, វិន័យ, ធម្មវិន័យ, បាវចនៈ, ព្រហ្មចរិយៈ និងសត្ថុសាសនៈ ។

សត្ថុសាសនៈ ដោយអំណាចនៃការឱ្យសេចក្ដីទូន្មាន ។ ព្រោះហេតុនោះ ក្នុងពាក្យថា **ឥមិស្សា ធិដ្ឋិយា** ជាដើម ទើបបានដល់ ក្នុងទិដ្ឋិរបស់ព្រះពុទ្ធនេះ; ក្នុងខន្តិរបស់ព្រះពុទ្ធជាម្ចាស់នេះ, ក្នុងរុចិរបស់ព្រះពុទ្ធជាម្ចាស់នេះ, ក្នុងលទ្ធិរបស់ព្រះពុទ្ធជាម្ចាស់នេះ, ក្នុងធម្មរបស់ព្រះពុទ្ធជាម្ចាស់នេះ, ក្នុងវិន័យរបស់ព្រះពុទ្ធជាម្ចាស់នេះ ។

ក្នុងសេចក្ដីនេះ បណ្ឌិតគប្បីជ្រាបសេចក្ដីដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា "ម្នាលគោតមី នាងជ្រាបធម៌ឯណា ធម៌នេះប្រព្រឹត្តទៅដើម្បីតម្រេក, មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក; ប្រព្រឹត្តទៅដើម្បីការប្រកប, មិនប្រព្រឹត្តទៅដើម្បីការមិនប្រកប; ប្រព្រឹត្តទៅដើម្បីបង្គ, មិនប្រព្រឹត្តទៅដើម្បីមិនបង្គ; ប្រព្រឹត្តទៅដើម្បីការប្រកាន់, មិនប្រព្រឹត្តទៅដើម្បីការលះបង់; ប្រព្រឹត្តទៅដើម្បីប្រាថ្នាច្រើន, មិនប្រព្រឹត្តទៅដើម្បីប្រាថ្នាតិច; ប្រព្រឹត្តទៅដើម្បីមិនសន្តោស, មិនប្រព្រឹត្តទៅដើម្បីសន្តោស; ប្រព្រឹត្តទៅដើម្បីការច្របូកច្របល់, មិនប្រព្រឹត្តទៅដើម្បីការស្ងប់ស្ងាត់; ប្រព្រឹត្តទៅដើម្បីការខ្ជិលច្រអូស, មិនប្រព្រឹត្តទៅដើម្បីការប្រារព្ធព្យាយាម; ប្រព្រឹត្តទៅដើម្បីចិញ្ចឹមក្រ, មិនប្រព្រឹត្តទៅដើម្បីចិញ្ចឹមងាយ ។ ម្នាលគោតមី នាងគប្បីទ្រទ្រង់ចាំទុកធម៌ទាំងនេះដោយចំណែកតែមួយថា 'នុ៎ះមិនមែនធម៌, នុ៎ះមិនមែនវិន័យ, នុ៎ះមិនមែនសត្ថុសាសនា" ។

ម្នាលគោតមី នាងជ្រាបធម៌ឯណាថា 'ធម៌នេះ រមែងប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក, មិនប្រព្រឹត្តទៅដើម្បីតម្រេក ។ល ។ រមែងប្រព្រឹត្តទៅដើម្បីចិញ្ចឹមងាយ,

មិនប្រព្រឹត្តទៅដើម្បីចិញ្ចឹមលំបាក’ ដូច្នេះ ។

ម្នាលគោតមី នាងគប្បីទ្រទ្រង់ចាំទុកដោយចំណែកមួយថា ‘ នុ៎ះជាធម៌, នុ៎ះជាវិន័យ, នុ៎ះជាសត្ថុសាសនា” [១១] ដូច្នេះ ។ កាលដែលសេចក្ដីប្រព្រឹត្តទៅដូច្នេះ ក្នុងធម្មវិន័យរបស់ព្រះពុទ្ធនេះ ក្នុងបាវចនៈរបស់ព្រះពុទ្ធជាម្ចាស់នេះ ក្នុងព្រហ្មចរិយៈនេះ ក្នុងពាក្យទូន្មានរបស់ព្រះពុទ្ធនេះ ក៏ដូចគ្នា ។ ម្យ៉ាងទៀត ពាក្យទូន្មានទាំងអស់ ពោលគឺត្រៃសិក្ខានេះ ឈ្មោះថា **ទិដ្ឋិ** ព្រោះសេចក្ដីជាធម៌ ដែលព្រះមានព្រះភាគទ្រង់ឃើញហើយ ព្រោះសេចក្ដីជាបច្ច័យដល់សម្មាទិដ្ឋិ និងព្រោះសេចក្ដីជាខាងដើមរបស់សម្មាទិដ្ឋិ; ឈ្មោះថា **ខន្តិ** ដោយអំណាចនៃការអត់ធន់របស់ព្រះពុទ្ធជាម្ចាស់; ឈ្មោះថា **រុចិ** ដោយអំណាចនៃការពេញចិត្ត; និងឈ្មោះថា **លទ្ធិ** ដោយអំណាចនៃការប្រកាន់យក ។

សភាវៈណា រមែងទ្រទ្រង់នូវការកៈ (ការធ្វើ) របស់ខ្លួនមិនឱ្យធ្លាក់ទៅក្នុងអបាយទាំងឡាយ ព្រោះហេតុដូច្នោះ សភាវៈនោះ ទើបឈ្មោះថា **ធម្មៈ**; សភាវៈនុ៎ះឯង ទើបឈ្មោះថា **វិន័យ** ព្រោះអត្ថថា រមែងនាំចេញនូវសភាវៈដែលជាចំណែកនៃសង្កិលេស ។ ធម្មនោះផង វិន័យនោះផង ឈ្មោះថា **ធម្មវិន័យ** ។

ម្យ៉ាងទៀត ឈ្មោះថា **ធម្មវិន័យ** ព្រោះអត្ថថា ជាសភាវៈកម្ចាត់អកុសលទាំងឡាយ ដោយកុសលធម៌ទាំងឡាយ ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា “ម្នាលគោតមី នាងគប្បីជ្រាបធម៌ណា ធម៌នោះ រមែងប្រព្រឹត្តទៅដើម្បី

---

[១១] វិនយ. ១១, អំ. អដ្ឋក. ។

ប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីតម្រេក ។ ល ។ ម្នាលគោតមី នាងគប្បីដឹងដោយចំណែកមួយថា ' នុ៎ះជាធម៌, នុ៎ះជាវិន័យ, នុ៎ះជាសត្ថុសាសនា" [១២] ដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា **ធម្មវិន័យ** ព្រោះអត្ថថា ការហ្វឹកហាត់ដោយធម៌ មិនមែនហ្វឹកហាត់ដោយអាជ្ញា មានដំបងជាដើម ។ ពិតដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

**"ទណ្ឌេនេកេ ទមយន្តិ អង្កុសេហិ កសាហិ ច**
**អទណ្ឌេន អសត្ថេន នាគោ ទន្តោ មហេសិនា**

មនុស្សពួកខ្លះ រមែងហ្វឹកហាត់សត្វដោយដំបង ជន្លួញ
និងដោយខ្សែតី តែព្រះមានព្រះភាគ អ្នកស្វែងរកគុណ
ដ៏ធំ ទ្រង់ហ្វឹកហាត់ដំរីដ៏ប្រសើរ មិនមែនដោយដំបង មិន
មែនដោយសស្ត្រាទេ" [១៣] ដូច្នេះ ។

កាលសត្វទាំងឡាយដែលព្រះអង្គទ្រង់ណែនាំដោយធម៌ដូច្នោះហើយ សេចក្តីឫស្យា នឹងគប្បីមានដល់អ្នកដឹងទាំងឡាយ បានយ៉ាងណា [១៤] ។ ម្យ៉ាងទៀត ការ

---

[១២] វិនយ. ១១, អំ. អដ្ឋក.។

[១៣] វិនយ., ម. ម.។

[១៤] វិនយ.។

[១៥] អំ. ចតុក្ក.។

[១៦] ម. ម.។

ណែនាំដោយធម៌ ឈ្មោះថា **ធម្មវិន័យ** ។ ពិតមែន ការណែនាំ (វិន័យ) នេះ រមែងប្រព្រឹត្តទៅដើម្បីធម៌ដែលរកទោសមិនបាន, ទាំងមិនប្រព្រឹត្តទៅដើម្បីភោគៈ និងអាមិសក្នុងភព ។ ដោយហេតុនោះ ព្រះភគវាអ្នកមានបញ្ញាទូលំទូលាយ ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ រមែងមិនប្រព្រឹត្តព្រហ្មចរិយៈដើម្បីបោកបញ្ឆោតពួកជន"[១៥] ដូច្នេះ ។ សូម្បីព្រះបុណ្ណត្ថេរ ក៏បានពោលថា "ម្នាលអាវុសោ ភិក្ខុរមែងប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីអនុបាទាបរិនិព្វាន (រលត់មិនមានសល់)"[១៦] ដូច្នេះ ។ មួយាងទៀត ឈ្មោះថា វិន័យ ព្រោះអត្ថថា រមែងនាំអ្នកប្រសើរទៅ ។ វិន័យ (ការណែនាំ) ដោយធម៌ ក៏ឈ្មោះថា **ធម្មវិន័យ** ។ ពិតមែន ធម្មវិន័យនេះ រមែងឱ្យចេញចាកសង្ខារធម៌ ឬសោកាទិធម៌ ហើយនាំទៅកាន់ព្រះនិព្វានដ៏ប្រសើរបាន ។ មួយាងទៀត វិន័យរបស់ព្រះពុទ្ធអ្នកមានធម៌, មិនមែនរបស់ម្ចាស់លទ្ធិទាំងឡាយទេ ព្រោះហេតុនោះ ទើបឈ្មោះថា **ធម្មវិន័យ** ។ ពិតមែន ព្រះមានព្រះភាគព្រះអង្គជាធម្មភូត (អ្នករកឃើញធម៌) ទើបត្រាស់ថា វិន័យរបស់ធម៌នោះឯង ។

មួយាងទៀត ព្រោះធម៌ទាំងឡាយនោះឯង ជាធម៌គប្បីដឹងក្រៃលែង = **អភិញ្ញេយ្យ**, ជាធម៌គប្បីកំណត់ដឹង = **បរិញ្ញេយ្យ**, ជាធម៌គប្បីលះ = **បហាតព្វា**, ជាធម៌គប្បីចម្រើន = **ភាវេតព្វា**, ជាធម៌គប្បីធ្វើឱ្យជាក់ច្បាស់ = **សច្ឆិកាតព្វា**; ព្រោះហេតុនោះ វិន័យក្នុងធម៌ទាំងឡាយនេះ មិនមែនវិន័យក្នុងសត្វទាំងឡាយ មិនមែនវិន័យក្នុងជីវៈទាំងឡាយ ទើបឈ្មោះថា **ធម្មវិន័យ** ។ ឈ្មោះថា **បវចនៈ** ព្រោះអត្ថថា ជាប្រធាន

(ជាធំ) ជាងពាក្យរបស់ពួកជនដទៃ ដោយពាក្យទាំងឡាយ មានពាក្យដែលប្រព្រឹត្ត ទៅជាមួយអត្ថ និងព្យញ្ជនៈជាដើម ។ បវចនៈនោះឯង ឈ្មោះថា **បាវចនៈ** ។ ឈ្មោះ ថា **ព្រហ្មចរិយៈ** ព្រោះជាព្រហ្មចរិយៈដ៏ប្រសើរជាងព្រហ្មចរិយៈទាំងអស់ ។ ឈ្មោះថា សត្ថុសាសនា ព្រោះថា ពាក្យទូន្មានរបស់ព្រះមានព្រះភាគនោះ ជាគ្រូរបស់ទេវតា និងមនុស្សទាំងឡាយ ។ ម្យ៉ាងទៀត សូម្បីពាក្យថា ពាក្យទូន្មានដែលជាសាស្តា ក៏ ឈ្មោះថា **សត្ថុសាសនា** បាន ។ ពិតមែន ព្រះធម្មវិន័យនោះឯង ព្រះមានព្រះភាគ ត្រាស់ថា ជាសាស្តា ដូចបាលីថា **“សោ វោ មមច្ចយេន សត្ថា** = ធម៌ និងវិន័យនោះ នឹងជាសាស្តារបស់អ្នកទាំងឡាយ ដោយកាលកន្លងទៅនៃតថាគត” ជាដើម គប្បីជ្រាប សេចក្តីនៃបទទាំងឡាយនោះ ដូចពណ៌នាមកដូច្នេះ; ក៏ព្រោះភាវៈនៃភិក្ខុជាអ្នកញ៉ាំង ឈាន មានប្រការទាំងពួង ឱ្យកើតឡើងប្រាកដក្នុងសាសនានេះ, មិនបានប្រាកដក្នុង សាសនាដទៃ, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ធ្វើពាក្យនិយមក្នុងបទនោះ ទុក ដោយបទថា **“ឥមិស្សា”** ដូច្នេះខ្លះ ថា **“ឥមស្មឹ”** ដូច្នេះខ្លះ (ក្នុងទិដ្ឋិនេះជាដើម) ។ សេចក្តីនេះ ជាពាក្យអធិប្បាយមាតិកាបទនិទ្ទេសក្នុងពាក្យថា **“ឥធ”** ៕

## ភិក្ខុនិទ្ទេស

ក្នុងភិក្ខុនិទ្ទេស បទថា **សមញ្ញាយ** (បានដល់ជាភិក្ខុ) ដោយបញ្ញត្តិ, គឺដោយ វោហារ, ពិតមែន មនុស្សខ្លះរមែងប្រាកដថា ជាភិក្ខុដោយសមញ្ញានោះឯង ។ ពិត យ៉ាងនោះមែន ជនទាំងឡាយរាប់ចំនួនភិក្ខុទាំងឡាយ ក្នុងគ្រានិមន្តជាដើម រមែងរួម

សូម្បីទាំងសាមណេរផង ហើយពោលថា “មានភិក្ខុ ១០០ រូប, ១០០០ រូប” ដូច្នេះ ។

បទថា **បដិញ្ញាយ** (បានដល់ជាភិក្ខុ) ដោយបដិញ្ញារបស់ខ្លួន; ពិតមែន អ្នកខ្លះជាភិក្ខុសូម្បីដោយការបដិញ្ញា ។ គប្បីជ្រាបការកើតឡើងនៃបទថា **ភោ ឯត្ថ** នោះ បណ្ដាពាក្យទាំងឡាយ មានពាក្យបដិញ្ញាថា “ម្នាលអ្នកមានអាយុ យើងជាភិក្ខុ” ជាដើម ។ ក៏បដិញ្ញានេះ ឈ្មោះថា ប្រកបដោយធម៌ ជាពាក្យដែលព្រះអានន្ទពោលហើយ ។ មួយទៀត ក្នុងវេលារាត្រី ជនទាំងឡាយសូម្បីទ្រុស្តសីលដើរតាមផ្លូវមក កាលមានអ្នកសួរថា “អ្នកណាក្នុងទីនេះ” ដូច្នេះ អ្នកទ្រុស្តសីលនោះ រមែងពោលដោយបដិញ្ញា ដែលមិនជាធម៌ ដែលមិនពិតថា “យើងជាភិក្ខុ” ។

បទថា **ភិក្ខតិ** = រមែងសុំ ។ ពិតមែន អ្នកខ្លះ រមែងសុំ រមែងស្វែងរក រមែងស្វែងរកនូវភិក្ខា, បានក៏ដោយ មិនបានក៏ដោយ អ្នកនោះ ឈ្មោះថា ភិក្ខុ ព្រោះអត្ថថា រមែងសុំដោយពិត ។ បទថា ភិក្ខកោ គឺលោកបន្ថែមដោយព្យញ្ជនៈ, អធិប្បាយថា ក៏ឈ្មោះថា ភិក្ខុ ព្រោះជាអ្នកមានការសុំជាធម្មតា; បទថា ភិក្ខាចរិយំ **អជ្ឈុបគតោ** = ឈ្មោះថា ជាអ្នកចូលដល់ភិក្ខាចារ ព្រោះភាវៈជាអ្នកចូលដល់ភិក្ខា ដែលព្រះពុទ្ធជាដើមចូលដល់ហើយ; ពិតមែន អ្នកខ្លះលះគំនរភោគតិចខ្លះ ច្រើនខ្លះ ចេញអំពីផ្ទះហើយ បួសជាបព្វជិតមិនមានផ្ទះ លះការចិញ្ចឹមជីវិតដោយកសិកម្ម និងគោរក្ខកម្មជាដើម អ្នកនោះឈ្មោះថា **ភិក្ខុ** ព្រោះអត្ថថា អ្នកចូលដល់ភិក្ខាចារដោយការបិទបាំងទុកនូវភេទ ។ ម្យ៉ាងទៀត សូម្បីអ្នកណាបរិភោគបាយដែលគេរែកមក ត្រង់កណ្ដាលវិហារ ព្រោះភាព

ជាអ្នកមានជីវិតជាប់ដោយសារអ្នកដទៃ អ្នកនោះ ក៏ឈ្មោះថា **ភិក្ខុ** ព្រោះអត្ថថា អ្នកចូលដល់ភិក្ខា ។

ម្យ៉ាងទៀត អ្នកណាអាស្រ័យដុំបាយ ព្រោះភាពជាអ្នកមានឧស្សាហ៍កើតឡើងហើយក្នុងបព្វជ្ជា អ្នកនោះ ក៏ឈ្មោះថា ភិក្ខុ អ្នកចូលដល់ភិក្ខាចារ ។

បុគ្គលណាដែលទ្រទ្រង់ផ្ទាំងសំពត់ដែលត្រូវទម្លាយ ដោយការទម្លាយនូវតម្លៃ ផស្សៈ (ការពាល់ត្រូវ) និងពណ៌; ក្នុងការទម្លាយទាំងនោះ គប្បីជ្រាបការទម្លាយតម្លៃដោយការកាត់ដោយកាំបិត ។ ពិតមែន ផ្ទាំងសំពត់ សូម្បីមានតម្លៃទាំងពាន់ កាលត្រូវកាត់ឱ្យជាកំណាត់តូច កំណាត់ធំហើយ រមែងជាសំពត់មានតម្លៃដែលទម្លាយហើយ រមែងមិនបានតម្លៃ សូម្បីតែពាក់កណ្ដាលនៃតម្លៃដើម ។ គប្បីជ្រាបការទម្លាយផស្សៈដោយការដេរដោយអំបោះ ។ ពិតមែន ផ្ទាំងសំពត់សូម្បីមានសម្ផស្សសប្បាយ រមែងជាផស្សៈដែលទម្លាយដោយអំបោះហើយ រមែងដល់សភាពជាផស្សៈគ្រោតគ្រាត; គប្បីជ្រាបការទម្លាយដោយពណ៌ ដោយការជ្រលក់ ព្រោះស្នឹមនៃម្ជុលជាដើម ។ ពិតណាស់ ផ្ទាំងសំពត់សូម្បីស្អាតល្អហើយ រមែងជាផ្ទាំងសំពត់ដែលត្រូវទម្លាយដោយស្នឹម មន្ទិលនៃម្ជុល ចាប់ផ្ដើមអំពីដេរក្នុងទីបំផុត រមែងត្រូវប្រឡាក់ទៅដោយវត្ថុបដិកូលទាំងឡាយមានញើសដៃ និងរបស់បដិកូលជាដើម និងដោយការជ្រលក់ ការធ្វើពិន្ទុកប្ប (ចំណុចសម្គាល់) រមែងខុសទៅពីពណ៌ដើម ។ អ្នកណាទ្រទ្រង់ផ្ទាំងសំពត់ដែលត្រូវទម្លាយហើយ ព្រោះការទ្រទ្រង់ផ្ទាំងសំពត់ដែលត្រូវទម្លាយដោយអាការ ៣ យ៉ាងនេះ អ្នកនោះឈ្មោះថា **ភិក្ខុ** ។ ម្យ៉ាងទៀត ឈ្មោះថា **ភិក្ខុ** ព្រោះអត្ថថា ទ្រទ្រង់សំពត់ដែលត្រូវ

ទម្លាយហើយ ដោយត្រឹមតែហេតុថា ការទ្រទ្រង់សំពត់កាសាវៈដែលជាវិសភាគ (ផ្សេង) ពីសំពត់របស់គ្រហស្ថ ។ ឈ្មោះថា **ភិក្ខុ** ព្រោះកំពុងទម្លាយបាបអកុសលធម៌ទាំងឡាយ ។ ឈ្មោះថា **ភិក្ខុ** ព្រោះកំពុងទម្លាយកិលេស ៥ ដោយសោតាបត្តិមគ្គ; ឈ្មោះថា **ភិក្ខុ** ព្រោះកំពុងទម្លាយកិលេស ៤ ដោយសកទាគាមិមគ្គ; ឈ្មោះថា **ភិក្ខុ** ព្រោះកំពុងទម្លាយកិលេស ៤ ដោយអនាគាមិមគ្គ; ឈ្មោះថា **ភិក្ខុ** ព្រោះកំពុងទម្លាយកិលេស ៨ ដោយអរហត្តមគ្គ; ព្រះមានព្រះភាគទ្រង់សម្តែងបុគ្គលដែលតាំងនៅក្នុងមគ្គ ៤ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ ចំណែកបុគ្គលដែលតាំងនៅក្នុងផល ៤ ព្រះអង្គទ្រង់សម្តែងនូវពាក្យថា **ភិន្នត្តា** = ទម្លាយបាបអកុសលធម៌ហើយ; ពិតមែន ព្រះសោតាបន្នទម្លាយកិលេស ៥ យ៉ាង ដោយសោតាបត្តិមគ្គហើយតាំងនៅ, សកទាគាមីទម្លាយកិលេស ៤ ដោយសកទាគាមិមគ្គហើយតាំងនៅ, ព្រះអនាគាមីទម្លាយកិលេស ៤ ដោយអនាគាមិមគ្គហើយតាំងនៅ, ព្រះអរហន្តទម្លាយកិលេស ៨ ដោយអរហត្តមគ្គហើយតាំងនៅ ។ ព្រះអរិយបុគ្គលទាំងឡាយ អ្នកតាំងនៅក្នុងផល ៤ យ៉ាងនេះ ឈ្មោះថា ភិក្ខុ ព្រោះទម្លាយបាបអកុសលហើយ ដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **“ឱធិសោ កិលេសានំ បហានា** = ព្រោះលះកិលេសចំណែកខ្លះ” ។ ពាក្យថា **ឱធិ** បានដល់ ចំណែកខ្លះ ឬខេត្តដែន មានពីរយ៉ាង គឺ មគ្គោធិ ( **មគ្គ** + **ឱធិ > មគ្គោធិ** = ចំណែក ឬដែនរបស់មគ្គ), **កិលេសោធិ** ( **កិលេស** + **ឱធិ > កិលេសោធិ** = ចំណែក ឬខេត្តដែនរបស់កិលេស), ខេត្តដែន ឈ្មោះថា **ឱធិ**; ក្នុងឱធិ ២ នោះ ព្រះសោតាបន្ន ឈ្មោះថា **ភិក្ខុ** ព្រោះលះកិលេសចំណែកខ្លះ ដោយ

មគ្គោធិ ។ ពិតមែន មគ្គទាំង ៤ មគ្គ ១ ប៉ុណ្ណោះ លះកិលេសទៅចំណែកខ្លះ មិនមែន មគ្គ ៤ លះកិលេសទាំងអស់ទេ ។ សូម្បីក្នុងសកទាគាមី និងអនាគាមី ក៏ន័យនេះដែរ ។ ក៏ព្រោះសោតាបន្ន ឈ្មោះថា **ភិក្ខុ** ព្រោះលះកិលេសចំណែកខ្លះ គឺកិលេសោធិ ។ ពិតមែន ក្នុងកិលេសដែលលោកគួរលះ លោកលះទៅបានត្រឹមចំណែកខ្លះ, មិនមែនលះទៅម្តងទាំងអស់ទេ ។ តែព្រះអរហន្ត ឈ្មោះថា **ភិក្ខុ** ព្រោះលះកិលេសដោយមិនមានសេសសល់ ។ ពិតមែន លោកលះកិលេសទៅដោយមិនមានសល់ដោយមគ្គ ៤, មិនមែនលះទៅដោយខេត្តដែននៃមគ្គតែមួយទេ ។ ម្យ៉ាងទៀត ក្នុងកិលេសដែលគប្បីលះ លោកលះទៅដោយមិនមានចំណែកនៅសល់ឡើយ ។ ព្រោះថា ដែននៃកិលេសសូម្បីត្រឹមតែម្យ៉ាង ឈ្មោះថា តាំងនៅ មិនបានមាន ។ សូម្បីក្នុងចំណែកទាំងពីរនោះ ព្រះអរហន្ត ឈ្មោះថា **ភិក្ខុ** ព្រោះលះកិលេសទាំងឡាយដោយមិនមានចំណែកនៅសល់ ដូចពណ៌នាមកនេះ ។ គប្បីជ្រាបវិគ្រោះក្នុងបទថា **សេក្ខោ** តទៅ ៖

ព្រះអរិយបុគ្គល ៧ ជាមួយកល្យាណបុថុជ្ជន អ្នកនៅមានការសិក្សា (សិក្ខា) ៣ ព្រោះហេតុនោះ បុគ្គលនេះ ទើបឈ្មោះថា **សេក្ខោ** = អ្នកកំពុងនៅមានការសិក្សា; ក្នុងបុគ្គលទាំងនោះ ព្រះសេក្ខៈណា១ ក៏ឈ្មោះថា ភិក្ខុ; ឈ្មោះថា **អសេក្ខោ** ព្រោះមិនត្រូវការសិក្សា ។ ព្រះខីណាស្រពឈានកន្លងសេក្ខធម៌ហើយ តាំងនៅក្នុងផលដ៏ប្រសើរ ហៅថា **ខីណាសវាសេក្ខៈ** ព្រោះមិនមានសេក្ខធម៌ ដែលលោកគប្បីសិក្សាឱ្យក្រៃលែងជាងនោះ ។

ភិក្ខុបុថុជ្ជនដែលនៅសល់ កំពុងសិក្សានូវសិក្ខា ៣ ក៏មិនមែន សិក្សាហើយក៏មិនមែន ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ភិក្ខុបុថុជ្ជននោះ មិនមែនព្រះសេក្ខៈ និងព្រះអសេក្ខបុគ្គល ។ អ្នកសម្រេចធម៌ដ៏ប្រសើរ គឺសីលដ៏ប្រសើរ សមាធិដ៏ប្រសើរ បញ្ញាដ៏ប្រសើរ វិមុត្តិដ៏ប្រសើរ នេះតាំងនៅ ឈ្មោះថា ភិក្ខុដ៏ប្រសើរ អ្នកមិនលាមក (មិនថោកទាប) ឈ្មោះថា ប្រកបដោយធម៌ដ៏ល្អ ។ ពិតមែន តាំងអំពីកល្យាណបុថុជ្ជនដរាបដល់ព្រះអរហន្ត រមែងដល់ការរាប់ថា ជាភិក្ខុអ្នកតាំងនៅក្នុងធម៌ដ៏ល្អ ព្រោះប្រកបដោយសីលដ៏ល្អ សមាធិដ៏ល្អ បញ្ញាដ៏ល្អ វិមុត្តិដ៏ល្អ វិមុត្តិញ្ញាណទស្សនៈដ៏ល្អ ។ ភិក្ខុអ្នកមិនសៅហ្មង ឈ្មោះថា ភិក្ខុអ្នកបរិសុទ្ធផូរផង់, មានសេចក្តីផូរផង់វិសេសហើយជាអត្ថ ដូចសេចក្តីផូរផង់របស់ទឹកដោះថ្លា ។

បទថា **សារោ** គប្បីជ្រាបថា ឈ្មោះថា ភិក្ខុអ្នកប្រកបដោយធម៌ ដែលជាសារៈ ព្រោះប្រកបដោយសារៈ ៣ មានសីលសារៈជាដើម ដូចផ្ទាំងសំពត់ខៀវ ព្រោះប្រកបដោយពណ៌ខៀវ ។ម្យ៉ាងទៀត ព្រះខីណាស្រពទាំងនោះ គប្បីជ្រាបថា ឈ្មោះថា អ្នកមានធម៌ដែលជាសារៈ ព្រោះប្រាសចាកកិលេសដែលឥតប្រយោជន៍ ។

មួយទៀត ក្នុងសេចក្តីថា ឈ្មោះថា **ភិក្ខុ** ព្រោះកំពុងទម្លាយបាបអកុសលធម៌ទាំងឡាយ ឈ្មោះថា ភិក្ខុ ព្រោះលះកិលេសដោយចំពោះ ដោយចំណែក និងព្រះសេក្ខៈក៏ឈ្មោះថា ភិក្ខុនេះដែរ ។ ក្នុងស្ថាន ៣ ដូចពោលមកនេះ ព្រះមានព្រះភាគត្រាស់សំដៅយកព្រះសេក្ខៈ ៧ ។ ពាក្យថា ឈ្មោះថា ភិក្ខុ ព្រោះទម្លាយបាបអកុសលធម៌ហើយ ។ ឈ្មោះថា ភិក្ខុ ព្រោះលះកិលេសដោយមិនចំពោះ (ដោយមិនសេសសល់) និងអ្នកបរិសុទ្ធផូរផង់ អ្នកឈ្មោះថា ភិក្ខុទាំងពួងនេះ ព្រះមានព្រះភាគត្រាស់សំដៅ

យកព្រះខីណាស្រព; ព្រះមានព្រះភាគជាម្ចាស់ គ្រាទ្រង់សម្ដែងពាក្យថា ភិក្ខុ ដោយសញ្ញាជាដើមយ៉ាងនេះហើយ ឥឡូវនេះដើម្បីសម្ដែងភាពជាភិក្ខុដោយអំណាចនៃការឧបសម្ប័ទ ទើបត្រាស់ថា “**សមគ្គេន សង្ឃេន**” ជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យថា “**សមគ្គេន សង្ឃេន** = ដោយសង្ឃអ្នកព្រមព្រៀងគ្នា” បានដល់ ភិក្ខុអ្នកគួរដល់សង្ឃកម្មក្នុងការធ្វើកម្មយ៉ាងទាបត្រូវមានភិក្ខុ ៥ រូប ក្នុងការធ្វើកម្មគ្រប់គ្រា ដោយមិនកម្រើក ត្រូវនាំឆន្ទៈរបស់ភិក្ខុដែលមាននៅមក ។ កាលភិក្ខុទាំងនោះ ចូលមកហើយ ទើបឈ្មោះថា ជាអ្នកព្រមព្រៀងគ្នា ព្រោះឆន្ទៈដែលភិក្ខុនាំមកហើយ ។

ពាក្យថា “**ញត្តិចតុត្ថេន** = មានញត្តិជាគម្រប់ ៤” បានដល់ កម្មដែលសង្ឃត្រូវធ្វើដោយអនុសាវនា ៣ ដង និងដោយញត្តិមួយដង ។

ពាក្យថា **កម្មេន** បានដល់ ដោយវិនយកម្មដែលត្រឹមត្រូវ (ដែលជាធម៌) ។

ពាក្យថា **អកុប្បេន** បានដល់ ចូលដល់ហើយ នូវភាវៈនៃកម្មនោះ ជាកម្មដែលមិនញាប់ញ័រ គឺមាំទាំ ព្រោះដល់ព្រមដោយវត្ថុសម្បត្តិ, ញត្តិសម្បត្តិ, អនុសាវនា-សម្បត្តិ, សីមាសម្បត្តិ និងបរិស័ទសម្បត្តិ (ដល់ព្រមដោយពួកគណៈ) ។

ពាក្យថា “**ឋានារហេន** = គួរដល់ឋានៈ” បានដល់ គួរដល់ហេតុ គួរដល់សត្ថុសាសន៍, គឺអ្នកដល់ហើយ សម្រេចហើយនូវភាវៈខាងលើ ឈ្មោះថា ជាឧបសម្បន្ន (អ្នកបួសហើយ) ។ ពិតមែន ភាពជាភិក្ខុ ឈ្មោះថា ភាវៈខាងលើ (ឧបរិភាវៈ); ព្រះ

មានព្រះភាគជាម្ចាស់ ត្រាស់ហៅភាវៈខាងលើថា ឧបសម្បន្ន ព្រោះភាពជាអ្នកដល់ព្រមដោយកម្ម (ការបួស) តាមដែលពោលហើយ ។

ន័យទាំងនេះ សំដៅដល់ឧបសម្បទា ដែលព្រះមានព្រះភាគជាម្ចាស់ ត្រាស់ការឧបសម្បទា ៨ យ៉ាង គឺ

១. ឯហិភិក្ខូបសម្បទា
២. សរណគមនូបសម្បទា
៣. ឱវាទបដិគ្គហណូបសម្បទា
៤. បញ្ហាព្យាករណូបសម្បទា
៥. គរុធម្មបដិគ្គហណូបសម្បទា
៦. ទូតេនូបសម្បទា
៧. អដ្ឋវាចិកាឧបសម្បទា
៨. ញត្តិចតុត្ថកម្មូបសម្បទា ។

បណ្ដាឧបសម្បទាទាំងនោះ ឧបសម្បទា ៣ គឺ ទូតេនូបសម្បទា អដ្ឋវាចិកា-ឧបសម្បទា និងញត្តិចតុត្ថកម្មូបសម្បទានេះប៉ុណ្ណោះ ជាថាវរៈ ។ ចំណែកដែលនៅសល់ បានមាននៅតែត្រឹមសម័យព្រះពុទ្ធជាម្ចាស់ ទ្រង់ព្រះជន្មនៅប៉ុណ្ណោះ ។

បណ្ដាឧបសម្បទាទាំងនោះ ក្នុងទីនេះ លោកប្រាថ្នាយក ញត្តិចតុត្ថកម្មូប-សម្បទាតែម្យ៉ាង ៕

## បាតិមោក្ខសំវរនិទ្ទេស

ក្នុងនិទ្ទេសនៃបាតិមោក្ខសំវរៈ ពាក្យថា **បាតិមោក្ខំ** បានដល់ សិក្ខាបទ គឺសីល ។ ពិតមែន សភាវៈណា រមែងឃុំគ្រង រមែងរក្សា រមែងឱ្យរួចផុត រមែងឱ្យឃ្លាតចាកទុក្ខទាំងពួង មានទុក្ខក្នុងអបាយជាដើម; ព្រោះហេតុដូច្នោះ ទើបត្រាស់សភាវៈនេះថា

“បាតិមោក្ខ” ។ ពាក្យថា **សីលជាទីអាស្រ័យ** ជាដើម [*] ជាវេវចនៈរបស់បាតិមោក្ខនោះឯង ។ ក្នុងពាក្យទាំងនោះ ពាក្យថា **សីល** នេះ ជាវេវចនៈរបស់បាតិមោក្ខ ដែលសម្រេចក្នុងវេលាជាទីចុងបំផុត ចុះព្រមនឹងកម្មវាចាតែម្តង ។ សូម្បីកាលបើដូច្នោះមែន ធម៌ទាំងឡាយមានចេតនាជាដើម របស់អ្នកវៀរចាកបាណាតិបាតជាដើម ឬថា អ្នកញុំាងវត្ត និងការបដិបត្តិឱ្យពេញ គប្បីជ្រាបថា ខនោះ ក៏ជាសីល ។ សមពិតតាមដែលពោលទុកក្នុងបដិសម្ភិទាថា “អ្វីជាសីល ? ឆ្លើយថា **ចេតនា** ជាសីល, ចេតសិក ជាសីល, សេចក្តីសង្រួម ជាសីល, ការមិនប្រព្រឹត្តកន្លង ជាសីល” [១៧] ។

ក្នុងពាក្យទាំងនោះ ចេតនារបស់អ្នកវៀរចាកបាណាតិបាតជាដើម ឬថា ការញុំាងវត្តបដិបត្តិឱ្យពេញ ឈ្មោះថា **ចេតនា** ជាសីល ។

ការវៀររបស់បុគ្គលអ្នកវៀរចាកបាណាតិបាតជាដើម ឈ្មោះថា ចេតសិក ជាសីល ។ ម្យ៉ាងទៀត ចេតនាដែលប្រព្រឹត្តទៅក្នុងកម្មបថ ៧ របស់អ្នកលះបាណាតិបាតជាដើម ក៏ឈ្មោះថា ចេតនា ជាសីល ។ ក្នុងសំយុត្តនិកាយមហាវគ្គ លោកពោលធម៌ទាំងឡាយ មានសេចក្តីមិនលោភ មិនព្យាបាទ និងសម្មាទិដ្ឋិ ដោយន័យជាដើមថា “បុគ្គលលះអភិជ្ឈាហើយ នៅដោយចេតនាប្រាសចាកសេចក្តីលោភ” ដូច្នេះ ក៏ឈ្មោះថា ចេតសិក ជាសីល ។

---

[*] ពាក្យថាជាដើម គឺជាចរណៈ ជាគ្រឿងសង្រួម រវាំង ជាប្រមុខ ជាប្រធាន ។

[១៧] ខុ. បដិ., វិសុទ្ធិ. ១ ។

ក្នុងពាក្យថា សេចក្ដីសង្រួម ជាសីល គប្បីជ្រាបដោយសេចក្ដីសង្រួម ៥ គឺ

១. បាតិមោក្ខសំវរៈ សេចក្ដីសង្រួមដោយបាតិមោក្ខ

២. សតិសំវរៈ សេចក្ដីសង្រួមដោយសតិ

៣. ញាណសំវរៈ សេចក្ដីសង្រួមដោយញាណ

៤. ខន្តិសំវរៈ សេចក្ដីសង្រួមដោយខន្តី

៥. វីរិយសំវរៈ សេចក្ដីសង្រួមដោយការព្យាយាម ។

សេចក្ដីផ្សេងគ្នា (នានាករណំ) របស់សេចក្ដីសង្រួមទាំងនោះ លោកពោលទុកក្នុងបករណ៏វិសេស ឈ្មោះថា វិសុទ្ធិមគ្គ [១៨] ។

ពាក្យថា ការមិនប្រព្រឹត្តកន្លងជាសីល អធិប្បាយថា ការមិនកន្លងដែលប្រព្រឹត្តទៅផ្លូវកាយ និងផ្លូវវាចារបស់អ្នកមានសីលដែលសមាទានហើយ; ពាក្យថា ការសង្រួមជាសីល ការមិនប្រព្រឹត្តកន្លងជាសីលនេះឯង ជាសីលដោយត្រង់ (និប្បរិយាយ); ចំណែកពាក្យថា ចេតនាជាសីល និងចេតសិកជាសីល នេះ គប្បីជ្រាបថា ជាសីលដោយបរិយាយ (ដោយអម) ក៏ព្រោះភិក្ខុ ឈ្មោះថា រមែងតាំងមាំក្នុងព្រះសាសនា ដោយបាតិមោក្ខសំវរសីល ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា “សីលនោះ ជាទីអាស្រ័យ” ដូច្នេះ ។

សួរថា ឈ្មោះថា ជាទីអាស្រ័យ ព្រោះភិក្ខុរមែងតាំងមាំក្នុងព្រះសាសនានេះ, ឬកុសលធម៌ទាំងឡាយប៉ុណ្ណោះ រមែងតាំងមាំក្នុងព្រះសាសនានេះ ។

---

[១៨] វិសុទ្ធិ. ១/សីលនិទ្ទេស ។

ឆ្លើយថា សេចក្ដីនេះ គប្បីជ្រាបដោយអំណាចនៃព្រះសូត្រដែលត្រាស់ទុកថា

**"សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ**
**អាតាបី និបកោ ភិក្ខុ សោ ឥមំ វិជដយេ ជដំ ។**

នរៈជនអ្នកមានបញ្ញា តាំងនៅមាំហើយក្នុងសីល ចម្រើនចិត្ត
និងបញ្ញាហើយ ជាអ្នកមានសេចក្ដីព្យាយាម មានភាពឈ្លាសវៃ ជា
ភិក្ខុ គេនឹងគប្បីត្រដោះនូវគ្រឿងចាក់ស្រេះនេះបាន"[១៩] ដូច្នេះផង ។

ព្រះសូត្រថា "ម្នាលមហារាជ ជនទាំងឡាយអាស្រ័យសីលហើយ គប្បីញុំាងកុសលធម៌ទាំងឡាយ ឱ្យកើតឡើង" ជាដើមផង និងព្រះសូត្រថា "ម្នាលមហារាជ កាលបុគ្គលអាស្រ័យសីលហើយ កុសលធម៌ទាំងឡាយ រមែងមិនសាបសូន្យទៅដោយជុំវិញ" ផង ។ សីលនោះ ឈ្មោះថា ជាខាងដើម ព្រោះអត្ថថា កើតមុន ។ សមពិតដូចដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា "ព្រោះហេតុនោះឯង លោកគប្បីជម្រះធម៌ (សីល) ដែលជាខាងដើមនោះឯង ឱ្យក្រៃលែងឡើង ក៏បណ្ដាកុសលធម៌ទាំងឡាយអ្វីទៅ ឈ្មោះថាជាធម៌ខាងដើម, ក៏សីលដែលបរិសុទ្ធល្អហើយផង និងទិដ្ឋិដែលត្រង់ផង ជាធម៌ខាងដើមរបស់កុសលទាំងឡាយ"[២០] ។ ប្រៀបដូចជាងសាងនគរ មានសេចក្ដីប្រាថ្នានឹងសាងនគរ រមែងជម្រះផែនដីរបស់នគរជាមុន, ខាងក្រោយ ទើបបែងទីសាង

[១៩] វិសុទ្ធិ. ១/១ សីលនិទ្ទេស ។
[២០] សំ. ម. ។

នគរ ដោយកំណត់យកផ្លូវបែកជា ៣ បែកជា ៤ ជាដើម យ៉ាងណា, ព្រះយោគាវចរ ក៏ដូច្នោះដែរ រមែងជម្រះសីលតាំងពីដើមមែនពិត, ខាងក្រោយអំពីនោះ ក៏ធ្វើឱ្យជាក់ច្បាស់នូវសមថៈ វិបស្សនា មគ្គ ផល និងនិព្វាន ។

ម្យ៉ាងទៀត ប្រៀបដូចជាងជ្រលក់ បោកសំពត់ដោយទឹកក្បុង កាលសំពត់ស្អាតល្អហើយ ទើបជ្រលក់ដោយពណ៌ផ្សេងៗ តាមប្រាថ្នា យ៉ាងណា; ឬថា វិចិត្រករ (ជាងគំនូរ) អ្នកឈ្លាសប្រាថ្នានឹងគូររូប គេរមែងធ្វើការតាក់តែងជញ្ជាំងជាមុន, ក្រោយពីនោះ ទើបគូររូប យ៉ាងណា ព្រះយោគាវចរ ក៏ដូច្នោះដែរ ជម្រះសីលអំពីខាងដើមរួចរាល់ហើយ ក្រោយពីនោះ ក៏ធ្វើឱ្យជាក់ច្បាស់នូវសមថៈ និងវិបស្សនាជាដើម ។ ព្រោះហេតុនោះ ទើបពោលថា “សីលជាខាងដើម” ។

សីលនោះៗ ទើបឈ្មោះថា ចរណៈ ព្រោះជាធម្មជាតិដូចជើងជាគ្រឿងដើរទៅ; ពិតមែន ជើងព្រះមានព្រះភាគត្រាស់ទុកថា ជាចរណៈ ដូចឧទាហរណ៍ថា សភាពនៃការតាក់តែងដំណើរទៅកាន់ទិស រមែងមិនកើតដល់បុរសអ្នកមានជើងដាច់ហើយ រមែងកើតដល់បុរសអ្នកមានជើងសម្បូណ៌ហើយនោះឯង យ៉ាងណា, សេចក្ដីនេះ ក៏ដូច្នោះដែរ សីលរបស់អ្នកណាបែកហើយ ដាច់ហើយ មិនសម្បូណ៌ហើយ, ការដើរទៅកាន់ញាណដើម្បីសម្រេចព្រះនិព្វាន ក៏រមែងមិនសម្រេចដល់អ្នកនោះ; ចំណែកអ្នកណាមានសីលមិនបែក មិនដាច់ គឺបរិបូណ៌ហើយ, អ្នកនោះនឹងដើរទៅកាន់ញាណ ដើម្បីសម្រេចព្រះនិព្វានដូច្នោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគជាម្ចាស់ ត្រាស់ថា សីលជាចរណៈ ។

សីលនោះៗ ឈ្មោះថា សំយមៈ (គ្រឿងសង្រួម) ដោយអំណាចនៃការរវាំង ឈ្មោះថា សំវរៈ (គ្រឿងរវាំងប្រយ័ត្ន) ដោយអំណាចនៃការបិទបាំងការពារ, សូម្បីដោយហេតុទាំងពីរនេះឯង ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា "សីលជាគ្រឿងសង្រួម ជាគ្រឿងរវាំង" ដូច្នេះ ។ គប្បីជ្រាបវចនត្ថៈ ក្នុងទីនេះថា ៖

សភាវៈណា រមែងសង្រួមការក្តៅក្រហាយ ដោយការឈានកន្លងដល់បុគ្គល ឬថា រមែងសង្រួមនូវបុគ្គល គឺថា រមែងមិនឱ្យដើម្បីការរសាប់រសល់ទៅដល់បុគ្គលនោះ ដោយអំណាចនៃការឈានកន្លង ព្រោះហេតុដូច្នោះ សភាវៈនោះ ទើបឈ្មោះថា សំយមៈ (គ្រឿងសង្រួម) ។ ឈ្មោះថា **សំវរៈ** (គ្រឿងរវាំង) ព្រោះរមែងបិទបាំង ការពារទ្វារដែលជាទីចូលទៅរបស់បុគ្គលអ្នកឈានកន្លង ។

ពាក្យថា **មោក្ខំ** បានដល់ ជាធម៌ខ្ពស់បំផុត ឬជាប្រធាន ។ ដូចអាហារ ៤ យ៉ាង របស់សត្វទាំងឡាយ ចូលទៅតាមផ្លូវមាត់ រមែងផ្សាយទៅកាន់អវយវៈតូចធំយ៉ាងណា, កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៤ សូម្បីរបស់ព្រះយោគី ក៏ដូច្នោះដែរ ចូលទៅតាមផ្លូវមាត់ គឺសីលហើយ រមែងញ៉ាំងសេចក្តីសម្រេចនៃប្រយោជន៍ ឱ្យបរិបូណ៌ ។ ដោយហេតុនេះ ទើបព្រះមានព្រះភាគត្រាស់ថា "សីលជាប្រធាន" ។

ពាក្យថា **បមុខេន សាធុ** អធិប្បាយថា ជាប្រធាន; ជាធម៌ដ៏ប្រសើរ ជាធម្មជាតិដល់មុន ជាធម្មជាតិប្រសើរបំផុត ។ ពាក្យថា "**កុសលានំ ធម្មានំ សមាបត្តិយា** = ដើម្បីសេចក្តីដល់ព្រមនៃកុសលធម៌ទាំងឡាយ" បណ្ឌិតគប្បីជ្រាបថា សីលជា

ធម៌ប្រសើរ ជាធម៌ដល់មុន ជាធម៌ប្រសើរបំផុត ជាប្រធាន ដើម្បីការបានចំពោះនូវកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។

ពាក្យថា កាយិកោ **អវីតិក្កមោ** = ការមិនកន្លងល្មើសផ្លូវកាយ” បានដល់កាយសុចរិត ៣ យ៉ាង ។ ពាក្យថា “**វាចសិកោ** = ការមិនប្រព្រឹត្តិកន្លងល្មើសផ្លូវវាចា” បានដល់ វចីសុចរិត ៤ យ៉ាង ។ ទាំងពីរនោះ ឈ្មោះថា **កាយិកវាចសិកោ** = ការមិនកន្លងល្មើសផ្លូវកាយ និងផ្លូវវាចា ។ លោករមែងកាន់យកអាជីវមដ្ឋកសីល (គឺសីលមានអាជីវៈជាទី ៨) រមែងសម្តែងដោយការមិនកន្លងល្មើសផ្លូវកាយ និងផ្លូវវាចានេះ ។

ពាក្យថា **សំវុតោ** បានដល់ ដែលគេបិទហើយ; អធិប្បាយថា មានឥន្ទ្រិយដែលសង្រួមហើយ ឈ្មោះថា មានឥន្ទ្រិយដែលបិទហើយ ។ ដូចយ៉ាងថា ផ្ទះមានទ្វារបិទហើយ លោកហៅថា ផ្ទះដែលគេបិទហើយ រវាំងហើយ យ៉ាងណា; ក្នុងសេចក្តីនេះក៏ដូច្នោះដែរ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ភិក្ខុមានឥន្ទ្រិយសង្រួមហើយ មានឥន្ទ្រិយរវាំងឃុំគ្រងហើយ ។

ពាក្យថា **បាតិមោក្ខសំវរេន** បានដល់ ដោយបាដិមោក្ខ និងសំវរៈ;ម្យ៉ាង-ទៀត បានដល់ ដោយសំវរៈ ពោលគឺបាតិមោក្ខ ។

ពាក្យថា “**វិហរតោ** = អ្នកចូលទៅដល់ហើយ” ជាដើម មានសេចក្តីដូចដែលពោលហើយនោះឯង ។ ព្រះមានព្រះភាគត្រាស់ថា ការនៅដោយឥរិយាបថរបស់ភិក្ខុ

អ្នកតាំងនៅក្នុងបាតិមោក្ខសំវរសីល សូម្បីដោយបទទាំង ៧ * មានពាក្យថា **ឥរិយតិ** ជាដើម ៕

## **អនាចារនិទ្ទេស**

ក្នុងនិទ្ទេសនៃអាចារៈ និង គោចរៈ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់ប្រាថ្នានឹងពោលអាចារៈរបស់សមណៈ គោចររបស់សមណៈ សូម្បីដោយពិត ទើបទ្រង់លើកនូវបទថា អាចារៈមាន អនាចារៈមាន ដោយបទថា **“អាចារគោចរសម្បន្នោ”** ។

ដូចយ៉ាងបុរសឈ្លាសក្នុងផ្លូវ កាលនឹងប្រាប់ផ្លូវ ទើបពោលថា “លោកចូរលះផ្លូវឆ្វេង; ចូរកាន់យកផ្លូវស្តាំ” ដូច្នេះ រមែងប្រាប់ផ្លូវដែលមានភ័យ ផ្លូវដែលខុស ដែលបុគ្គលគប្បីលះជាមុន, ខាងក្រោយ ទើបបានប្រាប់ផ្លូវដ៏ក្សេម ផ្លូវដែលត្រង់ ដែលបុគ្គលគប្បីកាន់យក យ៉ាងណា, សេចក្តីនេះ ក៏ដូច្នោះដែរ ព្រះធម្មរាជា ដូចជាអ្នកឈ្លាសក្នុងផ្លូវ ទ្រង់ប្រាប់អនាចារដែលព្រះពុទ្ធជាម្ចាស់ទ្រង់រង្កៀសហើយ ដែលបុគ្គលគប្បីលះជាមុន ប្រាថ្នានឹងទ្រង់ប្រាប់អាចារៈខាងក្រោយ ទើបត្រាស់ថា **“តត្ថ កតមោ អនាចារោ”** ជាដើម ។ ពិតមែន ផ្លូវដែលបុគ្គលប្រាប់ហើយ គប្បីទៅដល់ ឬមិនដល់ក៏ដោយ, ចំណែកផ្លូវដែលតថាគតប្រាប់ហើយ ជាផ្លូវត្រូវតាមធម៌ មិនខុសបំណង រមែងឱ្យ

---

* បទទាំង ៧ គឺអ្នកចូលទៅហើយ, ចូលទៅហើយដោយល្អ, ចូលមកដល់ហើយ, ចូលមកដល់ហើយដោយល្អ, ចូលដល់ហើយ, ចូលដល់ហើយដោយល្អ និងប្រកបហើយ ។

សម្រេចដល់នគរ គឺព្រះនិព្វាន ដូចវជិរាវុធដែលព្រះឥន្ទ្រទ្រង់បាញ់ទៅហើយដូច្នោះ ។ ដោយហេតុនោះ ទើបបានពោលថា "បុរសអ្នកឈ្លាសក្នុងផ្លូវដូច្នេះឯង, ម្នាលតិស្សៈ ពាក្យថា ព្រះអរហន្តសម្មាសម្ពុទ្ធ នេះ ជាឈ្មោះរបស់ព្រះតថាគត"[២១] ។ មួយាង-ទៀត ព្រោះការប្រកបសេចក្ដីព្យាយាមក្នុងកល្យាណធម៌ រមែងជាធម៌ដែលសម្បូណ៌ដល់បុគ្គលអ្នកមានបាបធម៌ដែលលះបង់ហើយ ប្រៀបដូចការទ្រទ្រង់ដោយគ្រឿងប្រដាប់ មានកម្រងផ្កាឈើ របស់ក្រអូប និងគ្រឿងលាបជាដើម រមែងសមគួរដល់បុគ្គលអ្នកមានញើសក្អែល និងមន្ទិលដែលខ្លួនជម្រះហើយ ដោយការងូតទឹកព្រមទាំងក្បាល, ព្រោះហេតុដូច្នោះ សូម្បីព្រះមានព្រះភាគទ្រង់ប្រាថ្នានឹងប្រាប់អនាចារដែលបុគ្គលគប្បីលះជាមុន ដូចបុគ្គលធ្វើការសម្អាតជម្រះលាងក្អែលញើស និងមន្ទិល ដោយការងូតទឹកកក់ក្បាល ។ ខាងក្រោយប្រាប់អនាចារ ដែលប្រៀបដូចការទ្រទ្រង់ដោយគ្រឿងប្រដាប់ មានកម្រងផ្កាឈើ របស់ក្រអូប និងគ្រឿងលាបជាដើម ទើបត្រាស់ពាក្យថា "**តត្ថ កតមោ អនាចារោ**" ជាដើម ។ បណ្ដាពាក្យទាំងនោះ ពាក្យថា ការកន្លងល្មើសផ្លូវកាយ បានដល់ កាយទុច្ចរិត ៣ ។ ពាក្យថា ការកន្លងល្មើសផ្លូវវាចា បានដល់ វចីទុច្ចរិត ៤ ។ ពាក្យថា ការកន្លងល្មើសផ្លូវកាយ និងផ្លូវវាចា បានដល់ កាយទុច្ចរិត ៣ និងវចីទុច្ចរិត ៤ ទាំងនោះ ។ ព្រះមានព្រះភាគទ្រង់សម្ដែងការប្រព្រឹត្តកន្លងរបស់បុគ្គលអ្នកមានអាជីវដ្ឋមកសីល (សីលមានអាជីវៈជាទី ៨) នោះឯង ដោយអាការយ៉ាងនេះ ។ ក៏ព្រោះបុគ្គលមិនប្រព្រឹត្តអនាចារដោយកាយ និងវាចាតែប៉ុណ្ណោះ

---

[២១] សំ. ខ. ។

ទេ, តែរមែងប្រព្រឹត្តសូម្បីដោយចិត្តដែរ, ព្រោះហេតុដូច្នោះ ដើម្បីនឹងសម្តែងសេចក្តីនោះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា "សូម្បីភាពជាអ្នកទ្រុស្តសីលទាំងពួងក៏ហៅថា អនាចារ" ដូច្នេះ; ក្នុងសេចក្តីនេះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់ចែកសម្តែងអនាចារយ៉ាងណាមួយ ទើបត្រាស់ពាក្យថា **"ឥធេកច្ចោ វេឡុទានេន** = ភិក្ខុរូបខ្លះ ក្នុងសាសនានេះ ចិញ្ចឹមជីវិតដោយការឱ្យឫស្សី" ជាដើម ។ បណ្តាពាក្យទាំងនោះ ពាក្យថា ការឱ្យឫស្សី បានដល់ ការឱ្យឫស្សីដែលជាគ្រឿងអាស្រ័យហេតុ; អធិប្បាយថា ភិក្ខុមិនគួរឱ្យដល់ឧបដ្ឋាក ដោយការគិតថា "យើងនាំឫស្សីដែលកើតឡើងឯងមកពីព្រៃ ឫស្សីដែលមានបុគ្គលឃុំគ្រងរក្សា មកឱ្យជាគ្រឿងប្រើប្រាស់ដោយអាការៈយ៉ាងនេះ" ជាដើម ពីព្រោះថា ភិក្ខុកាលសម្រេចចិញ្ចឹមជីវិតយ៉ាងនេះ រមែងជាការនៅដោយការស្វែងរកដែលមិនត្រូវតាមធម៌ ជាមិច្ឆាអាជីវៈ ។ ភិក្ខុនោះឯង រមែងដល់ការគរហា (តិះដៀល) ក្នុងបច្ចុប្បន្ន, ក្នុងបរលោក ក៏ឈ្មោះថា ជាអ្នកពេញក្នុងអបាយ; ភិក្ខុនោះកាលឱ្យឫស្សីដែលជារបស់ខ្លួន រមែងត្រូវអាបត្តិទុក្កដ ឈ្មោះកុលទូសកៈ (អ្នកទ្រុស្តត្រកូល), កាលឱ្យឫស្សីជារបស់អ្នកដទៃ រមែងត្រូវអាបត្តិដោយថេយ្យចិត្ត (លួច) សង្ឃគប្បីធ្វើទណ្ឌកម្មដល់លោកតាមតម្លៃរបស់នោះ ។ សូម្បីការឱ្យឫស្សីជារបស់សង្ឃ ក៏ន័យនេះដែរ ។ ក៏បើថាភិក្ខុឱ្យឫស្សីនោះ ព្រោះភាវៈនៃខ្លួនជាធំ លោកនឹងត្រូវអាបត្តិ (ថុល្លច្ច័យ) ព្រោះការលះបង់គរុភណ្ឌ ។

ឫស្សីប្រភេទណា ជាគរុភណ្ឌ, ប្រភេទណា មិនជាគរុភណ្ឌ គប្បីជ្រាបសេចក្តីនេះ ដូចតទៅនេះ ៖

ឫស្សីណា ដែលមិនបានដាំទុក គឺកើតឡើងឯង១, ឫស្សីនោះជាគរុភណ្ឌ តាមស្ថានដែលសង្ឃកំណត់ទុកប៉ុណ្ណោះ, ក្រៅពីនោះ មិនជាគរុភណ្ឌ ។ ឫស្សីទាំងអស់ជាគរុភណ្ឌ ដោយប្រការទាំងពួង ក្នុងទីដែលសង្ឃដាំទុកហើយ ។ ឫស្សីនោះ លោកកំណត់ហើយដោយប្រមាណ ។

ពិតមែន មានប្រមាណមួយនាឡិដួសប្រេង ចាត់ជាគរុភណ្ឌ, ខ្លីជាងនោះ មិនជាគរុភណ្ឌ ។ មួយទៀត ភិក្ខុណាមួយ មានសេចក្ដីត្រូវការដោយនាឡិដួសប្រេង ឬត្រូវការឈើច្រត់, សង្ឃគប្បីយកវត្ថុនោះ ធ្វើឱ្យជាផាតិកម្មចុះ * ។ ផាតិកម្មជារបស់មានតម្លៃ ឬជារបស់ច្រើនជាងរបស់សង្ឃ រមែងគួរ, តិចជាងមិនគួរ ។ សូម្បីហត្ថកម្ម ត្រឹមតែជាវត្ថុជាគ្រឿងនាំទឹកទៅ ឬថា វត្ថុជាគ្រឿងជម្រះស្មៅតូចតាច ក៏ដូចគ្នា, សង្ឃគួរធ្វើផាតិកម្ម (ផ្លាស់ប្ដូរ) នោះ ឱ្យជាថាវរៈ ។ ព្រោះហេតុដូច្នោះ កាលដែលភិក្ខុកាយអាចម៍ដីឡើងពីស្រះទឹកក្ដី ប្រើឱ្យបុគ្គលក្រាលកម្រាលផ្ទៃដី ត្រង់ជណ្ដើរ ដើម្បីធ្វើផ្ទៃដីដែលមិនស្មើ ឱ្យស្មើក្ដី រមែងគួរ ។ តែមិនត្រូវកាន់យកគ្រឿងផាតិកម្ម គឺកាលលោកអាស្រ័យនៅទីនោះ១ ឯង គប្បីប្រើប្រាស់, កាលលោកជៀសទៅហើយ គប្បីធ្វើរបស់ទាំងនោះឱ្យជារបស់សង្ឃ; កាលលោកច្រឡំកាន់យកវត្ថុណាមួយហើយទៅ ពេលទៅក្នុងទីណារឭកបាន, ក៏គប្បីនាំត្រឡប់មកសងពីទីនោះ; បើមានភ័យក្នុងចន្លោះផ្លូវ ក៏

* ផាតិកម្ម សំដៅដល់វត្ថុផ្លាស់ប្ដូរ, ក្នុងផ្លូវព្រះវិន័យ សំដៅដល់ការសងរបស់សង្ឃ ដោយវត្ថុដទៃ ។

គប្បីដាក់វត្ថុក្នុងព្រះវិហារដែលខ្លួនទៅដល់ហើយ ។ ពួកមនុស្សទៅកាន់វិហារសុំឫស្សី, ភិក្ខុទាំងឡាយមិនអាចនឹងឱ្យបាន ដោយការប្រាប់ថា "នោះជារបស់សង្ឃ" , បើពួកគេសុំញយ១ ឬគម្រាម, ក្នុងវេលានោះ ភិក្ខុទាំងឡាយគួរពោលថា "អ្នកទាំងឡាយគប្បីធ្វើទណ្ឌកម្ម * (តម្លៃប្តូរ) ហើយកាន់យកចុះ ។ ក៏ឈ្មោះថា ការឱ្យឫស្សី រមែងមិនមាន ។ បើថា មនុស្សនោះ ថ្វាយវត្ថុមានកាំបិត និងពូថៅជាដើម ឬខាទនីយៈ និងភោជនីយៈ ដើម្បីធ្វើឱ្យជាតម្លៃប្តូរ, មិនគួរទទួល ។ តែក្នុងអដ្ឋកថាព្រះវិន័យ លោកសម្តែងទុកថា "ពួកមនុស្សត្រូវភ្លើងឆេះផ្ទះ កាន់យករបស់របរទៅ ភិក្ខុមិនគួរហាម"។ បើផ្លែឫស្សីកើតឡើងត្រង់គុម្ពឫស្សីរបស់សង្ឃ, កាលមិនឱ្យអ្នកណាគាស់ឫស្សីនោះរមែងវិនាសទៅ សង្ឃនឹងគប្បីធ្វើយ៉ាងណា ? សង្ឃគប្បីប្រាប់ពួកមនុស្ស ក្នុងវេលាដែលទៅភិក្ខាចារ; បើពួកគេមិនប្រាថ្នានឹងជួយធ្វើ, គប្បីនិយាយថា ពួកអ្នកនឹងបានចំណែកចែកប៉ុនគ្នា; បើគេមិនត្រូវការដដែល ក៏គប្បីនិយាយថា ពួកអ្នកនឹងបាន ២ ចំណែក; កាលពួកគេមិនប្រាថ្នា សូម្បីដោយអាការ យ៉ាងនេះ នៅតែមិនត្រូវការឫស្សីនោះទៀត គប្បីប្រាប់ថា "មនុស្សរបស់អ្នកមាន អ្នកចូរធ្វើជាតម្លៃប្តូរ (ពលកម្ម) ចូរគាស់ឫស្សី ហើយកាន់យកវត្ថុនោះចុះ" ។

---

* ទណ្ឌកម្ម សំដៅដល់ ការពិន័យ ឬតម្លៃរបស់ដែលនឹងត្រូវផ្លាស់ប្តូរ ។

ក៏ឈ្មោះថា ការឱ្យឫស្សីរមែងមិនមាន ។ សូម្បីគុម្ពឫស្សី ត្រូវភ្លើងឆេះក្តី សូម្បីត្រូវទឹកផាត់កួចទៅក្តី ក៏មានន័យដូចគ្នានេះដែរ ។

កថាមគ្គ សូម្បីក្នុងដើមឈើទាំងឡាយ ក៏មានន័យដូចគ្នានេះដែរ ។ សម្រាប់ដើមឈើ មានប្រមាណប៉ុនដងម្ជុល (ដែកចារ) ក៏ចាត់ជាគរុភណ្ឌបាន ។ ភិក្ខុទម្លាយដើមឈើ ដែលជារបស់សង្ឃ ដើម្បីធ្វើអាវាស (ទីនៅ) ដែលជារបស់សង្ឃ សូម្បីមិនប្រាប់ មិនអនុញ្ញាតពីសង្ឃជាមុន ក៏ធ្វើបាន តែដើម្បីកាត់កន្លងនូវវាទៈ (ពីពាក្យតិះ-ដៀលរបស់អ្នកដទៃ) គប្បីប្រាប់ សូមអនុញ្ញាតសិនហើយសឹមធ្វើ ។

សួរថា ភិក្ខុទម្លាយដើមឈើរបស់សង្ឃ មិនបានប្រាប់សូមអនុញ្ញាតពីសង្ឃជាមុន គួរដើម្បីធ្វើអាវាសចំពោះបុគ្គលឬទេ ?

ឆ្លើយថា មិនគួរទេ ។

ក៏កាលពោលអំពីហត្ថកម្មយ៉ាងខ្ពស់ ភិក្ខុរមែងបានត្រឹមតែទីជាកន្លែងតាំងគ្រែក្នុងផ្ទះមួយខ្នង; ក្នុងផ្ទះ ៣ ខ្នង ភិក្ខុមានសិទ្ធិបានត្រឹមតែមួយខ្នង ។ បើទព្វសម្ភារៈជារបស់បុគ្គល, ផ្ទៃដីជារបស់សង្ឃ, ភិក្ខុនោះ រមែងបានចំណែកស្មើគ្នា ធ្វើផ្ទះ ១ ខ្នង ក្នុងផ្ទះដែលលោកធ្វើ ២ ខ្នង លោកគួរបាន ១ ខ្នង ។ កាលដើមឈើជារបស់សង្ឃបៀត-បៀនអាវាស (ទីនៅ) របស់សង្ឃ ភិក្ខុមិនសុំអនុញ្ញាតពីសង្ឃជាមុន នាំចេញទៅគួរឬទេ ? ឆ្លើយថា គួរ, តែដើម្បីកាត់នូវកន្លងនៃវាទៈ គួរសុំអនុញ្ញាតពីសង្ឃជាមុន ហើយនាំចេញទៅ ។ បើលាភធំរបស់សង្ឃមាន ព្រោះអាស្រ័យដើមឈើ ក៏មិនគួរនាំចេញទៅ។ កាលដើមឈើដែលជារបស់បុគ្គល បៀតបៀនអាវាសដែលជារបស់សង្ឃ គប្បីប្រាប់ដល់ម្ចាស់របស់ដើមឈើ ។ បើថា គេមិនប្រាថ្នានឹងនាំចេញទៅ គប្បីឱ្យបុគ្គលកាត់ចេញ

ហើយនាំទៅ ។ កាលត្រូវគេចោទ (ទារ) ថា "ពួកលោក ចូរឱ្យដើមឈើដល់យើង" ដូច្នេះ គប្បីឱ្យគេកាត់តម្លៃដើមឈើនោះ ហើយឱ្យទ្រព្យតាមតម្លៃចុះ ។ កាលដើមឈើជារបស់សង្ឃ បៀតបៀនអាវាសដែលជារបស់បុគ្គលក្តី ដើមឈើជារបស់បុគ្គល បៀត-បៀនអាវាសរបស់បុគ្គលក្តី ក៏ន័យនេះដែរ ។

កថាមគ្គ សូម្បីក្នុងវល្លិ ក៏ន័យនេះដែរ ។

មួយទៀត ក្នុងទីណា វល្លិជារបស់រកបានដោយលំបាក គេរមែងធ្វើការលក់ដូរគ្នា ក្នុងទីនោះ ចាត់ជាគរុភណ្ឌ ។ ក៏វល្លិនោះឯង មានប្រមាណ ១ ហត្ថ ចាត់ជាគរុ-ភណ្ឌ ។ កំណាត់វល្លិខ្លីជាងនោះ មិនជាគរុភណ្ឌ ។ សូម្បីក្នុងពាក្យទាំងពួង ពាក្យថា ការឱ្យស្លឹកឈើ ជាដើម ដែលមានពាក្យថា អាស្រ័យហេតុ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងការឱ្យឫស្សី ។

គប្បីជ្រាបវិនិច្ឆ័យអំពីភាវៈនៃវត្ថុជាគរុភណ្ឌក្នុងអធិការនេះ តទៅ ៖

ពិតមែន បុគ្គលរមែងទិញលក់ សូម្បីស្លឹកឈើក្នុងទីណា ជនទាំងឡាយ រមែងកាន់យកដើម្បីត្រូវការដល់ប្រយោជន៍ទាំងឡាយ មានការខ្ចប់ស្បៀវភៅជាដើម ក្នុងទីដែលរកបានដោយលំបាកដូច្នោះ រមែងចាត់ជាគរុភណ្ឌមែនពិត ។ គប្បីជ្រាបវិនិច្ឆ័យក្នុងស្លឹកចារ និងស្លឹកត្នោតជាដើម ។ សូម្បីស្លឹកត្នោត បណ្ឌិតគប្បីពោលក្នុងឋាននេះដូចគ្នា; ពិតមែន សូម្បីស្លឹកត្នោតក្នុងព្រៃត្នោតដែលកើតឯង ក្នុងទីដែលសង្ឃកំណត់ទុកនោះឯង ចាត់ជាគរុភណ្ឌ, ក្រៅពីនោះ មិនជាគរុភណ្ឌ ។ សូម្បីត្នោតដែលសង្ឃដាំទុក

ជាគរុភណ្ឌទាំងអស់ ។ សៀវភៅ [២២] ទទេ ដោយហោចទៅ មានប្រមាណ ៨ ធ្នាប់ ជាប្រមាណរបស់គរុភណ្ឌ ។ សូម្បីស្មៅក៏គប្បីអនុលោមចូលក្នុងសេចក្តីនេះដែរ ។ ក៏ក្នុងទីណា ស្មៅមិនមាន ក្នុងទីនោះ ជនទាំងឡាយ រមែងបិទបាំងដោយស្មៅដំណេក ទន្សាយ និងស្លឹកដូងជាដើម ព្រោះហេតុនោះ សូម្បីស្មៅទាំងឡាយនោះ លោកក៏សង្គ្រោះចូលក្នុងសេចក្តីនេះ ។ ក្នុងស្មៅដំណេកទន្សាយជាដើម ស្មៅយ៉ាងណាមួយ មានប្រមាណមួយក្តាប់ ជាគរុភណ្ឌ; ក្នុងស្លឹកដូងជាដើម សូម្បីស្លឹកមួយដែលបុគ្គលថ្វាយដល់សង្ឃ ឬដែលកើតក្នុងទីរបស់សង្ឃ ឬស្មៅដែលកើតឯង ជារបស់ដែលបុគ្គលឃុំគ្រងរក្សាក្នុងផ្ទៃដីកន្លែងដុះស្មៅ របស់សង្ឃខាងក្រៅអារាម ក៏ចាត់ជាគរុភណ្ឌ ។ កាលសង្ឃធ្វើ សង្ឃកម្មក្តី ធ្វើចេតិយក្តី ក្នុងការកំណត់ដែលជារបស់បុគ្គលក្តី ការឱ្យស្មៅនោះ លើសហួសទៅក៏គួរ ។ សូម្បីក្នុងឫស្សីដែលពោលហើយក្នុងគ្រាក្រោយ ក៏ន័យនេះដែរ ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងការឱ្យផ្កាឈើទាំងឡាយ ដែលចាត់ជាគរុភណ្ឌ គឺដែលសង្ឃកំណត់ទុកយ៉ាងនេះថា "ភិក្ខុទាំងឡាយបេះផ្កាឈើ ត្រង់ដើមឈើទាំងឡាយ មានប្រមាណប៉ុណ្ណេះ ហើយបង្អោនទៅក្នុងយាគូ និងភត្ត, ឬបង្អោនទៅក្នុងការបដិសង្ខរណ៍ (ជួសជុល) សេនាសនៈមានប្រមាណប៉ុណ្ណេះ" ដូច្នេះ; សាមណេរទាំងឡាយបេះផ្កាឈើទាំងឡាយខាងក្រៅធ្វើឱ្យជាគំនរទុក; ភិក្ខុប្រកបដោយអង្គ ៥ ដែលជាអ្នកចែកផ្កាឈើ រាប់ចំនួនភិក្ខុសង្ឃហើយបែងទុកជាចំណែក១, លោកមិនត្រូវសុំអនុញ្ញាត

---

[២២] សព្ទនេះ បាលីថា **វិត្តបោត្ថកៈ** ប្រែថា សៀវភៅទទេ, ស្លឹករឹតទទេ... (សំដៅដល់សៀវភៅ ឬស្លឹករឹត ... ដែលមិនទាន់សរសេរ) ។

ពីសង្ឃមុន រមែងចែកបរិស័ទ គឺសង្ឃដែលមកហើយបាន ។ មួយទៀត ភិក្ខុអ្នកចែកនោះ សង្ឃនៅមិនបានសម្មតិ គប្បីសុំអនុញ្ញាតពីសង្ឃហើយ គប្បីធ្វើការចែកចុះ ។ សួរថា ក៏ភិក្ខុរមែងបានដើម្បីនឹងឱ្យផ្កាឈើទាំងឡាយដល់អ្នកណា ? រមែងមិនបានឱ្យដល់អ្នកណា ? ឆ្លើយថា ភិក្ខុសូម្បីនាំផ្កាឈើទៅកាន់ផ្ទះមាតាបិតាក្តី ឬញ៉ាំងបុគ្គលឱ្យហៅមាតាបិតាមកពីផ្ទះក្តី លោករមែងបានឱ្យដោយពាក្យថា "លោកទាំងឡាយ ចូរបូជាព្រះរតនត្រ័យ" ដូច្នេះ, មិនមែនឱ្យដើម្បីជាគ្រឿងប្រដាប់ ។ តែភិក្ខុមិនគួរនាំទៅដល់ពួកញាតិទាំងឡាយដែលនៅសល់, គួរឱ្យបុគ្គលហៅមក ហើយឱ្យដោយពាក្យថា "ពួកអ្នកទាំងឡាយ ចូរធ្វើការបូជា" ដូច្នេះ ។ ភិក្ខុនោះមិនគប្បីប្រាថ្នាឱ្យដល់ជនដែលនៅសល់ អ្នកមកកាន់ទីបូជា ។ ឈ្មោះថា ការឱ្យផ្កាឈើ រមែងមិនមាន ។ ក្នុងវិហារ មានផ្កាឈើច្រើន, ភិក្ខុអ្នកត្រាច់បិណ្ឌបាត ឃើញពួកមនុស្សហើយ ទើបនិយាយថា "ក្នុងវិហារមានផ្កាឈើច្រើន ពួកអ្នកចូរបូជាចុះ" ដូច្នេះ ។ ទោសរមែងមិនមាន ព្រោះត្រឹមតែពាក្យនិយាយ ។ តែថា លោកមិនគួរនិយាយដោយគិតថា "ពួកមនុស្សកាន់ យកខាទនីយៈ និងភោជនីយៈហើយនឹងមក" ដូច្នេះ; បើលោកនិយាយ, មិនគប្បីបរិភោគខាទនីយៈ និងភោជនីយៈ, បើមនុស្សទាំងឡាយ សួរតាមធម្មតារបស់គេថា "ផ្កាឈើទាំងឡាយ មាននៅក្នុងវិហារឬ ?, នឹងពោលតទៅថា 'ពួកខ្ញុំនឹងមកកាន់វិហារ ក្នុងថ្ងៃឈ្មោះឯណោះ, លោកទាំងឡាយ កុំឱ្យពួកសាមណេរបេះផ្កាឈើទាំងឡាយ" ដូច្នេះ ។ តែពួកភិក្ខុភ្លេចប្រាប់សាមណេរ, ពួកសាមណេរក៏បេះផ្កាឈើទាំងឡាយដាក់ទុក; កាល

ពួកមនុស្សទាំងឡាយ ចូលទៅរកភិក្ខុនិយាយថា “បពិត្រលោកដ៏ចម្រើន ក្នុងថ្ងៃឯណោះសោះ ពួកខ្ញុំបានប្រាប់ដល់លោកហើយថា កុំឱ្យសាមណេរបេះផ្កាឈើ ព្រោះហេតុអ្វី បានជាពួកលោកមិនបានហាម” ។ ភិក្ខុគប្បីពោលថា “យើងភ្លេចស្មារតី, ផ្កាឈើទាំងឡាយគ្រាន់តែសាមណេរបេះហើយប៉ុណ្ណោះ នៅមិនទាន់បានបូជាទេ”។ មិនគួរពោលពាក្យថា “អ្នកចូរកាន់យក, ចូរបូជា” ដូច្នេះ ។ បើនិយាយ, មិនគប្បីបរិភោគនូវអាមិស ។ ភិក្ខុដទៃរមែងប្រាប់ដល់ពួកសាមណេរថា “មនុស្សនៅក្នុងស្រុកឯណោះប្រាប់ថា ‘ពួកអ្នកកុំបេះផ្កាឈើ” ដូច្នេះ; សូម្បីពួកមនុស្សនាំអាមិសមកថ្វាយទាន នឹងពោលថា “មនុស្សពួកខ្ញុំមិនមានច្រើនទេ, ពួកលោកកុំបានបញ្ជាឱ្យសាមណេរបេះផ្កាឈើព្រមនឹងពួកខ្ញុំ” ។ ពួកភិក្ខុគប្បីពោលថា “ម្នាលឧបាសក សាមណេរទាំងឡាយមានភិក្ខាហើយ, ភិក្ខុណា មិនទៅភិក្ខាចារ, ភិក្ខុនោះនឹងដឹងឯង” ។ ភិក្ខុបានន័យមានប្រមាណប៉ុណ្ណេះ ទោសព្រោះធ្វើសាមណេរ ឬបុត្រ ឬក៏បងប្រុស ប្អូនប្រុសឱ្យបេះផ្កាឈើទាំងឡាយ រមែងមិនមាន ។ ឈ្មោះថា ការឱ្យនូវផ្កាឈើ ក៏មិនមាន ។

ក្នុងការឱ្យផ្លែឈើ សូម្បីផ្លែឈើដែលសង្ឃកំណត់ទុកហើយ ដូចផ្កាឈើនោះឯងចាត់ជាគរុភណ្ឌ ។ កាលមានផ្លែឈើតូចធំច្រើនក្នុងវិហារ ពួកមនុស្សមិនមានសេចក្ដីសប្បាយមកសុំ ។ ភិក្ខុទាំងឡាយមិនខ្វល់ខ្វាយដើម្បីឱ្យ ដោយគិតថា “វត្ថុនោះជារបស់សង្ឃ” ។

ពួកមនុស្សអ្នកក្ដៅក្រហាយរមែងជេរ រមែងបរិភាស; ក្នុងសេចក្ដីនេះ ភិក្ខុគប្បីធ្វើយ៉ាងណា ?

ភិក្ខុទាំងឡាយ ត្រូវតាំងកតិកា (ច្បាប់) កំណត់ដោយផ្លែឈើទាំងឡាយ ឬដោយដើមឈើទាំងឡាយថា "អ្នកទាំងឡាយ មិនគប្បីហាមពួកមនុស្សអ្នកកាន់យកផ្លែឈើទាំងឡាយទៅមានប្រមាណប៉ុណ្ណេះ ត្រង់ដើមឯណោះៗ ឬថា អ្នកកាន់យកផ្លែឈើទាំងឡាយ ត្រង់ដើមឈើទាំងឡាយ មានប្រមាណប៉ុណ្ណេះ" ។

មួយទៀត ពួកចោរ ឬអ្នកជាធំកាន់យកដោយពលក្ការ (ការគំរាមកំហែង) ក៏មិនគប្បីហាម ។ ព្រោះថា ជនទាំងឡាយក្រោធហើយ គប្បីញ៉ាំងវិហារទាំងអស់ឱ្យវិនាសទៅបាន ។ ភិក្ខុប្រាប់ដល់ទោសដែលញ៉ាំងទុក្ខឱ្យប្រព្រឹត្តទៅដោយក្រៃលែង ។

ក្នុងការឱ្យលំអិតសម្រាប់ងូត លំអិតសម្រាប់ងូតដែលគេបុក (កិនញី) ហើយ មិនជាគរុភណ្ឌ ។ សម្បកឈើដែលគេមិនទាន់ដំបុកនោះឯង ជាគរុភណ្ឌ ។ តែលំអិតសម្រាប់ងូតដែលឆ្អិនហើយ ដោយគ្រឿងជ្រលក់ សមគួរដល់អ្នកមិនមានជំងឺ; លំអិតសម្រាប់ងូតយ៉ាងណាមួយ រមែងគួរដល់អ្នកជំងឺទាំងនោះ ។ សូម្បីដីស្អិត ក៏រួមនៅក្នុងសេចក្តីនេះដែរ ។ ពិតមែន សូម្បីដីស្អិតក្នុងទីណា ជារបស់រកបានលំបាក, ក្នុងទីនោះ នុ៎ះឯង ចាត់ជាគរុភណ្ឌ; សូម្បីដីស្អិតនោះយ៉ាងតិចបំផុត មានប្រមាណប៉ុនស្គរអំពៅទម្ងន់ ៣០ បល្ល: (តាមមាត្រាជញ្ជីងទឹកទម្ងន់ប៉ុននឹង ៤ អន្ស៊ី[*]) ប៉ុណ្ណោះ ស្រាលជាងនោះ មិនជាគរុភណ្ឌ ។

ក្នុងការឱ្យឈើជម្រះធ្មេញ ឈើជម្រះធ្មេញ ដែលគេមិនទាន់ប្រើជាគរុភណ្ឌ ។ វារៈនៃការឱ្យឈើស្ទន់អំពីសង្ឃ រមែងមានដល់សាមណេរណា, សាមណេរទាំងនោះ

[*] អន្ស៊ី ជារង្វាស់ទម្ងន់ស្មើនឹង ២៨, ៣៥ ក្រាម ។

រមែងមិនបានដើម្បីឱ្យដោយទ្បែក១ ដល់អាចារ្យ និងឧបជ្ឈាយ៍ ។ តែថា សាមណេរ ណាកំណត់ថា “ជនទាំងឡាយ គប្បីនាំឈើជម្រះធ្មេញ មានប្រមាណប៉ុណ្ណោះមក” , សាមណេរទាំងនោះ រមែងបានដើម្បីការថ្វាយដល់អាចារ្យ និងឧបជ្ឈាយ៍លើស ។ ភិក្ខុ មួយរូប មិនគួរកាន់យកឈើជម្រះធ្មេញចំនួនច្រើន មកពីរោងឈើជម្រះធ្មេញទេ; គប្បីកាន់យកតែមួយប៉ុណ្ណោះ រាល់១ ថ្ងៃ ។ សូម្បីកាលនៅបែកគ្នា គប្បីរាប់ពួកភិក្ខុ ហើយកាន់យកឈើជម្រះធ្មេញតាមដែលមានដល់ខ្លួន ។ កាលអាគន្តុកភិក្ខុទាំងឡាយ មកក្នុងចន្លោះ (អន្តរកាល) ឬកាលលោកជៀសទៅកាន់ទិស គប្បីនាំឈើជម្រះធ្មេញ មកតាំងទុកក្នុងទីដែលកាន់យកបាននោះឯង ។

ព្រះមានព្រះភាគជាម្ចាស់ រមែងត្រាស់ហៅពាក្យសរសើរ ដើម្បីត្រូវការឱ្យគេ ស្រឡាញ់ប្រាថ្នា ព្រោះតាំងខ្លួនទុកទាបដូចទាសៈខ្លះ ការតាំងទុកដោយល្អនូវពាក្យដែល ខុសភ្លាំងភ្លាត់របស់មនុស្សដទៃខ្លះ ថាជាពាក្យនិយាយប្រាថ្នាដើម្បីត្រូវការឱ្យគេស្រ-ឡាញ់ ក្នុងបទថា **“ចាដុកម្យតាយ”** ជាដើម ។

ពាក្យថា **មុគ្គសូបតាយ** នេះ ជាឈ្មោះរបស់អ្នកចិញ្ចឹមជីវិត ដោយការនិយាយ ដែលពិតខ្លះ លេងខ្លះ ដូចសម្លសណ្ដែកបាយ ។ ប្រៀបដូចសម្លសណ្ដែកបាយកំពុងក្ដៅ សណ្ដែកបាយចំនួនច្រើន រមែងឆ្អិន ចំនួនតិច រមែងមិនឆ្អិន យ៉ាងណា, សេចក្ដីនេះ ក៏ ដូច្នោះដែរ អ្នកចិញ្ចឹមជីវិតដោយការនិយាយដែលពិត ដែលលេង រមែងនិយាយកុហក ច្រើន និយាយពិតតិច ។

ម្យ៉ាងទៀត ឈ្មោះថា ទីជាទីមិនសើមចូលទៅនៃទឹកសម្លសណ្ដែកបាយ រមែង មិនមាន យ៉ាងណា, សេចក្ដីនេះ ក៏យ៉ាងនោះដែរ ឈ្មោះថា វាចាដែលមិនចូលទៅ

របស់បុគ្គលអ្នកនិយាយដែលពិតខ្លះ មិនពិតខ្លះ រមែងមិនមាន ។ វាចានោះ រមែងចងពន្ធ ដើម្បីសេចក្តីតាំងនៅដែលខ្លួនប្រាថ្នាហើយ និងប្រាថ្នាហើយដូចង្កៀងដែកដែលនៅជាប់ ។ ដោយហេតុនោះ បុគ្គលដែលមានប្រក្រតីពោលពាក្យមុសានោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា “វាចាដូចសម្លសណ្តែកបាយ” ដូច្នេះ ។

ភាវៈនៃការងារដែលបុគ្គលអ្នកចិញ្ចឹមថែរក្សាហើយ ឈ្មោះថា **បារិភដ្យតា** = ភាពជាអ្នកចិញ្ចឹមថែរក្សាហើយ ។ ពិតមែន ការងាររបស់ក្មេង ដែលគេចិញ្ចឹមថែរក្សាហើយ ឈ្មោះថា ការចិញ្ចឹមថែរក្សាក្មេង ។ ភាវៈនៃបុគ្គលអ្នកចិញ្ចឹមថែរក្សាក្មេងនោះ ឈ្មោះថា **បារិភដ្យតា** ។ ពាក្យថា **បារិភដ្យតា** នោះ ជាឈ្មោះរបស់បុគ្គលអ្នកញុំាងក្មេងឱ្យលេង ដោយការធ្វើនូវគ្រឿងប្រដាប់ជាដើម ។

ពាក្យថា **ជង្ឃបេសនិកំ** បានដល់ ការនាំដំណឹងទៅ និងនាំត្រឡប់មករបស់គ្រហស្ថទាំងនោះៗ ក្នុងទីទាំងឡាយ មានចន្លោះភូមិ និងចន្លោះប្រទេសជាដើម ។

ពិតមែន ពាក្យនេះ ឈ្មោះថា ការដើរបញ្ជូនដំណឹងដល់មាតាបិតារបស់ខ្លួន, ក៏មាតាបិតាបម្រុងនូវភិក្ខុនោះ, ភិក្ខុកាន់យកដំណឹងរបស់មាតាបិតាទាំងនោះទៅ ដោយអំណាចនៃការទៅក្នុងទីណាៗ រមែងគួរ ។ ការនាំដំណឹងសូម្បីរបស់នាយជាងអ្នកធ្វើការងាររបស់ចេតិយ ឬរបស់សង្ឃ ឬថារបស់ខ្លួន ក៏សមគួរដែរ ។

មួយទៀត ពួកមនុស្សទូលថា “ពួកខ្ញុំនឹងថ្វាយទាន, នឹងធ្វើការបូជា, នឹងប្រាប់ដល់ភិក្ខុសង្ឃ” ដូច្នេះក្តី, មនុស្សទាំងឡាយ រមែងថ្វាយបិណ្ឌបាត ឬភេសជ្ជៈ ឬក៏ចីវរ ដោយពោលថា “សូមលោកទាំងឡាយ ចូរថ្វាយដល់ព្រះថេរៈឈ្មោះឯណោះ” ដូច្នេះ

ក្ដី, មនុស្សទាំងឡាយ រមែងប្រគល់វត្ថុទាំងឡាយ មានបាច់ផ្កាឈើ របស់ក្រអូប និង គ្រឿងលាបជាដើម ឬទង់ជ័យ និងទង់ផ្ទាំងសំពត់ជាដើម ដោយការទូលថា “លោកទាំងឡាយ ចូរធ្វើការបូជាក្នុងវិហារ” ដូច្នេះក្ដី, ការនាំដំណឹងទាំងអស់របស់ជនទាំងនោះទៅ សមគួរ ។ ឈ្មោះថា ការដើរបញ្ជូនដំណឹង រមែងមិនមាន ។ ភិក្ខុកាន់យកដំណឹងរបស់ជនទាំងឡាយដែលនៅសល់ក្រៅពីនោះទៅ មានទោសគ្រប់ៗ ជំហាន ។

ពាក្យថា **អញ្ញតរញ្ញតរេន** បានដល់ ដោយអាការយ៉ាងណាមួយនៃការឱ្យទាំងឡាយ មានការឱ្យឫស្សីជាដើមទាំងនោះ គឺថា ដោយយ៉ាងណាមួយនៃការងារទាំងឡាយ សម្រាប់ចិញ្ចឹមជីវិតប្រាកដដូច្នេះ គឺវេជ្ជកម្ម ភណ្ឌាគារិកកម្ម (ការរក្សាឃ្លាំង) ការដូរដុំបាយ ដោយដុំបាយ ការបម្រុងសង្ឃ និងចេតិយដែលខុសប្រក្រតី ឬដោយមិច្ឆាអាជីវៈ ។

ពាក្យថា **ពុទ្ធបដិកុដ្ឋេន** បានដល់ ដែលព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទ្រង់តិះ-ដៀលហើយ ទ្រង់បដិសេធហើយ ។

ពាក្យថា **អយំ វុច្ចតិ** បានដល់ ឈ្មោះថា សូម្បីអនាចារទាំងពួងនេះ ព្រះពុទ្ធជាម្ចាស់រមែងត្រាស់ទុក ។

អាចារនិទ្ទេស បណ្ឌិតគប្បីជ្រាបដោយន័យផ្ទុយគ្នា តាមដែលពោលហើយនេះចុះ ។

សូម្បីក្នុងគោចរនិទ្ទេស បណ្ឌិតគប្បីជ្រាបការធ្វើ ព្រោះពាក្យនៃអគោចរដោយន័យដែលពោលហើយ ក្នុងពេលមុននោះឯង ។

ក៏ក្នុងពាក្យទាំងនោះ ពាក្យថា **គោចរោ** បានដល់ ទីគួរចូលទៅដើម្បីត្រូវការបិណ្ឌបាតជាដើម ឈ្មោះថា គោចរ ។ ទីដែលមិនសមគួរដើម្បីការចូលទៅ ឈ្មោះថា អគោចរ ។ គោចរនៃស្រីពេស្យាមានហើយដល់ភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ ទើបឈ្មោះថា មានគោចរនៃស្រីពេស្យា, អធិប្បាយថា ទីជាទីគោចរដែលបុគ្គលគប្បីចូលទៅ ដោយអំណាចនៃសេចក្តីស្និទ្ធស្នាលដូចជាមិត្ត ។ ស្ត្រីទាំងឡាយ ចិញ្ចឹមជីវិតដោយរូប ឈ្មោះថា ស្រីពេស្យា ។ ក្នុងអធិការនេះ ភិក្ខុចូលទៅនៅអាចជាអ្នកប្រព្រឹត្តខុសបានដោយងាយ ឬដោយសេចក្តីស្និទ្ធស្នាលស្នេហាដូចជាមិត្ត ឈ្មោះថា មានគោចរនៃស្រីពេស្យា ។ ព្រោះហេតុដូច្នោះ ភិក្ខុនោះ ចូលទៅដោយអាការយ៉ាងនេះ រមែងមិនគួរ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះសេចក្តីជាវិបត្តិក្នុងការរក្សា ។

ពិតមែន សមណធម៌ សូម្បីដែលលោកឃុំគ្រងរក្សាហើយអស់កាលយូរ របស់ភិក្ខុអ្នកចូលទៅនៅដោយអាការយ៉ាងនេះ រមែងដល់សេចក្តីវិនាសទៅ ដោយហេតុដែលបន្តិចបន្តួចនោះឯង ។ សូម្បីបើថាសមណធម៌របស់លោក រមែងមិនវិនាសទៅ ក៏នឹងបានទទួលសេចក្តីតិះដៀល ។ មួយទៀត ភិក្ខុកាលចូលទៅដោយអំណាចនៃការទទួលទក្ខិណា (របស់ធ្វើបុណ្យ) គប្បីតាំងសតិ ហើយចូលទៅ ។ ស្ត្រីស្វាមីស្លាប់ ឬស្ត្រីដែលស្វាមីលែងលះហើយ លោកហៅថា ស្រីមេម៉ាយ ។ ស្ត្រីចាស់ដែលមិនបានរៀបការ ឈ្មោះថា ក្រមុំចាស់ ។

ពាក្យថា **បណ្ឌកា** បានដល់ មនុស្សខ្ទើយអ្នកមានពាក្យអាស្រ័យលោកាមិស មានកិលេសក្រាស់ មានសេចក្តីក្តៅក្រហាយមិនស្ងប់ ។ ទោសព្រោះការចូលទៅរបស់ភិក្ខុទាំងអស់នោះ គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង។ សូម្បីភិក្ខុនីទាំង-ឡាយ ក៏ន័យនេះដែរ ។

ម្យ៉ាងទៀត ធម្មតាភិក្ខុត្រូវប្រព្រឹត្តព្រហ្មចរិយៈឱ្យច្រើន, ភិក្ខុនីទាំងឡាយ ក៏ដូចគ្នាដែរ ។ ភិក្ខុនីទាំងនោះ រមែងញ៉ាំងសមណធម៌ ដែលភិក្ខុរក្សាឃុំគ្រងឱ្យវិនាសទៅដោយអំណាចនៃសេចក្តីសិទ្ធស្នាលនូវគ្នានឹងគ្នា ដែលជាហេតុតិចតួចនោះឯង ។ តែការដែលភិក្ខុទៅដោយអំណាចនៃការសួរជំងឺ រមែងគួរ ។ ភិក្ខុបានផ្កាឈើទាំងឡាយហើយទៅ ដើម្បីត្រូវការបូជាខ្លះ ដើម្បីត្រូវការឱ្យឱវាទខ្លះ រមែងគួរមែនពិត ។

រោងសុរា ឈ្មោះថា **បានាគារ**; រោងសុរានោះ រមែងមិនស្ងាត់ពីអ្នកលេង (អ្នកផឹក) សុរាដែលនឹងធ្វើអន្តរាយដល់ព្រហ្មចរិយៈ ។ ក្នុងរោងសុរានោះ ភិក្ខុទាំង-ឡាយ មិនគួរចូលទៅជាមួយអ្នកលេងសុរាទាំងនោះ ដោយអំណាចនៃការសេពគប់អ្នកលេង; ព្រោះអន្តរាយរមែងមានដល់ព្រហ្មចរិយៈ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យ ថា **សំសដ្ឋា វិហរតិ រាជូហិ** ជាដើម ព្រះរាជាណា អភិសេកហើយក៏ដោយ មិនអភិសេកហើយ ក៏ដោយ ចូរលើកទុកចុះ ។ ជនណារមែងសិក្សាក្នុងភាពជាព្រះរាជា ជនទាំងនោះ ក៏ឈ្មោះថា **រាជា** ។

ពាក្យថា **រាជមហាមត្តា** បានដល់ អ្នកប្រកបដោយភាពជាធំ ដូចនឹងភាពជាធំរបស់ព្រះរាជា ។

ពាក្យថា **តិត្ថិយា** បានដល់ អ្នកបួសក្រៅព្រះពុទ្ធសាសនា ដែលមានសេចក្ដីយល់ឃើញខុស ។ បទថា **តិត្ថិយសាវិកា** បានដល់ អ្នកឱ្យបច្ច័យដល់តិត្ថិយទាំងនោះ ដោយអំណាចនៃការស្និទ្ធស្នាល, គឺថាជាអ្នកច្រឡូកច្រឡំនឹងជនទាំងនោះ ។

ពាក្យថា **អននុលោមិកេន គិហិសំសគ្គេន** បានដល់ បុគ្គលណាជាប់ទាក់ទងនឹងសត្រូវ ដែលមិនស្របតាមសិក្ខា ៣ រមែងដល់ការឈានកន្លងបញ្ញត្តិ ជាអន្តរាយចំពោះព្រហ្មចរិយៈ រមែងដល់នូវសេចក្ដីសាបសូន្យជុំវិញចាកការដុះខាត់ ដោយសភាវៈណា សភាវៈនោះ ឈ្មោះថា ការច្របូកច្របល់នឹងគ្រហស្ថដែលមិនសមគួរ ។ គឺយ៉ាងណា ? គឺថា ជាអ្នកមានសេចក្ដីសោក មានសេចក្ដីសុខស្រួល មានសុខទុក្ខរួមនឹងព្រះរាជា និងមហាមាត្យរបស់ព្រះរាជា ឬក្នុងកាលមានករណីយកិច្ចកើតឡើង ជាអ្នកជួយឈឺឆ្អាលដោយខ្លួនឯង, និងភាពជាអ្នកមានសមាចារជាឯកច្ឆន្ទ ជាមួយនឹងតិត្ថិយនិងសាវកតិត្ថិយទាំងឡាយ ឬក៏នាំមកនូវភារៈនៃសមាចារដែលពេញចិត្តជាឯកច្ឆន្ទ ឬថាសេចក្ដីជិតស្និទ្ធ មានចិត្តច្រើនដោយសេចក្ដីស្នេហា ។ ក្នុងអធិការនេះ ការច្របូកច្របល់ជាមួយព្រះរាជា និងមហាមាត្យរបស់ព្រះរាជា រមែងធ្វើអន្តរាយដល់ព្រហ្មចរិយៈ ។ ការច្របូកច្របល់នឹងតិត្ថិយ និងសាវ័ករបស់តិត្ថិយទាំងឡាយ រមែងធ្វើអន្តរាយ គឺការកាន់យកលទ្ធិរបស់ជនទាំងនោះ ។ តែថា ភិក្ខុដែលអាចចូលទៅដើម្បីទម្លាយវាទៈ (លទ្ធិ) របស់តិត្ថិយ និងសាវ័ករបស់តិត្ថិយ ហើយឱ្យកាន់យកលទ្ធិរបស់ខ្លួន រមែងគួរ ។

ឥឡូវនេះ ដើម្បីសម្ដែងអគោចរដោយបរិយាយ សូម្បីដទៃទៀត ទើបព្រះមានព្រះភាគជាម្ចាស់ ផ្ដើមពាក្យថា **"យានិ វា បន តានិ កុលានិ"** ជាដើម ។

បណ្តាពាក្យទាំងនោះ ពាក្យថា **អសទ្ធានិ** បានដល់ ជាអ្នកមិនមានសទ្ធាក្នុងព្រះពុទ្ធជាដើម, គឺមិនជឿថា "ព្រះពុទ្ធជាម្ចាស់ជាសព្វញ្ញូ, ព្រះធម៌ជានិយ្យានិកៈ (ជាធម៌នាំសត្វចេញចាកវដ្តៈ), ព្រះសង្ឃជាអ្នកបដិបត្តិល្អហើយ" ដូច្នេះ ។

ពាក្យថា **អប្បសន្នានិ** បានដល់ មិនអាចដើម្បីធ្វើចិត្តឱ្យថ្លាផូរផង់ មិនឱ្យល្អក់ ។

ពាក្យថា **អក្កោសកបរិភាសកានិ** បានដល់ ការជេរ និងការបរិភាស, គឺរមែងជេរ រមែងបរិភាសដោយអក្កោសវត្ថុ ១០ ថា "អ្នកជាចោរ, ជាមនុស្សពាល, ជាមនុស្សវង្វេង, ជាឱដ្ឋ, ជាគោ, ជាលា, ជាអ្នកកើតក្នុងអបាយ, ជាសត្វនរក, ជាសត្វតិរច្ឆាន, សុគតិរបស់លោកមិនមាន, មានតែទុគ្គតិប៉ុណ្ណោះ ជាទីសង្ឃឹមទុក" ។ ម្យ៉ាង-ទៀត ឈ្មោះថា ការជេរ និងការប្រទេចនោះ ចូរលើកទុកសិន ឈ្មោះថា រមែងបរិភាស ព្រោះចង្អុលឱ្យឃើញភ័យយ៉ាងនេះថា "ឥឡូវនេះ យើងនឹងប្រហារលោក នឹងចងលោក នឹងសម្លាប់លោក" ដូច្នេះ ។

បទថា **អនត្ថកាមានិ** បានដល់ រមែងមិនប្រាថ្នាប្រយោជន៍, គឺរមែងប្រាថ្នាសេចក្តីវិនាសនោះឯង ។

បទថា **អហិតកាមានិ** បានដល់ រមែងប្រាថ្នាប្រយោជន៍មិនបាន, គឺមិនត្រូវការប្រយោជន៍ ។

បទថា **អផាសុកាមានិ** បានដល់ រមែងមិនប្រាថ្នានូវផាសុក, គឺមិនប្រាថ្នានូវសេចក្តីសប្បាយ; បទថា **អយោគក្ខេមកាមានិ** បានដល់ រមែងមិនប្រាថ្នាដែនក្សេម

ចាកយោគៈ ៤ ដែលមិនមានភ័យ, គឺរមែងប្រាថ្នាដែនដែលប្រព្រឹត្តទៅជាមួយភ័យនោះឯង ។ សូម្បីសាមណេរទាំងឡាយ ក៏រមែងដល់សេចក្ដីសង្គ្រោះចូលក្នុងពាក្យថា **ភិក្ខូនំ** ដូច្នេះដែរ ។ សូម្បីសិក្ខមានា និងសាមណេរីទាំងឡាយ ក៏ដល់ការសង្គ្រោះចូលក្នុងពាក្យថា **ភិក្ខុនីនំ** នេះដែរ ។ ពិតមែន ត្រកូលទាំងនោះ ឈ្មោះថា ជាអ្នកប្រាថ្នាតែសេចក្ដីវិនាសដល់បរិស័ទ សូម្បីទាំង ៤ គឺដល់ពួកជនទាំងឡាយ អ្នកបួសឧទ្ទិសចំពោះព្រះមានព្រះភាគជាម្ចាស់ និងអ្នកដល់សរណគមន៍នោះឯង ។

ពាក្យថា **តថារូបានិ កុលានិ** ត្រកូលទាំងឡាយ មានត្រកូលនៃក្សត្រជាដើមប្រាកដដូច្នោះ ។

ពាក្យថា **សេវតិ** បានដល់ អាស្រ័យចិញ្ចឹមជីវិត ។

ពាក្យថា **ភជតិ** បានដល់ រមែងចូលទៅរក ។

ពាក្យថា **បយិរុបាសតិ** បានដល់ ចូលទៅរកញយៗ ។

ពាក្យថា **អយំ វុច្ចតិ** បានដល់ គោចរដែលមិនសមគួរ សូម្បីមានប្រការទាំង ៣ នេះ គឺគោចរក្នុងសំណាក់របស់ស្រីពេស្យា គោចរក្នុងសំណាក់នៃព្រះរាជាជាដើម, ដោយការច្រឡូកច្រឡំជាមួយនឹងព្រះរាជាជាដើម, គោចរក្នុងត្រកូលរបស់អ្នកមិនមានសទ្ធាជាដើមទាំងនេះ បណ្ឌិតគប្បីជ្រាបថា ជាអគោចរ ។ សេចក្ដីជាកន្លែងអគោចរនៃភិក្ខុនោះ គប្បីជ្រាបដោយបរិយាយនេះ ។ សំណាក់នៃស្រីពេស្យាជាដើម គប្បីជ្រាបថា ជាអគោចរ ព្រោះជាគោចរអាស្រ័យបញ្ចកាមគុណពិត ។ ដូចពាក្យដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក៏អគោចររបស់ភិក្ខុជាវិស័យរបស់អ្នក

ដទៃ តើដូចម្តេច ? អគោចរជាវិស័យរបស់អ្នកដទៃណា គឺបញ្ចកាមគុណ” [២៣] ។ សំណាក់នៃព្រះរាជាជាដើមនោះ ជាអគោចរ ព្រោះមិនជាឧបនិស្ស័យនៃការប្រកបសេចក្តីព្យាយាមរឿយ១ ក្នុងឈាន និងព្រោះការសន្ទុំលាភសក្ការៈដែលជាគ្រឿងទម្លាយ និងព្រោះវិបត្តិនៃទិដ្ឋិជាហេតុ ។ សំណាក់នៃត្រកូលអ្នកមិនមានសទ្ធាជាដើម ឈ្មោះថា ជាអគោចរ ព្រោះការទម្លាយសទ្ធា គឺនាំចិត្តដែលត្រេកអរចេញទៅ ។

ក្នុងគោចរនិទ្ទេស ពាក្យថា **ន ខេសិយគោចរោ** ជាដើម បណ្ឌិតគប្បីជ្រាបដោយអំណាចនៃពាក្យជាបដិបក្ខចំពោះពាក្យដែលពោលហើយ ។

ក៏ក្នុងពាក្យទាំងឡាយ មានពាក្យថា **ឱបានភូតានិ** ជាដើម ពាក្យថា **ឱបាន-ភូតានិ** បានដល់ ដូចជាអណ្តូងទឹក ដូចស្រះបោក្ខរណី ដែលគេជីកហើយក្នុងផ្លូវធំទាំង ៤ កន្លែង ដើម្បីភិក្ខុសង្ឃ និងដូចផ្ទះរបស់ចិត្តមហាមាត្យ ដែលគេជីកដើម្បីងូតទឹកតាមការសប្បាយ ។ បានឮថា ផ្ទះរបស់មហាមាត្យនោះ គេប្រកបសសរវេលា (នាឡិកា) ទុកក្នុងផ្ទះនោះឯង ។ ឈ្មោះថា សេចក្តីខ្វះខាតដោយបច្ច័យរបស់ភិក្ខុអ្នកមកដល់ទ្វារផ្ទះរបស់មហាមាត្យនោះ មិនបានមាន ។ ក្នុងថ្ងៃនីមួយ១ គេប្រើប្រាស់ចាយប្រាក់ដល់ ៦០ កហាបណៈ ចេញទៅដើម្បីសេចក្តីប្រព្រឹត្តទៅនៃភេសជ្ជៈនោះឯង ។

ពាក្យថា **ភាសាខបង្ខោតានិ** បានដល់ ឱភាសម្យ៉ាង នៃរស្មីរបស់សំពត់កាសាវៈទាំងឡាយដែលភិក្ខុ និងភិក្ខុនី អ្នកស្លៀកដណ្តប់ហើយនោះឯង ដូចនឹងត្រកូលសេដ្ឋីឈ្មោះថា ភូតបាល ។

---

[២៣] សំ. ម. ។

ពាក្យថា **ឥសិវាតបដិវាតានិ** បានដល់ ជារបស់រុងរឿងផ្សាយទៅ ដោយខ្យល់នៃចីវររបស់ឥសីទាំងឡាយ ពោលគឺភិក្ខុ និងភិក្ខុនីទាំងឡាយអ្នកចូលផ្ទះ និងចេញចាកផ្ទះ និងដោយខ្យល់នៃសរីរៈដែលឃ្លាតញ៉រទៅដោយការលាចេញ និងការបត់ចូលមកជាដើម ឬថាជាអ្នកមានអកុសលទាំងឡាយកម្ចាត់ចេញហើយ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេសនៃភិក្ខុភាវៈជាអ្នកមានប្រក្រតីឃើញភ័យក្នុងទោសទាំងឡាយ មានប្រមាណតិច ។ ពាក្យថា **វជ្ជានិ** បានដល់ ទោសទាំងឡាយ ។ ពាក្យថា **អណុមត្តានិ** បានដល់ ទោសមានប្រមាណតិច ។ ពាក្យថា **យានិ តានិ វជ្ជានិ** បានដល់ ឈ្មោះថាទោសទាំងឡាយនោះឯង ព្រោះអត្ថថា ជាវត្ថុដែលបណ្ឌិតគប្បីតិះដៀល ។ ពាក្យថា **អប្បមត្តកានិ** បានដល់ ឈ្មោះថា មានប្រមាណតិចតួច គឺមានប្រមាណតូច ។ ពាក្យថា **ឱរមត្តកានិ** បានដល់ មានប្រមាណល្អិត ព្រោះមានប្រមាណទាបបំផុតសូម្បីជាងប្រមាណតូច ។ ពាក្យថា **លហុសានិ** បានដល់ ជារបស់ស្រាល ។ ពាក្យថា **លហុ** ក្នុងពាក្យថា **លហុសម្មតានិ** បានដល់ ជារបស់សម្មតិ ។ ពាក្យថា សញ្ញមករណីយានិ បានដល់ ការធ្វើសង (សម្ដែងចេញ) ដែលភិក្ខុគប្បីធ្វើដោយសេចក្ដីសង្រួម ។ ពាក្យថា **សំវរករណីយានិ** បានដល់ គប្បីធ្វើដោយការសង្រួម គឺការធ្វើសងដែលភិក្ខុនោះគប្បីធ្វើដោយសេចក្ដីរវាំង ។ ពាក្យថា ចិត្តុប្បាទករណីយានិ បានដល់ ការធ្វើសងដែលភិក្ខុនោះ គប្បីធ្វើដោយត្រឹមតែចិត្តុប្បាទ ។ ពាក្យថា **មន-សិការបដិពទ្ធានិ** បានដល់ ការធ្វើសង ដែលភិក្ខុគប្បីធ្វើត្រឹមតែការរំពឹងហើយ ដោយចិត្តនោះឯង ។

តើការធ្វើសងទាំងនោះ ដូចម្តេច ?

គប្បីជ្រាបថា **ព្រះសុមត្ថេរ** អ្នកមានប្រក្រតីនៅក្នុងទិវាវិហារ (កោះលង្កា) លោកពោលទុកថា "ភិក្ខុទាំងឡាយ រមែងបរិសុទ្ធបានដោយចិត្ត គឺត្រឹមតែការនឹកហើយនោះឯងថា យើងនឹងធ្វើនូវអាបត្តិទាំងនោះ ត្រឹមតែថាចិត្តុប្បាទ ឱ្យដល់នូវអនាបត្តិ ឱ្យមានសភាពយ៉ាងនេះទៀត, ឈ្មោះថា ធ្វើការបើកបង្ហាញដោយការអធិដ្ឋាន" នេះជាការដែលខ្ញុំពោលហើយ ។ ចំណែកព្រះតិបិដកចូឡនាគត្ថេរ ដែលជាអន្តេវាសិករបស់លោកនោះ ពោលថា "ក៏បទនេះ ជាបទភាជនិយបាតិមោក្ខនោះឯង, ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបថា ទោសក្នុងទីនេះ គឺអាបត្តិទុក្កដ និងទុព្ភាសិត ស្រាលជាងទោសទាំងពួង, ឈ្មោះថា ការបើកបង្ហាញ គឺការចាកចេញទោសនោះ ប្រព្រឹត្តទៅតាមដែលខ្ញុំពោលហើយ" ។

ពាក្យថា **ឥតិ ឥមេសុ** បានដល់ ពួកនេះមានប្រការយ៉ាងនេះ ។

ពាក្យថា **វជ្ជទស្សាវី** បានដល់ មានប្រក្រតីឃើញទោសដោយភាពជាទោស ។

ពាក្យថា **ភយទស្សាវី** បានដល់ មានប្រក្រតីឃើញភ័យដោយការប្រព្រឹត្តទៅនៃភ័យ ៤ យ៉ាង ។

ក្នុងពាក្យថា **អាទីនវទស្សាវី** នេះ បានដល់ មានប្រក្រតីឃើញទោស មានប្រការផ្សេងៗ គឺដោយការនាំមកនូវសេចក្តីនិន្ទា ដោយមានទុក្ខ ជាផលខាងមុខ ដោយធ្វើអន្តរាយចំពោះគុណខាងលើ និងព្រោះឱ្យកើតសេចក្តីក្តៅក្រហាយ ។

ពាក្យថា **និស្សរណទស្សាវី** បានដល់ មានប្រក្រតីឃើញទោសរបស់ភិក្ខុ រើដក

ចេញពីទោសភ័យនោះ ។

ក៏ក្នុងអធិការនេះ ការដកចេញចាកទោសភ័យនោះ តើដូចម្តេច ?

ក្នុងអាចរិយថេរវាទពោលទុកមកថា “ការបើកបង្ហាញដោយការអធិដ្ឋានដោយសតិ ឈ្មោះថា ការរើចេញ ព្រោះភាពជាអ្នកដល់អនាបត្តិ (ការមិនមានអាបត្តិ) ” ។

ក្នុងថេរវាទនៃអន្តេវាសិករបស់លោក ពោលថា “ការបើកបង្ហាញដោយការចេញចាកដោយសតិ ឈ្មោះថា ការរើដកចេញ ព្រោះភាពជាអ្នកត្រូវអាបត្តិ” ។ សម្រាប់ក្នុងទីនេះ ភិក្ខុបែបនេះ ឈ្មោះថា រមែងឃើញទោសទាំងឡាយ មានប្រមាណតិច ដោយសេចក្តីជាទោស ដោយសេចក្តីជាភ័យ ។ ដើម្បីសម្តែងនូវទោសមានប្រមាណតិច ដោយសេចក្តីជាទោស ដោយសេចក្តីជាភ័យនោះ លោកពោលមាត្រា (ប្រមាណ) ទុកថាដូច្នេះ ៖

១. ឈ្មោះថា **បរមាណូ** = ចំណែកនៃអាកាស,
២. ឈ្មោះថា **អណូ** = រស្មីព្រះអាទិត្យ
៣. ឈ្មោះថា **តជ្ជារី** = វត្ថុកើតពីអណូនោះ,
៤. ឈ្មោះថា **រថរេណូ** = លម្អងរថ
៥. ឈ្មោះថា **លិក្ខា** = ពងចៃ,
៦. ឈ្មោះថា **ឩកា** = មេចៃ
៧. ឈ្មោះថា **ធញ្ញមាស** = គ្រាប់ស្រូវ,
៨. ឈ្មោះថា **អង្គុលី** = ម្រាមដៃ
៩. ឈ្មោះថា **វិទត្ថិ** = ចំអាម,
១០. ឈ្មោះថា **រតនៈ** = ហត្ថ
១១. ឈ្មោះថា **យដ្ឋី** = គោលសសរ,
១២. ឈ្មោះថា **ឧសភៈ** = គោពេញកម្លាំង
១៣. ឈ្មោះថា **គាវុត**,
១៤. ឈ្មោះថា **យោជន៍** ។

បណ្តាឈ្មោះទាំងនោះ ឈ្មោះថា បរមាណូ ជាចំណែកនៃអាកាស (អនុភាគ

ដែលតូចមិនអាចឃើញដោយមំសចក្ខុបាន ឃើញបានដោយទិព្វចក្ខុ) មិនមកកាន់គន្លងនៃភ្នែកសាច់ រមែងមកកាន់គន្លងនៃភ្នែកទិព្វប៉ុណ្ណោះ ។ ឈ្មោះថា អណូ គឺរស្មីនៃព្រះអាទិត្យដែលបញ្ចេញចូលទៅតាមចន្លោះជញ្ជាំង ចន្លោះស្លឹកត្នោតជារង្វង់មូលៗ ដោយល្អ ប្រាកដវិលទៅ ។ ឈ្មោះថា តជ្ជារី ព្រោះចោះត្រង់ផ្លូវគោ ផ្លូវមនុស្ស និងផ្លូវកង់ហើយ ប្រាកដផ្សាយទៅត្រង់ខាងទាំងពីរ ។ ឈ្មោះថា រថរេណូ រមែងជាប់នៅត្រង់រថនោះឯង ។ ឈ្មោះថា លិក្ខា ជាដើម ប្រាកដច្បាស់ហើយមែនពិត ។

ក៏ក្នុងពាក្យទាំងនោះ គប្បីជ្រាបប្រមាណដូចនេះ ៖

| | | | | | |
|---|---|---|---|---|---|
| ៣៦ បរមាណូ | ជាប្រមាណ | ១ អណូ, | ៣៦ អណូ | ជាប្រមាណ | ១ តជ្ជារី; |
| ៣៦ តជ្ជារី | ,, | ១ រថរេណូ, | ៣៦ រថរេណូ | ,, | ១ លិក្ខា; |
| ៧ លិក្ខា | ,, | ១ ឩកា, | ៧ ឩកា | ,, | ១ ធញ្ញមាស; |
| ៧ ធញ្ញមាស | ជាប្រមាណ | ១ អង្គុលី, | ១២ អង្គុលី | ជាប្រមាណ | ១ វិទត្ថិ; |
| ១២ វិទត្ថិ | ,, | ១ រតនៈ, | ៧ រតនៈ | ,, | ១ យដ្ឋិ; |
| ២០ យដ្ឋិ | ,, | ១ ឧសភ, | ៨០ ឧសភ | ,, | ១ គាវុត (៤ គីឡូម៉ែត្រ); |

៤ គាវុត ស្មើ ១ យោជន៍, ១០.០៦៨ យោជន៍ (ផ្នែកកម្ពស់) ស្មើនឹងភ្នំសិនេរុរាជ ។

ភិក្ខុណាធ្វើនូវទោសមានប្រមាណតិច ឱ្យដូចនឹងភ្នំសិនេរុរាជ ដែលខ្ពស់ប្រមាណ ១០.០៦៨ យោជន៍ អាចដើម្បីនឹងឃើញ (គឺកាលឃើញថា ជាទោសធំ ត្រូវអាបត្តិ) បាន, ភិក្ខុណា ឈ្មោះថា រមែងឃើញទោសទាំងឡាយ មានប្រមាណតិច ដោយសេចក្ដីជាភ័យ; ភិក្ខុណា សូម្បីធ្វើនៅត្រឹមតែទោស គឺអាបត្តិទុក្កដ និងទុព្ភាសិត ដែលស្រាល

ជាងទោសទាំងពួង ឱ្យឃើញដូចនឹងអាបត្តិបឋមបារាជិក, ភិក្ខុនោះ បណ្ឌិតគប្បីជ្រាប ថា ឈ្មោះថា រមែងឃើញទោសទាំងឡាយ មានប្រមាណតិច ដោយសេចក្តីជាទោស ដោយសេចក្តីជាភ័យដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃបទថា **“សមាទាយ សិក្ខតិ សិក្ខាបទេសុ”** ។

ពាក្យថា **ភិក្ខុសិក្ខា** បានដល់ សិក្ខា ដែលភិក្ខុទាំងឡាយគប្បីសិក្សា ។ ភិក្ខុ-សិក្ខានោះ ទូទៅជាមួយនឹងភិក្ខុនីខ្លះ មិនទូទៅខ្លះ សូម្បីយ៉ាងនោះ ក៏ឈ្មោះថា ភិក្ខុ-សិក្ខានោះឯង ។ ពាក្យថា **ភិក្ខុនីសិក្ខា** បានដល់ សិក្ខាដែលភិក្ខុនីទាំងឡាយគប្បីសិក្សា; សូម្បីភិក្ខុនីសិក្ខានោះ ទូទៅដល់ភិក្ខុទាំងឡាយក្តី មិនទូទៅក្តី ឈ្មោះថា ភិក្ខុនីសិក្ខាដូចគ្នាដែរ ។ សូម្បីសិក្ខារបស់សាមណេរ សិក្ខមានា និងសាមណេរីទាំងឡាយ ក៏រួមនៅក្នុងសេចក្តីនេះឯង ។

ពាក្យថា **ឧបាសកសិក្ខា** បានដល់ សិក្ខាដែលឧបាសកទាំងឡាយគប្បីសិក្សា ។ សិក្ខារបស់ឧបាសកនោះ រមែងប្រព្រឹត្តទៅដោយអំណាចនៃសីល ៥ និងសីល ១០ ។

ពាក្យថា **ឧបាសិកាសិក្ខា** បានដល់ សិក្ខាដែលឧបាសិកាទាំងឡាយ គប្បីសិក្សា; សូម្បីសិក្ខានោះ រមែងប្រព្រឹត្តទៅដោយអំណាចនៃសីល ៥ និងសីល ១០ ។

បណ្តាសិក្ខាទាំងនោះ សិក្ខារបស់ភិក្ខុ និងភិក្ខុនី រមែងប្រព្រឹត្តទៅដរាបដល់អរហត្តមគ្គ ។ សិក្ខារបស់ឧបាសក និងឧបាសិកា រមែងប្រព្រឹត្តទៅដរាបដល់អនាគាមិមគ្គ ។ ក្នុងទីនេះ ភិក្ខុរមែងសិក្សាក្នុងសិក្ខាបទទាំងឡាយ ដែលខ្លួនគប្បីសិក្សាតែប៉ុណ្ណោះ ។ ចំណែកសិក្ខាបទដែលនៅសល់ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុក

ដើម្បីសម្តែងអត្ថរបស់សិក្ខាបទ ដោយអំណាចនៃការលើកឡើងនូវប្រយោជន៍ ។

ពាក្យថា **ឥតិ ឥមាសុ សិក្ខាសុ** បានដល់ ក្នុងសិក្ខាបទទាំងឡាយនេះ មានប្រការយ៉ាងនេះ ។

ពាក្យថា **សព្វេន សព្វំ** បានដល់ សិក្ខាទាំងពួង ដោយការសមាទានសិក្ខាបទទាំងពួង ។

ពាក្យថា **សព្វថា សព្វំ** បានដល់ សិក្ខាបទទាំងពួង ដោយមានប្រការដែលបុគ្គលទាំងពួងគប្បីសិក្សា ។

ពាក្យថា **អសេសំ និស្សេសំ** បានដល់ ឈ្មោះថា **អសេសំ** (មិនឱ្យសល់) ព្រោះមិនមានចំណែកសល់, ឈ្មោះថា **និស្សេសំ** ព្រោះធ្វើសិក្ខាបទ សូម្បីដែលដាច់ហើយ ដោយសេចក្តីវង្វេងភ្លេច ឱ្យជាប្រក្រតីទៀត ។

ពាក្យថា **សមាទាយ វត្តតិ** បានដល់ សមាទាន កាន់យក ទើបប្រព្រឹត្ត ។

ពាក្យថា **តេន វុច្ចតិ** បានដល់ សមាទានសិក្ខាបទទាំងពួងនេះហើយ រមែងសិក្សា រមែងឱ្យពេញដោយអាការដែលបុគ្គលទាំងពួងគប្បីសិក្សា, ដោយហេតុនោះទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា “**សមាទាយ សិក្ខតិ សិក្ខាបទេសុ** = សមាទានហើយប្រព្រឹត្តនៅក្នុងសិក្ខាបទទាំងឡាយ” ដូច្នេះ ។

ក្នុងនិទ្ទេសពួក ២ នៃបទថា **ឥន្ទ្រិយេសុ គុត្តទ្វារោ, ភោជនេ មត្តញ្ញូ** គប្បីជ្រាបការប្រកបដោយពាក្យដំបូងនៃភិក្ខុអ្នកជំពាក់ទាក់ទិនក្នុងធម៌ដែលខ្មៅ ដោយន័យដែលខ្ញុំពោលហើយក្នុងអាចារនិទ្ទេសនោះឯង ។ ក៏ពាក្យថា **តត្ថ កតមា ឥន្ទ្រិយេសុ**

**អគុត្តទ្វារតា** ជាដើម ពាក្យណាដែលគួរពោល ពាក្យទាំងអស់នោះ ខ្ញុំពោលហើយក្នុងនិក្ខេបកណ្ឌវណ្ណនានោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ជាគរិយានុយោគ** តទៅ ៖

ខាងដើមនៃរាត្រី ពោលគឺពេលយប់ ឈ្មោះថា **បុព្វរត្ត** ក្នុងពាក្យថា បុព្វ-រត្តាបររត្តំ នេះ ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់កាន់យកនូវបឋមយាម និងបច្ឆាភត្ត ដោយសព្ទថា **បុព្វរត្ត** នេះ ។ ខាងក្រោយនៃរាត្រី ឈ្មោះថា **អបររត្តំ**; ទ្រង់កាន់យកបច្ឆិមយាម និងបុរេភត្ត ដោយសព្ទថា អបររត្តនេះ ។

ចំណែកមជ្ឈិមយាម លោកមិនកាន់យក ព្រោះជាឱកាសនៃការដេកលក់ និងការបន្ទោបង់សេចក្តីនឿយហត់របស់ភិក្ខុ ។

ពាក្យថា **ជាគរិយានុយោគំ** បានដល់ ការប្រកបរឿយៗ របស់អ្នកភ្ញាក់ ដែលឈ្មោះថា ជាគរិយៈ ។

ពាក្យថា **អនុយុត្តោ ហោតិ** បានដល់ ការប្រកបរឿយៗ ការខ្វល់ខ្វាយនូវការសេព ការចម្រើន ពោលគឺអនុយោគនោះ ។ ក៏ក្នុងនិទ្ទេសនៃពាក្យនេះ ក្នុងបទថា **ភិក្ខុ ទិវសំ** បានដល់ លោកកាន់យកមួយថ្ងៃ បែងចែកជា ៣ ចំណែក គឺវេលាព្រឹក វេលាថ្ងៃត្រង់ និងវេលាល្ងាច ។

ពាក្យថា **ចង្កមេន និសជ្ជាយ** បានដល់ ភិក្ខុកាលនៅសូម្បីដោយឥរិយាបថទាំងពីរនេះ រមែងជម្រះចិត្តចាកពីអាវរណចិត្ត (ឧបសគ្គរបស់ចិត្ត) ឬចាកពីធម៌ដែលជាគ្រឿងរារាំង ឬថាចាកនីវរណៈទាំង ៥ ឬក៏អកុសលធម៌ទាំងអស់ គឺថា រមែងជម្រះ

ចិត្ត រមែងដោះចិត្តចាកពីអកុសលធម៌ទាំងនោះ ។ មួយទៀត ការឈរក្នុងអធិការនេះ លោកមិនកាន់យកក៏ពិតមែន, តែក៏គប្បីកាន់យកការឈរនោះឯងផង ព្រោះអាស្រ័យ យកចន្លោះការដើរ និងការអង្គុយ ។

ពាក្យថា **បឋមយាមំ** បានដល់ សូម្បីក្នុងបឋមយាមទាំងអស់ ។ ពាក្យថា **មជ្ឈិមយាមំ** បានដល់ ក្នុងមជ្ឈិមយាម ពោលគឺចំណែកទាំង ៦ របស់ពេលយប់ និង ពេលថ្ងៃ ។

ក្នុងពាក្យថា **សីហសេយ្យំ** នេះ បានដល់ **សេយ្យា** ( ការដេក) ៤ យ៉ាង គឺ

១. **កាមភោគីសេយ្យា** ដេកដូចអ្នកបរិភោគកាម

២. **បេតសេយ្យា** ដេកដូចប្រេត

៣. **សីហសេយ្យា** ដេកដូចសីហៈ

៤. **តថាគតសេយ្យា** ដេកដូចព្រះតថាគត ។

គប្បីជ្រាបការដេកទាំងនោះថា “ម្នាលភិក្ខុទាំងឡាយ អ្នកបរិភោគកាមដោយ ច្រើន រមែងដេកផ្អៀងមកផ្នែកខាងឆ្វេង” ព្រោះហេតុដូច្នោះ អ្នកនេះ ទើបឈ្មោះថា កាមភោគីសេយ្យា ។ ពិតមែន បណ្តាអ្នកបរិភោគកាមទាំងនោះ ដោយច្រើន ឈ្មោះថា រមែងមិនដេកផ្អៀងខាងស្តាំ ។ “ម្នាលភិក្ខុទាំងឡាយ ដោយច្រើន បុគ្គល ណារមែងដេកផ្ងារ ព្រោះហេតុដូច្នោះ បុគ្គលនោះ ទើបឈ្មោះថា បេតសេយ្យា ( ដេក ដូចប្រេត ឬអ្នកដែលស្លាប់ទៅហើយ) ” ។ ពិតមែន បុគ្គលរមែងមិនអាចដើម្បីដេក ផ្អៀងខាងណាមួយ ព្រោះភាវៈនៃខ្លួនមានសាច់ និងឈាមតិច និងព្រោះឆ្អឹងត្រង់កន្លែង

ដែលតគ្នា មិនជាប្រក្រតី ទើបបានតែដេកផ្ងារប៉ុណ្ណោះ ។ “ម្នាលភិក្ខុទាំងឡាយ សីហៈ ជាសត្វមិគរាជ ជាសត្វមានចិត្តជារបស់ខ្លួន រមែងសម្រេចការដេកដោយផ្អៀងខាងស្តាំ ព្រោះហេតុដូច្នោះ ការដេកនេះ ទើបឈ្មោះថា **សីហសេយ្យា** [២៤] ។ ពិតណាស់ សីហៈ ជាសត្វមិគរាជ ដាក់ជើងមុខទាំងពីរទុកមួយកន្លែង ដាក់ជើងក្រោយទុកមួយកន្លែង និង យកកន្ទុយដាក់ទុកត្រង់ចន្លោះភ្លៅ ហើយកំណត់ឱកាស (គឺការប្រាកដ) ទាំងជើងមុខ និងជើងក្រោយ ដែលខ្លួនដាក់ទុកហើយ ទើបដេកដាក់ក្បាលលើជើងមុខទាំងពីរ ព្រោះ ភាវៈនៃខ្លួនជាអ្នកមានអំណាចច្រើន, សូម្បីដេករហូតដល់អស់មួយថ្ងៃ ភ្ញាក់ឡើងមក ក៏មិនភ័យខ្លាច (ស្លុតចិត្ត), កាលនឹងក្រោក ក៏ងើបក្បាលឡើង កំណត់មើលការប្រាកដ ជើងមុខជាដើម តាមដែលខ្លួនដាក់ទុក; បើថាការប្រាកដរបស់ជើងជាដើម ឃ្លាតទៅ កាន់ទីណា១ ចាកពីទីដែលដាក់ទុកពីខាងដើម រមែងនឹងមិនជាអ្នកមានចិត្តជារបស់ខ្លួន១ ដោយគិតថា “លក្ខណៈនេះមិនគួរដល់ភាពជាអ្នកក្លាហាន ដោយជាតិរបស់ខ្លួន” ហើយ ក៏នឹងដេកក្នុងទីនោះ១ ឯង, មិនចេញទៅរកអាហារ; ក៏បើថា ជើងមុខជាដើម ដែល ខ្លួនតាំងទុកហើយ មិនឃ្លាតខុសប្រក្រតីទៅ រមែងជាអ្នកមានចិត្តត្រេកអរ រីករាយ និងគិតថា “អាការនេះ សមគួរដល់ភាពជាអ្នកក្លាហានរបស់ខ្លួន ដោយជាតិ” ហើយ ទើបក្រោកឡើងសម្តែងជើងកន្ទុយរបស់សីហៈ រលាស់ក និងបន្លឺសីហនាទអស់ ៣ ដង ទើបចេញទៅស្វែងរកអាហារ ។

---

[២៤] អំ. ចតុក្ក. ។

ចំណែកការដេកប្រកបដោយឈានទី ៤ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ហៅថា តថាគតសេយ្យោ ។ បណ្ដាការដេកទាំងនោះ **សីហសេយ្យា** មកក្នុងទីនេះ ។ ពិតមែន ឈ្មោះថា **សីហសេយ្យា** ព្រោះភាពជាឥរិយាបថដែលឧត្ដមដោយតេជៈ ។

ពាក្យថា **បាទេ បាទំ** បានដល់ ដាក់ជើងឆ្វេងតម្រួតទៅលើជើងស្ដាំ ។

ពាក្យថា **អច្ចាធាយ** បានដល់ ត្រួតឱ្យហួសគ្នាបន្ដិច (គឺដាក់កុំឱ្យស្មើគ្នា) ។ ព្រោះថា កាលថ្នាំងកជើង (ភ្នែកគោរ) ខ្ទប់នឹងថ្នាំងកជើង (ភ្នែកគោរ) ឬជង្គង់ខ្ទប់នឹងជង្គង់ វេទនារមែងកើតឡើងរឿយៗ ចិត្តរមែងមិនមានអារម្មណ៍តែមួយ ទាំងការដេកក៏មិនសប្បាយ ។ ក៏ការដេកនោះ ជង្គង់ និងថ្នាំងកជើង រមែងមិនតម្រួតគ្នា ដោយប្រការណា ។ កាលដាក់ជើងលៀនចេញពីគ្នាទៅ ដោយអាការៈនោះហើយ ទុក្ខវេទនានោះរមែងមិនកើតឡើង ។ ចិត្តរមែងមានអារម្មណ៍តែមួយ ។ ទាំងការដេកក៏សប្បាយ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា "ដាក់ជើងឆ្វេងតម្រួតលើជើងស្ដាំ (ឱ្យហួសគ្នាបន្ដិច)" ដូច្នេះ ។

ពាក្យថា **សតោ សម្បជានោ** បានដល់ ជាអ្នកប្រកបដោយសតិ និងបញ្ញាជាគ្រឿងដឹងព្រម ។ ក៏សតិ និងសម្បជញ្ញៈដែលភិក្ខុកំណត់កាន់យកល្អហើយ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកដោយបទថា **សតោ សម្បជានោ** នេះ ។

ពាក្យថា **ឧដ្ឋានសញ្ញំ មនសិករិត្វា** បានដល់ តាំងសញ្ញាក្នុងកាលដែលនឹងក្រោកឡើង ក្នុងចិត្តកំណត់វេលាដែលនឹងក្រោកឡើង យ៉ាងនេះថា "យើងនឹងក្រោក

ឡើងក្នុងវេលាឈ្មោះឯណោះ” ។ ពិតមែន ការធ្វើយ៉ាងនេះហើយដេក ក៏គួរដើម្បីនឹងក្រោកឡើងក្នុងវេលាតាមដែលលោកកំណត់ទុកនោះឯង ។

ពាក្យថា **សាតច្ចំ នេបក្កំ** អធិប្បាយថា ភិក្ខុប្រកបហើយ ប្រកបរឿយៗ ហើយញុំាងវិរិយៈ ពោលគឺសេចក្ដីព្យាយាម (ដែលប្រព្រឹត្តទៅ) ឈ្មោះថា សាតច្ចៈ ព្រោះញុំាងសេចក្ដីព្យាយាមនោះឱ្យប្រព្រឹត្តទៅទូទៅ និងញុំាងបញ្ញា ពោលគឺនេបក្កៈ (បញ្ញាជាគ្រឿងរក្សា) ដែលដល់សេចក្ដីចាស់ក្លា ឱ្យប្រព្រឹត្តទៅនោះឯង ទើបឈ្មោះថា ប្រកបរឿយៗ ក្នុងជាគរិយានុយោគ ។ ក៏ក្នុងទីនេះ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់សេចក្ដីព្យាយាមលាយដោយលោកិយ និងលោកកុត្តរ ។ សូម្បីបញ្ញា ក៏មានគតិដូចវិរិយៈនោះដែរ ។ គឺកាលត្រាស់រឿងវិរិយៈក្នុងលោកិយ វិរិយៈនោះ ក៏ជាលោកិយ ។ ត្រាស់វិរិយៈក្នុងលោកុត្តរ ក៏ជាលោកុត្តរ ។

ពាក្យថា **ពោធិបក្ខិយានំ ធម្មានំ** បានដល់ ធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងផ្នែកនៃមគ្គញ្ញាណ ពោលគឺបញ្ញាជាគ្រឿងត្រាស់ដឹងសច្ចៈទាំង ៤ ។ អធិប្បាយថា ព្រះមានព្រះភាគ ទ្រង់រួមពោធិបក្ខិយធម៌ទាំងអស់ទុកមានប្រមាណ ៣៧, កាលនឹងទ្រង់សម្ដែងអង្គនៃការត្រាស់ដឹងនោះឯង ដែលអាចប្រព្រឹត្តទៅដោយសេចក្ដីតែមួយក្នុងអារម្មណ៍មួយនៃភាវនា សូម្បីជាលោកិយ ទើបត្រាស់ពាក្យថា **សត្ត ពោជ្ឈង្គា** ជាដើម ។ ពោធិបក្ខិយធម៌ទាំងនោះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ជាមិស្សកៈ គឺលាយដោយលោកិយ និងលោកុត្តរ ។ ពាក្យដែលនៅសល់ក្នុងទីនេះ មានអត្ថងាយស្រួលទាំងអស់ ព្រោះមានន័យដូចដែលខ្ញុំពោលហើយ ក្នុងកាលមុនន៉ុះឯង ៕

សម្មោហវិនោទនី

## **អធិប្បាយឥរិយាបថ**

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃពាក្យថា **អភិក្កន្តេ** ជាដើម ការឈានទៅខាងមុខ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ហៅថា **អភិក្កន្តំ** ជាមុន ក្នុងពាក្យថា **អភិក្កន្តេ បដិក្កន្តេន** នេះ; ការថយត្រឡប់មកខាងក្រោយ ហៅថា **បដិក្កន្តៈ** ។ **អភិក្កន្តៈ** និង **បដិក្កន្តៈ** សូម្បីទាំង ២ នេះ រមែងបានក្នុងឥរិយាបថ ៤ គឺ

ក្នុងឥរិយាបថដើមជាមុនសិន កាលបង្អោនកាយទៅមុខ ឈ្មោះថា **អភិក្កន្តៈ** ។ កាលថយត្រឡប់មក ឈ្មោះថា **បដិក្កន្តៈ** ។ សូម្បីក្នុងឥរិយាបថនៅឈរនោះឯង កាលបង្អោនកាយទៅខាងមុខ ឈ្មោះថា **អភិក្កន្តៈ**, កាលបង្អោនកាយមកខាងក្រោយ ឈ្មោះថា **បដិក្កន្តៈ** ។ សូម្បីក្នុងឥរិយាបថនៅអង្គុយនោះឯង មានមុខឆ្ពោះទៅចំណែកខាងមុខនៃអាសនៈ និងកំពុងបង្អោនកាយទៅ ឈ្មោះថា **អភិក្កន្តៈ** ។ បង្អោនកាយទៅចំណែកខាងក្រោយ ឈ្មោះថា **បដិក្កន្តៈ** ។ សូម្បីក្នុងឥរិយាបថដេក ក៏ន័យនេះដែរ ។

ពាក្យថា **សម្បជានការី ហោតិ** បានដល់ ជាអ្នកមានប្រក្រតីធ្វើកិច្ចទាំងពួងដោយសម្បជញ្ញៈ, ឬជាអ្នកមានប្រក្រតីធ្វើនូវសម្បជញ្ញៈនោះឯង ។ ពិតមែន ភិក្ខុនោះរមែងធ្វើនូវសម្បជញ្ញៈនោះឯង ក្នុងឥរិយាបថទាំងឡាយ មានការឈានទៅខាងមុខជាដើម, គឺថា គេរមែងជាអ្នកមិនវៀរចាកសម្បជញ្ញៈក្នុងឥរិយាបថណា១ ឡើយ ។ ក៏

ព្រោះសម្បជញ្ញៈនោះ សម្បយុត្តដោយសតិនោះឯង, ព្រោះហេតុនោះ ក្នុងនិទ្ទេសនៃឈានវិភង្គនេះ ទើបត្រាស់ថា **“សតោ សម្បជានោ អភិក្កមតិ សតោ សម្បជានោ បដិក្កមតិ** ។ ពិតមែន ភិក្ខុនេះឈានទៅខាងមុខ ឬថយក្រោយ ឈ្មោះថា ជាអ្នកមិនភ្លេចសតិ មានសម្បជញ្ញៈ ។ គឺថា ភិក្ខុប្រកបដោយសតិ មានសេចក្ដីរឮកដឹងខ្លួនទូទៅ ព្រមដោយបញ្ញានោះឯង រមែងឈានទៅខាងមុខផង រមែងថយក្រោយផង ។ លោករមែងញ៉ាំងសម្បជញ្ញៈ ៤ យ៉ាង ឱ្យធ្លាក់ចុះក្នុងឥរិយាបថទាំងពួង មានការឈានទៅខាងមុខជាដើម ។ មែនពិត សម្បជញ្ញៈនេះ មាន ៤ យ៉ាងគឺ

**១. សាត្ថកសម្បជញ្ញៈ** ដឹងច្បាស់ថាមានប្រយោជន៍

**២. សប្បាយសម្បជញ្ញៈ** ដឹងច្បាស់ថាមានការសប្បាយ

**៣. គោចរសម្បជញ្ញៈ** ដឹងច្បាស់ថាមានគោចរ

**៤. អសម្មោហសម្បជញ្ញៈ** ដឹងច្បាស់ថានឹងមិនជួបអារម្មណ៍នាំឱ្យវង្វេង ។

បណ្ដាសម្បជញ្ញៈទាំងនោះ កាលចិត្តកើតឡើងក្នុងការឈានទៅខាងមុខ កើតឡើងកំណត់វត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ **កាន់យកតែប្រយោជន៍** ដោយពិចារណាថា “អ្វីហ្ន៎ ! ជាប្រយោជន៍ក្នុងការទៅ ឬការមិនទៅក្នុងទីនេះ” ឈ្មោះថា សាត្ថកសម្បជញ្ញៈ ។

ក៏ក្នុងពាក្យទាំងនោះ ពាក្យថា **ប្រយោជន៍** បានដល់ សេចក្ដីចម្រើនដោយធម៌ ដោយអំណាចនៃការឃើញចេតិយ ការឃើញដើមពោធិ៍ ការឃើញព្រះសង្ឃ ការឃើញព្រះថេរៈ និងការឃើញអសុភជាដើម ។ ពិតមែន ភិក្ខុសូម្បីឃើញចេតិយ ឬដើមពោធិ៍ ញ៉ាំងបីតិមានព្រះពុទ្ធជាអារម្មណ៍ ឬញ៉ាំងបីតិមានព្រះសង្ឃជាអារម្មណ៍ ដោយអំណាចនៃការឃើញព្រះសង្ឃ ឱ្យកើតឡើងហើយ ពិចារណានូវវត្ថុនោះៗ ឯង ដោយការអស់ទៅ សូន្យទៅ រមែងសម្រេចអរហត្តបាន ។

បុគ្គលឃើញព្រះថេរៈទាំងឡាយ អាស្រ័យឱវាទរបស់លោកទាំងនោះ ឬឃើញអសុភហើយញ៉ាំងបឋមជ្ឈានក្នុងអសុភនោះ ឱ្យកើតឡើង ពិចារណាវត្ថុនោះៗ ឯង ដោយការអស់ទៅ សូន្យទៅ ក៏រមែងសម្រេចអរហត្តបាន ។ ព្រោះហេតុនោះ ការឃើញវត្ថុទាំងនោះ ទើបឈ្មោះថា **សាត្ថំ** គឺមានប្រយោជន៍ ។

មួយទៀត អាចារ្យពួកខ្លះ ពោលថា “ការចម្រើនសូម្បីដោយអាមិស ក៏ឈ្មោះថា ជាប្រយោជន៍ដូចគ្នា, ក៏ព្រោះភារៈនៃខ្លួនជាអ្នកអាស្រ័យវត្ថុនោះ ហើយបដិបត្តិដើម្បីអនុគ្រោះដល់ព្រហ្មចរិយៈ” ដូច្នេះ ។

ការដែលភិក្ខុកំណត់សប្បាយ និងអសប្បាយ ក្នុងការដើរទៅ ហើយកំណត់យកតែសប្បាយ ឈ្មោះថា **សប្បាយសម្បជញ្ញៈ**, គឺយ៉ាងណា ? គឺថា ការឃើញព្រះ

ចេតិយដែលប្រព្រឹត្តទៅដោយប្រយោជន៍ជាមុនសិន; ក៏បើថា បរិស័ទប្រជុំគ្នាក្នុងចន្លោះផ្លូវ ១២ យោជន៍ ដើម្បីធ្វើការបូជាធំចំពោះចេតិយ, ទាំងស្រី ទាំងប្រុស រមែងមានរូបល្អ ស្អាតដូចជាវិចិត្តកម្ម ប្រដាប់តាក់តែងតាមសេចក្ដីសមគួរនឹងសម្បត្តិរបស់ខ្លួនៗនាំគ្នាត្រាច់ទៅ ។ ក៏ក្នុងទីដូច្នេះ សេចក្ដីលោភរបស់បុគ្គលនោះ រមែងកើតក្នុងអារម្មណ៍ដែលពេញចិត្ត, បដិឃៈរមែងកើតក្នុងអារម្មណ៍ដែលមិនពេញចិត្ត មោហៈរមែងកើតក្នុងការមិនពិនិត្យពិចារណា ។

ម្យ៉ាងទៀត ភិក្ខុនោះ រមែងត្រូវអាបត្តិកាយសំសគ្គៈ (ការប៉ះកាយ) ឬថាមានអន្តរាយនៃជីវិត និងព្រហ្មចរិយៈ ។ ការឈរក្នុងទីដូច្នោះ រមែងជាអសប្បាយ, ជាសប្បាយ ព្រោះមិនមានអន្តរាយ មានប្រការតាមដែលពោលហើយ ។ សូម្បីក្នុងការមើលដើមពោធិ៍ ក៏ន័យនេះដែរ ។

សូម្បីក្នុងការមើលព្រះសង្ឃ ក៏ប្រព្រឹត្តទៅជាមួយនឹងប្រយោជន៍; គឺបើថាកាលពួកមនុស្សធ្វើបារាំ (រោង) ធំ ក្នុងចន្លោះភូមិ ហើយស្ដាប់ធម៌រហូតដល់អស់មួយយប់ ការប្រជុំរបស់ជនមានប្រការតាមដែលពោលហើយនោះឯង និងទាំងអន្តរាយក៏មានដែរ ។ ការឈរក្នុងទីដូច្នោះ ដោយអាការៈដែលពោលមកហើយនេះ ជាអសប្បាយ ។ ជាសប្បាយ ព្រោះមិនមានសេចក្ដីអន្តរាយ ។ សូម្បីក្នុងការឃើញព្រះថេរៈ

ទាំងឡាយអ្នកមានបរិស័ទច្រើន ក៏ន័យនេះដែរ ។

សូម្បីការឃើញអសុភ ក៏ប្រព្រឹត្តទៅជាមួយនឹងប្រយោជន៍, ដើម្បីសម្តែងប្រ-យោជន៍ក្នុងអសុភនោះ មានរឿងដូចតទៅនេះ ជាឧទាហរណ៍ ៖

បានឮមកថា ភិក្ខុកំលោះមួយរូប នាំសាមណេរដើរផ្លូវទៅដើម្បីត្រូវការឈើជម្រះធ្មេញ, សាមណេរដើរទៅខាងមុខរបស់ភិក្ខុ កាលលោកឈានចុះពីផ្លូវទៅ ក៏ឃើញអសុភ ទើបសម្លឹងមើល ហើយញុំាងបឋមជ្ឈានឱ្យកើតឡើង ធ្វើឈាននោះនុ៎ះឯង ឱ្យជាបាទនៃវិបស្សនា ពិចារណានូវសង្ខារទាំងឡាយ ធ្វើផលទាំង ៣ ឱ្យជាក់ច្បាស់ ហើយក៏កំណត់តាំងកម្មដ្ឋាន ដើម្បីត្រូវការមគ្គខាងលើ ។ ចំណែកភិក្ខុកំលោះ កាលមិនឃើញសាមណេរនោះ ទើបស្រែកហៅថា "សាមណេរ" ដូច្នេះ ។ សាមណេរនោះគិតថា "ចាប់ផ្តើមពីថ្ងៃដែលយើងបួសហើយ ឈ្មោះថា ការហៅ ២ ដង របស់ភិក្ខុនេះមិនបានមានដល់យើង, ចាំក្នុងថ្ងៃដទៃចុះ យើងនឹងញុំាងគុណវិសេសខាងលើឱ្យកើតឡើង" ដូច្នេះ ទើបឆ្លើយទទួលថា "អ្វីលោកម្ចាស់" ដូច្នេះ ទើបភិក្ខុកំលោះពោលថា "លោកមកនេះ" សាមណេរនោះមកហើយ ដោយពាក្យត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ ហើយទើបទូលថា "បពិត្រលោកដ៏ចម្រើន សូមលោកទៅឈរមើលខាងមុខ ក្នុងទីដែលខ្ញុំឈរនៅត្រង់ផ្លូវនេះមួយភ្លែតសិន លោកម្ចាស់" ។ ភិក្ខុនោះធ្វើយ៉ាងនោះហើយ

ក៏សម្រេចគុណវិសេស ដែលសាមណេរនោះសម្រេចហើយដែរ ។

អសុភមួយកើតឡើងដើម្បីប្រយោជន៍ដល់ជនទាំងពីរ ដោយអាការយ៉ាងនេះ ។

មួយទៀត អសុភរបស់**មាតុគ្រាម** សូម្បីនឹងប្រព្រឹត្តទៅជាមួយនឹងប្រយោជន៍, តែក៏រមែងជាអសប្បាយដល់បុរស, ឯអសុភរបស់បុរសនោះ ក៏ជាអសប្បាយដល់មាតុ-គ្រាមដូចគ្នា ។ ការកំណត់សប្បាយថា "នេះជាសប្បាយ ជាសភាគដូចដែលពណ៌នាមក" ដូច្នេះ ឈ្មោះថា **សប្បាយសម្បជញ្ញៈ** ។

មួយទៀត ការដែលភិក្ខុរៀនយកគោចរ ពោលគឺកម្មដ្ឋានដែលពេញចិត្តដល់ចរិតរបស់ខ្លួនក្នុងកម្មដ្ឋាន ៣៨ យ៉ាង ដើម្បីសប្បាយដែលប្រព្រឹត្តទៅជាមួយនឹងប្រ-យោជន៍ដែលកំណត់យ៉ាងនេះ ហើយកាន់យកកម្មដ្ឋាននោះ ក្នុងវេលាគោចរ ដើម្បីភិក្ខា-ចារ ឈ្មោះថា **គោចរសម្បជញ្ញៈ** ។

បណ្ឌិតគប្បីជ្រាបពួក ៤ ដើម្បីការជាក់ច្បាស់នៃវណ្ណនានោះ ដូចតទៅនេះ ៖

**១. ភិក្ខុរូបខ្លះក្នុងសាសនានេះ រមែងនាំកម្មដ្ឋានទៅ, តែមិននាំត្រឡប់មក**

**២. ភិក្ខុរូបខ្លះ រមែងនាំត្រឡប់មក, តែមិននាំទៅ**

**៣. ភិក្ខុរូបខ្លះ ទាំងមិននាំទៅ, ទាំងមិននាំត្រឡប់មក**

**៤. ភិក្ខុរូបខ្លះ រមែងនាំទៅផង រមែងនាំត្រឡប់មកផង ។**

បណ្ដាភិក្ខុទាំងនោះ ភិក្ខុរូបណាជម្រះចិត្តឱ្យបរិសុទ្ធចាកធម៌ទាំងឡាយ ដែល

ជាគ្រឿងរារាំងរហូតដល់អស់មួយថ្ងៃ ដោយការដើរ និងការអង្គុយ ក្នុងបឋមយាមនៃរាត្រី ក៏យ៉ាងនោះដែរ ក្នុងមជ្ឈិមយាមលោកសម្រេចការដេក សូម្បីក្នុងបច្ឆិមយាមលោកក៏ញុំាងកាលឱ្យកន្លងទៅដោយការអង្គុយ ការដើរ ការធ្វើវត្ត គឺបោសលានព្រះចេតិយ លានមហាពោធិ៍ជាមុន ហើយស្រោចទឹកដើមមហាពោធិ៍ ចូលទៅតាំងទឹកឆាន់ទឹកប្រើប្រាស់ សមាទានប្រព្រឹត្តវត្តទាំងពួងតូចៗ បន្តិចបន្តួចៗ មានអាចរិយវត្ត និងឧបជ្ឈាយវត្តជាដើម ។ កាលលោកជម្រះរាងកាយហើយ ក៏ចូលទៅកាន់សេនាសនៈផ្លាស់ប្តូរឥរិយាបថ ២-៣ ដង ត្រង់បល្ល័ង្កឱ្យកម្តៅកើតឡើង ហើយប្រកបកម្មដ្ឋានរឿយៗ ក្រោកឡើងក្នុងវេលាដែលត្រាច់ទៅដើម្បីភិក្ខា កាន់យកបាត្រ និងចីវរជាមួយនឹងកម្មដ្ឋានដែលជាសីសៈ (ប្រធាន) នោះឯង ចេញទៅពីសេនាសនៈ ក៏មនសិការកម្មដ្ឋានយ៉ាងនោះ ទៅកាន់លាននៃព្រះចេតិយ បើ (កម្មដ្ឋានដើម) ជាពុទ្ធានុស្សតិកម្មដ្ឋាននៅមានសោត មិនត្រូវលះបង់កម្មដ្ឋាននោះឡើយ ចូលទៅកាន់លានព្រះចេតិយ ។ បើថា (ក្នុងខណៈនោះ) មានកម្មដ្ឋានដទៃ, ផ្អាកកម្មដ្ឋាននោះទុកត្រង់ជណ្តើរ ប្រៀបដូចបុគ្គលកាន់យករបស់មកហើយដាក់របស់នោះទុក គ្រាផ្អាកកម្មដ្ឋានដទៃនោះហើយ ក៏គប្បីកាន់យកបីតិដែលមានព្រះពុទ្ធគុណជាអារម្មណ៍ ឈានឡើងកាន់លានព្រះចេតិយធ្វើប្រទក្សិណចេតិយដ៏ធំអស់ ៣ ដង ហើយគប្បីថ្វាយបង្គំក្នុងទីទាំង ៤, គប្បីធ្វើការ

ប្រទក្សិណចេតិយតូចក្នុងទីនោះៗ ឯង ហើយគប្បីថ្វាយបង្គំក្នុងទីទាំង ៨ ។ ភិក្ខុអ្នកដែលដល់លានចេតិយ គ្រាថ្វាយបង្គំព្រះចេតិយហើយ ក៏គប្បីសម្ដែងសេចក្ដីកោតក្រែងចំពោះព្រះពុទ្ធជាម្ចាស់ ដូចការនៅចំពោះមុខព្រះភក្ត្រព្រះមានព្រះភាគជាម្ចាស់ ហើយថ្វាយបង្គំដើមមហាពោធិ ។ ភិក្ខុនោះថ្វាយបង្គំចេតិយ និងដើមមហាពោធិហើយ ក៏ត្រឡប់ទៅកាន់ទីសម្រាករបស់ខ្លួនៗ រក្សាកម្មដ្ឋានកាន់យកកម្មដ្ឋានដែលខ្លួនដាក់ទុកហើយ ដូចបុគ្គលកាន់យកវត្ថុដែលខ្លួនដាក់ទុកទៅដូច្នោះ ដណ្ដប់ចីវរក្នុងទីជិតភូមិដោយកម្មដ្ឋានសីសៈនោះឯង ហើយទើបចូលទៅកាន់ភូមិដើម្បីបិណ្ឌបាត ។ ក្នុងកាលនោះពួកមនុស្សឃើញភិក្ខុនោះហើយ ក៏នាំគ្នាក្រោកឡើងទទួល ដោយគិតថា “លោកម្ចាស់របស់ពួកយើងមកហើយ” ដូច្នេះ ទទួលបាត្រ និមន្តឱ្យគង់ ត្រង់រោងឆាន់ ឬក្នុងផ្ទះបាយ ថ្វាយយាគូ ដរាបដែលភត្តនៅមិនសម្រេច, ក៏លាងជើង លាបដោយប្រេង អង្គុយខាងមុខសួរបញ្ហាខ្លះ, ប្រាថ្នានឹងជាអ្នកស្ដាប់ធម៌ខ្លះ ។

ព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា សូម្បីបើថា ពួកមនុស្សមិនត្រូវការឱ្យភិក្ខុពោលធម៌, ធម្មតាថា ធម្មកថា (ការសម្ដែងធម៌) ដើម្បីការសង្គ្រោះប្រជាជន ភិក្ខុនោះត្រូវតែធ្វើ ។ ពិតមែន ធម្មតាថា **ធម្មកថា ដែលនឹងផុតទៅពីកម្មដ្ឋាន រមែងមិនមាន** ។ ព្រោះហេតុនោះ ភិក្ខុឆាន់អាហារដោយកម្មដ្ឋានសីសៈនោះឯង ស្រេចហើយ

ពោលអនុមោទនា ភិក្ខុនោះអ្នកដែលមានមនុស្សទាំងឡាយ តាមជូនដំណើរចេញទៅពីភូមិហើយ គួរឱ្យមនុស្សទាំងនោះត្រឡប់ ហើយក៏ដើរទៅតាមផ្លូវ ។ លំដាប់នោះសាមណេរ និងភិក្ខុកំលោះទាំងឡាយអ្នកចេញទៅកាន់ភូមិមុន មានភត្តកិច្ចដែលធ្វើខាងក្រៅភូមិស្រេចរួចរាល់អស់ហើយ ឃើញភិក្ខុនោះដែលកំពុងដើរមក ក៏នាំគ្នាក្រោកទៅទទួល ហើយកាន់យកបាត្រ និងចីវររបស់លោក ។

បានឮថា ភិក្ខុទាំងឡាយក្នុងកាលមុន មិនបានជ្រើសរើសថា “អ្នកនេះជាព្រះឧបជ្ឈាយ៍របស់យើង, អ្នកនេះជាអាចារ្យរបស់យើងទេ” ដូច្នេះ ហើយក៏ធ្វើវត្ត, គឺរមែងធ្វើការកំណត់ដល់ភិក្ខុទាំងឡាយ អ្នកមកហើយប៉ុណ្ណោះ ។

សាមណេរ និងភិក្ខុកំលោះទាំងនោះ សួរភិក្ខុនោះថា “លោកម្ចាស់ មនុស្សទាំងនោះ ត្រូវជាអ្វីនឹងលោក, ជាអ្នកជាប់ទាក់ទងខាងមាតា ឬបិតា ?” ដូច្នេះ ។

ភិក្ខុនោះ **សួរថា** លោកឃើញអ្វីទើបសួរ ?

សាមណេរ និងភិក្ខុកំលោះទាំងនោះ ឆ្លើយតបថា “ពួកខ្ញុំឃើញការស្រឡាញ់រាប់អានរបស់ជនទាំងនោះ មានច្រើនក្នុងលោកម្ចាស់” ។

ភិក្ខុនោះពោលថា “នែអ្នកមានអាយុទាំងឡាយ កម្មណាសូម្បីមាតាបិតារបស់យើងធ្វើបានលំបាក, តែមនុស្សទាំងនេះធ្វើបានស្រួល, សូម្បីបាត្រ និងចីវរដែលជាវត្ថុ

ប្រើប្រាស់របស់ពួកយើង, ដោយអានុភាពនៃជនទាំងនោះ ពួកយើងរមែងមិនដឹងដល់ភ័យក្នុងវេលាមានភ័យ និងមិនដឹងដល់សេចក្ដីលំបាកក្នុងវេលាដែលត្រូវលំបាក ជនទាំងឡាយ ដូចនឹងមនុស្សអ្នកមានឧបការៈទាំងនេះរបស់ពួកយើង រមែងមិនមានឡើយ” កាលពោលសរសើរគុណរបស់មនុស្សទាំងនោះ ទើបដើរទៅ ។

ភិក្ខុនេះ លោកហៅថា **រមែងនាំកម្មដ្ឋានទៅ តែមិនត្រឡប់មក** ។

មួយទៀត កាលភិក្ខុណាធ្វើវត្តបដិបត្តិ មានប្រការតាមដែលពោលហើយអំពីព្រឹក សេចក្ដីក្ដៅកើតពីកម្ម (កម្មជ្ជតេជោ) របស់លោក រមែងដុតរោល, បញ្ចេញនូវអនុបាទិន្នករូប ហើយកាន់យកនូវឧបាទិន្នករូប, ញើសទាំងឡាយរមែងហូរចេញពីសរីរៈ រមែងមិនអាចឈានឡើងកាន់វីថិនៃកម្មដ្ឋានបាន, ភិក្ខុនោះកាន់យកបាត្រ និងចីវរអំពីព្រឹក សំពះព្រះចេតិយដោយរហ័ស ចេញទៅកាន់ភូមិក្នុងវេលាជាទីចេញទៅនៃវារៈហ្វូងគោនោះឯង បានយាគូបបរនាំទៅកាន់អាសនសាលាហើយឆាន់ ។ លំដាប់នោះ តេជោធាតុដែលកើតពីកម្ម ក៏បញ្ចេញឧបាទិន្នករូប កាន់យកអនុបាទិន្នករូបដោយហេតុត្រឹមតែការចូលទៅអស់វារៈ ២ ដងផង ៣ ដងផង ។ ភិក្ខុនោះដល់សេចក្ដីរលត់ការក្ដៅក្រហាយ ដែលកើតពីកម្មជ្ជតេជោធាតុចេញបាន ដូចងូតទឹកទាំងរយឆ្នាំង ឆាន់យាគូដោយកម្មដ្ឋានសីសៈ លាងបាត្រ និងមាត់ស្រេចហើយ ក៏មនសិការកម្មដ្ឋាន

ក្នុងចន្លោះវេលានៃភត្ត ត្រាច់ទៅដើម្បីបិណ្ឌបាត្រក្នុងស្ថានទីដែលនៅសល់ ឆាន់អាហារដោយកម្មដ្ឋានសីសៈ ចាប់ផ្តើមពីកាលនោះមក ក៏កាន់តែបដិបត្តិកម្មដ្ឋានដែលលោកពាល់ត្រូវ យកចិត្តទុកដាក់ហើយនោះឯង ត្រឡប់មក ។

ភិក្ខុនេះ លោកហៅថា **រមែងនាំកម្មដ្ឋានត្រឡប់មក តែមិននាំទៅ** ។

ក៏ភិក្ខុដូច្នេះ ឆាន់បបរយាគូហើយប្រារព្ធវិបស្សនា ឈ្មោះថា សម្រេចអរហត្តក្នុងពុទ្ធសាសនាហួសដែលនឹងរាប់បាន ។ នៅទ្វីបសីហឡៈនោះឯង ក្នុងអាសនសាលានៃពួកអ្នកស្រុកនោះៗ ពួកភិក្ខុដែលឆាន់យាគូក្នុងទីដូចនោះហើយមិនសម្រេចអរហត្តមិនមានឡើយ ។

ក៏ភិក្ខុណាជាអ្នកមានប្រក្រតី នៅដោយសេចក្តីប្រមាទ, មានធុរៈដែលដាក់ចោលចេញហើយ ទម្លាយវត្តទាំងពួង មានចិត្តជាប់ជំពាក់ដោយគ្រឿងចងចិត្ត ៥ យ៉ាង (នីវរណៈ ៥) នៅមិនមានសញ្ញាក្នុងកម្មដ្ឋាន សូម្បីរៀនមកហើយ ចូលទៅភូមិដើម្បីបិណ្ឌបាត ជាអ្នកច្របូកច្របល់ដោយការច្របូកច្របល់ជារបស់គ្រហស្ថ ដែលមិនសមគួរត្រាច់ទៅផង ឆាន់អាហារផង (ដើរឆាន់) ឥតប្រយោជន៍ឈានទៅៗ (ទាំងទៅទាំងត្រឡប់) ។

ភិក្ខុដូច្នេះ លោកហៅថា **មិននាំកម្មដ្ឋានទៅ មិននាំកម្មដ្ឋានត្រឡប់មក** ។

ចំណែកភិក្ខុណា ដែលលោកពោលទុកថា "ភិក្ខុនោះរមែងនាំកម្មដ្ឋានទៅផង រមែងត្រឡប់មកផង" ដូច្នេះ, បណ្ឌិតគប្បីជ្រាបភិក្ខុនោះ ដោយអំណាចនៃវត្តរបស់ភិក្ខុអ្នកនាំទៅ និងត្រឡប់មក ជាន័យផ្ទុយគ្នាតាមដែលពោលហើយ ។

ពិតមែន កុលបុត្រទាំងឡាយ អ្នកប្រាថ្នាប្រយោជន៍ បួសក្នុងព្រះពុទ្ធសាសនាហើយ នៅរួមគ្នា ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ ៤០ ឆ្នាំខ្លះ ៥០ ឆ្នាំខ្លះ និង ១០០ ឆ្នាំខ្លះ រមែងធ្វើកតិកាវត្តថា **"អ្នកមានអាយុទាំងឡាយ ពួកលោកមិនបានបួសគេចពីបំណុល, មិនបានបួសគេចពីភ័យ, មិនបានបួសដើម្បីចិញ្ចឹមជីវិត, តែពួកលោក ជាអ្នកប្រាថ្នាដើម្បីនឹងរួចផុតចាកទុក្ខ ទើបបួសក្នុងព្រះពុទ្ធសាសនានេះ, ព្រោះហេតុនោះ កិលេសកើតឡើងក្នុងវេលាដើរ ពួកលោកចូរគ្របសង្កត់កិលេសក្នុងខណៈដើរនុ៎ះឯង ។ កិលេសកើតឡើងក្នុងវេលាឈរ, អង្គុយ, ដេក, ក៏ចូរគ្របសង្កត់កិលេសក្នុងវេលាឈរ អង្គុយ ដេកនុ៎ះឯង"** ។

ភិក្ខុទាំងនោះ គ្រាធ្វើកតិកាវត្តដូច្នេះហើយ កាលត្រាច់ទៅភិក្ខាចារ រមែងមនសិការកម្មដ្ឋានដោយសញ្ញានៃថ្មាំងថ្ម ដែលមាននៅក្នុងចន្លោះពាក់កណ្តាលឧសភៈខ្លះ មួយឧសភៈខ្លះ កន្លះគាវុតខ្លះ និងមួយគាវុតខ្លះ ។ បើកិលេសរបស់អ្នកណាៗ កើតឡើងក្នុងខណៈដើរសោត, អ្នកនោះរមែងគ្របសង្កត់កិលេសនោះ ក្នុងទីនោះនុ៎ះឯងហើយទើបទៅ ។ កាលមិនអាចគ្របសង្កត់បាន លោកក៏ចូរឈប់, កាលបើដូច្នោះ សូម្បី

ភិក្ខុអ្នកមកខាងក្រោយរបស់លោក ក៏ត្រូវឈប់ដែរ ។ ភិក្ខុ (អ្នកឈប់មុន) គិតថា “ភិក្ខុនេះ រមែងដឹងវិតក្កៈរបស់យើងដែលកើតឡើង, ដំណើរនេះ មិនសមគួរដល់អ្នកឡើយ” តិះដៀលខ្លួនឯងដូច្នេះហើយ ញុំាងវិបស្សនាឱ្យចម្រើន ឱ្យឈានចុះកាន់អរិយភូមិ ។ កាលមិនអាចដូច្នោះ លោកក៏ចូរអង្គុយ កាលកិលេសកើតឡើងវេលាអង្គុយ លោកក៏នឹងអង្គុយនោះឯង សូម្បីភិក្ខុអ្នកមកខាងក្រោយលោក ក៏អង្គុយដូច្នោះដែរ ។ កាលលោកមិនអាចឈានចុះអរិយភូមិ ក៏មនសិការកម្មដ្ឋានគ្របសង្កត់កិលេសនោះហើយ ទើបក្រោកទៅ ។ ភិក្ខុនោះរមែងមិនលើកជើងឡើង ដោយចិត្តដែលប្រាសចាកកម្មដ្ឋាន ។ បើលើកជើងឡើងដោយចិត្តប្រាសចាកកម្មដ្ឋានសោត, លោកក៏នឹងត្រឡប់ទៅ ដើរតាំងពីដើមមកថ្មីក្នុងសញ្ញា (ស្នាម) នៃជើងឈានដំបូងមែនពិត ដូចព្រះថេរៈឈ្មោះថា **មហាបុស្សទេវៈ** អ្នកនៅត្រង់ **អាលិន្ទកប្រទេស** ៖

បានឮថា ព្រះថេរៈនោះបំពេញគតបច្ចាគតវត្តនោះឯង ដល់ ១៩ វស្សា ។ ន័យថា សូម្បីពួកមនុស្សអ្នកភ្ជួរស្រែ ព្រោះស្រូវ បញ្ជាន់ស្រូវ ធ្វើការងារផ្សេងៗ ក្នុងចន្លោះផ្លូវ ឃើញព្រះថេរៈអ្នកទៅដូច្នោះ ក៏សន្ទនាគ្នាយ៉ាងសប្បាយថា “ព្រះថេរៈនោះត្រឡប់ទៅ ត្រឡប់មក, លោកគង់នឹងច្រឡំផ្លូវ ឬលោកភ្លេចអ្វី” ដូច្នេះ ។

ព្រះថេរៈមិនអើពើនឹងពាក្យសម្តីនោះទេ ខំធ្វើសមណធម៌ដោយចិត្តប្រកប

ដោយកម្មដ្ឋាននុ៎ះឯង សម្រេចអរហត្តហើយក្នុងចន្លោះនៃវស្សា ២០ នោះឯង ។ ក៏ក្នុងថ្ងៃដែលលោកសម្រេចអរហត្ត ទេវតាអ្នកឋិតនៅក្នុងទីបំផុតនៃទីចង្ក្រមរបស់លោក បានឈរ ញ៉ាំងប្រទីបឱ្យភ្លឺច្បាស់ ដោយម្រាមដៃទាំងឡាយ, សូម្បីស្តេចមហារាជទាំង ៤ សក្កទេវរាជជាស្តេចទេវតា និងស្តេចសហម្បតីព្រហ្ម ក៏បានទៅកាន់ទីបម្រើ ។

ព្រះថេរៈ ឈ្មោះថា **មហាតិស្សៈ** អ្នកមានប្រក្រតីនៅក្នុងព្រៃ ឃើញឱភាសនោះ ទើបសួរលោកក្នុងថ្ងៃទី ២ ថា "ក្នុងវេលារាត្រី ឱភាសមានក្នុងសំណាក់របស់លោកមានអាយុ នោះជាឱភាសអ្វី ?" ដូច្នេះ ។

ព្រះថេរៈនោះ មិនប្រាថ្នានឹងប្រាប់ ទើបពោលថា ក៏ឈ្មោះថា ឱភាស រមែងជាឱភាសនៃប្រទីបក៏មាន, ជាឱភាសនៃកែវមណីក៏មានជាដើម ។ តពីនោះ លោកក៏អង្វរថា "សូមលោកចូរបិទបាំងឱភាស" ដូច្នេះ ទើបលោកទទួលពាក្យថា ខ្ញុំករុណានឹងបិទបាំង ទើបលោកប្រាប់សេចក្តីនោះ ។

ក៏រឿងព្រះថេរៈអ្នកបដិបត្តិកម្មដ្ឋានដូច្នេះ ដូចនឹងរឿងរបស់ព្រះថេរៈឈ្មោះថា **មហានាគ** អ្នកមានប្រក្រតីនៅក្នុងមណ្ឌប ឈ្មោះថា **កាលវល្លិ** ៖

បានឮថា ព្រះមហានាគត្ថេររូបនោះ **បំពេញគតបច្ចាគតវត្ត** បានអធិដ្ឋានឥរិយាបថត្រឹមតែការឈរ និងការចង្ក្រមប៉ុណ្ណោះ រហូតដល់ ៧ ឆ្នាំ ដោយគិតថា "ខាង

ដើម យើងនឹងបូជាមហាបធាន (គឺសេចក្ដីព្យាយាមធំ) របស់ព្រះមានព្រះភាគជាម្ចាស់ជាមុនសិន” ដូច្នេះ ។ តមកលោកក៏បំពេញគតបច្ចាគតវត្តរហូតដល់ ១៦ ឆ្នាំទៀត ទើបសម្រេចអរហត្ត ។

ក៏ព្រះមហានាគនោះ លើកជើងឡើងដោយចិត្តដែលប្រកបដោយកម្មដ្ឋានទុំះឯង គ្រាកាលលើកជើងឡើងប្រាសចាកកម្មដ្ឋាន ក៏នឹងវិលត្រឡប់ទៅកាន់ទីជិតភូមិ ឈរនៅក្នុងប្រទេសដែលជាទីសង្ស័យថា “ទុំះជាមេគោឬហ្ន៎ ឬថាជាបព្វជិត” , ដណ្ដប់ចីវរ លាងបាត្រដោយទឹកពីបំពង់ដែលត្បៀតខ្សៀកមក ហើយបៀមទឹកមួយក្អឹក ។

**សួរថា** ព្រោះហេតុអ្វី ?

ឆ្លើយថា កាលមនុស្សទាំងឡាយ មកដើម្បីថ្វាយភិក្ខា ឬដើម្បីនឹងថ្វាយបង្គំ សេចក្ដីរាយមាយទៅនៃកម្មដ្ឋានកុំបានមាន សូម្បីដោយត្រឹមតែពាក្យថា “សូមពួកអ្នកចូរមានអាយុវែង” ដូច្នេះ ។

ក៏ភិក្ខុនោះ ត្រូវមនុស្សទាំងឡាយសួរដល់ការរាប់ថ្ងៃថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះ ជាថ្ងៃអ្វី ?” ឬសួរចំនួនភិក្ខុ ឬក៏សួរបញ្ហា លេបទឹកហើយទើបប្រាប់។ បើមិនមានអ្នកសួរដល់ថ្ងៃជាដើម, ភិក្ខុនោះ ក៏នឹងខ្ពុរទឹកចោលត្រង់ទ្វារនៃស្រុកនោះឯង ក្នុងវេលាជាទីចេញទៅ ហើយទើបទៅ ។ មួយទៀត រឿងនេះ ដូចភិក្ខុ ៥០ រូប

អ្នកនៅចាំវស្សាក្នុងវិហារ ឈ្មោះថា **គលម្ពតិត្ថៈ** ៖

បានឮថា ភិក្ខុទាំងនោះ បានធ្វើកតិកាវត្តក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍថា "ពួកយើងនៅមិនសម្រេចអរហត្ត នឹងមិនសន្ទនារកគ្នា" ដូច្នេះ ។ មួយទៀត ភិក្ខុទាំងនោះ កាលនឹងចូលទៅកាន់ភូមិដើម្បីបិណ្ឌបាត ធ្វើការបៀមទឹកមួយក្ដឹកហើយ ទើបចូលទៅ; កាលត្រូវគេសួរដល់ថ្ងៃជាដើម ក៏បដិបត្តិដោយន័យដែលពោលហើយ ។ ពួកមនុស្សឃើញទីជាទីខ្ពុរទឹកចោលនោះ ក៏នឹងយល់ថា "ថ្ងៃនេះ លោកម្ចាស់របស់យើងមកមួយរូប ឬពីររូប" ។ ក៏មនុស្សទាំងនោះគិតថា "លោកម្ចាស់ទាំងអស់នេះ រមែងមិនសន្ទនាជាមួយពួកយើងប៉ុណ្ណោះឬហ្ន៎ ឬមិនសន្ទនាចំពោះគ្នានឹងគ្នា, បើថាពួកលោកមិនសន្ទនារកគ្នាសោត លោកនឹងត្រូវវិវាទគ្នាយ៉ាងពិត; ពួកយើងចូរមក, យើងនឹងឱ្យភិក្ខុទាំងនោះ អត់ទោសចំពោះគ្នានឹងគ្នា" ។ ពួកមនុស្សទាំងអស់នាំគ្នាទៅកាន់វិហារ ក៏បណ្ដាភិក្ខុ ៥០ រូប សូម្បីភិក្ខុពីររូបនៅក្នុងឱកាសតែមួយជាមួយគ្នាមិនបានមានឡើយ; ក្នុងមនុស្សទាំងនោះ អ្នកដែលមានបញ្ញាពោលក្នុងវេលានោះថា "ម្នាលលោកដ៏ចម្រើនទាំងឡាយ ឱកាសដែលជាទីនៅអាស្រ័យរបស់អ្នកឈ្លោះគ្នាមិនមែនដូច្នេះទេ, លានព្រះចេតិយ លានព្រះមហាពោធិ៍ ដែលលោកម្ចាស់ទាំងនេះបោសសម្អាតល្អហើយ, អំបោសទាំងឡាយ លោកក៏រក្សាទុករៀបរយ, ទាំងទឹកឆាន់ ទឹកប្រើប្រាស លោកក៏

ចាត់តាំងទុកយ៉ាងល្អ” ដូច្នេះ; មនុស្សទាំងនោះ ទើបនាំគ្នាត្រឡប់ទៅពីទីនោះវិញ ។

សូម្បីភិក្ខុទាំងនោះ សម្រេចអរហត្តខាងក្នុង ៣ ខែនោះឯង បវារណាហើយនូវសុទ្ធិបវារណា ក្នុងថ្ងៃមហាបវារណា ។

ភិក្ខុទាំងនោះ លើកជើងឡើងដោយចិត្តដែលប្រកបដោយកម្មដ្ឋាននោះឯង ដូចព្រះមហានាគត្ថេរ អ្នកអាស្រ័យនៅក្នុងកាលវល្លិមណ្ឌប និងដូចភិក្ខុ ៥០ រូប អ្នកចាំវស្សាក្នុងគលម្ពតិត្ថវិហារយ៉ាងនេះ គឺភិក្ខុអ្នកបដិបត្តិនោះ ទៅកាន់ទីជិតភូមិហើយទើបធ្វើការបៀមទឹកមួយក្អឹក ហើយក៏កំណត់ផ្លូវទាំងឡាយ នឹងដំណើរទៅកាន់វីថិដែលពួកជនមិនឈ្លោះគ្នា មិនមានអ្នកលេងសុរាជាដើម ឬដំរីកាច សេះកាច មិនមាននៅក្នុងទីនោះទេ ។ កាលលោកត្រាច់ទៅកាន់ភូមិដើម្បីបិណ្ឌ មិនគួរទៅដោយក្រវើនក្រតើន ដូចជនដែលមានធុរៈប្រញាប់ប្រញាល់; ព្រោះថា ឈ្មោះថា **បិណ្ឌបាតិកធុតង្គ** (អង្គនៃគុណជាគ្រឿងកម្ចាត់កិលេស របស់ភិក្ខុអ្នកឆាន់អាហារពីការបិណ្ឌបាតជាវត្ត) ណាៗ ដូច្នេះមិនមាន ។ រមែងជាអ្នកមិនញាប់ញ័រដើរទៅ ដូចរទេះផ្ទុកទឹកដល់ទីមិនស្មើគ្នាទៅ ។ ក៏ភិក្ខុអ្នកចូលទៅកាន់ចន្លោះស្រុក គួររង់ចាំវេលាដែលសមគួរដល់ភត្តនោះ ដើម្បីកំណត់ដល់អ្នកប្រាថ្នានឹងថ្វាយ ឬមិនថ្វាយ បើទទួលភិក្ខាបានហើយនៅខាងក្នុងភូមិ ឬខាងក្រៅភូមិក៏ដោយ ហើយក៏នឹងមកកាន់វិហារនោះឯង អង្គុយក្នុង

ឱកាសដ៏សមគួរតាមសេចក្ដីសប្បាយ មនសិការកម្មដ្ឋានញ៉ាំងបដិកូលសញ្ញាក្នុងអាហារឱ្យកើតឡើងនោះ រមែងពិចារណាដោយអំណាចនៃការប្រៀបធៀបនឹងប្រេងលាបភ្លៅរថ ប្រៀបដូចសំពត់រុំដំបៅ និងប្រៀបដូចសាច់កូនខ្លួនឯង ហើយទើបឆាន់អាហារប្រកបដោយអង្គ ៨, ជាអ្នកមានប្រក្រតីឆាន់អាហារដោយមនសិការថា **“នេវ ទវាយ ន មទាយ ។ល។ ផាសុវិហារោ ច”** ដូច្នេះ ។

‿**នេវ ទវាយ** មិនមែនដើម្បីលេង

‿**ន មទាយ** មិនមែនដើម្បីស្រវឹង

‿**ន មណ្ឌនាយ** មិនមែនដើម្បីប្រដាប់

‿**ន វិភូសនាយ** មិនមែនដើម្បីតាក់តែង

‿**យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ** ត្រឹមតែដើម្បីឱ្យកាយនេះតាំងនៅ ហើយប្រព្រឹត្តទៅ ។

‿**វិហឹសូបរតិយា** ដើម្បីរម្ងាប់ចេញនូវសេចក្ដីបៀតបៀន

‿**ព្រហ្មចរិយានុគ្គហាយ** ដើម្បីអនុគ្រោះព្រហ្មចរិយៈ

‿**ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ** នឹងកម្ចាត់បង់នូវវេទនាចាស់

‿**នវញ្ច វេទនំ ន ឧប្បាទេស្សាមិ** នឹងមិនឱ្យវេទនាថ្មីកើតឡើងបាន

**យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ច** សេចក្តីប្រព្រឹត្តទៅ សេចក្តីមិនមានទោស និងការនៅសប្បាយ នឹងមានដល់យើង ។

លុះឆាន់ហើយ ធ្វើកិច្ចដោយទឹកស្រេចហើយ ក៏រម្ងាប់ចិត្តពិចារណាដល់សេចក្តីលំបាកក្នុងការស្វែងរកភត្តត្រឹមតែមួយភ្លែត, ក្នុងបុរេភត្តពិចារណាយ៉ាងណា, ក្នុងបច្ឆាភត្តក៏យ៉ាងនោះដែរ រមែងមនសិការនូវកម្មដ្ឋាននោះឯង រហូតដល់អស់បុរិមយាម និងបច្ឆិមយាម ។

ភិក្ខុនេះ លោកហៅថា **រមែងនាំកម្មដ្ឋានទៅ និងនាំកម្មដ្ឋានត្រឡប់មក** ។

ក៏ភិក្ខុអ្នកបំពេញ**គតបច្ចាគតវត្ត** ពោលគឺការនាំកម្មដ្ឋានទៅ និងនាំកម្មដ្ឋានត្រឡប់មកនេះ បើលោកមានឧបនិស្ស័យដែលដល់ព្រមហើយ រមែងសម្រេចអរហត្តក្នុងបឋមវ័យ, បើមិនសម្រេចក្នុងបឋមវ័យ រមែងសម្រេចក្នុងមជ្ឈិមវ័យ; បើមិនសម្រេចក្នុងមជ្ឈិមវ័យ, ក៏នឹងសម្រេចក្នុងបច្ឆិមវ័យ; បើក្នុងបច្ឆិមវ័យមិនសម្រេច, ក៏នឹងសម្រេចក្នុងមរណសម័យ (វេលាជិតស្លាប់); បើមិនសម្រេចក្នុងមរណសម័យ កើតជាទេវបុត្រហើយរមែងសម្រេច; បើជាទេវបុត្រហើយមិនសម្រេច, កាលព្រះពុទ្ធជាម្ចាស់នៅមិនបានកើតឡើង លោកកើតឡើងហើយ រមែងធ្វើឱ្យជាក់ច្បាស់នូវបច្ចេកពោធិ; បើមិនធ្វើឱ្យជាក់ច្បាស់នូវបច្ចេកពោធិ, រមែងនឹងជាអ្នកត្រាស់ដឹងរហ័សស្មើនឹង

សាវ័កទាំងឡាយអ្នកត្រាស់ដឹងហើយ **ដូចជាព្រះពាហិយទារុចិរិយត្ថេរ**, ឬជាអ្នកមានបញ្ញា **ដូចព្រះសារីបុត្រ**, ឬក៏ជាអ្នកមានឫទ្ធិច្រើន **ដូចព្រះមហាមោគ្គល្លាន**, ឬថា ជាអ្នកទ្រទ្រង់ធុតង្គគុណ **ដូចព្រះមហាកស្សបត្ថេរ**, ឬមួយជាអ្នកមានទិព្វចក្ខុ **ដូចព្រះអនុរុទ្ធត្ថេរ**, ឬជាអ្នកទ្រទ្រង់ព្រះវិន័យ **ដូចព្រះឧបាលិត្ថេរ**, ឬជាធម្មកថិក **ដូចព្រះបុណ្ណមន្តានីបុត្ត**, ឬជាអ្នកនៅព្រៃជាវត្ត **ដូចព្រះរេវតត្ថេរ**, ឬជាពហុស្សូត្រ **ដូចព្រះអានន្ទត្ថេរ**, ឬនឹងជាអ្នកប្រាថ្នាចំពោះការសិក្សា **ដូចព្រះរាហុលពុទ្ធបុត្ត** ។

ក្នុងកម្មដ្ឋានដែលប្រកបដោយពួក ៤ នេះ ភិក្ខុណានាំកម្មដ្ឋានទៅផង នាំកម្មដ្ឋានត្រឡប់មកផង, គោចរសម្បជញ្ញៈរបស់លោក ឈ្មោះថា ដល់ថ្នាក់កំពូលមែនពិត ។

ក៏ការមិនវង្វេងក្នុងឥរិយាបថទាំងឡាយ មានការឈានទៅខាងមុខជាដើម ឈ្មោះថា **អសម្មោហសម្បជញ្ញៈ**; បណ្ឌិតគប្បីជ្រាបសេចក្ដីនោះ ដូចតទៅនេះ ៖

ក៏ភិក្ខុក្នុងធម្មវិន័យនេះ កាលឈានទៅមុខ ឬថយមកខាងក្រោយ មិនវង្វេងដូចបុថុជ្ជនអន្ធពាលវង្វេងថា “**អត្តា**រមែងឈានទៅក្នុងឥរិយាបថទាំងឡាយ មានការឈានទៅខាងមុខជាដើម ការឈានទៅសម្រេចបានដោយអត្តា” ឬថា “យើងរមែងឈានទៅ, ការឈានទៅសម្រេចបានដោយយើង” ដូច្នេះ, ការដែលពិត គ្រាកាលចិត្តកើតឡើងថា “**យើងនឹងឈានទៅ**” ដូច្នេះ ។ វាយោធាតុដែលមានចិត្តជាសមុដ្ឋាន

កើតឡើងជាមួយចិត្តនុ៎ះឯង ញុំាងការឃ្លាតកម្រើកឱ្យកើតឡើង ។ ដោយអាការយ៉ាងនេះ គ្រោងឆ្អឹងដែលសន្មតថា កាយនេះរមែងឃានទៅដោយអំណាចនៃការឃានទៅរបស់វាយោធាតុ ដែលកើតអំពីការធ្វើរបស់ចិត្ត ។ កាលលើកជើងឡើងខាងនេះ នៅយ៉ាងនេះ ធាតុទាំងពីរ (គឺបឋវីធាតុ និងអាបោធាតុ) មានប្រមាណតិច (ទាប) មានកម្លាំងតិច ។ ធាតុទាំងពីរក្រៅពីនេះ (គឺវាយោធាតុ និងតេជោធាតុ) មានប្រមាណច្រើន មានកម្លាំងច្រើន ។ ការលើកជើងទៅ ឬទៅហើយ ក៏ដូចគ្នាដែរ ។ ដូចក្នុងការដាក់ជើងចុះ គឺតេជោធាតុ និងវាយោធាតុ មានប្រមាណតិច (ទាប) មានកម្លាំងតិច, ចំណែកធាតុទាំងពីរក្រៅពីនេះ មានប្រមាណច្រើន មានកម្លាំងច្រើន ។ ក្នុងការដាក់ជើងចុះ និងការបញ្ឈប់ជើងទុកក៏ដូចគ្នាដែរ ។ ក្នុងការប្រព្រឹត្តទៅនេះ រូបធម៌ និងអរូបធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងការលើកឡើងនោះ (កើតរលត់ទៅហើយ) រមែងមិនដល់ការនាំទៅ ។ រូបធម៌ និងអរូបធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងខណៈនាំជើងទៅនោះ រមែងមិនដល់ការនាំទៅហើយ ។ រូបធម៌ និងអរូបធម៌ទាំងឡាយ ក្នុងខណៈឃានជើងទៅហើយ រមែងមិនដល់ការដាក់ជើងចុះ ។ រូបធម៌ និងអរូបធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងខណៈដាក់ជើងចុះ រមែងមិនដល់ការបញ្ឈប់ជើងទុក ។ រូបធម៌ និងអរូបធម៌ទាំងឡាយ ក្នុងខណៈដាក់ជើងចុះ រមែងមិនដល់ការបញ្ឈប់ជើង

ទុក ។ រូបធម៌ និងអរូបធម៌ទាំងឡាយ ក្នុងទីនោះនុ៎ះឯង ជាចំណែកមួយៗ ជាសន្ធិមួយៗ ជាខេត្តមួយៗ រមែងបែកធ្លាយទៅ ដូចគ្រាប់ល្ងដែលគេដាក់លើក្បឿងក្តៅ បញ្ចេញសម្លេងឮតដះតដះដូច្នោះ ។ **ក្នុងការប្រព្រឹត្តទៅដូច្នេះ មានអ្នកណាដែលឈានទៅឬ ? ឬថា ជាការឈានទៅរបស់អ្នកណា ?** ការពិត កាលពោលដោយបរមត្ថហើយ ជាការទៅរបស់ធាតុទាំងឡាយប៉ុណ្ណោះ, ជាការឈររបស់ធាតុទាំងឡាយ, ជាការអង្គុយរបស់ធាតុទាំងឡាយ, ជាការដេករបស់ធាតុទាំងឡាយ (សម្គាល់សេចក្តីថាជាអាការៈរបស់ធាតុទាំងឡាយប៉ុណ្ណោះ) ។ ព្រោះថា ក្នុងកោដ្ឋាសៈនោះៗ ចិត្តមួយខណៈកើតឡើងជាមួយនឹងរូបទាំងឡាយ ចិត្តមួយខណៈរមែងរលត់ទៅ ដូចក្រសែទឹកដែលជាប់តាមគ្នាទៅមិនដាច់ខ្សែហើយប្រព្រឹត្តទៅដូច្នោះ ។ ការមិនវង្វេងក្នុងឥរិយាបថទាំងឡាយ មានការឈានទៅខាងមុខជាដើម ដោយអាការយ៉ាងនេះ ឈ្មោះថា **អសម្មោហសម្បជញ្ញៈ** ៕

**ចប់សេចក្តីនៃបទថា**

**អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ ត្រឹមនេះ ។**

## អធិប្បាយ

**អាលោកិតេ** = ក្រឡេកទៅខាងមុខ, **វិលោកិតេ** = ក្រឡេកទៅខាងៗ ៖

ក្នុងពាក្យថា **អាលោកិតេ  វិលោកិតេ** នេះ ការសម្លឹងមើលខាងមុខ ឈ្មោះថា **អាលោកិតៈ** ។ ការសម្លឹងមើលទិសតូចទាំងឡាយ ឈ្មោះថា **វិលោកិតៈ** ។ សូម្បីការសម្លឹងមើលទិសដទៃៗ ដោយអំណាចនៃការសម្លឹងមើលខាងក្រោម ខាងលើ ខាងក្រោយ ក៏ឈ្មោះថា **ឱលោកិតៈ** = មើលខាងក្រោម, **ឧល្លោកិតៈ** = មើលខាងលើ, **អបលោកិតៈ** = មើលខាងក្រោយ; ការក្រឡេកមើល ៣ យ៉ាងនោះ លោកមិនបានកាន់យកក្នុងពាក្យថា **អាលោកិតេ វិលោកតេ** នេះទេ ព្រោះថា ការក្រឡេកមើលពីរយ៉ាងនេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់កាន់យកហើយ ដោយអំណាចនៃសេចក្តីសរុប ។ ម្យ៉ាងទៀត កាលពោលដោយល័ក្ខខ័ណ្ឌដែលជាប្រធានហើយ ការក្រឡេកមើលទាំងអស់នោះ ក៏រួមនៅក្នុងពាក្យថា **អាលោកិតេ វិលោកិតេ** នេះឯង ។

ក្នុងការក្រឡេកមើលទាំងនោះ កាលចិត្តកើតឡើងថា **“យើងនឹងក្រឡេកមើលខាងមុខ”** ដូច្នេះ មិនក្រឡេកមើលដោយអំណាចត្រឹមតែចិត្តប៉ុណ្ណោះ ត្រូវកំណត់កាន់យកប្រយោជន៍ផង ទើបឈ្មោះថា **សាត្ថកសម្បជញ្ញៈ** ។

សាត្ថកសម្បជញ្ញៈនោះ បណ្ឌិតគប្បីជ្រាបដោយធ្វើព្រះនន្ទឱ្យជាអង្គសាក្សីដូច្នេះ ៖

ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ បើព្រះនន្ទនឹងគប្បីក្រឡេកមើលទិសខាងមុខសោត ព្រះនន្ទក៏នឹងពិចារណាធម៌ទាំងពួង ហើយក្រឡេកមើលទិសខាងមុខ ព្រោះថា ការក្រឡេកមើលទិសខាងមុខយ៉ាងនេះ ធម៌ទាំងឡាយដែលជាអកុសលដ៏លាមក គឺអភិជ្ឈា និងទោមនស្ស នឹងមិនហូរទៅតាមដោយអាការយ៉ាងនេះឯង ឈ្មោះថា ជាអ្នកមានសេចក្ដីរឮកដឹងខ្លួនទូទៅព្រមក្នុងធម៌ដែលប្រព្រឹត្តទៅជាមួយនឹងប្រយោជន៍ (ឬឈ្មោះថា **សាត្ថកសម្បជានៈ**) ។

ម្នាលភិក្ខុទាំងឡាយ បើព្រះនន្ទនឹងគប្បីក្រឡេកមើលទិសខាងក្រោយ (ខាងលិច) សោត, នឹងគប្បីក្រឡេកមើលទិសខាងជើង, នឹងគប្បីក្រឡេកមើលទិសខាងត្បូង, នឹងគប្បីក្រឡេកមើល (ទិស) ខាងក្រោម, ខាងលើ, នឹងគប្បីក្រឡេកមើលទិសតូច, នន្ទក៏នឹងពិចារណាធម៌ទាំងពួង ហើយទើបក្រឡេកមើលទិសតូច ។ ព្រោះថា ការក្រឡេកមើលទិសតូចយ៉ាងនេះ... រមែងជាអ្នកឈ្មោះថា មានសម្បជានៈ (គឺមានសេចក្ដីរឮកដឹងខ្លួនទូទៅព្រមក្នុងប្រយោជន៍) ”[២៥] ដូច្នេះ ។

ម្យ៉ាងទៀត សូម្បីក្នុងពាក្យថា **អាលោកិតេ វិលោកិតេ** នេះ បណ្ឌិតគប្បី

[២៥] អំ. អដ្ឋក. ។

ជ្រាបដោយសេចក្ដីប្រព្រឹត្តទៅជាមួយនឹងប្រយោជន៍ និងការប្រព្រឹត្តទៅនៃសេចក្ដីសប្បាយ ដោយអំណាចនៃការឃើញព្រះចេតិយជាដើម តាមដែលពោលទុកក្នុងកាលមុននោះឯង ។ ក៏គោចរសម្បជញ្ញៈ មិនបានវៀរចាកកម្មដ្ឋានឡើយ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីធ្វើការក្រឡេកមើលទៅមុខ ការក្រឡេកមើលខាងៗ ដោយកម្មដ្ឋានសីសៈនោះឯង ដោយអំណាចនៃកម្មដ្ឋានដែលជារបស់ខ្លួន មានខន្ធ ធាតុ និងអាយតនៈជាទីតាំង ឬដោយកម្មដ្ឋានមានកសិណជាដើម ។ ក៏ខាងក្នុងនៃរាងកាយនេះឈ្មោះថា អត្តាជាអ្នកក្រឡេកមើលខាងមុខ ឬក្រឡេកមើលខាងក្រោយ មិនបានមានឡើយ, តែថា កាលចិត្តកើតឡើងថា **"នឹងក្រឡេកមើលខាងមុខ"** ដូច្នេះ **វាយោធាតុ** ដែលមានចិត្តជាសមុដ្ឋានជាមួយនឹងចិត្តនោះៗ ឯង ញុំាងសេចក្ដីឃ្លាតកម្រើក (វិញ្ញត្តិរូប) នៃរូប ឱ្យកើតឡើងភ្លាមនោះឯង; ស្បែក (ត្របក) ភ្នែកដែលជាចំណែកខាងក្រោម ក៏ធ្លាក់ចុះមកខាងក្រោម ស្បែកភ្នែកដែលជាចំណែកខាងលើ ក៏នឹងបើកឡើងទៅខាងលើ ដោយអំណាចនៃការផ្សាយទៅរបស់ **វាយោធាតុ** ដែលជាការធ្វើរបស់ចិត្ត ។ អ្នកណាៗ ឈ្មោះថា បើក (ភ្នែក) ដោយគ្រឿងយន្តមិនបានមានឡើយ, លំដាប់នោះ ចក្ខុវិញ្ញាណ ក៏កើតឡើង ញុំាងទស្សនកិច្ចឱ្យសម្រេចការដឹងយ៉ាងនេះឈ្មោះថា **អសម្មោហសម្បជញ្ញៈ** ក្នុងពាក្យថា **អាលោកិតេ វិលោកិតេ** នេះ ។

ក៏ម្យ៉ាងទៀត គប្បីជ្រាបអសម្មោហសម្បជញ្ញៈក្នុងទីនេះ ដោយអំណាចនៃសេចក្តីជាមូលបរិញ្ញា **អាគន្តុកៈ** និង **តាវកាលិកៈ** តទៅ ៖

ពោលអំពី **មូលបរិញ្ញា** (សេចក្តីដឹងជុំវិញដល់មូល) មុន ៖

**ភវង្គមាវជ្ជនញ្ចេវ ទស្សនំ សម្បដិច្ឆនំ**
**សន្តីរណំ វោដ្ឋព្វនំ ជវនំ ភវតិ សត្តមំ**

ភវង្គចិត្ត អាវជ្ជនចិត្ត ចក្ខុវិញ្ញាណចិត្ត
សម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត វោដ្ឋព្វនចិត្ត តពីនោះ ជវនចិត្តរមែងកើត ៧ ដួង ។

បណ្តាចិត្តទាំងនោះ **ភវង្គចិត្ត** រមែងញ៉ាំងកិច្ចដែលជាចំណែកនៃឧប្បត្តិភព ឱ្យសម្រេចការប្រព្រឹត្តទៅ, ព្រោះការរលត់ទៅនៃ**កិរិយាមនោធាតុ**នោះ ទើបចក្ខុ-វិញ្ញាណចិត្ត ញ៉ាំងទស្សនកិច្ចឱ្យប្រព្រឹត្តទៅ, ព្រោះការរលត់ទៅនៃ**ចក្ខុវិញ្ញាណចិត្ត-វិបាកមនោធាតុ** ទើបញ៉ាំងសម្បដិច្ឆន្នកិច្ច ឱ្យសម្រេចការប្រព្រឹត្តទៅ, ព្រោះការរលត់ទៅនៃ**កិរិយាមនោធាតុ**នោះ ទើបវិបាកមនោវិញ្ញាណធាតុ ញ៉ាំងសន្តីរណកិច្ចឱ្យសម្រេចការប្រព្រឹត្តទៅ, ព្រោះការរលត់ទៅនៃ **វិបាកមនោវិញ្ញាណធាតុ**នោះ ទើបកិរិយាមនោវិញ្ញាណធាតុ ញ៉ាំងវោដ្ឋព្វនកិច្ចឱ្យសម្រេចការប្រព្រឹត្តទៅ, ព្រោះការរលត់ទៅនៃ**កិរិយាមនោវិញ្ញាណធាតុ**នោះ ទើបជវនចិត្តត្រាច់ទៅ ៧ ដង ។

ក្នុងជវនចិត្តទាំងនោះ ការក្រឡេកមើលខាងមុខៗ ឬក្រឡេកមើលខាងៗ ថា "នេះជាស្រី, នេះជាប្រុស" ដូច្នេះ ដោយអំណាចនៃសេចក្តីត្រេកអរ ប្រទូសរ៉ាយ និងសេចក្តីវង្វេង រមែងមិនមានសូម្បីក្នុងជវនចិត្តដួងទីមួយ ។ សូម្បីក្នុងជវនចិត្តដួងទី ២ ។ ល ។ សូម្បីជវនចិត្តដួងទី ៧ ។ ក៏គ្រាកាលជវនចិត្តទាំងនោះ បែកធ្លាយទៅដោយអំណាចនៃការបែកធ្លាយតាំងពីដើម ដរាបដល់ទីបំផុត ដូចនឹងទាហានក្នុងសមរភូមិចម្បាំងត្រូវទម្លាយទៅ, ការក្រឡេកមើលខាងមុខ ឬការក្រឡេកមើលខាងៗ ថា "នេះជាស្រី, នេះជាប្រុស" ដូច្នេះ ដោយអំណាចនៃសេចក្តីត្រេកអរជាដើម ទើបមាន ។

បណ្ឌិតគប្បីជ្រាបអសម្មោហសម្បជញ្ញៈក្នុងទីនេះ ដោយអំណាចនៃ**មូលបរិញ្ញា** ដោយប្រការដូច្នេះសិន ។

**ពោលអំពីភាពជាអាគន្តុកៈ** (ដោយអំណាចនៃសេចក្តីដូចជាភ្ញៀវមករក) ៖

ក៏ក្នុងចក្ខុទ្វារ គ្រាកាលរូបមកកាន់គន្លងហើយ ដោយការឃ្លាតទៅនៃភវង្គខាងលើ បណ្តាចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាដើម កើតឡើងដោយអំណាចនៃការញុំាងកិច្ចរបស់ខ្លួនៗ ឱ្យសម្រេចហើយរលត់ទៅក្នុងទីបំផុត ជវនចិត្តក៏កើតឡើង, ជវនចិត្តនោះ រមែងកើតក្នុងចក្ខុទ្វារដែលជាផ្ទះរបស់អាវជ្ជនចិត្តជាដើម ដែលកើតឡើងមុន ដូចបុរសដែលជាភ្ញៀវ (អ្នកត្រាច់មក) ។ កាលបុរសអ្នកជាភ្ញៀវនោះ ចូលទៅដើម្បីសុំអ្វីៗ

ក្នុងផ្ទះរបស់អ្នកដទៃ មិនគួរធ្វើការប្រទូសរ៉ាយសូម្បីក្នុងម្ចាស់នៃផ្ទះ ដែលអង្គុយស្ងៀមព្រងើយ យ៉ាងណា, សូម្បីកាលអាវជ្ជនចិត្តជាដើម ដែលមិនត្រេកអរ មិនប្រទូសរ៉ាយ និងមិនវង្វេងក្នុងចក្ខុទ្វារ ដែលជាផ្ទះរបស់អាវជ្ជនចិត្តជាដើម សេចក្ដីត្រេកអរ សេចក្ដីប្រទូសរ៉ាយ សេចក្ដីវង្វេង ក៏មិនគួរមានឡើយ ។ គប្បីជ្រាបអសម្មោហសម្បជញ្ញៈ **ដោយអំណាចនៃភាពជាអាគន្តុកៈ** ដូចពណ៌នាមកដូច្នេះ ។

**ពោលអំពីភាពជាតាវកាលិកៈ** (គឺជាធម៌មួយជួរខណៈ) ៖

ក៏ចិត្តទាំងឡាយ មានវោដ្ឋព្វនចិត្តជាបរិយោសានឯណានោះ រមែងកើតឡើងក្នុងចក្ខុទ្វារ, ចិត្តទាំងនោះ និងសម្បយុត្តធម៌ទាំងឡាយ រមែងបែករលត់ទៅក្នុងទីនោះនុ៎ះឯង, រមែងមិនឃើញនូវគ្នានឹងគ្នា ព្រោះហេតុនោះ ចិត្តយ៉ាងណាមួយទាំងនេះ ទើបឈ្មោះថា ជា**តាវកាលិកៈ** គឺជាធម៌មួយជួរខណៈ; បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ក្នុងសេចក្ដីនោះ ដូចតទៅនេះ ៖

កាលពួកមនុស្សទាំងពួង ក្នុងផ្ទះមួយស្លាប់ហើយ វេលា (អាយុ) របស់ជនម្នាក់ដែលនៅសល់ ក៏នឹងស្លាប់ជាធម្មតា គេឈ្មោះថា រមែងត្រេកអរក្រៃលែង ក្នុងការរាំច្រៀងជាដើម ជាវត្ថុមិនគួរមាន យ៉ាងណា, ក្នុងទ្វារមួយ ក៏យ៉ាងនោះដែរ កាលអាវជ្ជនចិត្តជាដើម ព្រមដោយសម្បយុត្តធម៌ស្លាប់ទៅហើយក្នុងទីនោះនុ៎ះឯង ក្នុងខណៈ

របស់ចិត្តដែលនៅសល់នោះ ក៏មានសេចក្តីស្លាប់ជាធម្មតា ឈ្មោះថា រមែងត្រេកអរ ក្រៃលែង ដោយអំណាចនៃសេចក្តីត្រេកអរ ប្រទូសរ៉ាយ និងសេចក្តីវង្វេង សូម្បីរបស់ជវនចិត្ត ក៏មិនគួរនឹងមានទេ ។ គប្បីជ្រាបអសម្មោហសម្បជញ្ញៈ **ដោយអំណាចនៃភាពជាធម៌មួយជួរខណៈ** ដូចពណ៌នាមកយ៉ាងនេះ ។

ម្យ៉ាងទៀត **គប្បីជ្រាបអសម្មោហសម្បជញ្ញៈនោះ ដោយអំណាចនៃការពិចារណាដោយសេចក្តីជាខន្ធ អាយតនៈ ធាតុ និងបច្ច័យ ។ ពិតមែន ក្នុងការពិចារណាដោយសេចក្តីថា ខន្ធ ដូច្នេះ ៖**

ចក្ខុ និងរូបទាំងឡាយ ជារូបក្ខន្ធ

ចក្ខុវិញ្ញាណដែលធ្វើទស្សនកិច្ច ជាវិញ្ញាណក្ខន្ធ

វេទនាដែលសម្បយុត្តដោយចក្ខុវិញ្ញាណនោះ ជាវេទនាខន្ធ

សញ្ញាដែលសម្បយុត្តដោយចក្ខុវិញ្ញាណនោះ ជាសញ្ញាខន្ធ

ផស្សៈជាដើម ដែលសម្បយុត្តដោយចក្ខុវិញ្ញាណនោះ ជាសង្ខារក្ខន្ធ ។

**ដោយប្រការដូច្នេះ ការក្រឡេកមើលទៅខាងមុខ និងការក្រឡេកមើលខាងចំហៀង១ ព្រោះជាការប្រជុំគ្នានៃខន្ធទាំង ៥ នេះ ទើបប្រាកដឡើងបាន ក្នុងទីនេះ មានអ្នកណាត្រឹមតែម្នាក់ឬ ដែលក្រឡេកមើលទៅខាងមុខ ឬក្រឡេកមើលខាង១ ដោយទំនងតែមួយជាមួយគ្នា ពិចារណាដោយសេចក្តីជា**

អាយតនៈ គឺ៖

ចក្ខុ ជាចក្ខ្វាយតនៈ

រូប ជារូបាយតនៈ

ចក្ខុវិញ្ញាណដែលធ្វើទស្សនកិច្ច ជាមនាយតនៈ ។

ធម៌ដែលសម្បយុត្តដោយចក្ខុវិញ្ញាណមានវេទនាជាដើមនោះ ជាធម្មាយតនៈ។

ដោយប្រការដូច្នេះ ការក្រឡេកមើលទៅខាងមុខ និងការក្រឡេកមើលទៅខាងៗ រមែងប្រាកដឡើង ក៏ព្រោះការប្រជុំគ្នានៃអាយតនៈទាំង ៤ នោះ ។ ក្នុងទីនេះ នឹងមានអ្នកណាត្រឹមតែម្នាក់ឬ ដែលក្រឡេកមើលខាងមុខ ឬក្រឡេកមើលខាងៗ ដោយសេចក្ដីថាធាតុ ក៏ដូចគ្នានុ៎ះឯង គឺ៖

ចក្ខុ ជាចក្ខុធាតុ

រូប ជារូបធាតុ

ចក្ខុវិញ្ញាណ ជាចក្ខុវិញ្ញាណធាតុ ។

ធម៌ដែលសម្បយុត្តដោយចក្ខុវិញ្ញាណ មានវេទនាជាដើមនោះ ជាធម្មធាតុ ។

ដោយអាការយ៉ាងនេះ ការក្រឡេកមើលខាងមុខ ការក្រឡេកមើលខាងៗ ព្រោះការប្រជុំគ្នានៃធាតុទាំង ៤ នោះ ទើបប្រាកដឡើង, ក្នុងទីនេះ អ្នកណាហ្ន៎ ដែលក្រឡេកមើលខាងមុខ ឬក្រឡេកមើលខាងៗ ។ ពោលដោយ

សេចក្តីជាបច្ច័យ ក៏ដូចតែគ្នា គឺ៖

ចក្ខុ ជានិស្សយប្បច្ច័យ

រូប ជាអារម្មណប្បច្ច័យ

អាវជ្ជនចិត្ត ជាអនន្តរៈ សមនន្តរៈ អនន្តរូបនិស្សយៈ និងនត្ថិវិគតប្បច្ច័យ

អាលោក (ពន្លឺ) ជាឧបនិស្សយប្បច្ច័យ ។

ដោយប្រការដូច្នេះ ទើបប្រាកដជាការក្រឡេកមើលខាងមុខ ក្រឡេកមើល ខាង១ ព្រោះការប្រជុំគ្នានៃបច្ច័យទាំងឡាយនេះ ។ ក្នុងទីនេះ មានអ្នកណាហ្ន៎ ត្រឹមតែម្នាក់ឬ ដែលក្រឡេកមើលខាងមុខ ក្រឡេកមើលខាង១ ដូច្នេះ គប្បីជ្រាប អសម្មោហសម្បជញ្ញៈ ក្នុងពាក្យថា **អាលោកិតេ វិលោកិតេ** នេះ សូម្បីដោយអំណាចនៃសេចក្តីពិចារណាជាខន្ធ អាយតនៈ ធាតុ និងសេចក្តីជាបច្ច័យ ដូចពណ៌នាមកដូច្នេះឯង ៕

## អធិប្បាយ

### សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ

(ជាអ្នកដឹងច្បាស់ដោយប្រក្រតី ក្នុងការបត់អវយវៈចូល និងការលាអវយវៈចេញ) ដូចតទៅ៖

ពាក្យថា **សម្មិញ្ជិតេ បសារិតេ** បានដល់ ការបត់ចូល និងការលាអវយវៈនៃសន្លាក់ទាំងឡាយចេញ ។ ក្នុងទីនេះ ភិក្ខុមិនបានធ្វើការបត់ចូល និងការលាអវយវៈចេញ ដោយអំណាចនៃចិត្តប៉ុណ្ណោះទេ ត្រូវកំណត់ដល់ប្រយោជន៍ និងវត្ថុមិនមានប្រយោជន៍ ព្រោះការបត់ចូល ការលាដៃ និងជើងចេញជាបច្ច័យ ហើយកំណត់កាន់យកប្រយោជន៍ក្នុងការបត់ចូល បត់ចេញនោះ ឈ្មោះថា **សាត្ថកសម្បជញ្ញៈ** ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសេចក្តីនេះតទៅ ៖

កាលភិក្ខុនោះបត់អវយវៈនៃដៃ និងជើងយូរពេកទៅ ឬលាចេញយូរពេកទៅ, ទុក្ខវេទនារមែងកើតឡើងគ្រប់ៗ ខណៈ,ចិត្តរមែងមិនបានឯកគ្គតា, កម្មដ្ឋានរមែងធ្លាក់ទៅ, រមែងមិនសម្រេចគុណវិសេស ។

បើភិក្ខុនោះ បត់អវយវៈចូលក្នុងវេលាដែលគួរ កាលលាអវយវៈចេញក្នុងវេលាដែលគួរ ទុក្ខវេទនារមែងមិនកើត, ចិត្តរមែងជាធម្មជាតិស្ងប់ កម្មដ្ឋានរមែងដល់ការផ្សាយទៅ រមែងសម្រេចគុណវិសេស; គប្បីកំណត់ប្រយោជន៍ និងវត្ថុមិនមែនប្រយោជន៍យ៉ាងនេះ ។ ក៏សូម្បីកាលប្រយោជន៍មាន ការកំណត់សប្បាយ អសប្បាយហើយកាន់យកតែសប្បាយ ឈ្មោះថា **សប្បាយសម្បជញ្ញៈ** ។

## សម្មោហវិនោទនី

**ក្នុងការបត់អវយវៈចូល និងការលាអវយវៈចេញនោះ មានន័យដូច្នេះ ៖**

**បានឮថា** ភិក្ខុកំលោះទាំងឡាយ ស្វាធ្យាយពុទ្ធវចនៈ ត្រង់លានព្រះមហា-ចេតិយ, ភិក្ខុនីទាំងឡាយ កំពុងស្ដាប់ធម៌ នៅខាងក្រោយភិក្ខុកំលោះនោះ ។ បណ្ដាភិក្ខុទាំងនោះ ភិក្ខុកំលោះមួយរូប លាដៃចេញទៅត្រូវកាយនាងភិក្ខុនីក្រមុំ ហើយទើបជាហេតុឱ្យលោកត្រូវលាសិក្ខាទៅជាគ្រហស្ថ ។ មួយរូបទៀត កាលលាជើងចេញទៅ ក៏លាទៅលើគំនរភ្លើង, ភ្លើងឆេះជើងរបស់លោក ដរាបដល់ឆ្អឹង ។ មួយរូបទៀត លាទៅត្រង់ដំបូកកណ្ដៀរ, លោកត្រូវបានអាសិរពិសចឹក ។ មួយរូបផ្សេងទៀត លាចេញទៅត្រង់ស្នូចីវរ, ក៏ត្រូវពស់ខ្សៀវចឹកដែរ ។ ព្រោះហេតុនោះ ភិក្ខុមិនគប្បីលាដៃ លាជើងក្នុងទីអសប្បាយដូច្នេះទេ គួរលាចេញទៅក្នុងទីសប្បាយ ។ នេះឈ្មោះថា **សប្បាយ-សម្បជញ្ញៈ** ក្នុងសេចក្ដីនេះឯង ៕

## សម្តែងអំពីគោចរសម្បជញ្ញៈ

**ក៏គោចរសម្បជញ្ញៈ** បណ្ឌិតគប្បីសម្តែងរឿងរបស់មហាថេរដូច្នេះ ៖

បានឮថា ព្រះមហាថេរអង្គុយសម្រាកក្នុងទីសម្រាកវេលាថ្ងៃ សន្ទនាគ្នាជាមួយអន្តេវាសិកទាំងឡាយ ភ្លេចខ្លួន ក៏លាដៃចេញទៅដោយរហ័ស ហើយក៏នាំដៃត្រឡប់មកដល់ទីដើមវិញ ក៏លាសន្សឹមៗ ចេញទៅ, ពួកអន្តេវាសិកសួរលោកថា "ព្រោះហេតុអ្វីបានជាលោកម្ចាស់លាដៃចេញទៅដោយរហ័ស ហើយនាំដៃមកដាក់ទីដើមទៀត ទើបលាសន្សឹមៗ ចេញទៅ" , លោកឆ្លើយថា "លោកមានអាយុទាំងឡាយ ចាប់តាំងពីយើង ផ្តើមបំពេញមនសិការកម្មដ្ឋាន យើងមិនធ្លាប់លាដៃចេញទៅផុតពីកម្មដ្ឋាន, តែឥឡូវនេះ យើងកំពុងសន្ទនាជាមួយនឹងពួកលោក ពន្លែងកម្មដ្ឋានលាដៃចេញទៅហើយ, ព្រោះហេតុនោះ ទើបនាំដៃមកដាក់តាមដើមវិញ ហើយទើបលាចេញទៅទៀត" ។ ពួកអន្តេវាសិកទាំងនោះ នាំគ្នាសាធុការថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ល្អហើយ ធម្មតា ភិក្ខុគប្បីជាដូច្នេះឯង" ។

សូម្បីក្នុងពាក្យថា **សម្មិញ្ជិតេ បសារិតេ** នេះ គប្បីជ្រាបថា ជាសភាវៈមិនវៀរចាកកម្មដ្ឋាននោះឯង ដោយអាការយ៉ាងនេះ គឺ ៖

ធម្មតាថា អត្តាអ្វីៗ ខាងក្នុង បត់អវយវៈចេញ មិនមានឡើយ, ក៏ការកំណត់ថា "ការបត់អវយវៈចូល ការលាអវយវៈចេញ រមែងមានបាន ដោយការផ្សាយទៅរបស់វាយោធាតុ ដែលជាការធ្វើរបស់ចិត្តមានប្រការតាមដែលពោលហើយ

ដូចជារូបយន្តឈើ ឃ្លាតកម្រើកជើង និងដៃបាន ដោយអំណាចនៃការទាញខ្សែអំពោះ” ព្រោះហេតុនោះ ក្នុងលក្ខណៈយ៉ាងនេះ ទើបឈ្មោះថា **អសម្មោហសម្បជញ្ញៈ**។

ក្នុងពាក្យថា **“សង្ឃាដិបត្តចីវរធារណេ** = ជាអ្នកដឹងច្បាស់ដោយប្រក្រតីក្នុងការទ្រទ្រង់សង្ឃាដី បាត្រ និងចីវរ” នេះ ការប្រើប្រាស់សង្ឃាដី និងចីវរ ដោយអំណាចនៃការស្លៀកដណ្តប់ និងការប្រើបាត្រដោយអំណាចនៃការទទួលភិក្ខា ឈ្មោះថា ការទ្រទ្រង់ទុក ។ បណ្ឌិតគប្បីជ្រាបការទ្រទ្រង់សំពត់សង្ឃាដី និងចីវរ ក្នុងពាក្យថា **សង្ឃាដិបត្តចីវរធារណេ** នេះ សិនថា ៖

ព្រះមានព្រះភាគត្រាស់ប្រយោជន៍ក្នុងការទ្រទ្រង់សំពត់សង្ឃាដីទុក មានប្រការផ្សេងៗ ដោយន័យជាដើមថា “ការបានអាមិសរបស់ភិក្ខុ អ្នកស្លៀកដណ្តប់ ហើយត្រាច់ទៅដើម្បីបិណ្ឌ ដើម្បីការពាររងាជាដើមយ៉ាងនេះ ឈ្មោះថា ប្រយោជន៍” និងគប្បីជ្រាបថា **ជាសាត្ថកសម្បជញ្ញៈ** ដោយអំណាចនៃប្រយោជន៍នោះ ។

មួយទៀត ចីវរសាច់ស្តើង ឬទន់ ជាសប្បាយដល់ភិក្ខុអ្នកមានប្រក្រតីក្តៅ មានកម្លាំងខ្សោយ, ចីវរសាច់ក្រាស់ពីរជាន់ ជាសប្បាយដល់ភិក្ខុអ្នកមានប្រក្រតីរងា ។ ក្រៅពីនេះ ជាអសប្បាយ ។ អ្នកមានចីវរចាស់រយីករយាក ក៏ជាអសប្បាយដូចគ្នា ។ ព្រោះថា ចីវរចាស់ផ្ទាំងនោះ រមែងធ្វើបលិពោធឱ្យដល់លោកដោយត្រូវការអំពោះទុកជាដើម ។ ដោយទំនងដូចគ្នានោះឯង ចីវរដែលជាទីត្រេកអរពេញចិត្តរបស់ចោរទាំង-

ឡាយ មានសំពត់ទុកូល (សំពត់ប្រភេទល្អ) ដែលធ្វើដោយសូត្រ និងរោមសត្វជាដើម ក៏ជាអសប្បាយ ។ ពិតមែន សំពត់ដូច្នោះរមែងធ្វើអន្តរាយដល់ភិក្ខុស្លៀកដណ្តប់តែម្នាក់នៅក្នុងព្រៃ ឬរមែងធ្វើអន្តរាយចំពោះជីវិតរបស់លោកក៏បាន ។ មួយទៀត កាលពោលដោយនិប្បរិយាយហើយ ចីវរណាកើតឡើងដោយអំណាចនៃមិច្ឆាអាជីវៈ មានការទាយនិមិត្តជាដើម និងចីវរណា កាលលោកសេព អកុសលធម៌ទាំងឡាយរមែងចម្រើន, កុសលធម៌ទាំងឡាយរមែងសាបសូន្យទៅ, ចីវរនោះៗ ជាអសប្បាយ ។ ក្រៅពីនេះ ជាសប្បាយ ។

ក្នុងពាក្យថា **សង្ឃាដិបត្តចីវរធារណេ** នេះ ឈ្មោះថា ជាសប្បាយសម្បជញ្ញៈ ដោយអំណាចនៃការទ្រទ្រង់សំពត់សង្ឃាដី និងចីវរដែលជាសប្បាយនោះ ។ ទាំងគោ-ចរសម្បជញ្ញៈ ក៏គប្បីជ្រាបថា មិនវៀរចាកកម្មដ្ឋានដូចគ្នា គឺ ៖

**ឈ្មោះថា អត្តា គឺតួខ្លួនណាៗ ខាងក្នុង ធ្វើការដណ្តប់នូវចីវរមិនបានមាន,** ក៏ប៉ុន្តែថា ការដណ្តប់ចីវររមែងមានដោយអំណាចនៃការផ្សាយទៅនៃវាយោធាតុដែលជាការធ្វើរបស់ចិត្ត មានប្រការតាមដែលពោលហើយនោះឯង ។ ក្នុងការដណ្តប់ចីវរនោះ សូម្បីចីវរក៏មិនមានចេតនា, សូម្បីកាយក៏មិនមានចេតនា ។ ទាំងចីវរក៏មិនដឹងថា **“យើងដណ្តប់កាយទុក”** , សូម្បីកាយនោះ ក៏រមែងមិនដឹងថា **“យើងត្រូវចីវរដណ្តប់ទុក” ។ ពោលដោយសភាវៈ ធាតុទាំងឡាយនោះ រមែងបិទបាំងនូវពួកនៃធាតុផងគ្នា ដូចការវេចសៀវភៅដោយកំណាត់សំពត់ចាស់ៗ, ព្រោះ**

ហេតុនោះ ការដែលភិក្ខុបានចីវរប្រភេទល្អមក ក៏មិនគប្បីសោមនស្ស, បានចីវរប្រភេទមិនល្អមក ក៏មិនគប្បីទោមនស្ស ។ ដូចយ៉ាងថា ក្នុងស្ថានទីទាំងឡាយ មានដំបូក និងដើមឈើធំជាដើម អ្នកណា១ រមែងធ្វើសក្ការៈក្នុងទីនោះ១ ដោយវត្ថុទាំងឡាយ មានគ្រឿងប្រដាប់ដោយផ្កាឈើ និងរបស់ក្រអូបជាដើមក្តី, មិនធ្វើគ្រឿងសក្ការៈដោយចោលនូវគូថ (លាមក) មូត្រ (ទឹកនោម) ភក់ ឬប្រហារដោយកំណាត់ឈើ និងសស្ត្រាជាដើមក្តី; ដំបូក និងដើមឈើទាំងនោះ រមែងមិនសោមនស្ស មិនទោមនស្សដោយវត្ថុនោះ១ យ៉ាងណា, ភិក្ខុក៏ដូច្នោះដែរ បានចីវរយ៉ាងល្អ ក៏មិនធ្វើសេចក្តីពេញចិត្ត, បានចីវរមិនល្អ ក៏មិនធ្វើសេចក្តីអន់ចិត្ត ។ បណ្ឌិតគប្បីជ្រាបថា **ជាអសម្មោហសម្បជញ្ញៈ** ក្នុងការស្លៀកដណ្តប់ចីវរក្នុងទីនេះ ដោយអំណាចនៃការពិចារណាសេចក្តីប្រព្រឹត្តទៅ ដូចពណ៌នាមកយ៉ាងនេះ ។

សូម្បីក្នុងការទ្រទ្រង់បាត្រ ភិក្ខុក៏មិនកាន់បាត្រដោយរហ័សពេកទេ ដូចជាកាន់យកបាត្រទៅបិណ្ឌ ដោយប្រាថ្នាថា “យើងនឹងបានភិក្ខា ព្រោះការកាន់យកនូវបាត្រនេះ” ។ ដូចពណ៌នាមកដូច្នេះ គប្បីជ្រាបថា **ជាសាត្ថកសម្បជញ្ញៈ** ដោយអំណាចនៃប្រយោជន៍ដែលខ្លួនគួរបាន ។ បាត្រធ្ងន់ ជាអសប្បាយដល់ភិក្ខុអ្នកមានរាងកាយស្គមមិនមានកម្លាំង ។ បាត្រដែលធ្វើការសម្អាតមិនល្អ មានដុំស្នឹមឡើង ៤-៥ ដុំ ជាអសប្បាយ ។ ព្រោះថា បាត្រដែលភិក្ខុធ្វើសេចក្តីសម្អាតមិនល្អ មិនសមគួរដល់ភិក្ខុ, ព្រោះថា បលិពោធ (សេចក្តីកង្វល់) រមែងមានដល់លោកអ្នកជម្រះបាត្រនោះមែនពិត ។

មួយទៀត បាត្រមានពណ៌ដូចកែវមណីដែលជាទីតាំងនៃលោភៈ ជាអសប្បាយ ដូចន័យដែលពោលទុកក្នុងរឿងចីវរនោះឯង ។ ក៏បាត្រដែលបានមកដោយអំណាចនៃការទាយនិមិត្ត (គ្រូហោរ) ជាដើម, កាលលោកសេពបាត្រណា អកុសលធម៌ទាំងឡាយ រមែងចម្រើន, កុសលធម៌ទាំងឡាយរមែងសាបសូន្យ, បាត្រនេះជាអសប្បាយដោយចំណែកតែមួយមែនពិត ។ បាត្រក្រៅពីនេះ ជាសប្បាយ ។

ក្នុងការទ្រទ្រង់បាត្រ ឈ្មោះថា **សប្បាយសម្បជញ្ញៈ** ដោយអំណាចនៃសប្បាយនោះៗ និងគប្បីជ្រាបថា **ជាគោចរសម្បជញ្ញៈ** ដោយមិនវៀរកម្មដ្ឋានដូចគ្នា គឺ៖

ក៏ឈ្មោះថា តួខ្លួន (អត្តា) អ្វីខាងក្នុងកាន់នូវបាត្រមិនមានទេ, ព្រោះថា ការកាន់បាត្រ រមែងមានបានដោយអំណាចការផ្សាយទៅនៃវាយោធាតុ ដែលជាការធ្វើរបស់ចិត្ត មានប្រការតាមដែលពោលហើយនោះឯង ។

ក្នុងឋានដូច្នេះ សូម្បីបាត្រក៏មិនមានចេតនា, សូម្បីដៃក៏មិនមានចេតនា ។ បាត្ររមែងមិនដឹងថា “យើងត្រូវដៃកាន់ទុកហើយ” សូម្បីដៃសោត ក៏រមែងមិនដឹងថា “បាត្រយើងកាន់ទុកហើយ” ; (កាលមានអ្នកសួរជ្រែកមកថា កាលបើដូច្នេះ ក៏អ្នកណាទៅជាអ្នកកាន់ និងកាន់អ្វី ?) ក៏ធាតុទាំងឡាយនោះឯង រមែងកាន់នូវពួកនៃធាតុផងគ្នា ដូចការប្រើតង្កៀបថ្ពៀបបាត្ររោលភ្លើង ។ គប្បីជ្រាប **អសម្មោហសម្បជញ្ញៈ** ក្នុងពាក្យថា **ការទ្រទ្រង់បាត្រ** នេះ ដោយអំណាចនៃការពិចារណាសេចក្តីប្រ-

ព្រឹត្តទៅ ដូចពណ៌នាមកដូច្នេះ ។

ម្យ៉ាងទៀត បុរសអ្នកពេញដោយសេចក្តីករុណា ឃើញមនុស្សអនាថា មានដៃ និងជើងដែលដាច់ហើយ មានឈាមខ្ទុះហូរចេញមកជាមួយពួកដង្កូវតាមមុខដំបៅទ្រង់សាលាមនុស្សអនាថា ដែលរោមទៅដោយរុយក្បាលខៀវ ទើបបង្អោនទៅនូវវត្ថុទាំង- ឡាយ មានសំពត់សម្រាប់រុំដំបៅ និងថ្នាំសម្រាប់រក្សា (ព្យាបាល) ដោយក្បឿង (ភាជនៈដាក់របស់) ដើម្បីជនអនាថាទាំងនោះ; ក្នុងវត្ថុរបស់ទាំងនោះ អ្នកខ្លះរមែងបានសំពត់រុំដំបៅសាច់ស្តើង, អ្នកខ្លះបានសាច់គ្រោតគ្រាត; សូម្បីក្បឿងដាក់ភេសជ្ជៈក៏ដូចគ្នា អ្នកខ្លះបានរបស់ល្អ, អ្នកខ្លះបានរបស់អាក្រក់; គេទាំងនោះ រមែងមិនសប្បាយចិត្ត មិនអន់ចិត្ត ព្រោះថា សេចក្តីត្រូវការរបស់គេដោយសំពត់ត្រឹមតែការបិទបាំងប៉ុណ្ណោះ និងដោយក្បឿង ក៏ត្រឹមតែជាគ្រឿងទ្រភេសជ្ជៈនោះឯង យ៉ាងណា, សេចក្តីនេះ ក៏យ៉ាងនោះដែរ ភិក្ខុណារមែងកំណត់ (ពិចារណា) ចីវរ ដូចសំពត់រុំដំបៅ និងកំណត់ពិចារណាបាត្រ ដូចក្បឿងដាក់ភេសជ្ជៈ និងកំណត់ពិចារណាភិក្ខាដែលបានហើយក្នុងបាត្រ ដូចភេសជ្ជៈក្នុងក្បឿង, ភិក្ខុនេះ បណ្ឌិតគប្បីជ្រាបថា ជាអ្នកមានប្រក្រតីធ្វើសម្បជញ្ញៈដ៏ឧត្តម ដោយអសម្មោហសម្បជញ្ញៈ ក្នុងការទ្រទ្រង់សង្ឃាដី បាត្រ និងចីវរនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា **អសិតេ** ជាដើម ៖

ពាក្យថា **អសិតេ** បានដល់ ក្នុងការឆាន់អាហារ មានដុំបាយដែលធ្លាក់ទៅក្នុង

បាត្រជាដើម ។

ពាក្យថា **ចិតេ** បានដល់ ការឆាន់មានយាគូជាដើម ។

ពាក្យថា **ខាយិតេ** បានដល់ ការខាំទំពាអាហាររឹងដែលធ្វើដោយម្សៅជាដើម ។

ពាក្យថា **សាយិតេ** បានដល់ ការលិទ្ធភ្លក់រសទឹកឃ្មុំ និងទឹកអំពៅជាដើម ។

ក្នុងការឆាន់អាហារជាដើមនោះ សូម្បីប្រយោជន៍ទាំង ៨ យ៉ាង ដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកដោយន័យថា **"យើងនឹងមិនឆាន់ដើម្បីលេង"** ជាដើម ឈ្មោះថា ប្រយោជន៍ និងគប្បីជ្រាប **សាត្ថកសម្បជញ្ញៈ** ដោយអំណាចនៃការឆាន់ដែលជាប្រយោជន៍នោះថា ៖

ក៏បណ្ដាអាហារទាំងឡាយ ដែលអាក្រក់ ប្រណីត មានរសល្វីង និងរសផ្អែមជាដើម ភិក្ខុណាមិនមានសេចក្ដីសប្បាយ ដោយអាហារប្រភេទណា, អាហារនោះចាត់ជាអសប្បាយដល់លោក ។ មួយទៀត អាហារណាដែលលោកបានមកដោយអំណាចនៃការទាយនិមិត្ត (គ្រូហោរ) ជាដើម, ភិក្ខុឆាន់អាហារណា អកុសលធម៌ទាំងឡាយរមែងកើត, កុសលធម៌ទាំងឡាយរមែងសាបសូន្យទៅ, អាហារនោះៗ ជាអសប្បាយដោយពិត; អាហារដែលផ្ទុយគ្នានឹងអាហារដែលពោលមក ជាសប្បាយ ។ ក្នុងទីនេះគប្បីជ្រាបថា **ជាសប្បាយសម្បជញ្ញៈ** ដោយអំណាចនៃការឆាន់អាហារ ដែលជាសប្បាយនោះនុ៎ះឯង, គប្បីជ្រាបថា **ជាគោចរសម្បជញ្ញៈ** ដោយអំណាចនៃការមិនវៀរចាកកម្មដ្ឋាន គឺ ៖

ឈ្មោះថា តួខ្លួន (អត្តា) អ្វីៗ ខាងក្នុង ជាអ្នកបរិភោគអាហារមិនមានទេ, ព្រោះថា ឈ្មោះថា ការចាប់បាត្ររមែងមាន ព្រោះការផ្សាយទៅនៃ**វាយោធាតុ** ដែលជាការធ្វើរបស់ចិត្ត ។ ឈ្មោះថា ការលូកដៃចុះក្នុងបាត្រ រមែងមាន ព្រោះការផ្សាយទៅនៃវាយោធាតុ ដែលជាការធ្វើរបស់ចិត្តនោះឯង ។ ការធ្វើពំនូតបាយ ការលើកពំនូតបាយចូលមាត់ ការបើកមាត់ ក៏រមែងមាន ព្រោះការផ្សាយទៅនៃវាយោធាតុដែលជាការធ្វើរបស់ចិត្ត ។ មិនមានអ្នកណាបើកថ្គាមដោយកូនសោ ឬដោយគ្រឿងយន្តអ្វីៗ ព្រោះការផ្សាយទៅរបស់វាយោធាតុដែលមានចិត្តជាសមុដ្ឋាននោះឯង ទើបដាក់ពំនូតបាយក្នុងមាត់បាន, តពីនោះ ធ្មេញខាងលើ ក៏ធ្វើនាទីឱ្យសម្រេចដូចអង្រែ, ធ្មេញខាងក្រោម ក៏ញ៉ាំងនាទីឱ្យសម្រេចដូចត្បាល់, ទាំងអណ្តាត ក៏ធ្វើនាទីឱ្យសម្រេចបានដូចដៃ ។ ទឹកមាត់រាវត្រង់ចុងអណ្តាត ទឹកមាត់ខាប់ត្រង់គល់អណ្តាត រមែងច្របូកច្របល់នឹងអាហារក្នុងទីនោះៗ ដោយប្រការដូច្នេះ, ទើបពំនូតបាយនោះប្រព្រឹត្តទៅក្នុងត្បាល់ គឺធ្មេញខាងក្រោមផ្សើមដោយទឹកមាត់ បំបែកល្អិតហើយដោយអង្រែ គឺធ្មេញខាងលើ ឈ្មោះថា អ្នកណាៗ ដាក់ពំនូតបាយទៅខាងក្នុងដោយស្លាបព្រា ឬវែក មិនមានទេ ។ វាយោធាតុប៉ុណ្ណោះ រមែងឱ្យអាហារចូលទៅខាងក្នុង; ឈ្មោះថា អ្នកណាៗ ឱ្យពំនូតបាយដែលចូលទៅហើយៗ ឱ្យតាំងនៅ ធ្វើឱ្យក្លាយទៅកាន់សភាពជាកាក ក៏មិនមាន, ពំនូតបាយនោះ រមែងតាំងនៅបាន ដោយអំណាចនៃវាយោធាតុប៉ុណ្ណោះ ។ អ្នកណាៗ ឈ្មោះថា ធ្វើជើងក្រានបង្កាត់ភ្លើងដាំបាយយ៉ាងនោះក៏មិនមាន, តែជោធាតុ

នោះឯង រមែងញ៉ាំងអាហារនោះៗ ឱ្យឆ្អិន ។ ឈ្មោះថា អ្នកណាៗ នាំអាហារដែលឆ្អិន ហើយៗ ចេញទៅដោយកំណាត់ឈើ ឬចុងឈើច្រត់ ក៏មិនមាន, វាយោធាតុនោះឯង រមែងនាំចេញទៅ ដោយប្រការដូច្នេះ ទើបពោលបានថា ៖

**វាយោធាតុ** រមែងនាំអាហារនោះឱ្យចូលទៅខាងក្នុង ទាំងមិនឱ្យចូលទៅក៏បាន រមែងទ្រទ្រង់អាហារនោះទុក រមែងឱ្យឃ្លាតកម្រើក រមែងកម្ទេច រមែងឱ្យស្ងួត រមែងនាំចេញទៅខាងក្រៅ ។

**បឋវីធាតុ** រមែងជួយឱ្យអាហារតាំងនៅ ឱ្យឃ្លាតកម្រើក ឱ្យល្អិតខ្ទេច ឱ្យស្ងួត រមែងនាំចេញ ។

**អាបោធាតុ** ធ្វើអាហារឱ្យល្អិត ធ្វើឱ្យទទឹកសើម រមែងរក្សាអាហារនោះ ។

**តេជោធាតុ** រមែងឱ្យអាហារដែលចូលទៅខាងក្នុងពោះវៀនឆ្អិន ។

**អាកាសធាតុ** រមែងជាផ្លូវនៃអាហារចុះទៅ ។

**វិញ្ញាណធាតុ** អាស្រ័យការប្រកបសេចក្តីព្យាយាមដោយប្រពៃ ក្នុងទីនោះៗ ហើយ បរិភោគអាហារ ។

ក្នុងពាក្យថា **ការឆាន់** ជាដើមនេះ គប្បីជ្រាបថា ឈ្មោះថា **អសម្មោហសម្បជញ្ញៈ** ដោយអំណាចនៃការពិចារណាសេចក្តីប្រព្រឹត្តទៅយ៉ាងនេះ ។

ម្យ៉ាងទៀត ក្នុងទីនេះ គប្បីជ្រាបថា ឈ្មោះថា **អសម្មោហសម្បជញ្ញៈ** សូម្បីដោយការពិចារណាភាពជារបស់បដិកូល ១០ យ៉ាង គឺ ៖

**១. គមនតោ** ដោយការដើរទៅ

**២. បរិយេសនតោ** ដោយការស្វែងរក

**៣. បរិភោគតោ** ដោយការបរិភោគ

**៤. អាសយតោ** ដោយទីអាស្រ័យ ( អាហារដែលចូលទៅខាងក្នុងនោះ រមែងប្រឡាក់ដោយរបស់ ៤ យ៉ាង យ៉ាងណាមួយ គឺ ប្រឡាក់ដោយទឹកប្រមាត់ខ្លះ ដោយស្លេស្មខ្លះ ដោយខ្ទុះខ្លះ ដោយឈាមខ្លះ មិនបានវៀរអ្នកណាត្រឹមតែម្នាក់ឡើយ) ។

**៥. និធានតោ** ដោយការសន្សំ ( ក្រពះអាហារ គឺកាលប្រឡាក់ដោយរបស់ ៤ យ៉ាងហើយ ក៏ចុះទៅនៅត្រង់ទីរបស់ក្រពះអាហារ ដែលដូចជារណ្ដៅមូត្រ និងលាមក) ។

**៦. អបរិបក្កតោ** ដោយនៅជារបស់មិនរលួយ

**៧. បរិបក្កតោ** ដោយជារបស់ដែលរលួយហើយ

**៨. ផលតោ** ដោយជាផល (សំដៅដល់អាហារដែលរលួយហើយ ក៏បញ្ចេញទៅជាសក់ និងរោមជាដើម, ចំណែកដែលរលួយមិនល្អ ក៏បង្កឱ្យកើតរោគ រាប់រយប្រភេទ ។

**៩. និស្សន្ទតោ** ដោយការហូរចេញ

**១០. សម្មក្ខនតោ** ដោយការប្រឡាក់ប្រឡូស ។

ចំណែកពាក្យពិស្ដារក្នុងទីនេះ បណ្ឌិតគប្បីជ្រាប និងសិក្សា ក្នុងគម្ពីរវិសុទ្ធិមគ្គ

ដែលពោលអំពីនិទ្ទេសនៃអាហារបដិកូលសញ្ញានោះចុះ[២៦] ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **ឧច្ចារបស្សាវកម្មេ** តទៅ ៖

ពាក្យថា **ឧច្ចារបស្សាវកម្មេ** បានដល់ ការបន្ទោបង់ឧច្ចារៈ និងបស្សាវៈ ។

ក្នុងទីនេះ កាលបុគ្គលណា មិនធ្វើការបន្ទោបង់ឧច្ចារៈ និងបស្សាវៈ ក្នុងវេលាដែលគួរហើយ ញើសទាំងឡាយរមែងហូរចេញពីសរីរៈ, ភ្នែកទាំងពីរចេញទឹក, ចិត្តមិនតាំងមាំ, រោគផ្សេងៗ រមែងកើតឡើង ។ តែកាលធ្វើការបន្ទោបង់តាមប្រក្រតីហើយ ហេតុ ទាំងពួងនោះ រមែងមិនកើតឡើងដូច្នោះទេ ។ នេះឈ្មោះថា ជាប្រយោជន៍ក្នុងការបន្ទោបង់ឧច្ចារៈ និងបស្សាវៈ ។ គប្បីជ្រាបថា ឈ្មោះថា **ជាសាត្ថកសម្បជញ្ញៈ** ដោយអំណាចនៃការបន្ទោបង់ឧច្ចារៈ និងបស្សាវៈនោះ ។

មួយទៀត កាលធ្វើការបន្ទោបង់ឧច្ចារៈ និងបស្សាវៈ ក្នុងទីដែលមិនគួរ រមែងត្រូវទោសតាមផ្នែកព្រះវិន័យ, រមែងសាបសូន្យយស រមែងជាអន្តរាយចំពោះជីវិតក៏បាន ។ កាលធ្វើការបន្ទោបង់ក្នុងទីដែលសមគួរ ហេតុទាំងអស់នោះ រមែងមិនកើតឡើង ព្រោះហេតុដូច្នោះ សេចក្តីនេះ ទើបឈ្មោះថា ជាសប្បាយ ។ ក្នុងពាក្យថា **ឧច្ចារបស្សាវកម្មេ** នេះ ឈ្មោះថា **ជាសប្បាយសម្បជញ្ញៈ** ដោយអំណាចនៃការសប្បាយនោះ ។ គប្បីជ្រាបថា **ជាគោចរសម្បជញ្ញៈ** ដោយអំណាចនៃការមិនវៀរ

---

[២៦] វិសុទ្ធិ. ២ ។

ចាកកម្មដ្ឋាននោះឯង គឺ ៖

ឈ្មោះថា អត្តាណា១ ក្នុងការបន្ទោបង់ឧច្ចារៈ និងបស្សាវៈមិនមានទេ, ក៏ព្រោះការផ្សាយទៅនៃ **វាយោធាតុ** ដែលមានចិត្តជាសមុដ្ឋាននោះឯង ការបន្ទោបង់ឧច្ចារៈ និងបស្សាវៈ ទើបមានបាន ។ ដូចយ៉ាងថា គ្រាកាលក្បាលបូសទុំជោរហើយ ព្រោះការបែកទៅនៃបូសនោះ ខ្ទុះ និងឈាមទើបហូរចេញ ដោយមិនប្រាថ្នា នឹងឱ្យវាចេញ វាក៏ចេញយ៉ាងណា, ឬដូចយ៉ាងថា ទឹករមែងហូរធ្លាក់ពីភាជនៈរបស់ទឹក ដែលបុគ្គលចាក់ឱ្យហៀរហើយ ដោយមិនប្រាថ្នានឹងឱ្យទឹកនោះចេញយ៉ាងណា, ឧច្ចារៈក្នុងក្រពះអាហារ ឬបស្សាវៈក្នុងតម្រងនោម ក៏យ៉ាងនោះដែរ, ឧច្ចារៈ និងបស្សាវៈ ដែលសន្សំទុកហើយ ត្រូវបៀតបៀនដោយកម្លាំងនៃខ្យល់ក្នុងក្រពះ និងតម្រងនោម ក៏រមែងចេញទៅ សូម្បីមិនគប្បីប្រាថ្នានឹងឱ្យចេញក៏ដោយ វាត្រូវតែចេញទៅដោយអំណាចនៃ **វាយោធាតុ** ។ ក៏ឧច្ចារៈ និងបស្សាវៈនេះឯង មិនមែនជារបស់ភិក្ខុនោះទេ ទាំងមិនមែនរបស់អ្នកដទៃ ។ ឧច្ចារៈ និងបស្សាវៈនោះ ជារបស់បដិកូលដែលហូរចេញពីសរីរៈតាមធម្មតាប៉ុណ្ណោះ ។ **ប្រៀបដូចអ្វីទៅ ? ប្រៀបដូចបុគ្គលចាក់ទឹកចាស់ពីផ្ទាំងទឹក ទឹកចាស់នោះ ក៏មិនមែនជារបស់ផ្ទាំងទឹកនោះ ទាំងមិនមែនជារបស់អ្នកដទៃ, ត្រឹមតែដំណើរទៅតាមហេតុបច្ច័យ** យ៉ាងណា, ក្នុងសេចក្តីនេះ បណ្ឌិតគប្បីជ្រាបថា **ជាអសម្មោហសម្បជញ្ញៈ** ដោយអំណាចនៃការត្រិះរិះពិចារណាតាមសេចក្តីប្រព្រឹត្តទៅដូច្នោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **គតេ** ជាដើម ៖

ពាក្យថា **គតេ** បានដល់ ក្នុងការដើរ ។

ពាក្យថា **ឋិតេ** បានដល់ ក្នុងការឈរ ។

ពាក្យថា **និសិន្នេ** បានដល់ ក្នុងការអង្គុយ ។

ពាក្យថា **សុត្តេ** បានដល់ ក្នុងការដេក ។ (ពាក្យថា **សុត្តេ** = ក្នុងការដេកនេះ ទីនេះលោកអធិប្បាយថា បានដល់ ក្នុងការដេក លោកប្រើពាក្យថា **សយនេ**) ។

ក្នុងការដើរជាដើមនោះ បណ្ឌិតគប្បីជ្រាបការធ្វើសម្បជញ្ញៈ ដោយន័យដែលពោលទុកក្នុងការឈានទៅខាងមុខជាដើម ។

**ន័យមួយទៀត គប្បីជ្រាបក្នុងការដើរជាដើមដូចតទៅនេះ** ៖

សេចក្ដីថា ភិក្ខុ ២ រូប មួយរូបកាលលោកដើរទៅ ក៏គិតយ៉ាងដទៃ ត្រិះរិះយ៉ាងដទៃ, ភិក្ខុមួយរូបមិនលះបង់កម្មដ្ឋានហើយទៅ, ភិក្ខុមួយរូបទៀត ទៅដោយទំនងដូចតែគ្នា ការឈរក្ដី, ការអង្គុយក្ដី, ការដេកក្ដី ក៏គិតយ៉ាងដទៃ ត្រិះរិះយ៉ាងដទៃ, រមែងឈរ អង្គុយ និងដេកយ៉ាងនោះ ។ តែអាចារ្យពួកខ្លះ អធិប្បាយថា កម្មដ្ឋាននៅមិនប្រាកដដោយការចង្រ្កមមានប្រមាណប៉ុណ្ណេះ ។ ពិតមែន ភិក្ខុណាឈានចុះកាន់ទីចង្រ្កម ឈានទៅដរាបដល់ទីបំផុតនៃការចង្រ្កម ក៏កំណត់កម្មដ្ឋានថា ៖

“រូបធម៌ និងអរូបធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងទីបំផុតនៃការចង្រ្កមផ្លូវទិសខាងកើត រមែងរលត់ទៅក្នុងទីនោះឯង ដែលនឹងមិនដល់ទីបំផុតនៃទីចង្រ្កមផ្លូវទិស

ខាងលិចមែនពិត, រូបធម៌ និងអរូបធម៌ទាំងឡាយសូម្បីប្រព្រឹត្តទៅក្នុងទីបំផុតក្នុងផ្លូវទិសខាងលិច ក៏រមែងរលត់ទៅក្នុងទីនោះឯង ដែលនឹងមិនដល់ទីបំផុតនៃទីចង្ក្រមផ្លូវទិសខាងកើតនោះឯង, រូបធម៌ និងអរូបធម៌ទាំងឡាយដែលប្រព្រឹត្តទៅ ត្រង់កណ្ដាលទីចង្ក្រម ក៏រមែងរលត់ទៅក្នុងទីនោះឯង ដែលមិនទាន់ដល់ទីបំផុតទាំងពីរ (ខាងមុខ និងខាងក្រោយ) រមែងរលត់ទៅត្រង់កណ្ដាលទីចង្ក្រមនោះឯង ។ រូបធម៌ និងអរូបធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងការឈានទៅ រមែងរលត់ទៅក្នុងការឈានទៅនោះឯង គឺមិនទាន់ដល់ការឈរឡើយ ។ រូបធម៌ និងអរូបធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងការឈរនោះ ក៏រលត់ក្នុងការឈរនោះឯង គឺមិនទាន់ដល់ការអង្គុយឡើយ ។ ល ។ រមែងរលត់ក្នុងការអង្គុយនោះឯង គឺមិនទាន់ដល់ការដេកឡើយ” កាលលោកកំណត់យ៉ាងនេះនោះឯង ចិត្តរមែងធ្លាក់ចុះកាន់ភវង្គ, កាលឱ្យកម្មដ្ឋានតាំងឡើងហើយ ក៏កាន់យកកម្មដ្ឋាននោះឯង ឱ្យតាំងនៅតទៅ ។

ភិក្ខុនេះ ឈ្មោះថា **មានប្រក្រតីធ្វើសម្បជញ្ញៈ** ក្នុងពាក្យថា **ក្នុងការដើរ** ជាដើម ។

ចំណែកកម្មដ្ឋាន **ក្នុងការដេក** មិនបានច្បាស់ឡើយ, កម្មដ្ឋានដែលមិនច្បាស់ភិក្ខុមិនគួរធ្វើ ។ ព្រោះហេតុនោះ ភិក្ខុអាចត្រឹមណា ក៏កំណត់ឈានទៅត្រឹមនោះ កំណត់ឈរហើយ អង្គុយហើយត្រឹមនោះ **កាលដេក** កំណត់យ៉ាងនេះហើយ ទើបដេក គឺ ៖

កាយក៏មិនមានចេតនា គ្រែក៏មិនមានចេតនា ។ កាយរមែងមិនដឹងថា "យើងដេកលើគ្រែ" , សូម្បីគ្រែនោះ ក៏មិនដឹងថា កាយដេកលើយើង" , កាលកំណត់យ៉ាងនេះថា កាយមិនមានចេតនា ដេកហើយលើគ្រែដែលមិនមានចេតនាដូច្នេះ កំណត់ញយ១ រមែងធ្លាក់ចុះកាន់ភវង្គ ។ កាលភ្ញាក់ ក៏កាន់យកកម្មដ្ឋាននោះឯង រមែងភ្ញាក់ ។ ភិក្ខុនេះ ឈ្មោះថា មានប្រក្រតីធ្វើសម្បជញ្ញៈក្នុងការដេក ។

ពាក្យថា **ជាគរិតេ** = ក្នុងការភ្ញាក់ ។ ក្នុងសេចក្ដីនេះ កាលភវង្គចិត្ត (ក្នុងការដេក) នៅប្រព្រឹត្តទៅ ឈ្មោះថា ការភ្ញាក់ រមែងមិនមាន, ភិក្ខុកំណត់ថា កាលចិត្តគួរដល់ការប្រព្រឹត្តទៅ ការភ្ញាក់រមែងមាន ដូច្នេះ ឈ្មោះថា មានប្រក្រតីធ្វើសម្បជញ្ញៈក្នុងការភ្ញាក់ ។ មួយទៀត ភិក្ខុបែងចែកវេលាយប់ និងវេលាថ្ងៃ ចេញជា ៦ ចំណែក សូម្បីយកចិត្តទុកដាក់ក្នុង ៥ ចំណែក ក៏ឈ្មោះថា មានប្រក្រតីធ្វើសម្បជញ្ញៈក្នុងការភ្ញាក់ ។

ពាក្យថា **ភាសិតេ** = ក្នុងការនិយាយ ។ ក្នុងពាក្យនេះ កាលឧបាទាយរូប គឺ **សទ្ទាយតនៈ**មិនមាន ឈ្មោះថា ការនិយាយទៅមិនមាន, ភិក្ខុកំណត់សទ្ទាយតនៈដែលប្រព្រឹត្តទៅ ឈ្មោះថា មានប្រក្រតីធ្វើសម្បជញ្ញៈក្នុងការនិយាយ ។ ភិក្ខុសម្ដែងធម៌ដោយវិមុត្តាយតនសីសៈក្ដី ពោលពាក្យដែលអាស្រ័យរឿងកថាវត្ថុ ១០[*] យ៉ាង ដើម្បី

---

[*] គឺអប្បិច្ឆកថា សន្តុដ្ឋិកថា សល្លេខកថា អសំសដ្ឋកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា និងវិមុត្តិញ្ញាណទស្សនកថា ។

លះតិរច្ឆានកថា ៣២ យ៉ាងក្តី ឈ្មោះថា មានប្រក្រតីធ្វើសម្បជញ្ញៈក្នុងការនិយាយ ។

ពាក្យថា **តុណ្ហីភាវេ** បានដល់ ការស្ងៀម គឺការមិននិយាយ ។ ក្នុងសេចក្តីនេះ កាលឧបាទាយរូប គឺសទ្ទាយតនៈនៅប្រព្រឹត្តទៅនោះ ឈ្មោះថា ភាពជាអ្នកស្ងៀម ក៏មិនបានមាន ។ ភិក្ខុកំណត់ការប្រព្រឹត្តទៅនៃសទ្ទាយតនៈនោះ ឈ្មោះថា មានប្រក្រតីធ្វើសម្បជញ្ញៈ ក្នុងភាពជាអ្នកស្ងៀម ។ ក្នុងអារម្មណ៍នៃកម្មដ្ឋាន ៣៨ ប្រការនោះ (វៀរអាកាសកសិណ និងអាលោកកសិណ) ភិក្ខុកាន់យកកម្មដ្ឋាន តាមសេចក្តីពេញចិត្តអង្គុយក្តី ចូលទុតិយជ្ឈានក្តី ឈ្មោះថា ជាអ្នកមានប្រក្រតីធ្វើសម្បជញ្ញៈក្នុងភាពជាអ្នកស្ងៀម ។

ម្យ៉ាងទៀត ក្នុងនិទ្ទេសនៃឈានវិភង្គនេះ ឥរិយាបថមួយមកហើយក្នុងឋានទាំងពីរ (លោកសម្តែងទុកពីរយ៉ាង) គឺ ៖

ក្នុងពាក្យថា **អភិក្កន្តេ** = កាលឈានទៅខាងមុខ, **បដិក្កន្តេ** = កាលថយត្រឡប់មកខាងក្រោយ, ដែលលោកពោលទុកនោះ បណ្ឌិតគប្បីជ្រាបថា លោកពោលសំដៅយកភិក្ខុអ្នកដើរផ្លូវទៅកាន់ភូមិដើម្បីភិក្ខាហារ និងទាំងការដើរត្រឡប់មក ដោយអំណាចនៃការដើរផ្លូវឆ្ងាយ ។ ចំណែកក្នុងពាក្យថា **គតេ** (ក្នុងការដើរ) **ឋិតេ** (ក្នុងការឈរ) **និសិន្នេ** (ក្នុងការអង្គុយ) គប្បីជ្រាបថា លោកពោលដោយអំណាចនៃឥរិយាបថ ៤ **គឺក្នុងការឈានទៅបន្តិចៗ សន្សឹមៗ ក្នុងវិហារ** ។

បណ្តាពាក្យទាំងនោះ ពាក្យថា “**កថមា សតិ** = សតិតើដូចម្តេច ?” ជាដើម មានសេចក្តីងាយទាំងអស់ ។

**សួរថា** ព្រះមានព្រះភាគទ្រង់សម្តែងប្រយោជន៍អ្វី ដោយពាក្យថា **សោ ទិវិត្តំ** = ភិក្ខុនោះអាស្រ័យសេនាសនៈដ៏ស្ងាត់ដូច្នេះ ?

ឆ្លើយថា ទ្រង់សម្តែងសេនាសនៈដែលជាទីសប្បាយ ជាវិធីនៃការប្រកបសេចក្តីព្យាយាម ដែលជាទីចូលទៅអង្គុយរបស់ភិក្ខុនោះ ។

ពិតមែន គុណទាំងឡាយមានប្រមាណប៉ុណ្ណេះ របស់ភិក្ខុណាមាននៅខាងក្នុង (ខ្លួន), ភិក្ខុនោះសមគួរនៅព្រៃ ។ តែបើគុណនោះ មិនមានដល់ភិក្ខុណា, ភិក្ខុនោះក៏មិនគួរនៅព្រៃ ។ ព្រោះថា ការនៅព្រៃរបស់ភិក្ខុដូច្នេះ រមែងដូចនឹងការនៅក្នុងដងព្រៃរបស់សត្វកាចទាំងឡាយ មានស្វាខ្មៅ ខ្លាឃ្មុំ ខ្លាដំបង ខ្លារខិន និងម្រឹគជាដើម ។

**សួរថា** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះភិក្ខុនោះ ចូលទៅអាស្រ័យនៅតាមសេចក្តីប្រាថ្នា ។ ព្រោះថា ប្រយោជន៍អ្វីៗ ដែលមានការនៅព្រៃជាហេតុរបស់ភិក្ខុនោះមិនមាន លោករមែងប្រទូសរ៉ាយការនៅព្រៃផង និងប្រទូសរ៉ាយព្រៃទាំងឡាយផង, ទាំងរមែងញ៉ាំងសេចក្តីមិនជ្រះថ្លាឱ្យកើតឡើងក្នុងព្រះពុទ្ធសាសនា ។ ចំណែកភិក្ខុណា មានគុណមានប្រមាណប៉ុណ្ណេះនៅខាងក្នុង, ភិក្ខុនោះសមគួរនៅព្រៃ ។ ព្រោះថា ភិក្ខុនោះ អាស្រ័យការនៅព្រៃ ផ្តើមតាំងវិបស្សនាហើយកាន់យកព្រះអរហត្ត រមែងបរិនិព្វាន, ឈ្មោះថា រមែងធ្វើព្រៃទាំងអស់ឱ្យល្អ, រមែងធ្វើសីសៈនៃព្រៃទាំងឡាយឱ្យស្អាត, រមែងធ្វើពាក្យទូន្មានរបស់ព្រះជិនស្រីទាំងអស់ឱ្យផ្សាយទៅ ។ ព្រោះហេតុនោះ ព្រះសាស្តាកាលទ្រង់

សម្តែងសេនាសនៈ ដែលជាទីសប្បាយ ដែលជាវិថិនៃសេចក្តីព្យាយាម ដែលជាទីចូលទៅ អង្គុយរបស់ភិក្ខុដូច្នេះ ទើបត្រាស់ពាក្យជាដើមថា **សោ វិវិត្តំ សេនាសនំ ភជតិ** = ភិក្ខុនោះអាស្រ័យសេនាសនៈដ៏ស្ងាត់ ។

បណ្តាពាក្យទាំងនោះ ពាក្យថា **វិវិត្តំ** បានដល់ ជាសេនាសនៈទំនេរ ទទេ មានសំឡេងតិច គឺមានសំឡេងគឹកកងតិច; ក៏ដើម្បីសម្តែងសេចក្តីនោះនុ៎ះឯង ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា **តញ្ច អនាកិណ្ណំ** ជាដើម ។ បណ្តាពាក្យទាំងនោះ ពាក្យថា **អនាកិណ្ណំ** បានដល់ មិនរឹករវរហើយ គឺមិនត្រូវបៀតបៀន ។ ក្នុងទីនេះ ការនៅអាស្រ័យភ្នំ អាស្រ័យព្រៃ អាស្រ័យទន្លេ ដោយជុំវិញប្រមាណមួយគាវុតក្តី កន្លះយោជន៍ក្តី នៃសេនាសនៈណា ទាំងអ្នកណា១ មិនអាចដើម្បីចូលទៅក្នុងវេលាដែលមិនសមគួរ, សេនាសនៈនេះ ឈ្មោះថា មិនរឹករវរហើយសូម្បីក្នុងទីជិត ។ សេនាសនៈណា ឆ្ងាយមានប្រមាណកន្លះយោជន៍ ឬប្រមាណមួយយោជន៍, សេនាសនៈនោះ ឈ្មោះថា មិនរឹករវរក្នុងទីឆ្ងាយ ។

ភិក្ខុរមែងដេក និងរមែងអង្គុយក្នុងទីនោះ ព្រោះហេតុនោះ ទីនោះ ទើបឈ្មោះថា **សេនាសនៈរបស់ភិក្ខុ** ។ ដើម្បីសម្តែងប្រភេទនៃសេនាសនៈនោះ ទើបព្រះមានព្រះ ភាគត្រាស់ពាក្យថា **មញ្ចោ** = គ្រែ, **បីឋំ** = តាំងជាដើម ។

បណ្តាពាក្យនោះ ពាក្យថា **មញ្ចោ** បានដល់ គ្រែ ៤ ប្រភេទ គឺ

**១. មសារកោ** គ្រែមានមេស៊ិកចូលទៅក្នុងជើង

**២. ពុន្ទិកាពទ្ធោ** គ្រែមានមេជាប់ជាមួយនឹងជើង

**៣. កុឡីរបាទកោ** គ្រែមានជើងដូចជើងក្ដាម

**៤. អាហច្ចបាទកោ** គ្រែមានជើងទល់មេគ្រែដែលដោះចេញបាន ។

ឯតាំងវិញ ក៏ដូចគ្នាដែរ ។

ពាក្យថា **ភិសិ** បានដល់ ពូក ៥ ប្រភេទ គឺ

**១. ឧណ្ណាភិសិ** ពូកធ្វើដោយរោមសត្វ

**២. ចោឡភិសិ** ពូកធ្វើដោយកំណាត់សំពត់

**៣. វាកភិសិ** ពូកធ្វើដោយសំបកឈើ

**៤. បណ្ណភិសិ** ពូកធ្វើដោយស្លឹកឈើ

**៥. តិណភិសិ** ពូកធ្វើដោយស្មៅ ។

ខ្នើយកើយក្បាល ព្រះមានព្រះភាគត្រាស់ថា **សេនាសនៈ** គឺខ្នើយ ។ ខ្នើយនោះ ពោលអំពីខាងទទឹង មានប្រមាណមួយចំអាមបួនធ្នាប់ សមគួរ, ខាងបណ្ដោយប្រមាណសមគួរដល់ការទូលាយរបស់គ្រែ ។ ពាក្យថា “**វិហារោ** = សេនាសនៈ គឺវិហារ” បានដល់ សេនាសនៈដែលលោកសម្ដែងទុក គឺសេនាសនៈដែលជាទីសម្រាកក្នុងវេលាថ្ងៃ និងជាទីសម្រាកក្នុងវេលាយប់ ដែលជាស្ថានជុំវិញៗ បរិវេណ ។ ពាក្យថា “**អឌ្ឍយោគោ** = សេនាសនៈ គឺប្រាសាទត្រងិល” បានដល់ ផ្ទះមានរូបដូចគ្រុឌ ។ ពាក្យថា “**បសាទោ** = សេនាសនៈ គឺប្រាសាទ” បានដល់ ប្រាសាទវែងដែលគេធ្វើជា

កំពូល ២ (ឬជហ្វា ២); ពាក្យថា **“អឌ្ឍយោគោ** = សេនាសនៈ គឺបន្ទាយ” បានដល់ ទីសម្រាក នៅពិសេសមាន ៤- ៥ ជាន់ មានជញ្ជាំងមុខ ដែលគេបង្ករៀបដោយឥដ្ឋ ដើម្បីការពារ សត្រូវ មានព្រះរាជាអ្នកជាបរបក្ខ (សត្រូវ) គ្នាជាដើម ។ ពាក្យថា **“មាឡោ** = សេនាសនៈ គឺរោង” បានដល់ រោងមានរាងមូល ដូចនឹងរោងឆាន់អាហារ ។ ក្នុង អដ្ឋកថាព្រះវិន័យ លោកសម្ដែងថា ប្រាសាទ ៤ ជ្រុង សង្គ្រោះចូលក្នុងប្រាសាទមាន កំពូលតែមួយ ។ ពាក្យថា **“លេណំ** = សេនាសនៈ គឺទីពួន” បានដល់ សេនាសនៈ ដែលគេជីកភ្នំធ្វើ ឬសេនាសនៈដែលគេធ្វើខ្ទម ត្រង់ទីចំណែកខ្លះនៃញកភ្នំ ។ ពាក្យថា **“គុហា** = សេនាសនៈ គឺល្អាង” បានដល់ ក្នុងស្នាមបែកនៃផ្ទាំងថ្ម ឬក្នុងទីណាសមគួរ អុចប្រទីបទុក ទាំងពេលយប់ និងពេលថ្ងៃ ក្នុងទីនោះ ឈ្មោះថា ល្អាងនៃភ្នំ, ឬល្អាងនៃ ផែនដី ។ ពាក្យថា **“រុក្ខមូលំ** = សេនាសនៈ គឺគល់ឈើ” បានដល់ ខាងក្រោមដើម ឈើដែលគេព័ទ្ធរបងក្ដី មិនព័ទ្ធក្ដី ។ ពាក្យថា **“វេឡុគុម្ពោ** = សេនាសនៈ គឺគុម្ពឈើ” បានដល់ គុម្ពឫស្សី ឬគ្រៃជាដើម ដែលគេតាំងទុកដោយប្រាថ្នាថា “ភិក្ខុនឹងមក” ឬក៏ ក្នុងទីណា ពួកភិក្ខុរមែងប្រជុំគ្នា ឬថាទីណាជាកន្លែងប្រជុំរបស់ភិក្ខុនោះ ទីទាំងអស់នោះ ក៏ចាត់ជាសេនាសនៈ ។

ពាក្យថា **ភជតិ** បានដល់ ចូលដល់ ។ ក្នុងពាក្យថា **សម្ភជតិ** នោះ បានដល់ ជាអ្នកមិនអផ្សុក ដោយអំណាចនៃសេចក្ដីត្រេកអរក្រៃលែង ទើបឈ្មោះថា ចូលដល់ ដោយល្អ ។ បទថា **សេវតិ** បានដល់ រមែងសេពគប់ដោយអំណាចនៃការនៅអាស្រ័យ ។

បទថា **និសេវតិ** បានដល់ មិនអផ្សុកហើយ ចូលទៅនៅអាស្រ័យហើយ ឈ្មោះថា **សេព** ។ បទថា **សំសេវតិ** បានដល់ ការញុំាងសេនាសនវត្ត ឱ្យដល់ព្រម ឈ្មោះថា សេពដោយប្រពៃ ។

ឥឡូវនេះ ដើម្បីសម្តែងប្រភេទនៃបទថា **វិវិត្តំ** នោះ ទើបព្រះមានព្រះភាគ ផ្តើមពាក្យថា **អរញ្ញំ រុក្ខមូលំ** ជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អរញ្ញំ** ដូចតទៅនេះ ៖

ពោលដោយបរិយាយនៃព្រះវិន័យជាមុនសិន ពាក្យថា **ព្រៃ** លោកសំដៅយកស្ថានទីដែលវៀរចាកភូមិ និងឧបចារភូមិដែលនៅសល់ ហៅថា **ព្រៃ** [២៧] ។ ដោយបរិយាយនៃព្រះសូត្រ ពាក្យថា **ព្រៃ** បានដល់ ព្រៃដែលភិក្ខុអាស្រ័យនៅ គឺជាសេនាសនៈដែលនៅឆ្ងាយអំពីភូមិ ប្រមាណ ៥០០ ជួរធ្នូ (១.០០០ ម៉ែត្រ = ១ គីឡូម៉ែត្រ) ឈ្មោះថា **ព្រៃ** ។ ក៏សូម្បីព្រះវិន័យ និងព្រះសូត្រទាំងពីរ ឈ្មោះថា **បរិយាយទេសនា** (គឺព្រៃដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងដោយអម), ចំណែកព្រះអភិធម្ម ឈ្មោះថា **និប្បរិយាយទេសនា** (គឺព្រៃដែលទ្រង់សម្តែងដោយត្រង់) ។ ដើម្បីសម្តែងព្រៃ ដោយបរិយាយនៃព្រះអភិធម្ម ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **“និក្ខមិត្វា ពហិ ឥន្ទខីលំ ”** ។ អធិប្បាយថា បរិវេណក្រៅពីសសរខឿន ឈ្មោះថា

---

[២៧] វិនយ. ១។

ព្រៃ ។

ម្យ៉ាងទៀត បណ្តាសេនាសនៈទាំងឡាយ មានគល់ឈើជាដើម ឈ្មោះថា **គល់ឈើ** ព្រោះជាវត្ថុដែលបុគ្គលដឹងបានដោយងាយ តាមធម្មតា (ដោយហេតុនោះ) ទើបត្រាស់ថា **រុក្ខមូលំ** ជាដើម ។ ម្យ៉ាងទៀត បណ្តាសេនាសនៈទាំងឡាយ **គល់ឈើ** ដែលស្ងាត់ មានម្លប់ត្រជាក់យ៉ាងណានីមួយ ឈ្មោះថា **គល់ឈើ**។ ពាក្យថា **បព្វតំ** គឺភ្នំបានដល់ ថ្ម ។ ពិតមែន ក្នុងសេចក្តីនេះ ភិក្ខុធ្វើកិច្ចដោយទឹកក្នុងស្រះថ្មស្រេចហើយ អង្គុយសម្រាកនៅក្រោមម្លប់ឈើដ៏ត្រជាក់ ប៉ះខ្យល់ត្រជាក់ដែលផាត់មកអំពីទិសផ្សេងៗ ចិត្តរបស់លោករមែងស្ងប់ ។ វិនិច្ឆ័យក្នុងពាក្យថា **កន្ទរំ** = ទឹក, ព្រះភគវាត្រាស់ហៅថា **កំ** ។ **សួរថា** ប្រទេសនៃភ្នំនោះ ញែកចេញទៅដោយអ្វី ? ឆ្លើយថា ញែកចេញទៅដោយទឹក ។ អាចារ្យពួកខ្លះពោលថា ទីនោះជាទីចោតខ្លះ ថា ជាអាងទឹកខ្លះ ។ ពិតមែន ក្នុងទីនោះមានគ្រាប់ខ្សាច់ ដូចផ្ទាំងប្រាក់, ព្រៃស្តុកនោះ ដូចជាពិតានដែលសម្រេចហើយដោយកែវមណី, ទឹកដែលហូរទៅដូចគំនរកែវមណី, ភិក្ខុឈានចុះកាន់ញកភ្នំ ផឹកទឹកដែលគួរផឹក ធ្វើខ្លួនឱ្យត្រជាក់សប្បាយ ធ្វើគំនរខ្សាច់ឱ្យខ្ពស់ឡើង ចាត់ចែងសំពត់បង្សុកូលចីវរ ហើយអង្គុយធ្វើសមណធម៌ ចិត្តរបស់លោករមែងស្ងប់ ។

ពាក្យថា **"គិរិគុហំ** = ល្អាងក្នុងចន្លោះភ្នំ" គឺល្អាងក្នុងចន្លោះនៃភ្នំទាំងពីរ ឬថា ក្នុងភ្នំមួយមានចន្លោះធំ ដូចឧម្មង្គៈ (រូង) ។ លក្ខណៈនៃសុសាន (ព្រៃស្មសាន) ខ្ញុំពោល

ទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ[២៨] ។

ពាក្យថា **"វនបត្ថំ** = ព្រៃ" បានដល់ ស្ថានទីដែលក្រៅពីភូមិអ្នកស្រុក មិនមែនទីជិតខាងរបស់ពួកមនុស្ស គឺក្នុងទីមិនមានការភ្ជួរ និងការព្រោះសាប ។ ដោយហេតុនោះនុ៎ះឯង ទើបព្រះមានព្រះភាគត្រាស់ហៅសេនាសនៈដែលឆ្ងាយនេះថា **វន~បត្ថំ** ជាដើម ។ ម្យ៉ាងទៀត ព្រោះសេនាសនៈមានគល់ឈើជាដើម ព្រះអង្គទ្រង់ញែកចេញសម្ដែងសេនាសនៈដែលមិនមានសំឡេងរុកគួននេះទុកផ្សេងៗ, ព្រោះហេតុដូច្នោះបណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគមិនបានទ្រង់អធិប្បាយពាក្យនោះ តាមលំដាប់នៃបទ ដែលព្រះអង្គទ្រង់តាំងទុក, តែទ្រង់អធិប្បាយទុកក្នុងខាងក្រោយ នៃពាក្យទាំងពួងដូច្នេះ ។

ពាក្យថា **"អព្ភោកាសំ** = ទីវាល" គឺស្ថានទីដែលមិនមានកំបាំង ។ ក៏ភិក្ខុប្រាថ្នាក្នុងទីដូច្នោះ ត្រូវធ្វើឱ្យជាកុដិដោយចីវរហើយនៅចុះ ។

ពាក្យថា **"បលាលបុញ្ជំ"** បានដល់ គំនរចំបើង ។ ពិតមែន ភិក្ខុទាញចំបើងចេញពីគំនរចំបើងធំហើយ ធ្វើឱ្យជាទីនៅ ដូចញកភ្នំ និងល្អាង ។ សូម្បីភិក្ខុនឹងយកចំបើងដាក់ទុកលើគុម្ពឈើជាដើម ហើយអង្គុយខាងក្រោមធ្វើសមណធម៌ក៏បាន ។ ពាក្យនេះ លោកសំដៅយកសេនាសនៈ គឺគំនរចំបើងនោះឯង ។

---

[២៨] វិសុទ្ធិ. ១/( ធុតង្គនិទ្ទេស) ។

ក្នុងវិនបត្តនិទ្ទេស (និទ្ទេសពោលអំពីព្រៃស្តុក) ពាក្យថា **សលោមហដ្ឋានំ** បានដល់ ក្នុងទីណា កាលចូលទៅហើយ រោមបះ (ព្រឺរោម) ភ័យខ្លាច រន្ធត់ រមែងកើតឡើង, ក្នុងទីដូច្នេះ ឈ្មោះថា សេនាសនៈប្រកបដោយភាពគួរភ័យខ្លាច ។

ពាក្យថា **បរិយន្តានំ** បានដល់ ឈ្មោះថា សេនាសនៈដែលតាំងនៅចុងដែន ព្រោះជាសេនាសនៈឆ្ងាយ ។

ពាក្យថា **ន មនុស្សូបចារានំ** បានដល់ សេនាសនៈដែលតាំងនៅហួសទៅ គឺមិនមានពួកមនុស្សធ្វើការភ្ជួរ និងសាបព្រោះ ។

ពាក្យថា **ទុរភិសម្ភវានំ** បានដល់ សេនាសនៈដែលបុគ្គលមិនអាចដើម្បីនៅអាស្រ័យដោយសេចក្តីត្រេកអរពេញចិត្តក្នុងវិវេកបាន ។

ក្នុង**អប្បសទ្ទ**និទ្ទេសជាដើម ។ ពាក្យថា **អប្បសទ្ទំ** បានដល់ មានសំឡេងតិច (ស្ថានទីដែលមិនមានសំឡេងរុកកួន) ដោយសំដៅដល់សំឡេងនៃពាក្យនិយាយ ។

ពាក្យថា **អប្បនិគ្ឃោសំ** បានដល់ មានសំឡេងគឹកកងតិច (មិនមានសំឡេងទ្រហឹងអឹងកង) ដោយសំដៅដល់សំឡេងអឹងកងរបស់អ្នកស្រុក អ្នកនគរ; ក៏ព្រោះសូម្បីសព្ទទាំងពីរនេះ ដូចតែគ្នាដោយអត្ថនៃសព្ទ, ព្រោះហេតុនោះ ទើបព្រះមានព្រះ-ភាគត្រាស់ថា **"យទេវ តំ អប្បសទ្ទំ, តទេវ តំ អប្បនិគ្ឃោសំ"** ។

ពាក្យថា **វិជនវាតំ** បានដល់ វៀរចាកខ្យល់សរីរៈនៃជនអ្នកសញ្ចរមកខាងក្រោយ ។ ព្រះបាលីថា **"វិជវាតំ"** ដូច្នេះក៏មាន, អធិប្បាយថា វៀរហើយចាកការ

ពោលរបស់ជនអ្នកនៅខាងក្នុង ។ ក៏ព្រោះសេនាសនៈដែលមានសំឡេងតិចតួចតិចយ៉ាងណា, សេនាសនៈនោះនុ៎ះឯង វៀរចាកការសញ្ចររបស់ពួកជន និងចាកវាទៈរបស់ជន, ព្រោះហេតុនោះ ក្នុងនិទ្ទេសនៃព្រះបាលីនេះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា **"យទេវ តំ អប្បនិគ្ឃោសំ, តទេវ តំ វិជនវាតំ"** ។

ពាក្យថា **មនុស្សរាហសេយ្យកំ** បានដល់ ជាទីតាំងនៃការធ្វើសេចក្តីកំបាំងរបស់ពួកមនុស្ស ។ ក៏ព្រោះហេតុដែលសេនាសនៈនោះ វៀរចាកការសញ្ចររបស់ប្រជុំជន; ព្រោះហេតុនោះ ក្នុងនិទ្ទេសនៃព្រះបាលីនេះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា **"យទេវ តំ វិជនវាតំ, តទេវ តំ មនុស្សរាហសេយ្យកំ"** ។

ពាក្យថា **បដិសល្លានសារុប្បំ** បានដល់ ជាសេនាសនៈដែលសមគួរដល់វិវេក ។ ព្រោះសេនាសនៈនោះ ជាទីអាស្រ័យធ្វើសេចក្តីកំបាំងរបស់ពួកមនុស្ស ដោយការនិយមនោះឯងមាន, ព្រោះហេតុនោះ ក្នុងនិទ្ទេសនៃព្រះបាលីនេះ ទើបព្រះមានព្រះភាគត្រាស់ថា **"យទេវ តំ មនុស្សរាហសេយ្យកំ, តទេវ តំ បដិសល្លានសារុប្បំ"** ។

សេនាសនៈ គឺព្រៃ ខ្ញុំពោលហើយក្នុងនិទ្ទេសនៃពាក្យថា **អរញ្ញគតោ** ជាដើមនោះឯង ។ សេនាសនៈ គឺគល់ឈើ ក៏ដូចគ្នាដែរ ។ ចំណែកសេនាសនៈសូម្បីទាំងអស់ដែលនៅសល់ សង្គ្រោះដោយសុញ្ញាគារ ។

ពាក្យថា **"បល្លង្កំ អាភុជិត្វា** = អង្គុយពែនភ្នែន" បានដល់ ការអង្គុយពន្ធជើងដោយជុំវិញ ។

ពាក្យថា **ឧជុំ កាយំ បណិធាយ** បានដល់ តាំងសរីរៈផ្នែកខាងលើឱ្យត្រង់ គឺញុំាងទីតនៃសន្លាក់ឆ្អឹងខ្នង ១៨ សន្លាក់ ឱ្យប្រព្រឹត្តទៅតាមលំដាប់ ។ ពិតមែន កាលភិក្ខុនោះ អង្គុយយ៉ាងនេះ ស្បែក សាច់ និងសរសៃទាំងឡាយ រមែងមិនកោង; ពេលនោះ វេទនាយ៉ាងណារបស់លោកដែលគប្បីកើតឡើង ព្រោះការបង្អោនទៅនៃវត្ថុទាំងនោះ រមែងមិនកើតឡើង, កាលទុក្ខវេទនានោះមិនកើតឡើង ចិត្តរបស់លោករមែងជាធម្មជាតិស្ងប់, កម្មដ្ឋានរមែងមិនធ្លាក់ទៅ, រមែងចម្រើនឡើង គឺរមែងបន្ថែមឡើង ។ ក៏សូម្បីក្នុងពាក្យថា **ឧជុកោ ហោតិ កាយោ ឋិតោ បណិហិតោ** នេះ ព្រះមានព្រះភាគជាម្ចាស់ ក៏ត្រាស់សំដៅយកសេចក្តីនេះដូចគ្នា ។

ពាក្យថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** = តាំងសតិបែរមុខចំពោះកម្មដ្ឋាន ។ ម្យ៉ាងទៀត អធិប្បាយថា ធ្វើសតិក្នុងទីជិតមាត់ ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា **“សតិនេះ ដែលភិក្ខុចូលទៅតាំងទុកហើយ តាំងទុកល្អហើយត្រង់ចុងច្រមុះ** ឬថា **ត្រង់និមិត្តលើមាត់** (រឹមបបូរមាត់)” ។ ក៏ក្នុងពាក្យថា **មុខនិមិត្តំ** នេះ បណ្ឌិតគប្បីឃើញនូវប្រទេសត្រង់កណ្តាលនៃរឹមបបូរមាត់ខាងលើ, គឺថាខ្យល់នៃនាសិក (ច្រមុះ) រមែងខ្ទប់ក្នុងទីណា ។ ម្យ៉ាងទៀត ពាក្យថា **បរិ** បានដល់មានការកំណត់ជាអត្ថ ។ ពាក្យថា **មុខំ** មានការនាំចេញទៅជាអត្ថ ។ ពាក្យថា **សតិ** មានការតាំងមាំជាអត្ថ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា **“បរិមុខំ សតឹ”** ។

បណ្ឌិតគប្បីជ្រាបក្នុងសេចក្ដីនេះ សូម្បីដោយន័យដែលពោលហើយ ក្នុងបដិសម្ភិទា [២៩] ចុះ ។ សេចក្ដីសង្ខេប គប្បីជ្រាបក្នុងទីនេះថា **“ភិក្ខុសមគួរកំណត់ធ្វើសតិ”** ។

**អភិជ្ឈានិទ្ទេស** មានអត្ថងាយយល់ទាំងអស់ ។

**គប្បីជ្រាបការពណ៌នាដោយសង្ខេបក្នុងអភិជ្ឈានិទ្ទេស** ដូច្នេះ ៖

បទថា **“អភិជ្ឈំ លោកេ បហាយ** = លះអភិជ្ឈាក្នុងលោក” បានដល់ **លោក** ឈ្មោះថា ឧបាទានក្ខន្ធ ៥ ព្រោះអត្ថថា មានការសាបសូន្យ និងរលាយបាត់ទៅ ជាធម្មតា, ព្រោះហេតុនោះ ក្នុងសេចក្ដីនេះ គប្បីជ្រាបសេចក្ដីដូច្នេះថា លោកលះរាគៈគ្របសង្កត់កាមច្ឆន្ទៈ ក្នុងឧបាទានក្ខន្ធ ៥ ហើយ ។ ពាក្យថា **“វិគតាភិជ្ឈេន** = ចិត្តដែលប្រាសចាកអភិជ្ឈា” បានដល់ ឈ្មោះថា មានអភិជ្ឈាទៅប្រាសហើយ ព្រោះលះបង់បានហើយ ដោយវិក្ខម្ភនប្បហាន, អធិប្បាយថា មានអភិជ្ឈាទៅប្រាសហើយ ដូចចក្ខុវិញ្ញាណមិនបានឡើយ ។ ពាក្យថា **“អភិជ្ឈាយចិត្តំ បរិសោធេតិ** = ជម្រះចិត្តឱ្យបរិសុទ្ធចាកអភិជ្ឈា” បានដល់ ដោះចិត្តចេញពីអភិជ្ឈា ។ អធិប្បាយថា អភិជ្ឈានោះ រមែងដោះនូវចិត្តនោះ លុះដោះនូវចិត្តនោះហើយ រមែងមិនកាន់យកនូវចិត្តនោះទៀត ដោយប្រការណា, ភិក្ខុនោះរមែងធ្វើដោយប្រការនោះ ។ ក្នុងនិទ្ទេសនៃបទទាំងឡាយ

---

[២៩] ខុ. បដិ. ។

គប្បីជ្រាបសេចក្ដីយ៉ាងនេះថា កាលសេព ឈ្មោះថា **រមែងជម្រះនូវចិត្តនោះ**, កាលចម្រើន ឈ្មោះថា **រមែងញ៉ាំងចិត្តឱ្យហ្មត់ចត់**, កាលធ្វើឱ្យច្រើន ឈ្មោះថា **រមែងញ៉ាំងចិត្តឱ្យបរិសុទ្ធ**; សូម្បីក្នុងពាក្យថា **“មោចេតិ** = ឱ្យផុត” ជាដើម ក៏ន័យនេះដែរ ។ បណ្ឌិតគប្បីជ្រាបសេចក្ដីដោយន័យនេះឯង សូម្បីពាក្យទាំងឡាយ មានពាក្យថា **“ព្យាបាទបទោសំ បហាយ** = លះព្យាបាទ និងការប្រទូសរ៉ាយ” ជាដើម ។

ចិត្តព្យាបាទ រមែងលះប្រក្រតីភាវៈ ដោយធម្មជាតិនេះ ដូចនឹងនំកុម្មាសស្អុយជាដើម ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា **ព្យាបាទ** ។

ចិត្តណារមែងទម្លាយ ឬរមែងធ្វើឱ្យបាត់ ឬក៏រមែងវិនាសទៅ ព្រោះដល់ការប្រែប្រួល ព្រោះហេតុនោះ ចិត្តនោះ ទើបឈ្មោះថា **បទោសៈ** (គឺប្រទូសរ៉ាយ) ។

ពាក្យទាំងពីរនេះ ជាឈ្មោះរបស់**សេចក្ដីក្រោធមែនពិត** ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា **“យោ ព្យាបាទោ, សោ បទោសោ; យោ បទោសោ សោ ព្យាបាទោ** = សេចក្ដីព្យាបាទយ៉ាងនោះ ឈ្មោះថា ប្រទូសរ៉ាយ; សេចក្ដីប្រទូសរ៉ាយយ៉ាងនោះ ឈ្មោះថា ព្យាបាទ” ។ ក៏ព្រោះសព្ទនេះ លោកលើកឡើងសម្ដែងហើយ ដោយអំណាចនៃការសង្គ្រោះដល់សត្វទាំងពួង, ព្រោះហេតុនោះ ទើបព្រះអង្គមិនត្រាស់ត្រឹមតែប៉ុណ្ណេះថា **“សព្វបាណភូតហិតានុកម្បី”** ។ តែត្រាស់ថា **“អព្យាបន្នចិត្តោ”** ។

សេចក្ដីឈឺនៃចិត្ត ឈ្មោះថា **ថីនៈ**, សេចក្ដីឈឺនៃចេតសិក ឈ្មោះថា **មិទ្ធៈ**, ថិនៈផង មិទ្ធៈផង ឈ្មោះថា **ថីនមិទ្ធៈ** ។

ពីរបទថា **"សន្តា ហោន្តិ** = ស្ងប់" បានដល់ ធម៌ទាំងពីរ គឺថីនមិទ្ធៈនេះ ឈ្មោះថា ស្ងប់ចុះហើយ ព្រោះការស្ងប់ចុះដោយ**និរោធ** ។ ក្នុងទីនេះ លោកធ្វើការ ញែកពាក្យទុកដោយសំដៅយកថីនមិទ្ធៈនេះ ។

ពាក្យថា **"អាលោកសញ្ញី** = មានអាលោកសញ្ញា" បានដល់ អ្នកប្រកបដោយ សញ្ញាបរិសុទ្ធដែលមាននីវរណៈទៅប្រាសហើយ ដើម្បីអាចការចាំអាលោកៈដែលខ្លួន ឃើញហើយក្នុងវេលារាត្រីខ្លះ ក្នុងវេលាថ្ងៃខ្លះ ។

ពាក្យថា **"សតោ សម្បជានោ** = មានសតិសម្បជញ្ញៈ" បានដល់ អ្នកប្រកប ដោយសតិ និងញាណ ។ ពាក្យទាំងពីរនេះ លោកពោលហើយ ព្រោះជាធម៌មាន ឧបការៈដល់អាលោកសញ្ញា; ក៏ពាក្យថា **"ចត្តត្តា** = ព្រោះថីនមិទ្ធៈ... ដែលភិក្ខុនោះ លះហើយ" ជាដើម ក្នុងនិទ្ទេសបទនៃអាលោកសញ្ញា ដែលប្រាសចាកថីនមិទ្ធៈនោះ ជាវេវចនៈរបស់គ្នានឹងគ្នាមែនពិត ។

ក្នុងពាក្យថា **ចត្តត្តា** បានដល់ ជាហេតុរបស់អ្នកលះបង់ហើយ ។ សូម្បីក្នុងបទ ដែលនៅសល់ ក៏ន័យនេះដែរ ។ មួយទៀត ក្នុងពាក្យថា **ចត្តត្តា** នេះ ព្រះមានព្រះ-ភាគជាម្ចាស់ ត្រាស់ដោយអំណាចនៃការលះបង់ ដោយភាវៈរបស់ខ្លួន ។ ពាក្យថា **"វន្តត្តា** = ខ្ជាក់ហើយ" នេះ ត្រាស់ដោយអំណាចនៃការសម្ដែងនូវភាពជាអ្នកមិន

ប្រកាន់ ។ ពាក្យថា **"មុត្តត្តា** = បញ្ចេញហើយ" នេះ ត្រាស់ដោយអំណាចនៃការរួចផុតពីការបន្ត ។ ពាក្យថា **"ចហីនត្តា** = លះហើយ" នេះ ត្រាស់ដោយអំណាចនៃភាពជាអ្នកមិនមានទីជាទីតាំងក្នុងទីណា។ របស់អ្នករួចផុតហើយ ។ ពាក្យថា **"បដិ-និស្សជ្ជត្តា** = លះបង់ចោលហើយ" នេះ ត្រាស់ដោយអំណាចនៃការសម្តែងដល់ភិក្ខុអ្នកលះបង់នូវការធ្លាប់ប្រកាន់មកក្នុងកាលមុន, គឺឈ្មោះថា ភាពជាអ្នកលះបង់ហើយព្រោះរួចផុត ឬព្រោះគ្របសង្កត់ដោយអំណាចនៃភាវនា ។ ពាក្យថា **"ចហីនប្បដិ-និស្សជ្ជត្តា** = លះហើយ លះបង់ចោលហើយ" បានដល់ ការលះបង់ចោលដោយអំណាចនៃការគ្របសង្កត់, គឺរមែងមិនឱ្យការបន្តកើតឡើងញយ។ យ៉ាងណា, ឈ្មោះថា **បដិនិស្សជ្ជត្តា** ក៏ដូច្នោះដែរ ។ ពាក្យថា **"អាលោកា ហោតិ** = ពន្លឺ" បានដល់ មានរស្មីល្អ ។ ឈ្មោះថា **វិវដា** (បើកផ្សាយ) ព្រោះអត្ថថា មិនមានគ្រឿងការពារ ។ ឈ្មោះថា **បរិសុទ្ធិ** ព្រោះអត្ថថា មិនមានឧបក្កិលេស ។ ឈ្មោះថា **ផូរផង់** ព្រោះអត្ថថា បភស្សរៈ (ភ្លឺថ្លា) ។

អាការដែលមិនស្ងប់ ឈ្មោះថា **ឧទ្ធច្ចៈ** ក្នុងបទថា **ឧទ្ធច្ចកុក្កុច្ចំ** នេះ ។ សេចក្តីប្រព្រឹត្តខុសក្នុងវត្ថុ ឈ្មោះថា **កុក្កុច្ចៈ** ព្រោះភាពជាអ្នកមិនយល់ច្បាស់ ឬកាត់សេចក្តីក្នុងអារម្មណ៍ ។ សូម្បីក្នុងពាក្យថា **សន្តា ហោន្តិ** នេះ បណ្ឌិតគប្បីជ្រាបសេចក្តីផ្សេងគ្នានៃវាទៈ ដោយន័យមុននោះឯង ។

ពាក្យថា **"តិណ្ណវិចិកិច្ឆោ** = ជាអ្នកឆ្លងបានហើយនូវវិចិកិច្ឆា" បានដល់ ឆ្លង

ហើយ ឈានកន្លងហើយនូវវិចិកិច្ឆា ហើយតាំងនៅ ។ ពាក្យថា **តិណ្ណោ** សូម្បីក្នុងនិទ្ទេសនៃពាក្យថា **តិណ្ណវិចិកិច្ឆោ** នោះ ព្រះមានព្រះភាគជាម្ចាស់ ក៏ត្រាស់ដោយអំណាចនៃការសម្ដែងដល់សេចក្ដីមិនលិចចុះក្នុងវិចិកិច្ឆា ។ ពាក្យថា "**ឧត្តិណ្ណោ** = ឆ្លងផុតហើយ" នេះ ត្រាស់ហើយដោយអំណាចនៃការសម្ដែងដល់ការឈានកន្លងនៃវិចិ-កិច្ឆានោះ ។ ពាក្យថា "**និត្តិណ្ណោ** = ឆ្លងចេញហើយ" នេះ ត្រាស់ដោយអំណាចនៃភាវនា គឺដោយអំណាចនៃការសម្ដែងសភាពនៃវិចិកិច្ឆានោះ ដែលខ្លួនឆ្លងហើយ ព្រោះគ្របសង្កត់ឧបទ្ទវៈទាំងឡាយបាន ។ ពាក្យថា "**បារគតោ** = ដល់នូវត្រើយ" បានដល់ ដល់ត្រើយនៃវិចិកិច្ឆា គឺមិនមានវិចិកិច្ឆា ។ ពាក្យថា **បារមនុប្បត្តោ** បានដល់ ដល់ត្រើយនោះនុ៎ះឯង ដោយការប្រកបសេចក្ដីព្យាយាមភាវនារឿយៗ គឺសម្ដែងសេចក្ដីបដិបត្តិមានផលយ៉ាងនេះដល់ភិក្ខុ ។ ពាក្យថា **អកថំកថី** = មិនមានសេចក្ដីសង្ស័យដែលប្រព្រឹត្តទៅគ្រប់ហើយ យ៉ាងនេះថា "**នេះយ៉ាងណា នេះជាយ៉ាងណា**" ។ ពាក្យថា **កុសលេសុ ធម្មេសុ** បានដល់ ធម៌ទាំងឡាយដែលមិនមានទោស ។ ពាក្យថា **ន កង្ខតិ** បានដល់ មិនញុំាងសេចក្ដីសង្ស័យឱ្យកើតឡើងថា "ធម៌នេះ ជាកុសលឬហ្ន៎"។ ពាក្យថា "**ន វិចិកិច្ឆតិ** = មិនសង្ស័យ" បានដល់ មិនយ៉ាប់ មិនលំបាក ដើម្បីវិនិច្ឆ័យធម៌នោះ ដោយសភាវៈ ។ ពាក្យថា "**អកថំកថី ហោតិ** = មិនសង្ស័យ" បានដល់ ជាអ្នកវៀរចាកសេចក្ដីសង្ស័យថា "កុសលធម៌នេះ ជាយ៉ាងណាហ្ន៎" ។ ពាក្យថា "**និក្ក-ថំកថោ វិគតកថំកថោ** = អស់សង្ស័យ" ជាវេវចនៈរបស់ពាក្យថា **ជាអ្នកមិនមាន**

**សេចក្តីសង្ស័យនោះឯង** ។ មួយទៀត បណ្ឌិតគប្បីជ្រាបវចនត្ថៈ ក្នុងព្រះបាលីនោះដូចតទៅនេះ ៖

ភិក្ខុណាចេញទៅហើយចាកសេចក្តីសង្ស័យ ព្រោះហេតុនោះ ទើបភិក្ខុនោះឈ្មោះថា មានសេចក្តីសង្ស័យចេញហើយ (គឺមិនមានសេចក្តីសង្ស័យ) ។

សេចក្តីសង្ស័យរបស់ភិក្ខុនោះ ប្រាសចាកទៅហើយ ព្រោះហេតុនោះ ភិក្ខុនោះទើបឈ្មោះថា មានសេចក្តីសង្ស័យទៅប្រាសហើយ (គឺប្រាសចាកសេចក្តីសង្ស័យ) ។

ពាក្យថា **ឧបក្កិលេសេ** បានដល់ ឧបក្កិលេស ។ ពិតមែន ឧបក្កិលេសនោះ ចូលដល់ចិត្តហើយ នឹងញ៉ាំងចិត្តនោះឱ្យសៅហ្មង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "**ឧបក្កិលេស**" ។

ពាក្យថា "**បញ្ញាយ ទុព្វលីករណេ** = ធ្វើបញ្ញាឱ្យទ្រោម" បានដល់ នីវរណៈ ៥ នេះ កាលកើតឡើងហើយ រមែងមិនមានការកើតឡើងនៃបញ្ញា ដែលជាលោកិយ និងលោកុត្តរ ដែលនៅមិនកើតឡើង, ទាំងចូលទៅញ៉ាំងសមាបត្តិ ៨ អភិញ្ញា ៥ ដែលកើតឡើងហើយ ឱ្យធ្លាក់ចុះទៅ, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "**ឧបក្កិលេសនេះ ធ្វើបញ្ញាឱ្យខ្សោយ**", សូម្បីពាក្យថា "**អនុប្បន្នា ចេវ បញ្ញា ន ឧប្បជ្ជតិ ឧប្បន្នា ច បញ្ញា និរុជ្ឈតិ** = បញ្ញាដែលនៅមិនកើតឡើង រមែងមិនកើតឡើង និងបញ្ញាដែលកើតឡើងហើយ រមែងរលត់ទៅ " នោះ ព្រះមានព្រះភាគត្រាស់សំដៅយកសេចក្តីដែលពោលហើយនេះដូចគ្នា ។ ពាក្យទាំងពួងដែលនៅសល់ក្នុង

ទីនេះ មានសេចក្ដីងាយទាំងអស់ ព្រោះមានអត្ថដូចដែលខ្ញុំប្រកាសហើយ ក្នុងគ្រាមុន ក្នុងទីនោះឯង ។

ពាក្យណា ដែលខ្ញុំគប្បីពោលទុកក្នុងនិទ្ទេសទាំងឡាយ សូម្បីមានពាក្យថា **“វិវិច្ចេវ កាមេហិ** = ស្ងាត់ចាកកាមទាំងឡាយ” ជាដើម, ពាក្យនោះ ខ្ញុំក៏ពោលហើយក្នុងរូបាវចរនិទ្ទេស ត្រង់ចិត្តុប្បាទកណ្ឌក្នុងកាលមុន និងក្នុងទីនោះៗ ក្នុងនិទ្ទេសនេះ ។ ពិតមែន សូម្បីក្នុងនិទ្ទេសនៃទុតិយជ្ឈាន តតិយជ្ឈាន និងចតុត្ថជ្ឈានទាំងឡាយនោះ ព្រះមានព្រះភាគត្រាស់ទុកក្នុងកាលមុនថា “ឈានប្រកបដោយអង្គ ៣, ឈានប្រកបដោយអង្គ ២” យ៉ាងណា, ក្នុងនិទ្ទេសនេះ មិនបានត្រាស់ដូច្នោះទេ បណ្ឌិតគប្បីជ្រាបសេចក្ដីផ្សេងគ្នាយ៉ាងនេះថា ឈាននោះ ព្រះមានព្រះភាគទ្រង់លើកឡើងសម្ដែងហើយ ដោយន័យមានពាក្យថា **សម្បសាទៈ** (សេចក្ដីផូរផង់) បីតិ សុខ និងឯកគ្គតានៃចិត្ត ឈ្មោះថា **ឈាន** ព្រោះកាន់យកអង្គ ៣ និងសម្បសាទជាដើម ដោយបរិយាយនៃព្រះបាលីថា **“អជ្ឈត្តំ សម្បសាទនំ** = សេចក្ដីផូរផង់ប្រព្រឹត្តទៅខាងក្នុង” ជាដើម ។

ក៏ក្នុងនិទ្ទេសនេះថា **យន្តំ អរិយា អាចិក្ខន្តិ** ពាក្យទាំងអស់មានពាក្យថា **“អាចិក្ខន្តិ ទេសេន្តិ”** ជាដើម ជាវេវចនៈរបស់គ្នានឹងគ្នាដោយពិត ។ សូម្បីដូច្នោះ បណ្ឌិតគប្បីជ្រាបសេចក្ដីយ៉ាងនេះថា ព្រះមានព្រះភាគ **រមែងត្រាស់ប្រាប់** ដោយអំណាចនៃឧទ្ទេស (គឺគោលសេចក្ដីដែលលើកឡើងសម្ដែង) មានពាក្យថា **ឱបេក្ខកោ**

**សតិមា សុខវិហារី** = មានសតិ ជាឧបេក្ខា នៅជាសុខ” ជាដើម, **រមែងទ្រង់សម្តែង** ដោយអំណាចនៃនិទ្ទេស (គឺលើកឡើងចង្អុលបង្ហាញ), **រមែងទ្រង់បញ្ញត្ត** ដោយអំណាចនៃបដិនិទ្ទេស (គឺសម្តែងយ៉ាងទូលំទូលាយ), ឈ្មោះថា **រមែងតែងតាំង** ព្រោះ តាំងអត្ថដោយប្រការនោះៗ, កាលសម្តែងហេតុនៃអត្ថនោះៗ ឈ្មោះថា **រមែងបើកផ្សាយ**, កាលចែកនូវបទព្យញ្ជនៈ ឈ្មោះថា **រមែងទ្រង់ចែក**, កាលនាំសេចក្តីត្រង់បទនៃព្យញ្ជនៈដែលនៅមិនទាន់បើកបង្ហាញ និងសេចក្តីត្រង់បទនៃព្យញ្ជនៈនោះ មានអត្ថដែលជ្រៅចេញហើយ ញុំាងបទដែលជាទីពឹងដល់ញាណនៃសោតៈទាំងឡាយឱ្យកើតឡើង ឈ្មោះថា **រមែងធ្វើឱ្យជាក់ច្បាស់**, កាលកម្ចាត់នូវសេចក្តីងងឹត ក្នុងការមិនដឹងរបស់សោតៈទាំងឡាយ ដោយអាការនេះ សូម្បីទាំងអស់ ឈ្មោះថា **រមែងទ្រង់ប្រកាស** បណ្ឌិតគប្បីជ្រាបសេចក្តីយ៉ាងនេះ ដោយប្រការដូច្នេះ ។

សូម្បីក្នុងនិទ្ទេសនៃ **សមតិក្កមៈ** = ព្រោះការឈានកន្លង,ឈ្មោះថា **ឈានកន្លងហើយ** ព្រោះភាពជាអ្នកចេញហើយចាកធម៌នោះៗ (សំដៅដល់អង្គឈាននោះ) ក្នុងទី នោះៗ ឈ្មោះថា **ឆ្លងហើយ** ព្រោះសម្រេចភូមិខាងលើ, ឈ្មោះថា **ឆ្លងផុតហើយ** ព្រោះភាពជាអ្នកមិនសាបសូន្យចាកឈាននោះ បណ្ឌិតគប្បីជ្រាបសេចក្តីនេះ ដូចពណ៌នាមកដូច្នេះ ៕

**ការពណ៌នាអំពីសុត្តន្តភាជនិយចប់**

## ២.ពណ៌នាអំពីអភិធម្មភាជនិយ

បែបផែនក្នុងអភិធម្មភាជនិយ ព្រះមានព្រះភាគទ្រង់តាំងទុក ដោយន័យដែលមកហើយក្នុងចិត្តុប្បាទកណ្ឌក្នុងគ្រាមុននោះឯង, ព្រោះហេតុនោះ ក្នុងអភិធម្មភាជនិយនេះ បណ្ឌិតគប្បីជ្រាបសេចក្តីនៃឈានទាំងឡាយ សូម្បីទាំងអស់ដែលព្រះមានព្រះភាគទ្រង់សម្តែងទុកហើយ ដោយអំណាចនៃធម៌ដែលជាកុសល វិបាក និងកិរិយា ដោយន័យដែលពោលទុកក្នុងចិត្តុប្បាទកណ្ឌនោះឯង, សេចក្តីទាំងអស់ សូម្បីផ្សេងដោយសេចក្តី **មានសុទ្ធិកនវកៈ**ជាដើម ក៏ដូចនឹងន័យដែលពោលហើយក្នុងចិត្តុប្បាទកណ្ឌនុ៎ះឯង ៕

**ពណ៌នាអភិធម្មភាជនិយចប់**

## ៣.ពណ៌នាអំពីបញ្ហាបុច្ឆកៈ

ក្នុងបញ្ហាបុច្ឆកៈ បណ្ឌិតគប្បីជ្រាបសេចក្តីដែលឈានទាំងឡាយជាកុសលជាដើម ដោយទំនងនៃព្រះបាលីនោះឯង; ក៏ប៉ុន្តែក្នុងអារម្មណត្តិកៈ (គឺពួក ៣ នៃអារម្មណ៍) ឈាននោះគប្បីជ្រាបថា មិនគប្បីពោលដោយសេចក្តីជាអារម្មណ៍ មានបរិត្តារម្មណ៍ជាដើម ព្រោះសេចក្តីដែលឈានទាំង ៣ មាននិមិត្តជាអារម្មណ៍ ។ ចំណែកក្នុងបញ្ហាបុច្ឆកៈនេះ ឈាននោះជាលោកុត្តរ ជាអប្បមាណារម្មណ៍ គប្បីមានក្នុងវេលានៃមគ្គ ឬ

ក្នុងវេលានៃផល ។ ក្នុងពាក្យថា **“ចតុត្ថំ ឈានំ សិយា បរិត្តារម្មណំ** = ឈានទី ៤ គប្បីជាបរិត្តារម្មណ៍” នេះ ពោលអំពីកុសល ចតុត្ថជ្ឈានមាន ១៣ ប្រភេទ គឺ

-ចតុត្ថជ្ឈានដែលជាបាទនៃឈានទាំងពួង ១

-ចតុត្ថជ្ឈានដែលជាឥទ្ធិវិធៈ ១

-ចតុត្ថជ្ឈានដែលជាទិព្វសោតញ្ញាណ ១

-ចតុត្ថជ្ឈានដែលជាចេតោបរិយញ្ញាណ ១

-ចតុត្ថជ្ឈានដែលជាបុព្វេនិវាសញ្ញាណ ១

-ចតុត្ថជ្ឈានដែលជាទិព្វចក្ខុញ្ញាណ ១

-ចតុត្ថជ្ឈានដែលជាយថាកម្មូបគតញ្ញាណ ១

-ចតុត្ថជ្ឈានដែលជាអនាគតំសញ្ញាណ ១

-ចតុត្ថជ្ឈានដែលជាអាកាសានញ្ចាយតនជ្ឈានជាដើម ៤ ទៀត

-ចតុត្ថជ្ឈានដែលជាលោកុត្តរ ១ ។

ក្នុងឈាននោះ **ចតុត្ថជ្ឈានដែលជាបាទនៃឈានទាំងពួង** ជានវត្តព្វារម្មណ៍តែម្យ៉ាង (គឺមានអារម្មណ៍ដែលមិនគប្បីពោល) ។

កាលភិក្ខុបង្អោនកាយទៅកាន់ឈានទី ៤ **ដើម្បីធ្វើឥទ្ធិវិធៈ** ដោយអំណាចនៃចិត្ត (គឺរូបកាយទៅព្រមនឹងចិត្ត ឈ្មោះថា ជាបរិត្តារម្មណ៍ ព្រោះភាវៈនៃភិក្ខុនោះ មានកាយជាអារម្មណ៍ ក្នុងខណៈដែលធ្វើបាដិហារ្យ ដោយកាយដែលមិនប្រាកដ (គឺកាល

កាយទៅព្រមនឹងចិត្ត កាយក៏នឹងមិនប្រាកដ ហៅថា **អទិសមានកាយ**) ។

កាលភិក្ខុបង្អោនចិត្តទៅដោយអំណាចនៃកាយ (គឺឱ្យចិត្តទៅព្រមជាមួយនឹងកាយរមែងប្រាកដឃើញបាន) ធ្វើបាដិហារ្យ ដោយកាយដែលប្រាកដទៅកាន់ព្រហ្ម-លោក ឈ្មោះថា ជាមហគ្គតារម្មណ៍ ព្រោះសេចក្ដីដែលភិក្ខុនោះ មានចិត្តក្នុងសមាបត្តិជាអារម្មណ៍ ។

**ឈានទី ៤ ដែលឱ្យសម្រេចទិព្វសោតញ្ញាណ** ឈ្មោះថា បរិត្តារម្មណ៍ ព្រោះសេចក្ដីដែលភិក្ខុនោះ មានសំឡេងជាអារម្មណ៍ ។

**ឈានទី ៤ ដែលឱ្យសម្រេចចេតោបរិយញ្ញាណ** ជាបរិត្តារម្មណ៍ ក្នុងខណៈដឹងចិត្តដែលជាកាមាវចរ, ជាមហគ្គតារម្មណ៍ ក្នុងវេលាដឹងចិត្តដែលជារូបាវចរ និងអរូបាវចរ, ជាអប្បមាណារម្មណ៍ ក្នុងវេលាដឹងចិត្តដែលជាលោកុត្តរ ។ ក៏បុថុជ្ជនអ្នកបានចេតោបរិយញ្ញាណ រមែងដឹងចិត្តរបស់បុថុជ្ជនទាំងឡាយប៉ុណ្ណោះ, មិនដឹងចិត្តរបស់ព្រះអរិយៈទាំងឡាយ; ព្រះសោតាបន្នដឹងចិត្តរបស់ព្រះសោតាបន្ន និងដឹងចិត្តបុថុជ្ជនទាំងឡាយ; ព្រះសកទាគាមីដឹងចិត្តរបស់ព្រះសកទាគាមី និងបុគ្គលខាងក្រោម អ្នកមានភូមិទាបជាង; ព្រះអនាគាមីរមែងដឹងចិត្តអនាគាមី និងជនទាំងឡាយ ៣ ពួកខាងក្រោម; ព្រះខីណាស្រពដឹងចិត្តរបស់ជនសូម្បីទាំងអស់ ។

**ឈានទី ៤ ដែលជាបុព្វេនិវាសញ្ញាណ** ជាបរិត្តារម្មណ៍ ក្នុងខណៈដែលរឭកដល់ខន្ធដែលជាកាមាវចរ, ជាមហគ្គតារម្មណ៍ ក្នុងខណៈដែលតាមរឭកដល់ខន្ធដែលជា

រូបាវចរ និងអរូបាវចរ, ជាអប្បមាណារម្មណ៏ ក្នុងវេលាតាមរឭកថា “ក្នុងអតីតកាល ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធ ព្រះខីណាស្រពទាំងឡាយ ចម្រើនមគ្គហើយ ធ្វើឱ្យជាក់ច្បាស់នូវផល”, ជានវត្តព្វារម្មណ៏ក្នុងវេលាដែលតាមរឭកដល់ឈ្មោះ និងគោត្រ។

**ឈានទី ៤ ដែលជាទិព្វចក្ខុញ្ញាណ** ឈ្មោះថា ជាបរិត្តារម្មណ៏ ព្រោះសេចក្តីដែលភិក្ខុនោះ មានពណ៌ជាអារម្មណ៏ ។

**ឈានទី ៤ ដែលជាយថាកម្មូបគតញ្ញាណ** ជាបរិត្តារម្មណ៏ ក្នុងខណៈរឭកដល់កម្មដែលជាកាមាវចរ, ជាមហគ្គតារម្មណ៏ ក្នុងខណៈរឭកដល់កម្មដែលជារូបាវចរ និងអរូបាវចរ ។

**ឈានទី ៤ ដែលជាអនាគតង្សញ្ញាណ** ជាបរិត្តារម្មណ៏ក្នុងការកំណត់ដឹងដល់ការកើតឡើងនៃកាមធាតុ ក្នុងអនាគតកាល, ជាមហគ្គតារម្មណ៏ក្នុងវេលាដែលដឹងការកើតឡើងរបស់រូបភព និងអរូបភព, ជាអប្បមាណារម្មណ៏ក្នុងការដឹងថា “ក្នុងអនាគតកាល ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធ ព្រះខីណាស្រពទាំងឡាយ នឹងចម្រើននឹងសម្រេចផល ”, ជានវត្តព្វារម្មណ៏ក្នុងវេលាដែលរឭកដល់ឈ្មោះ និងគោត្រ ដោយន័យមានជាអាទិ៍ថា “ក្នុងកាលជាអនាគត នឹងមានព្រះរាជា ព្រះនាមថា **សង្ខៈ** ដោយពិត *” [៣០] ។

---

* ជាព្រះបាទចក្រពត្តិ (សម្មោ. អដ្ឋ.) ។

**ឈានទី ៤ ដែលជាអាកាសានញ្ចាយតនៈ និងអាកិញ្ចញ្ញាយតនៈ** ជានវត្តព្វារម្មណ៍ ។

**ឈានទី ៤ ដែលជាវិញ្ញាណញ្ចាយតនៈ និងនេវសញ្ញានាសញ្ញាយតនៈ** ជាមហគ្គតារម្មណ៍ ។

**លោកុត្តរចតុត្ថជ្ឈាន** ជាអប្បមាណារម្មណ៍ ។

សូម្បីដោយកិរិយាបែបផែនដែលជាអារម្មណ៍ ដូចពោលនេះឯង រមែងប្រព្រឹត្តទៅក្នុងឈាន ១២ នោះ ។

ពាក្យថា **តីណិ ឈានានិ ន មគ្គារម្មណា** បានដល់ បច្ចវេក្ខណញ្ញាណ ឬចេតោបរិយញ្ញាណជាដើម គប្បីធ្វើមគ្គឱ្យជាអារម្មណ៍បាន, ឈានទាំង ៣ មិនជាមគ្គារម្មណ៍ ព្រោះមិនប្រព្រឹត្តទៅយ៉ាងនោះ, តែគប្បីជាមគ្គហេតុកៈ ដោយអំណាចនៃសហជាតហេតុ ។ ជាមគ្គាធិបតីដោយការចម្រើនមគ្គ ដែលមានវីរិយៈជាប្រធាន ឬមានវីមង្សាជាប្រធាន ។ តែមិនគប្បីពោលថា ជាមគ្គាធិបតី ក្នុងកាលដែលមានឆន្ទៈ និងចិត្តជាប្រធាន និងកាលនៃផល ។

សូម្បីក្នុងពាក្យថា **ចតុត្ថំ ឈានំ** នេះ លោកពោលដោយកុសល ក្នុងចតុត្ថជ្ឈាន ១៣ មិនគប្បីពោលថា ឈានទី ៤ ដែលជាសព្វត្ថបាទកៈ ឥទ្ធិវិធៈ ទិព្វសោត-

---

[៣០] ទី. បា. ។

ញ្ញាណ ទិព្វចក្ខុញ្ញាណ យថាកម្មូបគតញ្ញាណ និងឈានទី ៤ ដែលជាអរូប ៤ យ៉ាង ជាមគ្គារម្មណ៍ជាដើម ។ ចំណែកឈានទី ៤ ដែលជាចេតោបរិយញ្ញាណ បុព្វេនិវាសញ្ញាណ និងអនាគតំសញ្ញាណ ជាមគ្គារម្មណ៍ ។ តែមិនគប្បីពោលថា ជាមគ្គហេតុកៈ ឬជាមគ្គាធិបតី ។ លោកុត្តរចតុត្ថជ្ឈាន មិនជាមគ្គារម្មណ៍, តែក្នុងកាលនៃមគ្គ ជាមគ្គហេតុកៈ ដោយអំណាចនៃសហជាតហេតុ ។ ជាមគ្គាធិបតី ក្នុងកាលចម្រើនមគ្គដែល មានវីរិយៈ និងវីមង្សាជាប្រធាន; មិនគប្បីពោលថា ជាមគ្គាធិបតី ក្នុងការចម្រើនមគ្គដែលមានឆន្ទៈ និងចិត្តជាប្រធាន និងក្នុងកាលនៃផល ។

សូម្បីកាលពោលអំពីកិរិយាហើយ ក្នុងឈាន ១២ ក៏ន័យនេះដែរ ។

ពាក្យថា **តីណិ ឈានានិ នវត្តព្វា** បណ្ឌិតគប្បីជ្រាបថា មិនគប្បីពោលថា ឈាន ៣ ជាបរិត្តារម្មណ៍ជាដើម ព្រោះមិនប្រារព្ធធម៌សូម្បីតែម្យ៉ាង ក្នុងអតីតៈ ឱ្យប្រព្រឹត្តទៅ ។

ពាក្យថា **ចតុត្ថំ ឈានំ** បានដល់ កាលពោលអំពីកុសល ចតុត្ថជ្ឈានដែលជាបាទនៃឈានទាំងអស់ ក្នុងចតុត្ថជ្ឈាន ១៣ ជានវត្តព្វារម្មណ៍ប៉ុណ្ណោះ ។

**ចតុត្ថជ្ឈានដែលជាឥទ្ធិវិធៈ** ជាអតីតារម្មណ៍ ព្រោះភាវៈនៃភិក្ខុនោះ មានចិត្តក្នុងសមាបត្តិ ជាអារម្មណ៍ក្នុងការបង្អោនចិត្តទៅតាមអំណាចនៃកាយ, ជាអនាគតារម្មណ៍ ក្នុងកាលអធិដ្ឋាន (របស់ព្រះថេរៈ) ថា "ក្នុងអនាគតកាល សូមផ្កាឈើទាំងនេះ ចូរកុំស្វិតទៅ, ប្រទីបទាំងនេះ ចូរកុំរលត់ទៅ, គំនរនៃអគ្គិមួយ ចូរតាំងឡើង,

បព្វតៈ (ភ្នំ) ចូរតាំងឡើងដោយល្អ” , ជាបច្ចុប្បន្នារម្មណ៍ ព្រោះភាវៈនៃភិក្ខុនោះមានកាយជាអារម្មណ៍ ក្នុងការបង្អោនទៅដោយអំណាចនៃចិត្ត (គឺឱ្យកាយទៅព្រមនឹងចិត្ត) ។

**ចតុត្ថជ្ឈានដែលជាទិព្វសោតញ្ញាណ** ឈ្មោះថា បច្ចុប្បន្នារម្មណ៍ ព្រោះសេចក្ដីថា ភិក្ខុនោះមានសំឡេងជាអារម្មណ៍ ។ **ចតុត្ថជ្ឈាន ដែលជាចេតោបរិយញ្ញាណ** ជាអតីតារម្មណ៍ ក្នុងកាលដឹងចិត្តដែលកើតឡើងហើយ រលត់ទៅខាងក្នុង ៧ ថ្ងៃ ដែលជាអតីតកាល, ជាអនាគតារម្មណ៍ ក្នុងកាលដឹងចិត្តដែលកើតឡើង ខាងក្នុង ៧ ថ្ងៃ ក្នុងអនាគតកាល ។

ពិតមែន ព្រះមានព្រះភាគទ្រង់ប្រកាសចេតោបរិយញ្ញាណនោះឯង ដោយព្រះសូត្រនេះថា “ព្រះអង្គនឹងទាយចិត្តសូម្បីច្រើនៗ ដោយកំណត់មនោសង្ខាររបស់បុគ្គលអ្នកចម្រើននេះ គេតាំងទុកហើយ ដោយប្រការណា ក្នុងចន្លោះនៃចិត្តដួងនេះ គេនឹងត្រិះរិះដល់វិតក្កៈឈ្មោះនេះ ដោយប្រការនោះ ចិត្តនោះ ក៏រមែងមានជាយ៉ាងនេះនោះឯង មិនជាយ៉ាងដទៃឡើយ” ។ ជាបច្ចុប្បន្នារម្មណ៍ ក្នុងកាលប្រារព្ធបច្ចុប្បន្នហើយប្រព្រឹត្តទៅដោយអំណាចនៃអទ្ធានបច្ចុប្បន្ន (បច្ចុប្បន្នកាលដែលយូរៗ) និងសន្តតិបច្ចុប្បន្ន គឺបច្ចុប្បន្នដែលបន្តគ្នាទៅ ។ ក្នុងសេចក្ដីនេះ គប្បីជ្រាបរឿងពិស្ដារ ដោយន័យដែលពោលហើយក្នុងការពណ៌នាអដ្ឋកថាកណ្ឌក្នុងកាលមុននោះឯង ។

**ចតុត្ថជ្ឈានដែលជាបុព្វេនិវាសញ្ញាណ** ជាអតីតារម្មណ៍ ក្នុងកាលតាមរឭក

ដល់អតីតក្ខន្ធ, ជានវត្តព្វារម្មណ៍ ក្នុងកាលតាមរឭកដល់ឈ្មោះ និងគោត្រ ។

**ចតុត្ថជ្ឈានដែលជាទិព្វចក្ខុ** ឈ្មោះថា ជាបច្ចុប្បន្នារម្មណ៍ ព្រោះភិក្ខុនោះ មានពណ៌ជាអារម្មណ៍ ។

**ចតុត្ថជ្ឈានដែលជាយថាកម្មូបគតញ្ញាណ** រមែងធ្វើអតីតកម្មប៉ុណ្ណោះ ឱ្យជាអារម្មណ៍ ព្រោះហេតុនោះ ចតុត្ថជ្ឈាននោះ ទើបឈ្មោះថា ជាអតីតារម្មណ៍ ។

**ចតុត្ថជ្ឈានដែលជាអនាគតង្សញ្ញាណ** ជាអនាគតារម្មណ៍ ក្នុងកាលតាមរឭកដល់ខន្ធដែលជាអនាគត, ជានវត្តព្វារម្មណ៍ ក្នុងកាលតាមរឭកដល់ឈ្មោះ និងគោត្រ ។

**អាកាសានញ្ចាយតនៈ និងអាកិញ្ចញ្ញាយតនចតុត្ថជ្ឈាន** ជានវត្តព្វារម្មណ៍តែប៉ុណ្ណោះ ។

**វិញ្ញាណញ្ចាយតនៈ និងនេវសញ្ញានាសញ្ញាយតនចតុត្ថជ្ឈាន** ជាអតីតារម្មណ៍តែប៉ុណ្ណោះ ។

**លោកុត្តរចតុត្ថជ្ឈាន** ជានវត្តព្វារម្មណ៍នោះឯង ។

សូម្បីពោលអំពីកិរិយា ក្នុងចតុត្ថជ្ឈាន ១២ ក៏ន័យនេះដែរ ។

ឈ្មោះថា **តីណិ ឈានានិ ពហិទ្ធារម្មណា** បានដល់ ឈ្មោះថា ពហិទ្ធារម្មណ៍ ព្រោះប្រារព្ធនិមិត្តដែលជាខាងក្រៅ ឱ្យប្រាកដនៅខាងក្នុងហើយប្រព្រឹត្តទៅ ។ សូម្បីក្នុងពាក្យថា **ចតុត្ថំ ឈានំ** នេះ កាលពោលអំពីកុសលហើយ បានដល់ ចតុត្ថជ្ឈាន ១៣ ដូចនេះ គឺ

**ចតុត្ថជ្ឈានដែលជាបាទនៃឈានទាំងពួង** ជាពហិទ្ធារម្មណ៍ ។

**ចតុត្ថជ្ឈានដែលជាឥទ្ធិវិធៈ** ឈ្មោះថា អជ្ឈត្តារម្មណ៍ ព្រោះភាវៈនៃភិក្ខុនោះ មានកាយ និងចិត្តជារបស់ខ្លួននោះឯង ជាអារម្មណ៍ ក្នុងកាលបង្អោនចិត្តទៅ ដោយអំណាចនៃកាយខ្លះ ក្នុងកាលបង្អោនកាយទៅដោយអំណាចនៃចិត្តខ្លះ, ជាពហិទ្ធារម្មណ៍ ក្នុងកាលប្រព្រឹត្តទៅ ដោយន័យថា “ភិក្ខុនេះ រមែងសម្តែងសូម្បីនូវរូបដំរីខាងក្រៅ” ជាដើម ។

**ចតុត្ថជ្ឈានដែលជាទិព្វសោតញ្ញាណ** ជាអជ្ឈត្តារម្មណ៍ ក្នុងកាលដែលភិក្ខុនោះ មានសំឡេងនៅក្នុងផ្ទៃពោះរបស់ខ្លួនជាអារម្មណ៍, ជាពហិទ្ធារម្មណ៍ក្នុងកាលដែលភិក្ខុនោះ មានសំឡេងរបស់អ្នកដទៃជាអារម្មណ៍, ជាអជ្ឈត្តពហិទ្ធារម្មណ៍ ដោយអំណាចនៃរូបទាំងរបស់ខ្លួន និងរបស់អ្នកដទៃជាអារម្មណ៍ ។

**ចតុត្ថជ្ឈានដែលជាចេតោបរិយញ្ញាណ** ជាពហិទ្ធារម្មណ៍តែម្យ៉ាង ។

**ចតុត្ថជ្ឈានដែលជាបុព្វេនិវាសញ្ញាណ** ជាអជ្ឈត្តារម្មណ៍ក្នុងកាលតាមរឭកដល់ខន្ធរបស់ខ្លួន, ជាពហិទ្ធារម្មណ៍ក្នុងកាលតាមរឭកដល់ខន្ធទាំងឡាយរបស់បុគ្គលដទៃ និងក្នុងកាលតាមរឭកដល់ឈ្មោះ និងគោត្រ ។

**ចតុត្ថជ្ឈានដែលជាទិព្វចក្ខុញ្ញាណ** ជាអជ្ឈត្តារម្មណ៍ ក្នុងកាលដែលមានរូបរបស់ខ្លួនជាអារម្មណ៍, ជាពហិទ្ធារម្មណ៍ ក្នុងកាលដែលមានរូបរបស់បុគ្គលដទៃ ជាអារម្មណ៍, ជាអជ្ឈត្តពហិទ្ធារម្មណ៍ សូម្បីដោយអំណាចនៃកាលមានរូបរបស់ខ្លួន និងរបស់

អ្នកដទៃជាអារម្មណ៍ ។

**ចតុត្ថជ្ឈានដែលជាយថាកម្មូបគតញ្ញាណ** ជាអជ្ឈត្តារម្មណ៍ក្នុងកាលដឹងកម្មរបស់ខ្លួន, ជាពហិទ្ធារម្មណ៍ ក្នុងកាលដឹងកម្មរបស់អ្នកដទៃ, ជាអជ្ឈត្តពហិទ្ធារម្មណ៍ ដោយអំណាចនៃការដឹងកម្មរបស់ខ្លួន និងរបស់អ្នកដទៃ ។

**ចតុត្ថជ្ឈានដែលជាអនាគតំសញ្ញាណ** ជាអជ្ឈត្តារម្មណ៍ ក្នុងកាលដឹងធម៌ដែលកើតឡើងក្នុងអនាគតរបស់ខ្លួន, ជាពហិទ្ធារម្មណ៍ ក្នុងកាលតាមរឭកដល់ខន្ធរបស់អ្នកដទៃ និងក្នុងកាលតាមរឭកដល់ឈ្មោះ និងគោត្រ, ជាអជ្ឈត្តពហិទ្ធារម្មណ៍ ដោយអំណាចនៃការតាមរឭកទាំង ២ នោះ ។

**អាកាសានញ្ចាយតនចតុត្ថជ្ឈាន** ជាពហិទ្ធារម្មណ៍ ។

**អាកិញ្ចញ្ញាយតនៈ** ជានវត្តព្វារម្មណ៍ ។

**វិញ្ញាណញ្ចាយតនៈ និងនេវសញ្ញានាសញ្ញាយតនចតុត្ថជ្ឈាន** ជាអជ្ឈត្តារម្មណ៍ ។

**លោកុត្តរចតុត្ថជ្ឈាន** ជាពហិទ្ធារម្មណ៍តែប៉ុណ្ណោះ ។

សូម្បីពោលអំពីកិរិយាក្នុងឈានទាំង ១២ ក៏ន័យនេះដែរ ។

**ពណ៌នាអំពីបញ្ហាបុច្ឆកៈចប់**

មួយទៀត ក្នុងឈានវិភង្គនេះ ព្រះសម្ពុទ្ធត្រាស់ឈានទាំងឡាយ ដែលជាមិស្សកៈ គឺជាលោកិយ និងលោកុត្តរ លាយចូលគ្នាទៅក្នុងការពណ៌នាសុត្តន្តភាជនិយខ្លះ, ក្នុងការពណ៌នាអភិធម្មភាជនិយខ្លះ, ក្នុងបញ្ហាបុច្ឆកៈខ្លះ; ពិតមែន ន័យទាំង ៣ នោះ ឈ្មោះថា ឯកបរិច្ឆេទនោះឯង ព្រោះន័យទាំង ៣ នោះ ជាធម៌ដែលលាយគ្នាក្នុងភូមិទាំង ៣ ។ សូម្បីឈានវិភង្គនេះ ព្រះមានព្រះភាគក៏ទ្រង់នាំចេញចែកសម្តែងហើយ ៣ បរិវដ្ត ដូចពណ៌នាមកដូច្នេះឯង ។

**អដ្ឋកថាឈានវិភង្គ**

**ចប់**

# ១៣. អដ្ឋកថាអប្បមញ្ញាវិភង្គ

## ១-ពណ៌នាអំពីសុត្តន្តភាជនិយ

ឥឡូវនេះ បណ្ឌិតគប្បីជ្រាប **អប្បមញ្ញាវិភង្គ** ក្នុងលំដាប់នៃឈានវិភង្គនោះ ដូចតទៅ ៖

ពាក្យថា ៤ ជាពាក្យកំណត់ចំនួន ។ ពាក្យថា **អប្បមញ្ញាយោ** បានដល់ ឈ្មោះថា អប្បមញ្ញា ព្រោះដោយអំណាចនៃការផ្សាយទៅមិនមានប្រមាណ ។

ពិតមែន ភិក្ខុនោះរមែងផ្សាយអប្បមញ្ញាទាំងនោះទៅកាន់សត្វទាំងឡាយ រកប្រមាណមិនបានដោយអំណាចនៃអារម្មណ៍ ឬថា រមែងផ្សាយដោយអំណាចនៃ ការផ្សាយទៅ ដែលមិនមានចំណែកនៅសល់ សូម្បីតែសត្វមួយ; ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់មេត្តាជាដើមថា ជាអប្បមញ្ញា ដោយអំណាចនៃការ ផ្សាយទៅក្នុងសត្វដែលមិនមានព្រំដែនដូច្នេះ ។

ពាក្យថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុក្នុងសាសនានេះ ។

ពាក្យថា **មេត្តាសហគតេន** បានដល់ ប្រកបដោយមេត្តា ។

ពាក្យថា **ចេតសា** បានដល់ ដោយចិត្ត ។

ពាក្យថា **ឯកំ ទិសំ** បានដល់ ទិសមួយ ។ ពាក្យនេះ ព្រះមានព្រះភាគ ត្រាស់សំដៅយកសត្វដែលភិក្ខុកំណត់គ្រាដំបូង ដោយអំណាចនៃការផ្សាយទៅ ដែលជាប់ដោយទិសមួយ ។

ពាក្យថា "**ផរិត្វា** = ផ្សាយទៅ" បានដល់ ពាល់ត្រូវហើយធ្វើឱ្យជាអារម្មណ៍ ។

ពាក្យថា **វិហរតិ** បានដល់ ឱ្យវិហារធម៌ក្នុងឥរិយាបថដែលខ្លួនតាំងមាំហើយ ដោយព្រហ្មវិហារប្រព្រឹត្តទៅ ។

ពាក្យថា **“តថា ទុតិយំ** = ទិសទី ២ ក៏យ៉ាងនោះ” អធិប្បាយថា បណ្ដាទិសទាំងឡាយ មានទិសខាងកើតជាដើម ភិក្ខុនោះរមែងផ្សាយទៅកាន់សត្វក្នុងទិសណាមួយ, ក្នុងទិសទី ២ ក៏យ៉ាងនោះ ក្នុងទិសទី ៣ និងទិសទី ៤ ក៏យ៉ាងនោះដែរ ។

ពាក្យថា **ឧទ្ធំអធោ** នេះ គប្បីជ្រាបពាក្យអធិប្បាយតាមដែលព្រះមានជោគត្រាស់ហើយដោយន័យនៃពាក្យថា **ឥតិ ឧទ្ធំ** នោះនុ៎ះឯង (**ឧទ្ធំ** = ទិសខាងលើ) ។

ពាក្យថា **អធោ តិរិយំ** បានដល់ ទិសខាងក្រោមក្ដី ខាងទទឹងក្ដី គប្បីផ្សាយមេត្តាទៅយ៉ាងនោះនុ៎ះឯង ។ ម្យ៉ាងទៀត ពាក្យថា **អធោ** នេះ បានដល់ ទិសខាងក្រោម ។ ពាក្យថា **តិរិយំ** បានដល់ អនុទិស (គឺទិសតូច) អធិប្បាយថា ភិក្ខុញ៉ាំងចិត្តដែលសហគតៈដោយមេត្តាឱ្យត្រាច់ទៅខ្លះ ឱ្យត្រាច់ត្រឡប់មកខ្លះ (ឱ្យរឭកទៅមក) ក្នុងទិសទាំងពួង ដោយអាការយ៉ាងនេះ ប្រៀបដូចសេះត្រាច់ទៅមកក្នុងហ្វូងនៃសេះដូច្នោះ ។

ការផ្សាយមេត្តាដោយចំពោះ (ឱធិសោ) ព្រះមានព្រះភាគទ្រង់កំណត់ទិសនីមួយៗ សម្ដែងហើយដោយពាក្យមានប្រមាណត្រឹមតែប៉ុណ្ណោះ ។ តែពាក្យថា **“សព្វធិ** = ភិក្ខុផ្សាយមេត្តាចិត្តទៅក្នុងសត្វទាំងពួង” ជាដើម ត្រាស់ទុកដើម្បីសំដែងការផ្សាយទៅដោយមិនចំពោះ (អនោធិសោ) ។

ក្នុងពាក្យទាំងនោះ ពាក្យថា **សព្វធិ** = ក្នុងសត្វលោកទាំងពួង ។

ពាក្យថា **“សព្វត្តតាយ** = ព្រោះជាអ្នកមានចិត្ត (ខ្លួន) ស្មើ ក្នុងសត្វគ្រប់ជំពូក” បានដល់ ព្រោះសេចក្ដីដែលមេត្តាចិត្តនោះ ប្រព្រឹត្តទៅក្នុងសត្វទាំងពួងគ្រប់ជំពូក ដែលផ្សេងដោយសត្វទាំងឡាយ មានសត្វប្រភេទថោកទាប កណ្ដាលឧក្រិដ្ឋ

ជាមិត្តសំឡាញ់ និងសត្វជាកណ្តាល (គឺមិនមែនមិត្ត មិនមែនសត្រូវ) ជាដើម ព្រះមានព្រះភាគទ្រង់អធិប្បាយពាក្យថា ព្រោះជាអ្នកមានចិត្ត (ខ្លួន) ស្មើគ្នា ដោយត្រាស់ថា "ព្រោះមិនធ្វើការបែងចែកថា ' នេះជាសត្វដទៃ" ដូច្នេះ ។

ម្យ៉ាងទៀត ពាក្យថា **សព្វត្តតាយ** នេះ បានដល់ ព្រោះជាចិត្តដែលប្រកបដោយមេត្តាទាំងឡាយ គឺទ្រង់អធិប្បាយថា ជាអ្នកមានចិត្តមេត្តា មិនបានផ្សាយទៅជាយ៉ាងដទៃសូម្បីបន្តិច ។

ពាក្យថា "**សព្វាវន្តំ** = ទាំងពួង" អធិប្បាយថា ប្រកបដោយសត្វលោកទាំងពួង ។ ពាក្យថា **លោកំ** បានដល់ សត្វលោក ។ សម្រាប់ក្នុងសេចក្តីនេះ ត្រាស់ថា មានចិត្តដែលសហគតៈដោយមេត្តាទៀត ដើម្បីសម្តែងបរិយាយ (គឺធ្វើវចនៈ) នៃពាក្យថា **វិបុលេន** = បរិបូណ៌ គឺផ្សាយមេត្តាចិត្តដែលបរិបូណ៌ជាដើមនោះឯង ។ ម្យ៉ាងទៀត សព្ទថា **តថា** ក្តី (តថាសព្ទ) សព្ទថា **ឥតិ** ក្តី (ឥតិសព្ទ) ព្រះមានព្រះ-ភាគមិនបានត្រាស់ដដែលក្នុងការផ្សាយទៅ ដោយមិនចំពោះនេះ ដូចការផ្សាយមេត្តាចិត្តទៅដោយចំពោះ, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា "**មេត្តាសហគតេន ចេតសា**" ដដែលទៀត ។ មួយវិញទៀត ពាក្យថា **មេត្តាសហគតេន ចេតសា** នេះ ត្រាស់ទុកដោយអំណាចនៃពាក្យនិគម (គឺពាក្យដែលត្រាស់សរុបសេចក្តី) ។

ម្យ៉ាងវិញទៀត ក្នុងពាក្យថា **វិបុលេន** នេះ បណ្ឌិតគប្បីជ្រាបថា ជាមេត្តាដែលបរិបូណ៌ដោយអំណាចនៃការផ្សាយទៅ ។ ក៏មេត្តាចិត្តនោះ ជាចិត្តទូលំទូលាយ (គឺចិត្តមហគ្គតៈ) ដោយអំណាចនៃភូមិ ។ ក៏មេត្តាចិត្តនោះ ជាចិត្តរកប្រមាណមិនបាន ដោយអំណាចនៃការធ្វើឱ្យស្ទាត់ជំនាញ និងគប្បីជ្រាបថា ជាចិត្តមិនមាន

ប្រមាណ ដោយអំណាចនៃការធ្វើសត្វឱ្យជាអារម្មណ៍ ។ មេត្តាចិត្តនោះ ជាចិត្តមិនមានពៀរ ព្រោះលះធម៌ដែលជាសត្រូវ គឺការបៀតបៀន ។ មេត្តាចិត្តនោះ ជាចិត្តមិនមានសេចក្ដីព្យាបាទ ព្រោះលះទោមនស្ស, ព្រះមានព្រះភាគត្រាស់អធិប្បាយថា "ជាចិត្តមិនមានទុក្ខ" ។ សេចក្ដីដែលបានពណ៌នាមកនេះ ជាអត្ថនៃមាតិកាដែលព្រះមានព្រះភាគទ្រង់តាំងទុក ដោយន័យថា "**មេត្តាសហគតេន ចេតសា** = ដោយចិត្តដែលសហគតៈដោយមេត្តា" ជាដើមត្រឹមនេះសិនចុះ ៕

## មេត្តាអប្បមញ្ញា

ឥឡូវនេះ គប្បីជ្រាបបទភាជនិយ ដែលព្រះមានព្រះភាគត្រាស់ទុកដោយន័យជាដើមថា "**ភិក្ខុ ភិក្ខវេ មេត្តាសហគតេន ចេតសា**" ជាដើម ។ ក្នុងបទភាជនិយនោះ កម្មដ្ឋានដែលប្រកបដោយមេត្តានេះ ជាសប្បាយដល់បុគ្គលអ្នកមានទោសចរិត, ព្រោះហេតុនោះ ទើបមេត្តានេះ ឈ្មោះថា ដល់អប្បនាក្នុងបុគ្គលតាមសេចក្ដីសមគួរ ។ ដើម្បីសម្ដែងនូវបុគ្គលដែលជាទីតាំងនៃមេត្តានោះ ទើបព្រះមានព្រះភាគត្រាស់ថា **សេយ្យថាបិ នាម ឯកំ បុគ្គលំ** ជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យថា **សេយ្យថាបិ នាម** ជានិបាត ចុះក្នុងអត្ថនៃសេចក្ដីឧបមា, អធិប្បាយថា ប្រៀបដូចបុគ្គលឃើញបុគ្គលម្នាក់ ។

ពាក្យថា **បិយំ** = ជាទីស្រឡាញ់ បានដល់ ជាទីតាំងនៃសេចក្ដីស្រឡាញ់ ។

ពាក្យថា **មនាបំ** = ជាទីពេញចិត្ត បានដល់ អ្នកធ្វើសេចក្ដីចម្រើនឱ្យដល់ចិត្ត ។

បណ្ដាពាក្យទាំងនោះ ឈ្មោះថា **ជាទីស្រឡាញ់** ព្រោះអំណាចនៃការធ្លាប់

នៅរួមគ្នាក្នុងកាលមុន ឬថា ដោយប្រយោជន៍ដែលសង្គ្រោះក្នុងបច្ចុប្បន្ន, ឈ្មោះថា **ជាទីពេញចិត្ត** ព្រោះការប្រកបដោយគុណមានសីលជាដើម ។

ម្យ៉ាងទៀត ភាវៈនៃបុគ្គលអ្នកជាទីស្រឡាញ់ គប្បីជ្រាបដោយភាវៈនៃខ្លួនជាអ្នកសម្បូរដោយទាន ។ ភាវៈនៃបុគ្គលអ្នកជាទីពេញចិត្ត គប្បីជ្រាបដោយភាពជាអ្នកមានវាចាពីរោះ និងប្រព្រឹត្តប្រយោជន៍ ។ ក្នុងទីនេះ ការលះព្យាបាទរបស់គេរមែងមាន ព្រោះភាវៈនៃបុគ្គលនោះគួរជាទីស្រឡាញ់, បន្ទាប់ពីនោះ មេត្តាក៏រមែងផ្សាយទៅបានដោយងាយ ។ ការព្រងើយកន្តើយរមែងមិនតាំងនៅព្រោះសេចក្តីពេញចិត្ត, ម្យ៉ាងទៀត បុគ្គលណា រមែងចូលទៅតាំងទុកនូវហិរិ និងឱត្តប្បៈ, បន្ទាប់ពីនោះ មេត្តារបស់គេរមែងមិនសាបសូន្យ ព្រោះភាពជាអ្នកតាមរក្សានូវហិរិ និងឱត្តប្បៈ, ព្រោះហេតុដូច្នោះ ពាក្យថា **បិយំ** = ជាទីស្រឡាញ់, **មនាបំ** = ជាទីចូលចិត្ត ព្រះមានព្រះភាគទ្រង់អធិប្បាយថា ដូចបុគ្គលឃើញបុគ្គលម្នាក់ជាទីស្រឡាញ់ ពេញចិត្តហើយ គប្បីធ្វើបុគ្គលអ្នកជាទីស្រឡាញ់ពេញចិត្តនោះ ឱ្យជាឧបមា ។

ពាក្យថា **មេត្តាយេយ្យ** = គប្បីផ្សាយមេត្តាទៅ អធិប្បាយថា គប្បីធ្វើមេត្តា គឺគប្បីញុំាងមេត្តាឱ្យប្រព្រឹត្តទៅក្នុងបុគ្គលនោះ ។

ពាក្យថា **ឯវមេវ សព្វេ សត្តេ** = ក្នុងសត្វទាំងពួង យ៉ាងនេះនោះឯង អធិប្បាយថា គប្បីផ្សាយមេត្តាទៅកាន់បុគ្គលអ្នកជាទីស្រឡាញ់ យ៉ាងណា, រមែងផ្សាយនូវមេត្តាដែលចូលដល់ភាពជាអ្នកជំនាញ ព្រោះក្នុងការពន្លុះអប្បនា របស់បុគ្គលនោះ ទៅកាន់សត្វទាំងពួង សូម្បីក្នុងបុគ្គលអ្នកបានកន្លងអ្នកមានពៀរដោយលំដាប់ដូច្នោះ ។

ពាក្យថា **មេត្តិ មេត្តាយនា** ជាដើម មានសេចក្ដីដូចដែលខ្ញុំពោលទុកហើយនោះឯង ។

ពាក្យថា **ទិនិសំ ទិវា** = ទិសផ្សេងៗ, ជាពាក្យព្រះមានព្រះភាគត្រាស់ហើយដើម្បីឱ្យសេចក្ដីនៃពាក្យថា **តិរិយំ ទិវា** ( ទិសខាងទទឹង) នេះជាក់ច្បាស់ឡើង ។

ពាក្យថា **ផរិត្វា** = ផ្សាយទៅហើយ បានដល់ ពាល់ត្រូវហើយដោយអំណាចនៃការធ្វើឱ្យជាអារម្មណ៍ ។

ពាក្យថា **អធិមុច្ចិត្វា** បានដល់ បង្អោនទៅដោយភាវៈនៃចិត្តដែលក្រៃលែង, អធិប្បាយថា បង្អោនទៅហើយ បង្អោនទៅល្អហើយ ឱ្យរព្វកល្អហើយ ឱ្យផ្សាយទៅហើយដោយល្អ យ៉ាងណា, ឈ្មោះថា បង្អោនចិត្តទៅហើយដូច្នេះឯង ។

ក្នុងនិទ្ទេសនៃពាក្យថា **សព្វធិ** ជាដើម បទពោលទាំង ៣ ជាបទសង្គ្រោះក្នុងធម៌ទាំងឡាយ ( គឺករុណា មុទិតា និងឧបេក្ខា) ព្រោះហេតុដូច្នោះ ដើម្បីសម្ដែងអត្ថនៃបទទាំងនោះដោយសេចក្ដីដូចគ្នា ទើបត្រាស់ថា **“សព្វេន សព្វំ”** ជាដើម ។ ភាវៈនៃធម៌ទាំងនោះ ព្រះមានព្រះភាគសម្ដែងទុកហើយ ក្នុងខាងក្រោយនោះឯង ។

ក្នុងនិទ្ទេសនៃពាក្យថា **“វិបុលា** = ដែលចម្រើន” ជាដើម ក៏ព្រោះមេត្តាចិត្តណា ជាធម្មជាតិដល់អប្បនា ចិត្តនោះ ឈ្មោះថា **ជាចិត្តចម្រើន** ចិត្តនោះឈ្មោះថា **ជាចិត្តធំទូលាយ** ដោយអំណាចនៃភូមិដោយកំណត់, ក៏ចិត្តណាជាចិត្តធំទូលាយ ចិត្តនោះ ឈ្មោះថា **ជាចិត្តមិនមានប្រមាណ** ដោយអំណាចនៃអារម្មណ៍ដែលរកប្រមាណមិនបាន ។ ចិត្តណារកប្រមាណមិនបាន ចិត្តនោះឈ្មោះថា មិនមាន

ពៀរ ដោយអំណាចនៃការប្រហារសត្រូវ, ចិត្តណាមិនមានពៀរ ចិត្តនោះ ឈ្មោះថា មិនមានព្យាបាទ ព្រោះកម្ចាត់ព្យាបាទបានហើយ ។ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **"យំ វិបុលំ តំ មហគ្គតំ** = ចិត្តណាចម្រើន ចិត្តនោះធំទូលាយ" ជាដើម ។

ម្យ៉ាងទៀត ក្នុងពាក្យនេះថា **អវេរោ អព្យាបជ្ជោ** នេះ លោកត្រាស់ហើយ ដោយបរិយាយនៃលិង្គវិបល្លាស (សម្គាល់សេចក្តីថា ចិត្តជានបុំសកលិង្គ បើតួគុណនាមជាបុំលិង្គ តាមភាសាវេយ្យាករណ៍) ម្យ៉ាងវិញទៀត លោកប្រើសព្ទថា **អវេរោ អព្យាបជ្ជោ** នេះ ចូលនឹងមនសព្ទ (គឺចិត្តឡើងជាប្រភេទតែមួយ) ដូចចិត្តណារកប្រមាណមិនបាន, មនះ គឺចិត្តនោះ ឈ្មោះថា មិនមានពៀរ; ចិត្តណាមិនមានពៀរ ចិត្តនោះ ឈ្មោះថា មិនមានសេចក្តីព្យាបាទដូច្នេះ ។

ម្យ៉ាងវិញសោត ក្នុងពាក្យថា ចិត្តណាចម្រើន ចិត្តនោះធំទូលាយជាដើម បណ្ឌិតគប្បីជ្រាបថា បទខាងក្រោយៗ អធិប្បាយបទខាងមុខៗ ឬថា បទខាងមុខៗ អធិប្បាយបទ ខាងក្រោយៗ ដូច្នេះក៏បាន ៕

## ករុណាអប្បមញ្ញា

សូម្បីពាក្យថា **"សេយ្យថាបិ នាម ឯកំ បុគ្គលំ ទុគ្គតំ ទុរូបេតំ** = ដូចបុគ្គលឃើញបុគ្គលម្នាក់ ដែលដល់នូវទុក្ខលំបាក គប្បីអាណិតដូច្នោះ" នេះ ព្រះមាន-ព្រះភាគត្រាស់ហើយ ដើម្បីសម្តែងនូវបុគ្គលដែលជាទីតាំងនៃករុណា; ពិតមែន ភាពជាអ្នកមានករុណាដែលមានកម្លាំង រមែងកើតក្នុងបុគ្គលមានសភាពដូច្នោះ ។

ក្នុងពាក្យពោលនោះ ពាក្យថា **ទុគ្គតំ** អ្នកដល់ព្រមដោយទុក្ខ ។

ពាក្យថា **ទុរូបេតំ** បានដល់ អ្នកចូលដល់ហើយ នូវកាយទុច្ចរិតជាដើម, ម្យ៉ាងទៀត គប្បីជ្រាបសេចក្ដីក្នុងពាក្យនោះឯងថា បុគ្គលអ្នកតាំងនៅក្នុងភាពជាអ្នកងងឹត ដោយអំណាចនៃគតិវិបត្តិ កូលវិបត្តិ និងភោគវិបត្តិជាដើម ឈ្មោះថា ទុគ្គតៈ (គឺជួបទុក្ខ) បុគ្គលអ្នកតាំងនៅក្នុងភាពជាអ្នកងងឹតក្នុងភពខាងមុខ ព្រោះភាវៈនៃខ្លួនជាអ្នកចូលដល់ហើយ ដោយកាយទុច្ចរិតជាដើម ឈ្មោះថា **ទុរូបេតោ** = គឺបុគ្គលអ្នកចូលដល់បានដោយលំបាក ៕

## មុទិតាអប្បមញ្ញា

សូម្បីពាក្យថា **"ឯកំ បុគ្គលំ បិយំ មនាបំ** = ដូចឃើញបុគ្គលម្នាក់ អ្នកជាទីស្រឡាញ់ពេញចិត្តហើយ" នេះ ព្រះមានព្រះភាគត្រាស់ហើយ ដើម្បីសម្ដែងបុគ្គលដែលជាទីតាំងនៃមុទិតា ។ ក្នុងសេចក្ដីនេះ គប្បីជ្រាបថា បុគ្គលអ្នករក្សានូវភាពជាអ្នករុងរឿងដោយអំណាចនៃគតិសម្បត្តិ ត្រកូលសម្បត្តិ និងភោគសម្បត្តិជាដើម ឈ្មោះថា **អ្នកជាទីស្រឡាញ់** និងគប្បីជ្រាបថា បុគ្គលអ្នករក្សានូវភាពជាអ្នកមានសេចក្ដីរុងរឿងក្នុងលោកខាងមុខ ព្រោះជាអ្នកចូលដល់ហើយដោយកាយ-សុចរិតជាដើម ឈ្មោះថា **អ្នកជាទីពេញចិត្ត** ៕

## ឧបេក្ខាអប្បមញ្ញា

សូម្បីពាក្យថា “**នេវ មនាបំ ន អមនាបំ** = ដូចបុគ្គលឃើញបុគ្គលម្នាក់ដែលជាទីពេញចិត្ត ក៏មិនមែន មិនជាទីពេញចិត្ត ក៏មិនមែន” នេះ ព្រះមានព្រះភាគត្រាស់ហើយ ដើម្បីសម្ដែងនូវបុគ្គលដែលជាទីតាំងនៃឧបេក្ខា; ក្នុងសេចក្ដីនេះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា **អ្នកជាទីពេញចិត្តក៏មិនមែន** ព្រោះភាវៈនៃខ្លួន មិនដល់ព្រមដោយភាពជាមិត្ត, ឈ្មោះថា **មិនជាទីពេញចិត្តក៏មិនមែន** ព្រោះភាវៈនៃខ្លួនមិនដល់ព្រមដោយភាពជាអមិត្ត; ពាក្យណាដែលនៅសល់ នឹងគប្បីពោលក្នុងទីនេះ, ពាក្យនោះទាំងអស់ ខ្ញុំពោលទុកហើយក្នុងចិត្តុប្បាទកណ្ឌ ក្នុងកាលមុននោះឯង ។

សូម្បីវិធីការចម្រើនភាវនា របស់កម្មដ្ឋានទាំងនោះ ខ្ញុំពោលទុកហើយដោយពិស្ដារក្នុងគម្ពីរវិសុទ្ធិមគ្គនុ៎ះឯង ៕

**ពណ៌នាអំពីសុត្តន្តភាជនិយចប់**

## ២-ពណ៌នាអំពីអភិធម្មភាជនិយ

ក្នុងអភិធម្មភាជនិយនេះ ពោលដោយកុសលក្ដី ដោយវិបាកក្ដី ព្រះមានព្រះ-ភាគទ្រង់ចែកចេញហើយ ដោយន័យដែលចែកទុកក្នុងចិត្តុប្បាទកណ្ឌ ក្នុងខាងក្រោយនោះឯង, សូម្បីសេចក្ដីនៃអភិធម្មភាជនិយនោះ បណ្ឌិតគប្បីជ្រាបដោយន័យដែលលោកពោលហើយក្នុងទីនុ៎ះឯង ៕

**ពណ៌នាអំពីអភិធម្មភាជនិយចប់**

## ៣-ពណ៌នាអំពីបញ្ហាបុច្ឆកៈ

**ក្នុងបញ្ហាបុច្ឆកៈ**បណ្ឌិតគប្បីជ្រាបភាវៈនៃធម៌ទាំងឡាយមានមេត្តាជាដើម ជាកុសលជាដើម ដោយទំនងនៃព្រះបាលីនោះឯង តែក្នុងអារម្មណត្តិកៈ អប្បមញ្ញា ៤ ជានវត្តព្វារម្មណ៍ (គឺជាអារម្មណ៍ដែលពោលមិនបាន) ក្នុងតិកៈទាំង ៣ តែម្តង; ក្នុងអជ្ឈត្តារម្មណត្តិកៈ អប្បមញ្ញា ៤ ជាពហិទ្ធារម្មណ៍ (គឺជាអារម្មណ៍ខាងក្រៅ) ។

ពណ៌នាអំពីបញ្ហាបុច្ឆកៈចប់

ម្យ៉ាងទៀត **ក្នុងអប្បមញ្ញាវិភង្គ** នេះ ដែលព្រះសម្មាសម្ពុទ្ធត្រាស់អប្បមញ្ញា ទាំងឡាយទុកក្នុងសុត្តន្តភាជនិយក្តី អភិធម្មភាជនិយក្តី បញ្ហាបុច្ឆកៈក្តី ជាលោកិយយ៉ាងពិត, ពិតណាស់ ន័យទាំង ៣ (គឺសុត្តន្តៈ អភិធម្ម និងបញ្ហាបុច្ឆកៈ) ដូចនេះ កំណត់បានដូចគ្នា ព្រោះភាវៈនៃធម៌ទាំងនោះ ជាលោកិយ ។ សូម្បីអប្បមញ្ញាវិភង្គនិទ្ទេសនេះ ព្រះមានព្រះភាគ ក៏ទ្រង់នាំចេញសម្តែងចែកហើយនូវបរិវដ្ដ ៣ ដូចពណ៌នាមកដូច្នោះឯង ៕

**អដ្ឋកថាអប្បមញ្ញាវិភង្គ**

**ចប់**

# ១៤. អដ្ឋកថាសិក្ខាបទវិភង្គ

## ១. ពណ៌នាអំពីសុត្តន្តភាជនិយ

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យ **សិក្ខាបទវិភង្គ** ដែលជាលំដាប់តអំពី**អប្ប-មញ្ញាវិភង្គ** នោះតទៅ ៖

ពាក្យថា **៥** ជាពាក្យកំណត់ចំនួន ។

ពាក្យថា **"សិក្ខាបទានិ** = សិក្ខាបទទាំងឡាយ" បានដល់ បទដែលកុលបុត្រគប្បីសិក្សា, អធិប្បាយថា សិក្ខាបទនេះ ជាចំណែកមួយនៃសិក្ខា (គឺសីល សមាធិ និងបញ្ញា) ។ ម្យ៉ាងទៀត សូម្បីកុសលធម៌ទាំងអស់ ដែលមកហើយក្នុងខាងលើ ឈ្មោះថា **សិក្ខា** ព្រោះជាធម៌ដែលកុលបុត្រគប្បីសិក្សា, ក៏បណ្ដាអង្គនៃសីល ៥ អង្គណាមួយ ឈ្មោះថា **បទ** ព្រោះអត្ថថា ជាទីអាស្រ័យរបស់សិក្ខាទាំងនោះ ព្រោះហេតុនោះ អង្គនៃសីលទាំងនោះ ទើបឈ្មោះថា **សិក្ខាបទ** ព្រោះជាចំណែកមួយៗ នៃសិក្ខា ។

ពាក្យថា **"បាណាតិបាតា"** បានដល់ ចាកការញ៉ាំងជីវិតសត្វ ឱ្យធ្លាក់ចុះកន្លងទៅ, គឺការសម្លាប់ ការឱ្យស្លាប់ ។

ពាក្យថា **"វេរមណី"** បានដល់ ការវៀរ ។

ពាក្យថា **"អទិន្នាទានា"** បានដល់ វៀរចាកការកាន់យករបស់ដែលអ្នកដទៃគេមិនបានឱ្យ, អធិប្បាយថា បានដល់ **ការនាំវត្ថុរបស់ដែលគេហួងហែងហើយទៅ** ។

ពាក្យថា **"កាមេសុ"** បានដល់ ក្នុងវត្ថុកាមទាំងឡាយ ។

ពាក្យថា **មិច្ឆាចារា** បានដល់ ចាកការប្រព្រឹត្តលាមកដោយអំណាចនៃ

កិលេសកាម ។

ពាក្យថា **“មុសាវាទា”** បានដល់ ចាកវាទៈដែលមិនពិត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងខថា **“សុរាមេរយមជ្ជប្បមាទដ្ឋានា”** នេះតទៅ ៖

ពាក្យថា **សុរា** បានដល់ សុរា ៥ ប្រភេទ គឺ

**១-បិដ្ឋសុរា** សុរាធ្វើដោយម្សៅ

**២-បូវសុរា** សុរាធ្វើដោយនំ

**៣-ឱទនសុរា** សុរាធ្វើដោយបាយ

**៤-កិណ្ណបក្ខិត្តា** សុរាដែលលាយមេស្រាចូលទៅ

**៥-សម្ភារសំយុត្តា** សុរាដែលគេផ្សំដោយគ្រឿងផ្សំផ្សេងៗ ។

ពាក្យថា “មេរ័យ” បានដល់ **គ្រឿងត្រាំ ៥ ប្រភេទ** គឺ

**១-បុប្ផាសវោ** ទឹកត្រាំដោយផ្កាឈើ

**២-ផលាសវោ** ទឹកត្រាំដោយផ្លែឈើ

**៣-គុឡាសវោ** ទឹកត្រាំដោយស្ករអំពៅ

**៤-មធ្វាសវោ** ទឹកត្រាំដោយផ្កាស្រគំ

**៥-សម្ភារសំយុត្តោ** ទឹកត្រាំដែលគេផ្សំដោយគ្រឿងផ្សំផ្សេងៗ ។

សូម្បីសុរា និងមេរ័យទាំងពីរនោះ ឈ្មោះថា **មជ្ជៈ** (ទឹកស្រវឹង) ព្រោះអត្ថថា ជាទីតាំងនៃសេចក្ដីស្រវឹង (មទនីយដ្ឋេន) ។ ជនទាំងឡាយរមែងផឹកសុរា ឬមេរ័យនោះ ដោយចេតនាណា, ចេតនានោះ ឈ្មោះថា **ជាទីតាំងនៃសេចក្ដីប្រមាទ** ព្រោះជាហេតុឱ្យវង្វេង, ព្រោះហេតុនោះ ទីតាំងនៃសេចក្ដីប្រមាទ ឈ្មោះ

ថា មាន ព្រោះការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ; សេចក្តីដែលព្រះមានព្រះភាគទ្រង់តាំងទុកក្នុងមាតិកា មានត្រឹមតែប៉ុណ្ណេះ ៕

## **បទភាជនិយ** (ការចែកបទ)

ពាក្យទាំងពួងថា **“យស្មឹ សមយេ កាមាវចរំ”** ជាដើម ក្នុងបទភាជនិយនេះ មានសេចក្តីងាយមែនពិត ព្រោះមានន័យដូចដែលបានពោលទុកហើយក្នុងកាលមុន ។ មួ្យ៉ាងទៀត ព្រោះការវៀរតែមួ្យ៉ាងប៉ុណ្ណោះ ជាសិក្ខាបទក៏ទេ, សូម្បីចេតនា ក៏ឈ្មោះថា ជាសិក្ខាបទដូចគ្នា, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងន័យទី ២ ដើម្បីសម្តែងដល់ចេតនាដែលជាសិក្ខាបទនោះ ក៏ធម៌ទាំងពីរ (គឺវិរតិ និងចេតនា) នោះ ជាសិក្ខាបទប៉ុណ្ណោះក៏ទេ, សូម្បីធម៌ដទៃ ៥០ ទៀត **ដែលសម្បយុត្តដោយចេតនា ក៏ជាសិក្ខាបទដែរ** ព្រោះជាចំណែកនៃធម៌ ដែលកុលបុត្រគប្បីសិក្សា, ដោយហេតុនោះ ទើបព្រះភគវាសម្តែងន័យសូម្បីទី ៣ ដូចតទៅ ៖

ក្នុងទីនេះ សិក្ខាបទមាន ២ យ៉ាង គឺ បរិយាយសិក្ខាបទ (សិក្ខាបទដោយអម) និងនិប្បរិយាយសិក្ខាបទ (សិក្ខាបទដោយត្រង់) ។

ក្នុងពីរយ៉ាងនោះ **វិរតិ** = ការវៀរ ជាសិក្ខាបទដោយត្រង់; ពិតមែន **វិរតិ** នោះ មកក្នុងព្រះបាលីថា **“បាណាតិបាតា វេរមណី”** ដូច្នេះ មិនមែនចេតនាទេ; ព្រោះថា បុគ្គលកាលវៀរ រមែងវៀរចាកបាណាតិបាតនោះៗ ដោយវិរតិនោះនុ៎ះឯង, មិនមែន ដោយចេតនាទេ ។ តែលោកក៏នាំចេតនាមកសម្តែងទុក; ដោយទំនងដូចគ្នា

នេះ ព្រះមានព្រះភាគទ្រង់នាំសម្បយុត្តធម៌ របស់ចេតនាដែលនៅសល់មកសម្តែងទុកទៀត ។ **ពិតមែន ក្នុងការឈានកន្លងចេតនាដែលជាបាប ឈ្មោះថាភាពជាអ្នកទ្រុស្តសីល** ។ ព្រោះហេតុដូច្នោះ សូម្បីក្នុងវេលានៃវិរតិ ទើបព្រះមានព្រះភាគត្រាស់ចេតនានោះ ដោយអំណាចនៃភាពជាអ្នកមានសីលល្អ, ធម៌ទាំងឡាយ ៥០ មានផស្សៈជាដើម ព្រះមានព្រះភាគទ្រង់កាន់យកហើយ ព្រោះជាធម៌ដែលសម្បយុត្តដោយវិរមណីដូច្នេះ ។

ឥឡូវនេះ ដើម្បីជំរុញញាណក្នុងសិក្ខាបទទាំងឡាយនេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទាំងឡាយ មានបាណាតិបាតសិក្ខាបទជាដើមនេះ ដោយធម៌, ដោយកោដ្ឋាសៈ, ដោយអារម្មណ៍, ដោយវេទនា, ដោយមូល, ដោយកម្ម, ដោយសាវជ្ជៈ និងដោយបយោគ ។

បណ្តាពាក្យទាំងឡាយនោះ ពាក្យថា “**ដោយធម៌**” បានដល់ ចេតនាធម៌ទាំងឡាយនេះ មានបាណាតិបាតជាដើម ។

ពាក្យថា “**ដោយកោដ្ឋាសៈ**” បានដល់ ជាកម្មបថសូម្បីទាំង ៥ តែម្តង ។

ពាក្យថា “**ដោយអារម្មណ៍**” បានដល់ បាណាតិបាត មានជីវិតិន្ទ្រិយជាអារម្មណ៍ ។ **អទិន្នាទាន** មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍ ។ **មិច្ឆាចារ** (ការប្រព្រឹត្តិខុស) មានស្រី និងប្រុសជាអារម្មណ៍; **មុសាវាទ** មានសត្វជាអារម្មណ៍ ឬសង្ខារជាអារម្មណ៍ ។ **ការផឹកសុរា** មានសង្ខារជាអារម្មណ៍ ។

**ពោលអំពីវេទនា បាណាតិបាត** ជាទុក្ខវេទនា ។ **អទិន្នាទាន** មានវេទនា ៣; ពិតមែន អទិន្នាទាននោះ ជាសុខវេទនាដល់អ្នកត្រេកអររីករាយ កាន់

យកវត្ថុដែលម្ចាស់របស់គេមិនបានឱ្យ, ជាទុក្ខវេទនា ព្រោះបុគ្គលអ្នកកាន់យកវត្ថុនោះមានសេចក្តីភ័យខ្លាច, ជាអទុក្ខមសុខវេទនាដល់អ្នកព្រងើយ ហើយកាន់យក, **មិច្ឆាចារ** ជាសុខវេទនា ឬអទុក្ខមសុខវេទនា ។ មុសាវាទ មានវេទនា ៣ ដូចអទិន្នាទានដែរ ។ **ការផឹកសុរា** ជាសុខមជ្ឈត្តវេទនា (សុខវេទនាជាកណ្តាល) ។

**ពោលអំពីមូល បាណាតិបាត** មានទោសៈជាមូល និងមោហៈជាមូល; **អទិន្នាទាន** គ្រាខ្លះ មានលោភៈ និងមោហៈជាមូល, គ្រាខ្លះ មានទោសៈ និងមោហៈជាមូល ។ **មិច្ឆាចារ** មានលោភៈ និងមោហៈជាមូល, **មុសាវាទ** គ្រាខ្លះមានលោភៈ និងមោហៈជាមូល, គ្រាខ្លះ មានទោសៈ និងមោហៈជាមូល ។ **ការផឹកសុរា** មានលោភៈ និងមោហៈជាមូល ។

**ពោលអំពីកម្ម** ក៏មុសាវាទក្នុងទីនេះ ជាវចីកម្ម, សិក្ខាបទដែលនៅសល់ជាកាយកម្មទាំងអស់ ។

**ពោលអំពីសាវជ្ជៈ** (ទោស) បាណាតិបាត មានទោសតិចក៏មាន, មានទោសច្រើនក៏មាន ។ សិក្ខាបទទាំងឡាយមានអទិន្នាទានជាដើម ក៏ដូចគ្នា ។ ហេតុផ្សេងៗនៃសិក្ខាបទទាំង ៥ នោះ លោកសម្តែងទុកហើយក្នុងកាលមុនន៎ុះឯង ៕

### បាណាតិបាត មានទោសតិច និងច្រើន ៖

សម្លាប់សត្វតូចៗ ដូចស្រមោចខ្មៅ ឈ្មោះថា មានទោសតិច

សម្លាប់សត្វដូច្នោះ ដែលធំជាងនោះ មានទោសច្រើនជាង

សម្លាប់សត្វប្រភេទរាប់ចូលដោយបក្សីធំជាងនោះ មានទោសច្រើនជាងនោះ

សម្លាប់សត្វប្រភេទល្មូន ( រំពារ ឬលូន) ធំជាងនោះ មានទោសច្រើនជាងនោះ

សម្លាប់សត្វប្រភេទទន្សាយ មានទោសច្រើនជាងនោះ

សម្លាប់សត្វប្រភេទម្រឹគ មានទោសច្រើនជាងនោះ

សម្លាប់សត្វគោ មានទោសច្រើនជាងនោះ

សម្លាប់សត្វសេះ មានទោសច្រើនជាងនោះ

សម្លាប់ដំរី មានទោសច្រើនជាងនោះ

សម្លាប់មនុស្សអ្នកទ្រុស្តសីល មានទោសច្រើនជាងនោះ

សម្លាប់មនុស្សអ្នកមានប្រក្រតីប្រព្រឹត្តដូចគោ មានទោសច្រើនជាងនោះ

សម្លាប់មនុស្សអ្នកដល់សរណៈ ( ត្រៃសរណគមន៍) មានទោសច្រើនជាងនោះ

សម្លាប់អ្នកតាំងនៅក្នុងសិក្ខាបទ ៥ មានទោសច្រើនជាងនោះ

សម្លាប់សាមណេរ មានទោសច្រើនជាងនោះ

សម្លាប់ភិក្ខុអ្នកជាបុថុជ្ជន មានទោសច្រើនជាងនោះ

សម្លាប់ព្រះសោតាបន្ន មានទោសច្រើនជាងនោះ

សម្លាប់ព្រះសកទាគាមី មានទោសច្រើនជាងនោះ

សម្លាប់ព្រះអនាគាមី មានទោសច្រើនជាងនោះ

សម្លាប់ព្រះខីណាស្រព មានទោសច្រើនក្រៃលែងណាស់ ។

**អទិន្នាទាន មានទោសតិច និងច្រើន** ៖

កាន់យកវត្ថុរបស់បុគ្គលអ្នកទ្រុស្តសីល មានទោសតិច

កាន់យកវត្ថុរបស់អ្នកមានប្រក្រតីប្រព្រឹត្តដូចគោ មានទោសច្រើនជាងនោះ
កាន់យកវត្ថុរបស់អ្នកដល់សរណៈ មានទោសច្រើនជាងនោះ
កាន់យកវត្ថុរបស់អ្នកតាំងនៅក្នុងសីល ៥ មានទោសច្រើនជាងនោះ
កាន់យកវត្ថុរបស់សាមណេរ មានទោសច្រើនជាងនោះ
កាន់យកវត្ថុរបស់ភិក្ខុបុថុជ្ជន មានទោសច្រើនជាងនោះ
កាន់យកវត្ថុរបស់ព្រះសោតាបន្ន មានទោសច្រើនជាងនោះ
កាន់យកវត្ថុរបស់ព្រះសកទាគាមី មានទោសច្រើនជាងនោះ
កាន់យកវត្ថុរបស់ព្រះអនាគាមី មានទោសច្រើនជាងនោះ
កាន់យកវត្ថុរបស់ព្រះខីណាស្រព មានទោសច្រើនក្រៃលែងណាស់ ៕

**កាមេសុមិច្ឆាចារ មានទោសតិច និងច្រើន ៖**

សូម្បី * ប្រព្រឹត្តខុសកន្លងក្នុងស្ត្រីទ្រុស្តសីល ក៏មានទោសតិច

ប្រព្រឹត្តខុសកន្លងក្នុងបុគ្គលអ្នកមានប្រក្រតីប្រព្រឹត្តដូចគោ មានទោសច្រើនជាងនោះ ។

ប្រព្រឹត្តខុសក្នុងបុគ្គលអ្នកដល់សរណៈ មានទោសច្រើនជាងនោះ
ប្រព្រឹត្តខុសក្នុងបុគ្គលអ្នកតាំងនៅក្នុងសីល ៥ មានទោសច្រើនជាងនោះ
ប្រព្រឹត្តខុសក្នុងសាមណេរី មានទោសច្រើនជាងនោះ

---

* ច្បាប់ភូមា មិនមានពាក្យថា **សូម្បី** នេះទេ ។

ប្រព្រឹត្តខុសក្នុងភិក្ខុនីបុថុជ្ជន មានទោសច្រើនជាងនោះ
ប្រព្រឹត្តខុសក្នុងភិក្ខុនីសោតាបន្ន មានទោសច្រើនជាងនោះ
ប្រព្រឹត្តខុសក្នុងភិក្ខុនីជាព្រះសកទាគាមី មានទោសច្រើនជាងនោះ
ប្រព្រឹត្តខុសក្នុងភិក្ខុនីជាព្រះអនាគាមី មានទោសច្រើនជាងនោះ
ប្រព្រឹត្តខុសក្នុងភិក្ខុនីជាព្រះខីណាស្រព មានទោសច្រើនក្រៃលែងណាស់ ។

## មុសាវាទ មានទោសតិច និង ច្រើន ៖

មុសាវាទ (និយាយកុហក) ដើម្បីត្រូវការទ្រព្យ មានប្រមាណមួយកាកណិក (ពាក្យថា កាកណិក ជាឈ្មោះមាត្រាប្រាក់យ៉ាងទាបបំផុត ទ្រព្យមានតម្លៃប៉ុនតម្លៃនៃដុំសាច់ល្មមក្អែកលេបស៊ីបាន) មានទោសតិច ព្រោះពាក្យនិយាយដែលជាមុសានោះ ។

មុសាវាទដើម្បីត្រូវការទ្រព្យកន្លះមាសក: មានទោសច្រើនជាងនោះ
មុសាវាទដើម្បីត្រូវការទ្រព្យមួយមាសក: មានទោសច្រើនជាងនោះ
មុសាវាទដើម្បីត្រូវការទ្រព្យ ៥ មាសក: មានទោសច្រើនជាងនោះ
មុសាវាទដើម្បីត្រូវការទ្រព្យកន្លះកហាបណៈ មានទោសច្រើនជាងនោះ
មុសាវាទដើម្បីត្រូវការទ្រព្យមួយកហាបណៈ មានទោសច្រើនជាងនោះ
មុសាវាទដើម្បីត្រូវការទ្រព្យមានតម្លៃរាប់មិនបាន មានទោសច្រើនជាងនោះ
តែមុសាវាទដើម្បីបំបែកសង្ឃឱ្យបែកគ្នា មានទោសច្រើនក្រៃលែងណាស់ ។

## ការផឹកសុរា មានទោសតិច និងច្រើន ៖

ការផឹកសុរាប្រមាណមួយបាតដៃ មានទោសតិច

ការផឹកសុរាប្រមាណមួយកម្បង់ដៃ មានទោសច្រើនជាងនោះ

តែការផឹកសុរាច្រើនអាចឱ្យកាយញ័រ (ក្លាហាន) ហើយធ្វើការប្លន់អ្នកស្រុក ប្លន់ពួកអ្នកភូមិ មានទោសច្រើនជាងនោះ ។

ពិតមែន ក្នុងបាណាតិបាត ការសម្លាប់ព្រះខីណាស្រពក្តី, ក្នុងអទិន្នាទាន ការកាន់យកវត្ថុរបស់ព្រះខីណាស្រពទៅក្តី, ក្នុងកាមេសុមិច្ឆាចារ ប្រព្រឹត្តខុសក្នុងភិក្ខុនីជាព្រះខីណាស្រពក្តី, ក្នុងមុសាវាទញ៉ាំងសង្ឃឱ្យបែកគ្នាក្តី ក្នុងការផឹកទឹកស្រវឹងដែលអាចឱ្យកាយញ័រឃ្លាតទៅប្លន់អ្នកស្រុក ប្លន់ពួកអ្នកភូមិក្តី ចាត់ថា មានទោសច្រើនទាំងអស់, តែថា **សង្ឃភេទដោយការពោលមុសាវាទប៉ុណ្ណោះ ចាត់ថាមានទោសច្រើនជាងទោស សូម្បីទាំងអស់នោះ**; ព្រោះថា អកុសលដែលច្រើននោះ អាចដើម្បីនឹងឱ្យឆេះក្នុងនរករហូតដល់អស់កប្ប ។

**ពោលអំពីបយោគ** បាណាតិបាត ជាសាហត្ថិកៈ (គឺធ្វើដោយដៃរបស់ខ្លួនឯង) ក៏មាន ជាអាណត្តិកៈ (គឺប្រើអ្នកដទៃឱ្យធ្វើ) ក៏មាន ។ អទិន្នាទាន ក៏យ៉ាងនោះដែរ ។ កាមេសុមិច្ឆាចារ មុសាវាទ និងសុរាបានៈ **ជាសាហត្ថិកៈប៉ុណ្ណោះ** ។

បណ្ឌិតកាលជ្រាបការវិនិច្ឆ័យសិក្ខាបទទាំងនេះ ដោយអំណាចនៃការវិនិច្ឆ័យនូវបាណាតិបាតជាដើម (គឺការញ៉ាំងសត្វមានជីវិតឱ្យធ្លាក់ចុះទៅ ដែលសំដៅដល់ការសម្លាប់សត្វជាដើម) ដោយធម៌ជាដើម យ៉ាងនេះហើយ ក៏គប្បីជ្រាបវិនិច្ឆ័យ សូម្បីនូវពាក្យថា **"បាណាតិបាតា វេរមណី** = វៀរចាកការញ៉ាំងសត្វមានជីវិតឱ្យធ្លាក់

ចុះកន្លងទៅ” ជាដើម ដោយធម៌ ដោយកោដ្ឋាសៈ ដោយអារម្មណ៍ ដោយវេទនា ដោយមូល ដោយកម្ម ដោយខណ្ឌ ដោយសមាទាន ដោយបយោគផង ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ពោលអំពីធម៌** បានដល់ សិក្ខាបទទាំង ៥ នោះ ជាធម៌មានចេតនា ដោយអំណាចនៃបរិយាយសីលប្រព្រឹត្តទៅតាមលំដាប់នោះនុ៎ះឯង ។

**ពោលអំពីកោដ្ឋាសៈ** សូម្បីសិក្ខាបទទាំង ៥ ក៏ជាកម្មបថ ។

**ពោលអំពីអារម្មណ៍** ការវៀរចាកបាណាតិបាត ព្រោះធ្វើជីវិតិន្ទ្រិយរបស់អ្នកដទៃឱ្យជាអារម្មណ៍ ឈ្មោះថា រមែងវៀរដោយចេតនាជាគ្រឿងវៀររបស់ខ្លួន ។ សូម្បីន័យក្នុងសិក្ខាបទដែលនៅសល់ក្រៅពីនេះ ក៏ន័យនេះដែរ, ព្រោះថា សូម្បីសិក្ខាបទទាំងអស់នេះ ធ្វើវត្ថុដែលបុគ្គលគប្បីកន្លងហើយ រមែងវៀរដោយចេតនាជាគ្រឿងវៀរដូចគ្នា ។

**ពោលអំពីវេទនា** សូម្បីសិក្ខាបទទាំងអស់ ជាសុខវេទនា ឬមជ្ឈត្តវេទនា។

**ពោលអំពីមូល** ការវៀរដោយចិត្តដែលសម្បយុត្តដោយញាណ រមែងជាអលោភមូល អទោសមូល និងអមោហមូល, ការវៀរដោយចិត្តប្រាសចាកញាណ រមែងជាអលោភមូល និងអទោសមូលប៉ុណ្ណោះ ។

**ពោលអំពីកម្ម** មុសាវាទា វេរមណី ក្នុងទីនេះ ជាវចីកម្ម, ដែលនៅសល់ជាកាយកម្ម ។

**ពោលអំពីខណ្ឌ** (ការដាច់) គ្រហស្ថទាំងឡាយ រមែងប្រព្រឹត្តកន្លងសិក្ខា-

បទណា១, **សិក្ខាបទនោះ១ ប៉ុណ្ណោះរមែងដាច់ រមែងបែក, សិក្ខាបទ ដែលនៅសល់ រមែងមិនដាច់ មិនបែក ។**

*សួរថា* ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះគ្រហស្ថទាំងឡាយ **មិនមែនជាអ្នកមានសីលជាប្រចាំ**, គេអាចរក្សាសិក្ខាបទណា១, ក៏រមែងរក្សាសិក្ខាបទនោះនុ៎ះឯង ។ តែសិក្ខាបទទាំង-ឡាយរបស់សាមណេរ សូម្បីឈានកន្លងត្រឹមតែសិក្ខាបទមួយ ក៏ឈ្មោះថា **ដាច់ទាំងអស់** * ; សូម្បីលោកមិនបានប្រព្រឹត្តកន្លងសិក្ខាបទទាំងអស់នោះក៏ដោយ, ក៏សិក្ខាបទដែលនៅសល់ទាំងអស់នោះ * ឈ្មោះថា ដាច់មែនពិត ។ ក៏ការប្រព្រឹត្តិកន្លងសីលរបស់សាមណេរនោះ មានវត្ថុជាទណ្ឌកម្ម (គឺត្រូវដាក់ទោស), កាលសាមណេរធ្វើទណ្ឌកម្មថា “ខ្ញុំនឹងមិនធ្វើយ៉ាងនេះទៀត” សីលរមែងបរិបូណ៌ ។

---

* សំដៅដល់សិក្ខាបទ ៥ ខាងដើម មានបាណាតិបាតា វេរមណីសិក្ខាបទជាដើម បើកាលណា ដាច់សិក្ខាបទណានីមួយ ឈ្មោះថា **ដាច់ទាំងអស់**, គឺដាច់រហូតដល់សិក្ខាបទ ៥ ខាងចុង មានវិកាល-ភោជនា វេរមណីសិក្ខាបទជាដើមទៀត ។ តែសិក្ខាបទ ៥ ខាងចុងនេះវិញ បើដាច់មួយណា ក៏នាំឱ្យដាច់តែសិក្ខាបទ ៥ ខាងចុងប៉ុណ្ណោះ គឺមិនអាចនាំឱ្យដាច់ដល់សិក្ខាបទ ៥ ខាងដើមបានឡើយ ។ (សម្រួលតាមដីកា និងយោជនា) ។

* សំដៅដល់សិក្ខាបទ ៥ ខាងចុង មានវិកាលភោជនា វេរមណីសិក្ខាបទជាដើម ។

**ពោលអំពីសមាទាន** កាលគ្រហស្ថតាំងចិត្តថា **“ខ្ញុំនឹងអធិដ្ឋានសីល ៥ នុ៎ះ ឯងមែនពិត”** ដូច្នេះក្តី កាលសមាទានសីលនោះ ដោយញែកតែមួយខ១ ក្តី រមែងឈ្មោះថា សមាទានហើយមែនពិត, គឺថា គ្រហស្ថនោះអង្គុយក្នុងសំណាក់នៃអ្នកណាហើយ ក៏កាន់យកដោយពាក្យថា **“ខ្ញុំនឹងសមាទានសីល ៥”** ក្តី សូមសមាទានតែមួយខ១ ក្តី ឈ្មោះថា សមាទានហើយមែនពិត ។

**ពោលអំពីបយោគ** សូម្បីសីលទាំង ៥ បណ្ឌិតគប្បីជ្រាបថា ជាសាហត្ថិកប្បយោគទាំងអស់ (គឺធ្វើដោយខ្លួនឯងទាំងអស់) ៕

## ធម៌ជាសិក្ខា

គប្បីជ្រាបវិនិច្ឆ័យធម៌ដែលជាសិក្ខានោះ ដូច្នេះ ៖

សូម្បីកុសលធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ ឈ្មោះថា **សិក្ខា**, ព្រោះសភាវៈនៃធម៌នោះ ជាធម៌ដែលបុគ្គលគប្បីសិក្សា ព្រោះហេតុនោះដើម្បីសម្តែងនូវសិក្ខាទាំងឡាយនោះ ទើបព្រះមានព្រះភាគត្រាស់ថា **“យស្មឹ សមយេ កាមាវចរំ”** ជាដើម ។ ក្នុងអធិការនេះ បណ្ឌិតគប្បីជ្រាបសេចក្តីដោយញុំាងព្រះបាលីឱ្យពិស្តារ ដោយន័យដែលពោលទុកក្នុងចិត្តុប្បាទកណ្ឌ ក្នុងកាលមុននុ៎ះឯង ។

ចំណែកក្នុងសិក្ខាបទវិភង្គនេះ សម្តែងទុកត្រឹមតែគោលសេចក្តីប៉ុណ្ណោះ ៕

**ចប់អភិធម្មភាជនិយ**

## ២.ពណ៌នាអំពីបញ្ហាបុច្ឆកៈ

ក្នុងបញ្ហាបុច្ឆកៈ បណ្ឌិតគប្បីជ្រាបសេចក្ដីដែលសិក្ខាបទទាំងឡាយ ជាកុសលជាដើម ដោយទំនងនៃន័យរបស់ព្រះបាលីនុ៎ះឯង ។ ក៏ក្នុងអារម្មណត្តិកៈទាំងឡាយ សិក្ខាបទណាដែលលោកពោលទុកក្នុងទីនេះថា ជាសត្តារម្មណ៍ (គឺមានសត្វជាអារម្មណ៍) ក៏ព្រោះសិក្ខាបទទាំងនោះ រមែងធ្វើសង្ខារដែលដល់ការរាប់ថាជាសត្វប៉ុណ្ណោះឱ្យជាអារម្មណ៍ និងព្រោះតែសិក្ខាបទទាំងនោះ សម្រេចហើយដោយអំណាចនៃសម្បត្តវិរតិមែនពិត, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា "ជាបរិត្តារម្មណ៍" ផង "ជាបច្ចុប្បន្នារម្មណ៍" ផង ។ មួយវិញទៀត បណ្ឌិតគប្បីជ្រាបថា សេចក្ដីនៃសិក្ខាបទសូម្បីទាំងអស់ ជាពហិទ្ធារម្មណ៍ ក៏ព្រោះការវៀរ រមែងមានដល់វត្ថុណា, វត្ថុនោះជារបស់ខាងក្រៅទាំងអស់មែនពិត ៕

### ពណ៌នាអំពីបញ្ហាបុច្ឆកៈចប់

ក៏សិក្ខាបទវិភង្គនេះ ក្នុងអភិធម្មភាជនិយក្ដី ក្នុងបញ្ហាបុច្ឆកៈក្ដី ព្រះសម្មាសម្ពុទ្ធត្រាស់សិក្ខាបទទាំងឡាយថា ជាលោកិយប៉ុណ្ណោះ; ព្រោះថា សូម្បីន័យទាំងពីរនេះ ក៏ជាបរិច្ឆេទតែមួយ ដោយសេចក្ដីជាលោកិយនុ៎ះឯង; សិក្ខាបទវិភង្គនេះ ព្រះមានព្រះភាគទ្រង់នាំចេញសម្ដែងចែកទុក ២ បរិវដ្ដ ដូចពណ៌នាមកដូច្នេះឯង ៕

### ចប់អដ្ឋកថាសិក្ខាបទវិភង្គ

# ១៥. អដ្ឋកថាបដិសម្ភិទាវិភង្គ

## ១-ពណ៌នាអំពីសុត្តន្តភាជនិយ

ឥឡូវនេះ គប្បីជ្រាបបដិសម្ភិទាវិភង្គជាលំដាប់នៃសិក្ខាបទវិភង្គនោះតទៅ ៖

ពាក្យថា **“៤”** ជាពាក្យកំណត់ចំនួន ។

ពាក្យថា **“បដិសម្ភិទា”** បានដល់ បញ្ញាបែកធ្លាយ, អធិប្បាយថា ក៏ព្រោះខាងមុខនេះ ព្រះមានព្រះភាគត្រាស់ទុកថា **“អត្ថេ ញាណំ អត្ថប្បដិសម្ភិទា** = ញាណ (បញ្ញា) ក្នុងអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទា” ជាដើម, ព្រោះហេតុដូច្នោះបណ្ឌិតគប្បីជ្រាបថា មិនមែនជាការបែកធ្លាយរបស់អ្នកណា១ ឡើយ, ក្រៅពីការបែកធ្លាយរបស់ញាណ (បញ្ញា) ប៉ុណ្ណោះ; ដោយប្រការដូច្នេះ ទើបខ្ញុំសង្គ្រោះសេចក្ដីនេះថា **ការបែកធ្លាយរបស់ញាណ ៤** នេះ ចុះក្នុងបទថា **“បដិសម្ភិទា ៤”** បដិសម្ភិទាក្នុងអត្ថ ឈ្មោះថា **អត្ថប្បដិសម្ភិទា**, អធិប្បាយថា ញាណ (បញ្ញា) ដែលដល់សេចក្ដីបែកធ្លាយក្នុងអត្ថដើម្បីអាចធ្វើការវិគ្រោះ (បែងចែក) អត្ថប្រភេទផ្សេង១ ឱ្យជាក់ច្បាស់ដោយការពិចារណា ។ សូម្បីក្នុងបទដែលនៅសល់ ក៏ន័យនេះដែរ ។ ពិតមែន ញាណដែលដល់សេចក្ដីដឹងឆ្លៀវឆ្លាសក្នុងធម៌ ដើម្បីអាចធ្វើការវិគ្រោះធម្មជាតិផ្សេង១ ឱ្យជាក់ច្បាស់ដោយការពិចារណា ឈ្មោះថា **ធម្មប្បដិសម្ភិទា**; ញាណដែលដល់សេចក្ដីដឹងឆ្លៀវឆ្លាសក្នុងការពោលនូវនិរុត្តិធម៌ ដើម្បីអាចធ្វើការវិគ្រោះនិរុត្តិ (គឺភាសាផ្សេង១) ឱ្យជាក់ច្បាស់ដោយការពិចារណា ឈ្មោះថា **និរុត្តិប្បដិសម្ភិទា** ។ ញាណដែលដល់សេចក្ដីដឹងឆ្លៀវឆ្លាសក្នុងបដិភាណ (គឺឈ្លាសវាងវៃក្នុងការឆ្លើយតបបានទាន់ពេល) ដើម្បីអាចធ្វើវិគ្រោះបដិភាណប្រភេទផ្សេង១ ឱ្យជាក់ច្បាស់ក្នុងការពិចារណា ឈ្មោះថា **បដិភាណប្បដិសម្ភិទា** ។

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់ចែកសម្ដែងបដិសម្ភិទាទាំងឡាយ តាមដែលទ្រង់តាំងទុក ទើបត្រាស់ពាក្យថា “**អត្ថេ ញាណំ អត្ថប្បដិសម្ភិទា** = សេចក្ដីឆ្លៀវឆ្លាសក្នុងអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទា” ជាដើម ៕

## អធិប្បាយពាក្យថា អត្ថៈ

បណ្ដាពាក្យទាំងនោះ ពាក្យថា “**អត្ថៈ**” កាលពោលដោយសង្ខេប បានដល់ផលរបស់ហេតុ (ផលដែលកើតពីហេតុ) ។ ពិតមែន ផលរបស់ហេតុនោះ គប្បីជារបស់ស្ងប់ (គឺប្រាសចាកកិលេស) គប្បីដល់ គប្បីសម្រេចបាន ដោយអំណាចនៃហេតុ, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា **អត្ថៈ** ។ កាលពោលដោយប្រភេទហើយ បណ្ឌិតគប្បីជ្រាបថា បានដល់ ធម៌ទាំង ៥ នេះ គឺ

១. សភាវៈណាមួយដែលអាស្រ័យគ្នាកើតឡើង ព្រោះបច្ច័យ
២. ព្រះនិព្វាន
៣. អត្ថនៃភាសិត
៤. វិបាក
៥. កិរិយា ។

កាលពិចារណាអត្ថនោះហើយ ញាណដែលដល់សេចក្ដីដឹងឆ្លៀវឆ្លាស ក្នុងអត្ថនោះៗ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ៕

## អធិប្បាយពាក្យថា ធម្មៈ

ពាក្យថា **“ធម្មៈ”** កាលពោលដោយសង្ខេប បានដល់ បច្ច័យ ។ ពិតមែន ព្រោះបច្ច័យនោះ រមែងចាត់ចែង រមែងឱ្យធម៌នោះៗ ប្រព្រឹត្តទៅផង ឱ្យដល់ផង, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា **ធម្មៈ**; តែកាលពោលដោយប្រភេទហើយ បណ្ឌិតគប្បីជ្រាបថា បានដល់ ធម៌ទាំង ៥ នេះ គឺ

១.ហេតុណាមួយដែលញ៉ាំងផលឱ្យកើតឡើង

២.អរិយមគ្គ

៣.ភាសិត (វាចាដែលពោលហើយ)

៤.កុសល

៥.អកុសល ។

កាលពិចារណាធម៌នោះហើយ ញាណដែលដល់សេចក្ដីដឹងឆ្លៀវឆ្លាសក្នុងធម៌នោះ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ៕

## អធិប្បាយពាក្យថា ធម្មនិរុត្តិ = ភាសារបស់សភាវៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងខថា **ញាណក្នុងការពោលនូវធម្មនិរុត្តិ** ដូច្នេះ ៖

សភាវនិរុត្តិ (ភាសារបស់សភាវៈ) យ៉ាងណា រមែងប្រព្រឹត្តទៅក្នុងអត្ថផង, ក្នុងធម៌ផង, កាលពិចារណាធ្វើសព្ទ (សំឡេង) ដែលជាសភាវនិរុត្តិនោះ ក្នុងការពោលយ៉ាងនោះ ញាណដែលដល់សេចក្ដីដឹងឆ្លៀវឈ្លាស ក្នុងពាក្យនិយាយដែលជាសភាវនិរុត្តិនោះ ឈ្មោះថា **និរុត្តិប្បដិសម្ភិទា** ។ និរុត្តិប្បដិសម្ភិទានេះ កើតឡើង

ដោយអាការយ៉ាងនេះ ឈ្មោះថា **មានសំឡេងជាអារម្មណ៍**, មិនឈ្មោះថា មានបញ្ញត្តជាអារម្មណ៍ទេ ។

**សួរថា** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះស្តាប់សំឡេងហើយរមែងដឹងថា "នេះជាសភាវនិរុត្តិ, នេះមិនមែន" ; ពិតមែន អ្នកសម្រេចបដិសម្ភិទានោះ កាលមានអ្នកពោលថា "**ផស្សោ**" ដូច្នេះ រមែងដឹងថា "នេះជាសភាវនិរុត្តិ" , ឬថា កាលអ្នកដទៃពោលថា "**ផស្សា**" ឬ "**ផស្សំ**" ដូច្នេះ ក៏រមែងដឹងថា "នេះមិនមែនជាសភាវនិរុត្តិ" ; សូម្បីក្នុងវេទនាជាដើម ក៏ន័យនេះដែរ ។

**សួរថា** ក៏អ្នកសម្រេចបដិសម្ភិទានោះរមែងដឹង ឬរមែងមិនដឹងនូវសំឡេងនៃព្យញ្ជនៈ ដែលជានាម អាខ្យាត និងឧបសគ្គដទៃៗ ឬ ?

ឆ្លើយថា ក្នុងកាលណាស្តាប់សំឡេងចំពោះមុខ រមែងដឹងថា "នេះជាសភាវ-និរុត្តិ, នេះមិនមែន" ក្នុងកាលនោះ នឹងដឹងបានសូម្បីនូវពាក្យនោះតាំងពីដើម ។ តែសេចក្តីនេះ មានអ្នកជំទាស់ថា "នេះមិនមែនជាកិច្ចរបស់បដិសម្ភិទា" ដូច្នេះ ហើយបានលើកយករឿងព្រះថេរៈមកពោលថា ៖

បានឮថា ព្រះថេរៈឈ្មោះថា **តិស្សទត្ត** កាន់យកស្លាកដែលជាវិការនៃមាសត្រង់ពោធិមណ្ឌល ហើយបវារណា (គឺសម្តាល់សេចក្តីថា បើកឱកាស ឬអនុ-ញ្ញាតឱ្យភិក្ខុស្តាប់ភាសាផ្សេងៗ តាមដែលត្រូវការ) ដល់ភិក្ខុទាំងឡាយ ដោយពាក្យថា "**ក្នុងបណ្តាភាសា ១៨ យ៉ាង ខ្ញុំនឹងពោលដោយភាសាណា**" ដូច្នេះ, ក៏ពាក្យបវារណានោះ ព្រះថេរៈលោកតាំងនៅក្នុងការសិក្សារបស់ខ្លួន ទើបបាន

បវារណា មិនមែនតាំងនៅក្នុងបដិសម្ភិទា ហើយពោលបវារណាទេ ។ ព្រោះថា ព្រះថេរៈនោះ លោកឱ្យបុគ្គលប្រាប់ហើយៗ លោកក៏រៀនយកភាសានោះៗ ព្រោះភាវៈនៃលោកជាអ្នកមានបញ្ញាច្រើន; បន្ទាប់ពីនោះមក ទើបលោកបវារណាយ៉ាងនេះ ព្រោះតាំងនៅហើយក្នុងការសិក្សារៀនសូត្រ ៕

## ភាសាមគធៈ ជាភាសាឫសគល់របស់សត្វលោក

ក៏ឯគ្រាលោកពោលហើយ ទើបពោលពាក្យក្នុងទីនេះ តទៅទៀតថា **"ធម្មតាថា សត្វទាំងឡាយក៏រមែងរៀនភាសា"** ដូច្នេះ; ពិតមែន មាតា និង បិតាឱ្យកូនតូចដេកលើគ្រែ ឬលើតាំងក្នុងវេលាដែលកូននៅជាទារក ហើយនិយាយនូវកិច្ចនោះៗ ធ្វើនូវកិច្ចនោះៗ; ក្មេងទាំងឡាយរមែងកំណត់ភាសានោះៗ របស់មាតា ឬបិតាថា "ពាក្យនេះ អ្នកនេះពោលហើយ, ពាក្យនោះ អ្នកនោះពោលហើយ" កាលកន្លងទៅៗ ពួកក្មេងៗ រមែងដឹងភាសាសូម្បីទាំងអស់ ។ មាតាជាអ្នកស្រុកទមិឡ, បិតាជាអ្នកស្រុកអន្ធកៈ; ក្មេងដែលកើតអំពីជនទាំងពីរនោះ បើគេស្តាប់ពាក្យរបស់មាតាមុន, គេនឹងនិយាយភាសាទមិឡមុន; បើស្តាប់ពាក្យរបស់បិតាមុន, គេនឹងនិយាយភាសាអ្នកស្រុកអន្ធកៈមុន ។ តែកាលមិនបានស្តាប់ពាក្យរបស់ជនសូម្បីទាំងពីរ ក៏នឹងពោល (និយាយ) **ភាសារបស់អ្នកស្រុកមគធៈ** ។ សូម្បីទារកណាកើតក្នុងព្រៃធំ មិនមានផ្ទះ (ភូមិ), អ្នកដទៃឈ្មោះថា ពោលហើយមិនមានក្នុងព្រៃធំនោះ, សូម្បីទារកនោះ កាលនឹងញុំាងវាចាឱ្យតាំងឡើង តាមធម្មតារបស់ខ្លួន ក៏នឹងពោលភាសារបស់អ្នកស្រុកមគធៈនោះនុ៎ះឯង ។

ភាសារបស់អ្នកស្រុកមគធៈប៉ុណ្ណោះ ប្រើច្រើនសន្ទឹកសន្ធាប់ (ជាភាសាយាន) ក្នុងទីទាំងពួង គឺ

១-ក្នុងនិរយៈ (នរក)

២-ក្នុងកំណើតនៃសត្វតិរច្ឆាន (មានសត្វដំរីជាដើម)

៣-ក្នុងប្រេតវិស័យ (កំណើតប្រេត)

៤-ក្នុងមនុស្សលោក

៥-ក្នុងទេវលោក ។

ក្នុងភាសារបស់សត្វទាំងឡាយ ភាសា ១៨ យ៉ាង ក្រៅអំពីភាសារបស់អ្នកស្រុកមគធៈ មានភាសារបស់មនុស្សព្រៃ របស់អ្នកស្រុកអន្ធកៈ អ្នកស្រុកយោនកៈ អ្នកស្រុកទមិឡៈ តាមដែលពោលហើយជាដើម រមែងប្រែប្រួលទៅ[*] , **ភាសារបស់អ្នកស្រុកមគធៈ ពោលគឺជាវោហាររបស់ព្រហ្ម ជាវោហាររបស់ព្រះអរិយៈ តាមសេចក្ដីពិត ភាសានេះតែមួយប៉ុណ្ណោះ មិនផ្លាស់ប្ដូរប្រែប្រួល;** សូម្បីព្រះសម្មាសម្ពុទ្ធ កាលនឹងទ្រង់លើកព្រះត្រៃបិដក គឺព្រះពុទ្ធវចនៈឡើងកាន់បែបផែន ក៏ទ្រង់លើកឡើងដោយភាសារបស់អ្នកស្រុកមគធៈដែរ ។

**សួរថា** ព្រោះហេតុអ្វី ?

ឆ្លើយថា ក៏ព្រោះដើម្បីនឹងនាំមកនូវអត្ថ (ប្រយោជន៍) បានដោយងាយ ។ ពិតមែន ការចូលដល់គន្លងក្រសែនៃពុទ្ធវចនៈ ដែលលើកឡើងកាន់បែបផែន ដោយ

---

[*] ជួនកាលមាន ជួនកាលមិនមាន ។

ភាសានៃអ្នកស្រុកមគធៈ រមែងជាការមានមកយ៉ាងពិស្តារ ដល់អ្នកសម្រេចបដិសម្ភិទាទាំងឡាយ ។ គឺថា កាលក្រសែនៃព្រះពុទ្ធវចនៈនោះ គ្រាន់តែអ្នកសម្រេចបដិសម្ភិទាហើយភ្លាមនុ៎ះឯង អត្ថរមែងមកប្រាកដ រាប់ដោយរយន័យ និងពាន់ន័យ ។ ក៏កាលបុគ្គលអ្នកត្រាច់ទៅហើយៗ រៀនយកនូវព្រះពុទ្ធវចនៈ ដែលលើកឡើងកាន់បែបផែន ដោយភាសាដទៃមានហើយ; **តែឈ្មោះថា ការសម្រេចបដិសម្ភិទារបស់បុថុជ្ជន ព្រោះរៀនយកពុទ្ធវចនៈនោះ សូម្បីច្រើន ក៏មិនមាន ។ ព្រះអរិយសាវកដែលមិនសម្រេចបដិសម្ភិទា មិនមានទេ ។**

ពាក្យថា "**ញាណេសុ ញាណំ** = សេចក្តីដឹងក្នុងញាណទាំងឡាយ" បានដល់ កាលលោកពិចារណាធ្វើញាណក្នុងទីទាំងពួង ឱ្យជាអារម្មណ៍ហើយ ញាណដែលដល់សេចក្តីដឹងឆ្លៀវឆ្លាស ឈ្មោះថា **បដិភាណប្បដិសម្ភិទា** ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបថា បដិសម្ភិទាទាំង ៤ នេះ រមែងដល់ការញែកចេញក្នុងឋាន (ភូមិ) ២ យ៉ាង; និងរមែងបរិសុទ្ធដោយហេតុ ៥ យ៉ាង ។

**សួរថា** បដិសម្ភិទា ៤ រមែងដល់ការញែកចេញក្នុងឋាន ២ តើដូចម្តេច ?

ឆ្លើយថា ក្នុងឋាន ២ គឺ សេក្ខភូមិ និងអសេក្ខភូមិ ។

**ក្នុងឋានទាំង ២ នោះ** សូម្បីបដិសម្ភិទារបស់ព្រះមហាថេរៈទាំង ៨០ រូប **ដល់ប្រភេទអសេក្ខភូមិ** បានដល់ បដិសម្ភិទារបស់ព្រះសារីបុត្តត្ថេរ ព្រះមហាមោគ្គល្លានត្ថេរ ព្រះមហាកស្សបត្ថេរ ព្រះមហាកច្ចាយនត្ថេរ ព្រះមហាកោដ្ឋិតត្ថេរជាដើម ។ **បដិសម្ភិទារបស់អ្នកដល់សេក្ខភូមិ** គឺបានដល់ បដិសម្ភិទារបស់ព្រះអានន្ទត្ថេរ ចិត្តគហបតី ធម្មិកឧបាសក ឧបាលិគហបតី នាងខុជ្ជុត្តរាឧបាសិកាជាដើម

បដិសម្ភិទាទាំងឡាយ រមែងដល់ការញែកចេញក្នុងភូមិទាំងពីរនេះ ដោយប្រការដូច្នេះ ។

**សួរថា** បដិសម្ភិទាទាំងឡាយ ជាធម្មជាតិបរិសុទ្ធដោយហេតុ ៥ យ៉ាង តើដូចម្ដេច ?

ឆ្លើយថា **ដោយអធិគម ដោយបរិយត្តិ ដោយសវនៈ ដោយបរិបុច្ឆា ដោយបុព្វយោគ** ។

ក្នុងហេតុទាំង ៥ នោះ **ព្រះអរហត្ត** ឈ្មោះថា **អធិគម**; ពិតមែន កាលសម្រេចអរហត្តហើយ បដិសម្ភិទាទាំងឡាយរមែងជាធម៌បរិសុទ្ធ ។ ព្រះពុទ្ធវចនៈឈ្មោះថា **បរិយត្តិ**; ពិតមែន ការរៀនយកនូវព្រះពុទ្ធវចនៈ បដិសម្ភិទាទាំងឡាយរមែងជាធម៌បរិសុទ្ធ ។ ការស្ដាប់ព្រះធម៌ ឈ្មោះថា **សវនៈ**; ពិតមែន កាលស្ដាប់ព្រះធម៌ដោយគោរព បដិសម្ភិទាទាំងឡាយរមែងជាធម៌បរិសុទ្ធ ។ អដ្ឋកថា ឈ្មោះថា **បរិបុច្ឆា**; ពិតមែន កាលពោលនូវអត្ថនៃព្រះបាលីដែលខ្លួនរៀនមកហើយ បដិ-សម្ភិទាទាំងឡាយ រមែងជាធម៌បរិសុទ្ធ ។ ភាពជាព្រះយោគាវចរក្នុងកាលមុន គឺសេចក្ដីដែលកម្មដ្ឋានដែលខ្លួនរក្សាហើយ ដោយន័យនៃការនាំកម្មដ្ឋានទៅ និងនាំកម្មដ្ឋានត្រឡប់មក (ហរណបច្ចាហរណវត្ត) ក្នុងអតីតភព ឈ្មោះថា **បុព្វយោគ**; ពិតមែន កាលធ្លាប់ចុះកាន់ (ការឈានចុះ) សេចក្ដីព្យាយាមមកហើយ ក្នុងកាលមុន បដិសម្ភិទាទាំងឡាយ ក៏រមែងជាធម៌បរិសុទ្ធ ។

បណ្ដាហេតុទាំង ៥ នោះ គប្បីជ្រាបបដិសម្ភិទាទាំងឡាយ **ព្រះតិស្សត្ថេរ** អ្នកជាបុត្រនៃកុដុម្ពិក៍ ឈ្មោះបុនព្វសុ បានជាធម៌បរិសុទ្ធហើយ ដោយការសម្រេច

ព្រះអរហត្ត មានរឿងនិទានទុកថា៖

បានឮថា **ព្រះតិស្សត្ថេរ** នោះ រៀនព្រះពុទ្ធវចនៈក្នុងតម្ពបណ្ណិទ្វីប (គឺក្នុងកោះរបស់ជនអ្នកមានបាតដៃក្រហម ឬហៅម្យ៉ាងទៀតថា លង្កាទ្វីប) ហើយទៅកាន់ត្រើយដទៃ រៀនយកពុទ្ធវចនៈក្នុងសំណាក់របស់ព្រះធម្មរក្ខិតត្ថេរ អ្នកស្រុកយោនកៈ សម្រេចពីការរៀន ក៏ដើរផ្លូវមកដល់កំពង់ជាទីឡើងទូក កើតសេចក្តីសង្ស័យក្នុងព្រះពុទ្ធវចនៈមួយបទ ទើបធ្វើដំណើរត្រឡប់មកផ្លូវដើមវិញប្រមាណ ១០០ យោជន៍ កាលទៅកាន់សំណាក់របស់អាចារ្យ ក្នុងចន្លោះផ្លូវបានបកស្រាយបញ្ហាដល់កុដុម្ពិកម្នាក់; កុដុម្ពិកម្នាក់នោះ មានសេចក្តីជ្រះថ្លា បានថ្វាយសំពត់កម្ពលមានតម្លៃមួយសែន; ព្រះតិស្សត្ថេរនោះ នាំសំពត់មកថ្វាយអាចារ្យ អាចារ្យរបស់ព្រះថេរៈនោះ ទម្លាយសំពត់ដែលមានតម្លៃមួយសែននោះ ដោយកាំបិត ហើយឱ្យធ្វើជារបស់ប្រើប្រាស់ក្នុងទីសម្រាប់អង្គុយ ។

***សួរថា*** ការដែលអាចារ្យធ្វើយ៉ាងនោះ ដើម្បីប្រយោជន៍អ្វី ?

ឆ្លើយថា ដើម្បីអនុគ្រោះដល់ជនអ្នកកើតមកក្នុងខាងក្រោយ ។ បានឮថា អាចារ្យនោះមានបរិវិតក្កៈថា "ក្នុងអនាគតកាលសព្រហ្មចារីទាំងឡាយ នឹងសម្គាល់ដល់ការបដិបត្តិដែលខ្លួនឱ្យបរិបូណ៌ហើយ ដោយការពិចារណាដល់មគ្គដែលពួកយើងសម្រេចហើយ (មិនមែនមានសេចក្តីកង្វល់យ៉ាងដទៃទេ)" ។ សូម្បីព្រះតិស្សត្ថេរ ក៏កាត់សេចក្តីសង្ស័យបានក្នុងសំណាក់របស់អាចារ្យហើយទើបទៅ លោកឈានចុះត្រង់កំពង់នៃប្រទេសឈ្មោះជម្ពុកោលៈ ដល់វិហារឈ្មោះថា **វាលិកៈ** ក្នុងវេលាដែលបោសលានព្រះចេតិយ លោកក៏បោសលានព្រះចេតិយ ។ ព្រះថេរៈទាំង-

ឡាយ ឃើញទីជាទីដែលព្រះតិស្សត្ថេរនោះបោសហើយ ទើបគិតថា **“ទីនេះជាទីបោសសំអាត ដែលភិក្ខុមានរាគៈទៅប្រាសហើយ ធ្វើការបោសសំអាត”** តែដើម្បីត្រូវការសាកល្បង ទើបសួរបញ្ហាផ្សេងៗ, ព្រះតិស្សត្ថេរនោះ ក៏ដោះស្រាយបញ្ហាដែលភិក្ខុទាំងនោះ សួរហើយគ្រប់ៗ បញ្ហា ព្រោះខ្លួនជាអ្នកសម្រេចបដិសម្ភិទាទាំងឡាយហើយ ។

បដិសម្ភិទារបស់ **ព្រះតិស្សត្ថេរ** និងរបស់ **ព្រះនាគសេនត្ថេរ** បានបរិសុទ្ធហើយ ដោយបរិយត្តិ ។ បដិសម្ភិទារបស់សាមណេរឈ្មោះ **សុធម្មៈ** បានបរិសុទ្ធហើយ ព្រោះការស្តាប់ធម៌ដោយគោរព ។

បានឮថា សាមណេរនោះ ជាក្មួយរបស់ **ព្រះធម្មទិន្នត្ថេរ** អ្នកនៅក្នុងតឡង្គរវាសី ក្នុងខណៈដែលកោរសក់ស្រេច ក៏សម្រេចព្រះអរហន្ត, កាលលោកកំពុងស្តាប់ធម៌ ក្នុងរោងវិនិច្ឆ័យធម៌របស់ព្រះថេរៈអ្នកជាឪពុកធំនោះឯង បានជាអ្នកជំនាញព្រះត្រៃបិដកហើយ ។

បដិសម្ភិទារបស់ **ព្រះតិស្សត្ថេរ** អ្នកពោលអត្ថ (បរិបុច្ឆា) ដោយព្រះបាលីដែលខ្លួនរៀនមក បានជាអ្នកបរិសុទ្ធហើយ ។ ម្យ៉ាងទៀត ព្រះយោគាវចរក្នុងកាលមុនបំពេញគតបច្ចាគតវត្ត (ការនាំកម្មដ្ឋានទៅ និងការនាំកម្មដ្ឋានត្រឡប់មក) ហើយខ្វល់ខ្វាយចម្រើនកម្មដ្ឋានដ៏សមគួរ មានបដិសម្ភិទាដែលដល់សេចក្តីបរិសុទ្ធហើយ មិនបានដល់ទីបំផុត (មានច្រើនៗ) ។

ក៏បណ្តាហេតុទាំង ៥ នោះ ហេតុទាំង ៣ នេះ គឺ បរិយត្តិ សវនៈ និងបរិបុច្ឆា ជាហេតុ (គ្រឿងធ្វើ) ដែលមានកម្លាំងដល់បញ្ញាជាគ្រឿងឆ្លៀវឆ្លាស ។ បុព្

យោគ ជាពលវប្បច្ច័យ (បច្ច័យដ៏មានកម្លាំង) ដល់អធិគម (ការសម្រេចព្រះអរហត្ត) ។

**សួរថា** បុព្វយោគ ជាបច្ច័យដ៏មានកម្លាំងដល់បញ្ញា ជាគ្រឿងឆ្លៀវឆ្លាស ឬទេ ?

ឆ្លើយថា ជា (បច្ច័យ...); តែមិនបានជាដូច្នេះ; ព្រោះបរិយត្តិ គឺព្រះពុទ្ធវចនៈ សវនៈ គឺការស្តាប់ធម៌ បរិបុច្ឆា គឺការសួរអត្ថធម៌ក្នុងកាលមុន នឹងមាន ឬមិនមានក៏ដោយ, តែកាលពោលដោយបុព្វយោគហើយ វៀរការពិចារណាសង្ខារទាំងឡាយ ក្នុងកាលមុនផង ក្នុងកាលបច្ចុប្បន្នផង បដិសម្ភិទាទាំងឡាយ ឈ្មោះថាមិនមានទេ; ម្យ៉ាងទៀត បុព្វយោគក្នុងកាលមុន និងក្នុងបច្ចុប្បន្ននេះ កាលរួមគ្នាចូលមកឧបត្ថម្ភហើយ រមែងធ្វើបដិសម្ភិទាឱ្យបរិសុទ្ធ ៕

## ពណ៌នាអំពីសង្គហវារៈ *

ឥឡូវនេះ ដើម្បីចែកបដិសម្ភិទាទាំងឡាយ ដោយន័យនៃការសម្តែងប្រភេទនៃការសង្គ្រោះអត្ថ និងធម៌ទាំង ៥ វារៈពួកណាមួយ ក្នុងសង្គហវារៈ, ទើបព្រះមានព្រះភាគ ផ្តើមប្រភេទវារៈ (គឺវារៈដែលមានប្រភេទផ្សេងគ្នា) ដោយន័យជាដើមថា **“ចតស្សោ** = បដិសម្ភិទា ៤” ដូច្នេះទៀត ។ វារៈនោះមាន ៥ យ៉ាង ដោយអំណាចនៃសច្ចវារៈ ហេតុវារៈ ធម្មវារៈ បច្ចយាការវារៈ និងបរិយត្តិវារៈ ។

ក្នុងវារៈទាំងនោះ ព្រះមានព្រះភាគត្រាស់ **សច្ចវារៈ** ទុក ក៏ដើម្បីសម្តែង

* សង្គហវារៈ សំដៅដល់វារៈដែលពោលរួមគ្នា ។

ដល់ព្រះនិព្វានជាធម៌ដែលសម្រេចបានដោយបច្ច័យនៃទុក្ខដែលអាស្រ័យគ្នា ហើយកើតឡើងថា ជាអត្ថ (អត្ថប្បដិសម្ភិទា) និងដើម្បីសម្ដែងដល់អរិយមគ្គ ដែលនាំមកនូវព្រះនិព្វានដែលជាហេតុញុំាងផលឱ្យកើតឡើងថា**ជាធម្ម**(ធម្មប្បដិសម្ភិទា) ។

ព្រះមានព្រះភាគត្រាស់ថា **ហេតុវារៈ** * ទុកក៏ដើម្បីសម្ដែងដល់ហេតុទាំងឡាយ ដែលញុំាងផលយ៉ាងណាមួយឱ្យកើតថា **ជាធម្មៈ** (ធម្មប្បដិសម្ភិទា) និងដើម្បីសម្ដែងដល់ផលរបស់ហេតុថា **ជាអត្ថ** (អត្ថប្បដិសម្ភិទា) ក្នុងសេចក្ដីនេះព្រះមានព្រះភាគ ទ្រង់លើកធម្មប្បដិសម្ភិទាឡើងពន្យល់មុន ដោយមិនប្រព្រឹត្តទៅតាមរបៀបដែលពោលដោយលំដាប់នៃហេតុ និងផលដែលទ្រង់តាំងទុកទេ ។

ម្យ៉ាងទៀត ធម៌ពួកណា ដែលផ្សេងដោយរូប និងអរូបធម៌ (ខន្ធ ៥) ដែលកើតឡើងហើយ មានហើយ ពីហេតុនោះៗ, ដើម្បីសម្ដែងនូវធម៌ទាំងនោះថា **ជាអត្ថ** (អត្ថប្បដិសម្ភិទា) និងដើម្បីសម្ដែងនូវហេតុដែលជាទីកើតឡើងនៃរូប និងអរូបធម៌នោះៗ ថា **ជាធម្មៈ** (ធម្មប្បដិសម្ភិទា) ទើបព្រះមានព្រះភាគត្រាស់**ធម្មវារៈ**ទុក ។

ក៏ដើម្បីសម្ដែងនូវធម៌មានជរា និងមរណៈជាដើមថា **ជាអត្ថ** (អត្ថប្បដិសម្ភិទា) និងនូវធម៌ **គឺជាតិ** (ការកើត) ពោលគឺហេតុកើតឡើងនៃជរា និងមរណៈ

---

* **ហេតុវារៈ** បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា ព្រះមានបុណ្យអធិប្បាយធម្មៈ (ហេតុ) មុន អត្ថៈ ។

ជាដើម ទើបព្រះមានព្រះភាគត្រាស់ **បច្ចយាការវារៈ** ។

លំដាប់នោះ ដើម្បីសម្ដែងនូវភាសិតនោះៗ ពោលគឺព្រះបរិយត្តិ និងនូវសេចក្ដីនៃអត្ថភាសិត ដែលគប្បីសម្រេចបានដោយបច្ច័យ ពោលគឺភាសិត ទើបព្រះមានព្រះភាគត្រាស់ **បរិយត្តិវារៈ**; ក្នុងសេចក្ដីនេះ អត្ថនៃភាសិតនោះ ដែលនឹងគប្បីដឹងបាន រមែងដឹងបានដោយភាសិត, ព្រោះហេតុដូច្នោះ ទើបព្រះអង្គទ្រង់លើកធម្មប្បដិសម្ភិទាឡើងពន្យល់សម្ដែងមុនអត្ថប្បដិសម្ភិទា ដោយមិនបានសម្ដែងទៅតាមលំដាប់នៃភាសិតដែលព្រះអង្គត្រាស់ទុកហើយៗ ។

ម្យ៉ាងទៀត ដើម្បីសម្ដែងប្រភេទនៃព្រះបរិយត្តិធម៌ថា "ក្នុងបដិសម្ភិទាទាំង ៤ នោះ ធម្មប្បដិសម្ភិទា តើដូចម្ដេច ?" ។ ទើបត្រាស់បដិនិទ្ទេសវារៈ (គឺវារៈដែលបែរត្រឡប់មកពន្យល់) មានពាក្យសួរជាប្រធាន ។ ក្នុងវារៈបែរត្រឡប់មកពោលពន្យល់នោះ ទ្រង់កាន់យកបែបផែនទាំងអស់ ដោយមិនមានសល់ ដោយអង្គ ៩ [*] ដែលមានពាក្យថាសុត្តៈជាដើម ជាធម្មប្បដិសម្ភិទា; ទ្រង់កាន់យកបែបផែនទាំងអស់ ដោយអស់ជើង ដោយការសម្ដែងមិនឱ្យនៅសល់ ដោយអំណាចនៃភាសិត សូម្បីក្នុងទីនេះថា "**នេះជាអត្ថនៃភាសិតនេះ, នេះជាអត្ថនៃភាសិតនេះ" ជាអត្ថប្បដិសម្ភិទា** ដូច្នេះឯង ៕

**ចប់សុត្តន្តភាជនិយ**

---

[*] អង្គ ៩ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ និងវេទល្លៈ ។

## ២.ពណ៌នាអំពីអភិធម្មភាជនិយ

បណ្តាបដិសម្ភិទាទាំង ៤ នោះ បដិសម្ភិទា ៣ គឺ ធម្មនិរុត្តិ និងបដិភាណ-ប្បដិសម្ភិទា ជាលោកិយ ។ អត្ថប្បដិសម្ភិទា ជាមិស្សកៈ គឺជាលោកិយក៏មាន ជាលោកុត្តរ ក៏មាន ។ ពិតមែន អត្ថប្បដិសម្ភិទានោះ ជាលោកុត្តរដោយអំណាចនៃញាណក្នុងមគ្គ និងផល ដែលមានព្រះនិព្វានជាអារម្មណ៍ ។

ក្នុងអភិធម្មភាជនិយ លោកចែកបដិសម្ភិទាទាំងនោះ ដោយវារៈទាំង ៤ ដោយអំណាចនៃកុសល អកុសល វិបាក និងកិរិយា ។ ក្នុងធម៌ទាំងនោះ បណ្ឌិតគប្បីជ្រាបថា កុសលចិត្តលោកចែកទុកក្នុងចិត្តុប្បាទកណ្ឌ ក្នុងគ្រាក្រោយមានប្រ-មាណប៉ុនណា, គប្បីជ្រាបបដិសម្ភិទានីមួយៗ ៤ ក្នុងចិត្តនិទ្ទេសមួយៗ ដោយអំណាចនៃធម៌ សូម្បីទាំងអស់នោះ ។ សូម្បីក្នុងកុសលចិត្តទាំងឡាយ ក៏ន័យនេះដែរ ៕

### បដិសម្ភិទា ៣ (វៀរធម្មៈ) [៣១]

ក្នុងវារៈពោលអំពីវិបាក និងកិរិយា លោកវៀរធម្មប្បដិសម្ភិទាចេញ ព្រោះវិបាក និងកិរិយាទាំងឡាយ **លោកសង្គ្រោះចូលក្នុងអត្ថប្បដិសម្ភិទា** [៣២] **ក្នុង**

---

[៣១] **ធម្មៈ** បានដល់ កាមាវចរកុសលចិត្ត រូបាវចរកុសលចិត្ត អរូបាវចរកុសលចិត្ត លោកុត្តរកុសលចិត្ត និងអកុសលចិត្ត ។

[៣២] **អត្ថៈ** បានដល់ អហេតុកកុសលវិបាកចិត្ត កាមាវចរកុសលវិបាកចិត្ត រូបាវចរវិបាកចិត្ត អរូបាវចរវិបាកចិត្ត លោកុត្តរកុសលវិបាកចិត្ត និងអកុសលវិបាកចិត្ត ។

វិបាកចិត្តក្ដី ក្នុងកិរិយាក្ដី យ៉ាងនីមួយៗ លោកចែកបដិសម្ភិទាទុកម្យ៉ាងៗ ៣ ប៉ុណ្ណោះ ។

ចំណែកព្រះបាលី លោកសម្ដែងសង្ខេបទុកត្រឹមតែគោលសេចក្ដី ។ បដិ-សម្ភិទាទាំង ៣ នោះ បណ្ឌិតគប្បីជ្រាបដោយអំណាចនៃសេចក្ដីពិស្ដារដែលមកហើយ ក្នុងកាលមុននុ៎ះឯង ។

**សួរថា** ក៏ក្នុងវារៈពោលអំពីកុសលទាំងឡាយ លោកពោលថា “ញាណក្នុងវិបាកនៃធម៌ទាំងនោះថា **ជាអត្ថប្បដិសម្ភិទា**” , ក្នុងវារៈពោលអំពីវិបាក និងកិរិយានេះ លោកមិនពោលថា “វិបាកនេះ នៃធម៌ទាំងឡាយណា, ញាណក្នុងធម៌ទាំងនោះ **ជាធម្មបដិសម្ភិទា**” , ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះលោកពោលទុកហើយក្នុងកាលមុន ។

សូម្បីអត្ថប្បដិសម្ភិទានេះ ក៏មិនគប្បីពោលទុកក្នុងទីនេះ ព្រោះលោកពោលទុកក្នុងកាលមុនហើយថា “ញាណក្នុងវិបាករបស់ធម៌ទាំងនោះ ជាអត្ថប្បដិសម្ភិទា”; តាមពិត មិនគួរពោលចេញឡើយ ក៏មិនមែន ។

**សួរថា** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះបដិសម្ភិទានេះ លោកមិនពោលដោយអំណាចនៃចិត្តុប្បាទរបស់វិបាក និងកិរិយាឡើយ ។

ម្យ៉ាងទៀត ក្នុងវារៈពោលអំពីកិរិយា លោកចែកបដិសម្ភិទាទុកមួយៗ ៣ ប៉ុណ្ណោះ សូម្បីក្នុងវារៈទាំង ២ នេះ ពាក្យថា “ធម៌ទាំងនេះជាកិរិយារបស់ធម៌ពួកណា” ដូច្នេះ មិនសមគួរ ។ ក្នុងវារៈទាំងនោះ បញ្ញត្តិយ៉ាងនេះថា “ផស្សៈនេះ

វេទនានេះ នៃធម៌ទាំងឡាយ ដែលព្រះមានព្រះភាគត្រាស់ហើយដោយន័យថា **‘យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ** = បញ្ញត្តិនៃធម៌ទាំងនោះ រមែងមានដោយនិរុត្តិណា” ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **“ធម្មនិរុត្តាភិលាបេ ញាណំ** = សេចក្ដីដឹងឆ្លៀវឆ្លាសក្នុងការពោលធម្មនិរុត្តិ” បានដល់ ញាណក្នុងការពោលធម៌ដោយសភាវប្បញ្ញត្តិ គឺធម្មនិរុត្តិនោះ ដែលប្រព្រឹត្តទៅក្នុងអត្ថ និងក្នុងធម៌នោះ ។ សូម្បីក្នុងសេចក្ដីនេះ លោកក៏ពោលថា “ញាណដែលកើតឡើងហើយ ព្រោះធ្វើអភិលាបសទ្ទៈ (សំឡេងក្នុងការពោល) ឱ្យជាអារម្មណ៏” ។ ពាក្យថា **យេន ញាណេន** បានដល់ ដោយបដិភាណប្បដិសម្ភិទាញាណណា ។ ពាក្យថា **តានិ ញាណានិ ជានាតិ** បានដល់ រមែងដឹងនូវញាណក្នុងបដិសម្ភិទា ៣ ក្រៅពីនេះ ។

ឥឡូវនេះ ដើម្បីសម្ដែងនូវសេចក្ដីប្រព្រឹត្តទៅក្នុងញាណទាំងឡាយ ដែលដឹងនូវញាណណា ដោយប្រការណានោះ ទើបព្រះមានព្រះភាគត្រាស់ថា **“ឥមានិ ញាណានិ ឥទមត្ថជោតកានិ** = ញាណទាំងនេះ ជាគុណជាតិបំភ្លឺនូវសេចក្ដីនេះ”។ បណ្ដាពាក្យទាំងនោះ ពាក្យថា **“ឥទមត្ថជោតកានិ** = បំភ្លឺសេចក្ដីនេះ” បានដល់ បំភ្លឺ គឺប្រកាសនូវសេចក្ដីនេះ, អធិប្បាយថា ញាណទាំង ៣ នេះ រមែងបំភ្លឺ រមែងប្រកាស រមែងកំណត់នូវសេចក្ដីឈ្មោះនេះ ។ ពាក្យថា **“ឥតិ ញាណេសុ ញាណំ** = សេចក្ដីដឹងឆ្លៀវឆ្លាស ក្នុងញាណទាំងឡាយ ដោយអាការយ៉ាងនេះ” បានដល់ សេចក្ដីដឹងក្នុងញាណទាំង ៣ ប្រព្រឹត្តទៅដោយអាការយ៉ាងនេះ ឈ្មោះថា **បដិភាណប្បដិសម្ភិទា** ។ ក្នុងបដិសម្ភិទាទាំង ៤ នោះ បដិភាណប្បដិសម្ភិទានេះ រមែងដឹងនូវកិច្ចរបស់បដិសម្ភិទាទាំងឡាយនេះថា “នេះជាកិច្ចរបស់បដិសម្ភិទានេះ

និងនេះជាកិច្ចរបស់បដិសម្ភិទានេះ” ក៏ពិតមែន, តែខ្លួនឯងក៏មិនអាចដើម្បីធ្វើកិច្ច (នាទី) របស់បដិសម្ភិទាទាំងនោះបាន ប្រៀបដូចធម្មកថិកអ្នកជាពហុស្សូត រមែងមិនអាចដើម្បីធ្វើកិច្ចរបស់ព្រះធម្មកថិកអ្នកជាអប្បស្សូត (អ្នកមានសុតៈតិច) បាន ។

បានឮថា ភិក្ខុ ២ រូប មួយរូប ជាពហុស្សូត មួយរូបទៀត ជាអប្បស្សូត ។ ភិក្ខុទាំង ២ រូបនោះរៀនរបៀប (មគ្គ) ការសម្ដែងធម៌ម្យ៉ាងជាមួយគ្នា ។ ក្នុងភិក្ខុទាំងពីររូបនោះ ភិក្ខុដែលមានសុតៈតិច បានជាអ្នកមានសំឡេងពីរោះ, ចំណែកភិក្ខុដែលជាពហុស្សូតមានសំឡេងស្រាល (មិនពីរោះ); ក្នុងពីររូបនោះ ភិក្ខុអ្នកជាអប្បស្សូត ញ៉ាំងបរិស័ទទាំងអស់ ឱ្យញាប់ញ័រ (គឺឱ្យជាប់ចិត្ត) ដោយសម្បត្តិ គឺសំឡេងរបស់ខ្លួន ក្នុងស្ថានទីដែលខ្លួនទៅហើយៗ ទើបសម្ដែងធម៌ ។ មហាជនស្ដាប់ធម៌របស់លោក ក៏រីករាយត្រេកអរពោលថា “អង្គនោះ សម្ដែងធម៌ប្រាកដដូចជាអ្នកទ្រទ្រង់ព្រះត្រៃបិដកមួយរូប” ។ តែភិក្ខុជាពហុស្សូតពោលថា “អ្នកទាំងឡាយនឹងជ្រាបបានក្នុងវេលាស្ដាប់ធម៌ថា ‘ភិក្ខុនេះទ្រទ្រង់ព្រះត្រៃបិដកឬទេ ?” ។ ភិក្ខុជាពហុស្សូតនោះ សូម្បីពោលយ៉ាងនេះ, តែលោកក៏មិនអាចញ៉ាំងបរិស័ទទាំងអស់ឱ្យញាប់ញ័រ ហើយសម្ដែងធម៌ដូចនោះបាន យ៉ាងណា, សេចក្ដីនេះ ក៏ដូច្នោះដែរ ព្រោះភិក្ខុជាពហុស្សូត មិនមានសេចក្ដីអង់អាចក្នុងការសម្ដែងធម៌ ។ បណ្ឌិតគប្បីជ្រាបថា “ក្នុងបដិសម្ភិទាទាំង ៤ នោះ បដិភាណប្បដិសម្ភិទា រមែងដឹងនូវកិច្ចរបស់បដិសម្ភិទា ៣ ក្រៅពីនេះ ដូចភិក្ខុពហុស្សូតដឹងនូវកិច្ចការងាររបស់ភិក្ខុអ្នកជាអប្ប-

សូត, តែខ្លួនឯង (បដិភាណប្បដិសម្ភិទា) មិនអាចធ្វើកិច្ចនោះបានទេ” ។

ក្នុងកាលឥឡូវនេះ ដើម្បីចែកបដិសម្ភិទាទាំងឡាយ ដោយអំណាចនៃការកើតឡើងរបស់កុសលចិត្តជាដើម ហើយសម្តែងខេត្តដែលជាឋាននៃការកើតឡើងរបស់បដិសម្ភិទាទាំងនោះ ទើបត្រាស់ពាក្យថា **“ចតស្សោ បដិសម្ភិទា** = បដិសម្ភិទា ៤” ជាដើមទៀត ។ បណ្តាបដិសម្ភិទាទាំងនោះ ពាក្យថា **“តិស្សោ បដិសម្ភិទា កាមាវចរកុសលតោ ចតូសុ ញាណសម្បយុត្តេសុ ចិត្តុប្បាទេសុ** = បដិសម្ភិទា ៣ កើតក្នុងចិត្តដែលសម្បយុត្តដោយញាណ ៤ ផ្នែកខាងកាមាវចរកុសល” នេះ ព្រះសាស្តាត្រាស់ហើយដោយអំណាចនៃព្រះសេក្ខៈទាំងឡាយ ។

ពិតមែន ធម្មប្បដិសម្ភិទា ធ្វើធម៌មានប្រការ ៥ យ៉ាង (មានសច្ចវារៈ ហេតុវារៈ ធម្មវារៈ បច្ចយាការវារៈ និងបរិយត្តិវារៈ) ដែលខ្ញុំពោលហើយក្នុងកាលមុន ក្នុងវេលាពិចារណាធម៌ (គឺហេតុ) សូម្បីនៃធម៌ទាំងនោះ ឱ្យជាអារម្មណ៍ ហើយកើតឡើងក្នុងកុសលចិត្តដែលសម្បយុត្តដោយញាណ ៤ ។ ដោយទំនងតែមួយ និរុត្តិប្បដិសម្ភិទា ធ្វើសំឡេងក្នុងវេលាពិចារណានិរុត្តិ ឱ្យជាអារម្មណ៍ ហើយកើតឡើង ។ បដិភាណប្បដិសម្ភិទា ធ្វើញាណ (សេចក្តីដឹង) ក្នុងញាណក្នុងទីទាំងពួង ក្នុងវេលាពិចារណាឱ្យជាអារម្មណ៍ ហើយកើតឡើង ។

ចំណែកពាក្យថា **“កិរិយតោ ចតូសុ”** នេះ ព្រះមានព្រះភាគត្រាស់ហើយដោយអំណាចនៃព្រះសេក្ខបុគ្គល ។ ពិតមែន ធម្មប្បដិសម្ភិទាធ្វើធម៌ ៥ ប្រការ តាមដែលពោលហើយក្នុងកាលមុន ក្នុងវេលាពិចារណាធម៌ (គឺហេតុ) នៃធម៌ទាំងនោះឱ្យជាអារម្មណ៍ ហើយកើតឡើងក្នុងកិរិយាចិត្ត ដែលសម្បយុត្តដោយញាណ ៤ ។

ដោយទំនងដូចគ្នានេះ និរុត្តិប្បដិសម្ភិទាធ្វើសំឡេងក្នុងវេលាពិចារណានិរុត្តិ ឱ្យជាអារម្មណ៍ហើយកើតឡើង ។ បដិភាណប្បដិសម្ភិទាធ្វើញាណក្នុងទីទាំងពួង ក្នុងវេលាពិចារណាញាណ ឱ្យជាអារម្មណ៍ហើយកើតឡើង ។

តែពាក្យថា **“អត្ថប្បដិសម្ភិទា ឯតេសុ ចេវ ឧប្បជ្ជតិ** = អត្ថប្បដិសម្ភិទារមែងកើតឡើងក្នុងចិត្តុប្បាទទាំងនេះផង រមែងកើតក្នុងមគ្គ ៤ និងផល ៤ ផង” នេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃព្រះសេក្ខៈ និងព្រះអសេក្ខៈ ។

ពិតយ៉ាងនោះមែន អត្ថប្បដិសម្ភិទានេះ ធ្វើអត្ថមានប្រភេទតាមដែលពោលហើយ ក្នុងកាលមុន ក្នុងវេលាពិចារណាអត្ថរបស់ព្រះសេក្ខទាំងឡាយ ឱ្យជាអារម្មណ៍ ហើយកើតឡើងក្នុងកុសលដែលសម្បយុត្តដោយញាណ ៤, ទាំងកើតក្នុងមគ្គក្នុងផល ក្នុងវេលានៃមគ្គ និងផលផង ។ ក៏បដិសម្ភិទានេះធ្វើអត្ថមានប្រភេទដូចពោលហើយ ក្នុងគ្រាមុន ក្នុងវេលាពិចារណាអត្ថរបស់ព្រះអសេក្ខៈ ឱ្យជាអារម្មណ៍ហើយ រមែងកើតឡើង ក្នុងកិរិយាចិត្តដែលសម្បយុត្តដោយញាណ ៤ ។

**ម្យ៉ាងទៀត បដិសម្ភិទាទាំងនេះ កាលកើតដល់ព្រះសេក្ខៈ និងព្រះអសេក្ខៈ រមែងកើតក្នុងភូមិទាំងនេះ (ភូមិ ៤) ក្នុងកាលនៃផល គឺក្នុងសាមញ្ញផល ដែលតាំងនៅក្នុងខាងលើ** យ៉ាងនេះ ដោយប្រការដូច្នេះ ទើបព្រះមានព្រះភាគទ្រង់សម្តែងន័យទុក ដើម្បីសម្តែងដល់ភូមិដូចពណ៌នាមកដូច្នេះ ៕

**ពណ៌នាអំពីអភិធម្មភាជនិយចប់**

## ៣.ពណ៌នាអំពីបញ្ហាបុច្ឆកៈ

**ក្នុងបញ្ហាបុច្ឆកៈ** បណ្ឌិតគប្បីជ្រាបសេចក្ដីដែលបដិសម្ភិទា ៤ ជាកុសលជាដើម ដោយទំនងនៃព្រះបាលីនុ៎ះឯង ។ ក៏ប៉ុន្តែ ក្នុងអារម្មណត្តិកៈទាំងឡាយ និរុត្តិប្បដិសម្ភិទា ឈ្មោះថា ជាបរិត្តារម្មណ៍ ព្រោះធ្វើសំឡេងប៉ុណ្ណោះ ឱ្យជាអារម្មណ៍ ។

**អត្ថប្បដិសម្ភិទា** ជាបរិត្តារម្មណ៍ដល់អ្នកពិចារណានូវអត្ថ ពោលគឺកាមាវចរវិបាក កិរិយា និងសភាវៈដែលអាស្រ័យគ្នាហើយកើតឡើង ព្រោះបច្ច័យ, កាលពិចារណាអត្ថនៃរូបាវចរ និងអរូបាវចរ មានប្រភេទតាមដែលពោលហើយនុ៎ះឯង ជាមហគ្គតារម្មណ៍, កាលពិចារណាព្រះនិព្វាន ដែលជាបរមត្ថ និងអត្ថ គឺលោកុត្តរវិបាក ឈ្មោះថា ជាអប្បមាណារម្មណ៍ ។

**ធម្មប្បដិសម្ភិទា** ជាបរិត្តារម្មណ៍ដល់អ្នកពិចារណានូវកាមាវចរកុសល អកុសល និងធម៌ដែលជាបច្ច័យ, កាលពិចារណាកុសលធម៌ដែលជារូបាវចរ អរូបាវចរ និងធម៌ដែលជាបច្ច័យ ជាមហគ្គតារម្មណ៍, កាលពិចារណានូវធម៌ដែលជាលោកុត្តរកុសល និងធម៌ដែលជាបច្ច័យ ជាអប្បមាណារម្មណ៍ ។

**បដិភាណប្បដិសម្ភិទា** ជាបរិត្តារម្មណ៍ ដល់អ្នកពិចារណានូវញាណ ក្នុងកាមាវចរកុសល វិបាក និងកិរិយា, កាលពិចារណានូវញាណក្នុងកុសល វិបាក និងកិរិយា ដែលជារូបាវចរារូបាវចរ ហើយដឹងនូវអារម្មណ៍ទាំងឡាយរបស់ធម៌ទាំងនោះ ជាមហគ្គតារម្មណ៍, កាលពិចារណានូវញាណក្នុងកុសល និងវិបាកដែលជាលោកុត្តរ ជាអប្បមាណារម្មណ៍ ។

**អត្ថប្បដិសម្ភិទា** ជាមគ្គហេតុកៈ ដោយអំណាចនៃសហជាតហេតុ, ជាមគ្គាធិបតី ដោយការចម្រើនមគ្គដែលមានវីរិយៈជាប្រធាន, មិនគប្បីពោលថា ជាមគ្គាធិបតី ដោយការចម្រើនមគ្គដែលមានឆន្ទៈ ចិត្តៈ ជាប្រធាន ។ សូម្បីក្នុងកាលនៃផល ក៏មិនគប្បីពោលឡើយ ។

**ធម្មប្បដិសម្ភិទា** ជាមគ្គារម្មណ៍ក្នុងវេលាពិចារណាមគ្គ, កាលពិចារណា ធ្វើមគ្គឱ្យជាប្រធាន ជាមគ្គាធិបតី ដោយអំណាចនៃអារម្មណាធិបតី ។

**បដិភាណប្បដិសម្ភិទា** ជាមគ្គារម្មណ៍ ក្នុងវេលាពិចារណាញាណក្នុងមគ្គ, កាលពិចារណាធ្វើមគ្គឱ្យជាប្រធាន ជាមគ្គាធិបតី ។ ជានវត្តព្វារម្មណ៍ ក្នុងវេលាពិចារណាញាណដែលនៅសល់ ។

**និរុត្តិប្បដិសម្ភិទា** ឈ្មោះថា ជាបច្ចុប្បន្នារម្មណ៍ ព្រោះធ្វើសំឡេងដែលជាបច្ចុប្បន្ននុ៎ះឯង ឱ្យជាអារម្មណ៍ ។

**អត្ថប្បដិសម្ភិទា** ជាអតីតារម្មណ៍ដល់អ្នកពិចារណានូវអត្ថនៃវិបាក អត្ថនៃកិរិយា និងអត្ថដែលអាស្រ័យបច្ច័យហើយកើតឡើង ជាអតីតៈ, ជាអនាគតារម្មណ៍ដល់អ្នកពិចារណានូវអត្ថទាំងនោះ ក្នុងអនាគត, កាលពិចារណាអត្ថដែលជាបច្ចុប្បន្ន ជាបច្ចុប្បន្នារម្មណ៍, កាលពិចារណាបរមត្ថ គឺព្រះនិព្វាន ជានវត្តព្វារម្មណ៍ ។

**ធម្មប្បដិសម្ភិទា** ជាអតីតារម្មណ៍ ដល់អ្នកពិចារណានូវកុសល អកុសល និងបច្ចយធម៌ ដែលជាអតីតៈ, កាលពិចារណាធម៌ទាំងនោះ ក្នុងអនាគត ជាអនាគតារម្មណ៍, កាលពិចារណាក្នុងបច្ចុប្បន្ន ជាបច្ចុប្បន្នារម្មណ៍ ។

**បដិភាណប្បដិសម្ភិទា** ជាអតីតារម្មណ៍ ដល់អ្នកពិចារណានូវកុសលញ្ញាណ វិបាកញ្ញាណ កិរិយាញ្ញាណ ដែលជាអតីតៈ, កាលពិចារណាក្នុងអនាគត ជាអនាគតារម្មណ៍, កាលពិចារណាក្នុងបច្ចុប្បន្ន ជាបច្ចុប្បន្នារម្មណ៍ ។

**និរុត្តិប្បដិសម្ភិទា** ជាពហិទ្ធារម្មណ៍ ព្រោះមានសំឡេងជាអារម្មណ៍ ។

បដិសម្ភិទា ៣ ក្រៅនេះ គឺ

**អត្ថប្បដិសម្ភិទា** ជាអជ្ឈត្តារម្មណ៍ ដល់អ្នកពិចារណានូវអត្ថនៃវិបាក អត្ថនៃកិរិយា និងនូវអត្ថដែលអាស្រ័យគ្នាហើយកើតឡើងព្រោះបច្ច័យ, កាលពិចារណាខាងក្រៅ ជាពហិទ្ធារម្មណ៍, កាលពិចារណាទាំងខាងក្នុង ទាំងខាងក្រៅ ជាអជ្ឈត្តពហិទ្ធារម្មណ៍, កាលពិចារណាបរមត្ថ គឺព្រះនិព្វាន ជាពហិទ្ធារម្មណ៍ប៉ុណ្ណោះ ។

**ធម្មប្បដិសម្ភិទា** ជាអជ្ឈត្តារម្មណ៍ ក្នុងវេលាពិចារណាធម៌ដែលជាបច្ច័យរបស់កុសល និងអកុសលខាងក្នុង, ជាពហិទ្ធារម្មណ៍ក្នុងវេលាពិចារណាធម៌ ដែលជាបច្ច័យ របស់កុសល និងអកុសលខាងក្រៅ, ជាអជ្ឈត្តពហិទ្ធារម្មណ៍ ក្នុងវេលាពិចារណាធម៌ដែលជាបច្ច័យរបស់កុសល និងអកុសល ទាំងខាងក្នុង ទាំងខាងក្រៅ ។

**បដិភាណប្បដិសម្ភិទា** ជាអជ្ឈត្តារម្មណ៍ ក្នុងវេលាពិចារណាញាណដែលជាកុសល វិបាក និងកិរិយាខាងក្នុង, ជាពហិទ្ធារម្មណ៍ក្នុងវេលាពិចារណាញាណ ក្នុងកុសល វិបាក និងកិរិយាខាងក្រៅ, ជាអជ្ឈត្តពហិទ្ធារម្មណ៍ក្នុងវេលាពិចារណាញាណក្នុងកុសល វិបាក និងកិរិយា ទាំងខាងក្នុង ទាំងខាងក្រៅ ៕

**ពណ៌នាអំពីបញ្ហាបុច្ឆកៈចប់**

សូម្បីក្នុងបញ្ហាបុច្ឆកៈ នេះ បដិសម្ភិទា ៣ ជាលោកិយ, អត្ថប្បដិសម្ភិទា ជាលោកុត្តរ ។ ពិតមែន ក្នុងបដិសម្ភិទាវិភង្គនេះ ព្រះសម្មាសម្ពុទ្ធត្រាស់ន័យសូម្បីទាំង ៣ (គឺសុត្តន្តន័យ អភិធម្មន័យ និងបញ្ហាបុច្ឆកន័យ) ទុកជាបរិច្ឆេទតែមួយ; ព្រោះបដិសម្ភិទាទាំង ៤ នោះ ជាមិស្សកៈ គឺជាលោកិយ និងលោកុត្តរ ។ សូម្បីក្នុងន័យទាំង ៣ នេះ បដិសម្ភិទា ៣ ជាលោកិយ, អត្ថប្បដិសម្ភិទា ជាលោកិយ និងលោកុត្តរ ។ សូម្បីបដិសម្ភិទាវិភង្គនេះ ព្រះមានព្រះភាគ ក៏ទ្រង់នាំចេញចែកសម្តែងហើយ ៣ បរិវដ្ដ ដូចពណ៌នាមកដូច្នេះ ។

**អដ្ឋកថាបដិសម្ភិទាវិភង្គចប់**

**សម្មោហវិនោទនី អដ្ឋកថាព្រះអភិធម្មបិដក**

**ឈ្មោះវិភង្គប្បករណ៍ ទុតិយភាគ ៧ ចប់**

**នៅមានទុតិយភាគ ៨ ជាបន្តទៀត**

**បោះពុម្ពលើកទី ២**

រក្សាសិទ្ធិ ( ហាមថតចម្លង)